ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា

# សៀវភៅគោល

## ស្តីពី

# ការឆ្លើយតបនឹងការកេងប្រវញ្ច
# និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ



គុណភាព ភាពមិនលម្អៀង សមធម៌ ក្រមសីលធម៌វិជ្ជាជីវៈ គណនេយ្យភាព និងនវានុវត្តន៍

ឆ្នាំ ២០២៤

(រក្សាសិទ្ធិ)

បានឃើញនិងអនុញ្ញាតឱ្យប្រើ

សៀវភៅគោលមុខវិជ្ជា

**ការឆ្លើយតបនឹងការកេងប្រវញ្ចនិងរំលោភបំពានផ្លូវភេទកុមារ**

**លើប្រព័ន្ធអនឡាញ**

ថ្ងៃ អង្គារ ១០កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២៤

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា

លេខ : ០៣៣.ណ.ប.ក

ថ្ងៃ[illegible] ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ជីវឥដ្ឋ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០២៤

## លិខិតបង្គាប់ការ

**យោង** : - កិច្ចសហការរវាងបណ្ឌិត្យសភានគរបាលកម្ពុជា និងអង្គការសកម្មភាពដើម្បីកុមារ(APLE)
- សំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ នៃបណ្ឌិត្យសភានគរបាលកម្ពុជា
- តាមការចាំបាច់របស់បណ្ឌិត្យសភានគរបាលកម្ពុជា។

ត្រូវបានបង្កើតក្រុមការងាររៀបចំតាក់តែងមុខវិជ្ជាជំនាញស្តីពី "ការឆ្លើយតបនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញសម្រាប់មន្ត្រីអនុវត្តច្បាប់" ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

### I- សមាសភាព

**ក- ក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ**

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យ | **ប្រាក់ ណារ៉ុង** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ | ប្រធាន |
| ២- | ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យជំនួយ | **ឃឹម សុវណ្ណារុធ** | គ្រូនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **អ៊ិន សុខន** | គ្រូនគរបាលជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **នួន វិទ្យាស័ក** | គ្រូនគរបាលជាតិ | អនុប្រធាន |
| ៥- | ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **ភោគ សាម៉ុន** | គ្រូនគរបាលជាតិ | សមាជិក |
| ៦- | ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **រស់ សារិទ្ធ** | គ្រូនគរបាលជាតិ | សមាជិក |
| ៧- | លោកឧត្តមសេនីយ៍ត្រី | **លឹម លាង** | គ្រូនគរបាលជាតិ | សមាជិក |
| ៨- | លោកស្រីវរសេនីយ៍ទោ | **ភោគ ភិរុណ** | គ្រូនគរបាលជាតិ | សមាជិក |
| ៩- | លោកវរសេនីយ៍ទោ | **អ៊ិន រស់វិទ្យា** | គ្រូនគរបាលជាតិ | សមាជិក |
| ១០- | លោកអនុសេនីយ៍ឯក | **អ៊ឹង សេរីរ័ត្ន** | គ្រូនគរបាលជាតិ | សមាជិក |
| ១១- | លោកអនុសេនីយ៍ឯក | **ទិត្យ ទីណា** | គ្រូនគរបាលជាតិ | សមាជិក |
| ១២- | កញ្ញាអនុសេនីយ៍ឯក | **ផង់ សុជាន់ណារី** | គ្រូនគរបាលជាតិ | សមាជិក |
| ១៣- | លោកអនុសេនីយ៍ឯក | **សួន សេដ្ឋារតនៈ** | គ្រូនគរបាលជាតិ | សមាជិក |

**ខ- តំណាងមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ៤រូប**

**គ- អង្គការសកម្មភាពដើម្បីកុមារ (APLE)**

| | | | |
|---|---|---|---|
| ១- | លោក | **សំលៀង សិលា** | នាយកប្រតិបត្តិ |
| ២- | លោក | **ណេង វណ្ណៈ** | អ្នកសម្របសម្រួលគម្រោង |
| ៣- | លោក | **ផៃ សុភ័ក្ត្រ** | ប្រធានកម្មវិធីអភិវឌ្ឍផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ |

**ឃ- មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)**

- លោកស្រី **អ៊ឹង កល្យាណ** បុគ្គលិកកិច្ចការពារកុមារ

**II- អំពីភារកិច្ច**

- សហការសម្របសម្រួលរៀបចំផែនការកម្មវិធីការងារសម្រាប់ដំណើរការ
- រៀបចំខ្លឹមសារមេរៀន និងពិនិត្យពិភាក្សាលើខ្លឹមសារមេរៀន ដើម្បីរៀបចំបោះពុម្ពជាសៀវភៅគោលសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីបណ្ដុះបណ្ដាល
- រៀបចំសិក្ខាសាលាត្រួតពិនិត្យកែសម្រួលចំណុចខ្វះខាត
- រៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល សម្រាប់ត្រៀមដំណើរការបង្ហាត់បង្រៀនតាមកម្មវិធីអប់រំរបស់បណ្ឌិត្យសភានគរបាលកម្ពុជា
- រាយការណ៍ពីសកម្មភាពនិងលទ្ធផលការងារជាបន្តបន្ទាប់ជូន ឯកឧត្ដម នាយឧត្ដមសេនីយ៍ សាស្ត្រាចារ្យ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា តាមរយៈប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ។

ក្រុមការងារមានសិទ្ធិចាត់ចែងមន្ត្រីក្រោមឱវាទរបស់ខ្លួន សម្រាប់ជួយបំពេញការងារ ដើម្បីសម្រេចភារកិច្ចប្រកបដោយជោគជ័យ។

ឯកឧត្ដម សាស្ត្រាចារ្យ គ្រូនគរបាលជាតិ អស់លោក លោកស្រី ដែលមានឈ្មោះក្នុងលិខិតបង្គាប់ការនេះ ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

**នាយឧត្ដមសេនីយ៍ សាស្ត្រាចារ្យ ឯក មនោសែន**

**កន្លែងទទួល ៖**
- ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា
- អង្គការសកម្មភាពដើម្បីកុមារ (APLE)
- មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

# សមាសភាពក្រុមអ្នកនិពន្ធ

## ក- សមាសភាពអ្នកចូលរួមពីបណ្ឌិត្យសភានគរបាលកម្ពុជា

| | | | |
|---|---|---|---|
| ១. ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យ | **ប្រាក់ ណារ៉ុង** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ | ប្រធាន |
| ២. ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យជំនួយ | **ឃឹម សុវណ្ណាវុធ** | អនុប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងជាអនុប្រធានអចិន្ត្រៃយ៍រៀបចំសៀវភៅគោល | អនុប្រធាន |
| ៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **អ៊ួន សុខន** | គ្រូនគរបាលជាតិ | អនុប្រធាន |
| ៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **ឆួន វិទ្យាស័ក** | គ្រូនគរបាលជាតិ | អនុប្រធាន |
| ៥. ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **តោគ សាម៉ុន** | គ្រូនគរបាលជាតិ | សមាជិក |
| ៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក សាស្ត្រាចារ្យរង | **រស់ សារិទ្ធ** | គ្រូនគរបាលជាតិ | សមាជិក |
| ៧. លោកឧត្តមសេនីយ៍ត្រី | **លឹម លាង** | គ្រូនគរបាលជាតិ | សមាជិក |
| ៨. លោកស្រីវរសេនីយ៍ទោ | **តោគ តិរុណ** | គ្រូនគរបាលជាតិ | សមាជិក |
| ៩. លោកវរសេនីយ៍ទោ | **អ៊ុន រស់វិទ្យា** | គ្រូនគរបាលជាតិ | សមាជិក |
| ១០. លោកស្រីវរសេនីយ៍ទោ | **តាំង ហេង** | គ្រូនគរបាលជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ១១. លោកវរសេនីយ៍ទោ | **អៀម រិត្យា** | គ្រូនគរបាលជាតិ | សមាជិក |
| ១២. លោកអនុសេនីយ៍ឯក | **អ៊ុំ សេរីវុត្ថ** | គ្រូនគរបាលជាតិ | សមាជិក |
| ១៣. លោកអនុសេនីយ៍ឯក | **និត្យ ធីណា** | គ្រូនគរបាលជាតិ | សមាជិក |
| ១៤. កញ្ញាអនុសេនីយ៍ឯក | **ផង់ សុជាន់ណារី** | គ្រូនគរបាលជាតិ | សមាជិក |
| ១៥. លោកអនុសេនីយ៍ឯក | **សួន សេដ្ឋារតនៈ** | គ្រូនគរបាលជាតិ | សមាជិក |
| ១៦. លោកអនុសេនីយ៍ត្រី | **ទៀម ចំរើន** | គ្រូនគរបាលជាតិ | សមាជិក |
| ១៧. លោកអនុសេនីយ៍ត្រី | **អ៊ុន អុណាម៉ាណាន់** | គ្រូនគរបាលជាតិ | សមាជិក |

## ខ- សមាសភាពអ្នកចូលរួមមកពីអង្គភាពពាក់ព័ន្ធ

| | | | |
|---|---|---|---|
| ១៨. លោក | **សំលៀង សីលា** | នាយកប្រតិបត្តិ អង្គការសកម្មភាពដើម្បីកុមារ (APLE) | សមាជិក |
| ១៩. លោក | **ឈោង វណ្ណៈ** | អ្នកសម្របសម្រួលគម្រោង អង្គការសកម្មភាពដើម្បីកុមារ (APLE) | សមាជិក |
| ២០. លោក | **ផៃ សុភ័ក្រ្ត** | ប្រធានកម្មវិធីអភិវឌ្ឍផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ អង្គការសកម្មភាពដើម្បីកុមារ (APLE) | សមាជិក |
| ២១. លោកស្រី | **អ៊ឹង ភល្យាណ** | បុគ្គលិកកិច្ចការពារកុមារ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) | សមាជិក |
| ២២. លោក | **ស៊ា សុឃន់** | ទីប្រឹក្សាគម្រោង អង្គការសកម្មភាពដើម្បីកុមារ (APLE) | សមាជិក |

# មាតិកា


សមាសភាពក្រុមអ្នកនិពន្ធ ........ iv

អារម្ភកថា ........ x

សេចក្តីថ្លែងអំណរគុណ ........ xii

សេចក្តីផ្តើម ........ ១

គោលបំណង ........ ៣

សារៈសំខាន់ ........ ៥

**មេរៀនទី១ ៖**

បច្ចេកវិទ្យា និងពិភពនិម្មិតរបស់កុមារ និងក្មេងជំទង់ក្នុងបរិបទកម្ពុជា ........ ៧

**មេរៀនទី២ ៖**

ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ( OCSEA ) ........ ៤៥

**មេរៀនទី៣ ៖**

ចរិតលក្ខណៈ និងផលប៉ះពាល់នៃការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ........ ៦៥

**មេរៀនទី៤ ៖**

មាត្រាច្បាប់ និងសូចនាករពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ........ ៨០

**មេរៀនទី៥ ៖**

សិទ្ធិកុមារនៅក្នុងពិភពឌីជីថល ........ ៩០

**មេរៀនទី៦ ៖**

គោលការណ៍អនុវត្តបែបកុមារមេត្រី ........ ១០៩

**មេរៀនទី៧ ៖**

ការស៊ើបអង្កេតបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ............ ១២២

**មេរៀនទី៨ ៖**

វិធីសាស្រ្ត ឆ្លើយតបការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ............ ១៣៨

**មេរៀនទី៩ ៖**

ដំណោះស្រាយចំពោះបញ្ហាប្រឈម និងផលវិបាកទូទៅ............ ១៥៣

**មេរៀនទី១០ ៖**

វិធានសុវត្ថិភាពនៅលើអនឡាញការរាយការណ៍ និងការស្វែងរកជំនួយ ............ ១៦១

**មេរៀនទី១១ ៖**

ការប្រតិបត្តិផ្អែកលើចំណេះដឹង និងជំនាញ ............ ១៧៥

**សេចក្តីសន្និដ្ឋាន** ............ ១៨០

**សន្ទានុក្រម** ............ ១៨២

**ឧបសម្ព័ន្ធ៖ ដំណើរការ និងជំហានសម្របសម្រួលវគ្គ**............ ១៨៦

**ឧបសម្ព័ន្ធមេរៀនទី១ ៖**

ការយល់ដឹងអំពីបច្ចេកវិទ្យា និងពិភពនិម្មិត របស់កុមារនិងយុវជនក្នុងបរិបទកម្ពុជា............ ១៨៦

**ឧបសម្ព័ន្ធមេរៀនទី២ ៖**

ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ( OCSEA)............ ១៩១

**ឧបសម្ព័ន្ធមេរៀនទី៣ ៖**

ចរិតលក្ខណៈ និងផលប៉ះពាល់នៃការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA)............ ១៩៦

**ឧបសម្ព័ន្ធមេរៀនទី៤ ៖**

មាត្រាច្បាប់ និងសូចនាករពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ............ ២០១

**ឧបសម្ព័ន្ធមេរៀនទី៥ ៖**

សិទ្ធិកុមារនៅក្នុងពិភពឌីជីថល ............ ២០៤

**ឧបសម្ព័ន្ធមេរៀនទី៦ ៖**

គោលការណ៍អនុវត្តបែបកុមារមេត្រី............ ២០៧

**ឧបសម្ព័ន្ធមេរៀនទី៧ ៖**

ការស៊ើបអង្កេតបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ............ ២១៣

**ឧបសម្ព័ន្ធមេរៀនទី៨ ៖**

វិធីសាស្ត្រឆ្លើយតបការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ
លើប្រព័ន្ធអនឡាញ (OCSEA) ............ ២១៨

**ឧបសម្ព័ន្ធមេរៀនទី៩ ៖**

ដំណោះស្រាយចំពោះបញ្ហាប្រឈម និងផលវិបាកទូទៅ............ ២២៥

**ឧបសម្ព័ន្ធមេរៀនទី១០ ៖**

វិធានសុវត្ថិភាពនៅលើអនឡាញ ការរាយការណ៍ និងការស្វែងរកជំនួយ ............ ២២៩

**ឧបសម្ព័ន្ធមេរៀនទី១១ ៖**

ការប្រតិបត្តិផ្អែកលើចំណេះដឹង និងជំនាញ ............ ២៣២

**ករណីសិក្សា** ............ ២៣៥

**ឯកសារយោង**............ ២៤៥

# អារម្ភកថា

បញ្ហានៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) នៅក្នុងប្រទេស កម្ពុជា និងនៅក្នុងពិភពលោក នាយុគសម័យឌីជីថលបច្ចុប្បន្ន ត្រូវបានរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឧស្សាហកម្មបច្ចេកវិទ្យា កំពុង ព្រួយបារម្ភ និងយកចិត្តទុកដាក់បំផុតដោយបានចាត់ទុក ជាបទល្មើសប្រឆាំងកុមារដ៏ធ្ងន់ធ្ងរដែលបង្កបញ្ហាប្រឈមយ៉ាងខ្លាំង ដល់សង្គមជាតិ។

នាពេលបច្ចុប្បន្ន ការយល់ដឹងរបស់អ្នកធ្វើការពាក់ព័ន្ធ រួមទាំងមន្ត្រីនគរបាល នៅតែមានគម្លាតដែលជាបញ្ហាប្រឈមក្នុងការឆ្លើយតបនឹង OCSEA។ ដូច្នេះ វាចាំបាច់ណាស់ក្នុងការសម្របសម្រួលរៀបចំការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដើម្បីបំពេញ កង្វះខាតនៃចំណេះដឹង ជំនាញ និងការអនុវត្តរបស់ ស្ថាប័នមានសមត្ថកិច្ច នានា។

ក្នុងន័យនេះ ការរៀបចំសៀវភៅគោលសម្រាប់បណ្តុះបណ្តាល ដែលមានចំណងជើងថា «ការឆ្លើយតបនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)» បានយកចិត្តទុកដាក់លើការយល់ដឹងស៊ីជម្រៅអំពី ការឆ្លើយតបដោយផ្តោតលើកុមាររងគ្រោះ ផលប៉ះទង្គិច ភាពរសើបនៃវប្បធម៌ សេវាគាំទ្រចម្រុះសម្រាប់កុមាររងគ្រោះ និងសាក្សីនៃ OCSEA។ សៀវភៅគោលនេះបានភ្ជាប់ជាមួយនូវឯកសារឧបសម្ព័ន្ធសម្រាប់ចែកជូនសិស្ស និស្សិត និងសិក្ខាកាម ដើម្បីពង្រីកចំណេះដឹងបន្ថែមអំពី OCSEA ការវិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថល និងហានិភ័យដែលវាអាចបង្កដល់កុមារ និងយុវជនកម្ពុជា។

ប្រធានបទ និងខ្លឹមសារ ដែលបានចងក្រងនៅក្នុងសៀវភៅនេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើលទ្ធផលស្រាវជ្រាវថ្មីៗអំពី OCSEA ក្នុងបរិបទជាក់ស្តែង ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ ប្រធានបទអំពីវិធីសាស្ត្រអនុវត្តបែបកុមារមេត្រី ក៏ត្រូវបានបញ្ចូលផងដែរដើម្បីរំលឹក និងលើកទឹកចិត្តដល់ការអនុវត្តដែលផ្តោតលើ សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។

សៀវភៅគោលសម្រាប់បណ្តុះបណ្តាល ក៏ផ្តល់ការណែនាំសម្រាប់ប្រធានបទនីមួយៗ រួមមានសន្លឹកកិច្ចការ ករណីសិក្សា ស្លាយ និងធនធានពាក់ព័ន្ធផ្សេងទៀត។ ប្រធានបទសិក្សានីមួយៗត្រូវបានកំណត់ដោយប្រើចំណងជើងដូចមានបង្ហាញជូននៅក្របខាងលើ ហើយកំណត់ចំណាំសម្រាប់

សម្របសម្រួលរបស់គ្រូ ក៏ត្រូវបានផ្តល់ជូននៅផ្នែកខាងក្រោមផងដែរ។ ការណែនាំត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជូនជាព័ត៌មាន ប៉ុន្តែក៏ផ្តល់ឱកាសសម្រាប់ការចូលរួមយ៉ាងសកម្មពីអ្នកចូលរួម និងអ្នកសម្របសម្រួលដោយពួកគេអាចចែករំលែកបទពិសោធន៍ និងទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេបានផងដែរ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅគោលសម្រាប់បណ្តុះបណ្តាលនឹងផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីនគរបាល ដែលប្រើប្រាស់សៀវភៅគោលនេះ និងរួមចំណែកប្រកបដោយប្រសិទ្ធភាពខ្ពស់ដល់ការបណ្តុះបណ្តាលសម្រាប់អ្នកអនុវត្តច្បាប់ជាតិ ព្រមទាំងជម្រុញ ការអនុវត្តបែបយុទ្ធសាស្ត្រ និងវប្បធម៌ ក្នុងការឆ្លើយតបនឹង OCSEA។

# សេចក្ដីថ្លែងអំណរគុណ

ភាពជឿនលឿននៃបច្ចេកវិទ្យាឌីជីថល បានជម្រុញឱ្យភាពរីកចម្រើននៃការងារនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលបាននាំប្រទេសកម្ពុជាកាន់តែខិតជិតទៅនឹងប្រទេសក្នុងតំបន់ និងពិភពលោក។ បើទោះជាបច្ចេកវិទ្យាឌីជីថលផ្ដល់នូវអត្ថប្រយោជន៍ និងឱកាសមហិមាសម្រាប់អ្នកប្រើប្រាស់ វាក៏ត្រូវបានប្រើប្រាស់ដោយ ជនល្មើសសម្រាប់ប្រព្រឹត្ត ឬសម្របសម្រួលដល់ OCSEA ដែលជាទម្រង់នៃបទល្មើសថ្មីមួយកំពុងរីករាលដាលនៅជុំវិញពិភពលោក រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ។

ផ្អែកលើបរិបទនេះ ការបណ្ដុះបណ្ដាលគឺជាការងារដ៏ចាំបាច់មួយដែលទទួលបានការគាំទ្រពីស្ថាប័ននគរបាលជាតិ ដូចបានបង្ហាញនៅក្នុងរបាយការណ៍ស្រាវជ្រាវ ស្ដីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disrupting Harm Global Study in Cambodia) ដែលបានប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការនៅខែកញ្ញា ឆ្នាំ២០២២។ អង្គការសកម្មភាពដើម្បីកុមារ (APLE) ដែលបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីនគរបាលកម្ពុជា បានដឹកនាំការវាយតម្លៃអំពីតម្រូវការនៃការបណ្ដុះបណ្ដាលសម្រាប់មន្ត្រីនគរបាល ដើម្បីកំណត់អទិភាព និងវិធីសាស្ត្រក្នុងការពង្រឹងសមត្ថភាពមន្ត្រីនគរបាលជាតិឱ្យកាន់តែមានប្រសិទ្ធភាព។

សៀវភៅគោលនេះត្រូវបានបង្កើតឡើងដោយលោក Alastair Hilton ជាទីប្រឹក្សារបស់អង្គការ APLE និងមានការចូលរួមផ្ដល់មតិយោបល់ និងត្រួតពិនិត្យបច្ចេកទេសពីបុគ្គលិករបស់អង្គការ APLE រួមមានលោក សំលៀង សីលា នាយកប្រតិបត្តិ លោក ផៃ សុភ័ក្ត្រ ប្រធានក្រុមកម្មវិធីអភិវឌ្ឍន៍យុត្តិធម៌ព្រហ្មទណ្ឌ លោក ញ៉ែម ពិសិដ្ឋ អ្នកវិភាគជាន់ខ្ពស់ និងលោក អៀង ឫទ្ធី ប្រធានផ្នែកស៊ើបអង្កេត ក្រោមបរិបទដ៏ទូលំទូលាយនៃគោលនយោបាយស្ថាប័នដែលតម្រូវឱ្យមានកិច្ចសហការរវាងភាគីពាក់ព័ន្ធ។ ការរៀបចំសៀវភៅគោលនេះផ្អែកលើរបាយការណ៍ប៉ាន់ប្រមាណតម្រូវការបណ្ដុះបណ្ដាល (TNA) ដែលបញ្ចូលមតិយោបល់ទទួលបានពីកិច្ចសម្ភាស ជាមួយអ្នកពាក់ព័ន្ធថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងសិក្ខាសាលាពិគ្រោះយោបល់ជាមួយមន្ត្រីនគរបាលជាតិជាន់ខ្ពស់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (AHTJPD) នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា (ACCD) នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ និងកោសលវិច័យ បណ្ឌិត្យសភា

នគរបាលកម្ពុជា (PAC) ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) ព្រមទាំងមន្ត្រីអនុវត្តច្បាប់អន្តរជាតិ ដែលយល់ដឹងច្បាស់ពីបទល្មើសពាក់ព័ន្ធនឹង OCSEA និងបរិបទរបស់ប្រទេសកម្ពុជា។ ជាមួយគ្នានេះ ក៏មានការចូលរួមពីអ្នកតំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបទពិសោធន៍ធ្វើការជាមួយកុមាររងគ្រោះ គ្រួសារ និងសហគមន៍។ ។

អង្គការសកម្មភាពដើម្បីកុមារ (APLE) និងបណ្ឌិត្យសភានគរបាលកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្របច្ចេកទេសរបស់អង្គការយូនីសេហ្វ ប្រចាំប្រទេសកម្ពុជា (UNICEF Cambodia) និងការគាំទ្រថវិការបស់ភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ (Global Partnership to End Violence Against Children) និងឧបត្ថម្ភបោះពុម្ពដោយជំនួយពីរដ្ឋាភិបាលអូស្ត្រាលី (Australian Aid) និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការដៃគូ សម្រាប់កិច្ចសហការយ៉ាងល្អក្នុងដំណើរការរៀបចំសៀវភៅគោលនេះដែលនាំឱ្យសម្រេចបាននូវលទ្ធផលប្រកបដោយមោទនភាព។

**សូមអរគុណ!**

# សេចក្តីផ្តើម

ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) បានដើរតួនាទីកាន់តែសំខាន់នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតមនុស្ស ហើយបានផ្លាស់ប្តូរជីវិតរបស់យើង ការងារ ការលំហែ ការទំនាក់ទំនង ជីវិតគ្រួសារ អាជីវកម្ម ការធ្វើដំណើរ ការរៀនសូត្រ ព្រមទាំងការចូលរួមសកម្មភាពនយោបាយ។ល។ គ្រប់ទិដ្ឋភាពនៃជីវិតរបស់យើងទទួលបានឥទ្ធិពលពីបច្ចេកវិទ្យាតាមរបៀបជាច្រើន។ ជាក់ស្តែងកាលពី២០ឆ្នាំមុន មិនមែនគ្រប់គ្នាសុទ្ធតែមានទូរសព្ទផ្ទាល់ខ្លួនទេ ហើយក៏មិនមែនជារឿងចម្លែកដែរ ក្នុងការឃើញ ស្តង់ទូរសព្ទសាធារណៈនៅកាច់ជ្រុងផ្លូវ។

សៀវភៅគោលនេះត្រូវបានបង្កើតឡើង បន្ទាប់ពីការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល (TNA) ជាមួយមន្ត្រីនគរបាលជាតិ។ គោលបំណងរួមនៃសៀវភៅនេះ គឺដើម្បីបង្កើតវគ្គបណ្តុះបណ្តាលដែលអាចជួយមន្ត្រីនគរបាលឱ្យយល់ដឹងអំពីការកំណត់អត្តសញ្ញាណ និងស៊ើបអង្កេតបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)។

របាយការណ៍ប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល (TNA) បានកំណត់ពីតម្រូវការក្នុងការអភិវឌ្ឍការរៀនដ៏ចាំបាច់ទាក់ទងនឹង OCSEA ដែលជាចំណុចផ្តោតសំខាន់នៃសៀវភៅគោលនេះផងដែរ។ របាយការណ៍នេះក៏បានកំណត់ពីតម្រូវការសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសឌីជីថលជាក់លាក់សម្រាប់មន្ត្រីនគរបាលជាតិ (CNP)។ ការបណ្តុះបណ្តាលទាំងនេះតម្រូវឱ្យមានដំណើរការខុសប្លែកគ្នា ហើយសង្ឃឹមថានឹងត្រូវបានបង្កើតឡើងនាពេលអនាគតដ៏ខ្លីខាងមុខនេះ នៅក្នុងដំណើរការរួមគ្នារវាងមន្ត្រីនគរបាលជាតិ អង្គការ APLE និងតួអង្គផ្សេងៗទៀត ដែលនឹងបំពេញបន្ថែមសៀវភៅគោលនេះ។ របាយការណ៍ TNA ក៏ផ្តល់អនុសាសន៍ជាក់លាក់ទាក់ទងនឹងខ្លឹមសារដែលគួរបញ្ចូលក្នុងការបណ្តុះបណ្តាលបច្ចេកទេសនេះ។

ដូច្នេះសៀវភៅគោលនេះ ផ្តោតលើផ្នែកជាច្រើននៃអ្វីដែលត្រូវបានពិពណ៌នាថាជា «ការរៀនដ៏ចាំបាច់» ដែលត្រូវបានរចនាឡើង ដើម្បីបំពេញបន្ថែម (មិនជំនួស) ការបណ្តុះបណ្តាលផ្សេងទៀតទាក់ទងនឹងការអនុវត្តបែបកុមារមេត្រី ដែលត្រូវបានបង្កើតឡើង និងផ្តល់ជូនអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

រយៈពេលបណ្តុះបណ្តាលនៃវគ្គនីមួយៗគឺអាស្រ័យលើទំហំនៃក្រុម និងស្ថានភាពទីកន្លែងនៃវគ្គទាំងនោះ។ យើងអាចផ្លាស់ប្តូររយៈពេលនេះបាន បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង ហើយក៏អាស្រ័យលើអ្នកចូលរួមវគ្គ និងស្ថិរភាពផ្សេងៗទៀតដែលតម្រូវឱ្យអ្នករៀបចំវគ្គបណ្តុះបណ្តាលបត់បែនទៅតាមភាពជាក់ស្តែង ហើយច្នៃប្រឌិតវិធីសាស្រ្តបង្រៀនស្របនឹងខ្លឹមសារមេរៀន រួមទាំងមធ្យោបាយគាំទ្រ និងធនធានផ្សេងៗទៀតផងដែរ។

# គោលបំណង

សៀវភៅគោលស្តីពី «ការឆ្លើយតបនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)» ដែលនឹងត្រូវដាក់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលនៅបណ្ឌិត្យសភានគរបាលកម្ពុជានេះ ជាចំណែកដ៏សំខាន់មួយនៃការអនុវត្តផែនការសកម្មភាពស្តីពីការបង្ការ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ២០២១-២០២៥ និងជួយដល់គ្រូបង្គោលក្នុងការបណ្តុះបណ្តាលបង្កើនចំណេះដឹង និងជំនាញដល់មន្ត្រីអនុវត្តច្បាប់ ជាពិសេសមន្ត្រីនគរបាលដែលកំពុងរៀននៅបណ្ឌិត្យសភានគរបាលកម្ពុជា និងកំពុងបំពេញការងារនៅតាមស្ថាប័នឬអង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ ក្នុងការអនុវត្តភារកិច្ចស្នូល ឱ្យមានសង្គតិភាព ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពខ្ពស់។

ខ្លឹមសារសៀវភៅគោលនេះ ក៏ផ្តល់នូវចំណេះដឹងអំពីបរិបទដែល OCSEA កើតឡើងដោយឆ្លុះបញ្ចាំងពីការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) របស់ពួកគេផ្ទាល់ ហើយពិចារណាអំពីអត្ថប្រយោជន៍ បញ្ហាប្រឈម និងហានិភ័យនៃការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះផងដែរ។ អ្នកសិក្សាអាចស្វែងយល់ពីរបៀបដែលកុមារ និងក្មេងជំទង់នៅកម្ពុជា កំពុងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងរបៀបដែលពួកគេរងផលប៉ះពាល់ពី OCSEA តាមរយៈវិធីដូចខាងក្រោម៖

- ផ្តល់នូវចំណេះដឹងទូលំទូលាយអំពីបរិបទនៃអំពើហិង្សាលើកុមារ ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ដោយឆ្លុះបញ្ចាំងអំពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់កុមារ និងក្មេងជំទង់នៅកម្ពុជា ហើយក៏ពិចារណាពីអត្ថប្រយោជន៍ បញ្ហាប្រឈម និងហានិភ័យនៃការប្រើប្រាស់ទាំងអស់នោះ។
- ស្វែងយល់អំពីការកំណត់និយមន័យដូចជាអំពើរំលោភបំពានផ្លូវភេទលើកុមារ (CSA) ការកេងប្រវ័ញ្ចផ្លូវភេទកុមារ (CSE) និងអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ការកំណត់ពីអាកប្បកិរិយា និងសកម្មភាពដែលត្រូវចាត់ជា OCSEA ។
- ពិចារណាពីជំនឿភ័ន្តច្រឡំទាក់ទងនឹង OCSEA និង CSA និងយល់ដឹងអំពីច្បាប់របស់ប្រទេសកម្ពុជា និងអន្តរជាតិទាក់ទងនឹង OCSEA និងគូសបញ្ជាក់ពីការប្រែប្រួលនៃក្របខណ្ឌច្បាប់ដែលរំពឹងទុក។

- ស្វែងយល់ពីទំនាក់ទំនងរវាង OCSEA និងការរំលោភបំពានផ្លូវភេទក្រៅប្រព័ន្ធអនឡាញ (CSA Offline) និងការឆ្លើយតបដ៏ល្អប្រសើរនៅពេលករណី OCSEA កើតឡើង។
- រំលឹកឡើងវិញនូវគោលការណ៍សំខាន់ៗនៃសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និងពិចារណានូវសិទ្ធិកុមារនៅក្នុងបរិយាកាសឌីជីថលផងដែរ។
- ស្វែងយល់អំពីវិធីសាស្រ្តអនុវត្តបែបកុមារមេត្រីក្នុងការសម្ភាស និងគាំទ្រកុមាររងគ្រោះពីការកេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទ។
- ឆ្លុះបញ្ចាំងពី ការស្រាវជ្រាវនៅប្រទេសកម្ពុជាទាក់ទងនឹងបទពិសោធន៍របស់កុមារនៅក្នុងការស្វែងរកជំនួយ និងផ្តល់ការសហការជាមួយមន្ត្រីនគរបាល ក្នុងដំណើរការស៊ើបអង្កេតករណី OCSEA។
- កំណត់បាននូវបញ្ហាប្រឈមដែលមន្ត្រីនគរបាលតែងតែជួបប្រទះនៅពេលធ្វើការជាមួយកុមាររងផលប៉ះពាល់ដោយ OCSEA និងដំណោះស្រាយដែលអាចយកទៅអនុវត្តបាន។
- ផ្តល់ការយល់ដឹងពីយន្តការរាយការណ៍ ការស៊ើបអង្កេត និងការឆ្លើយតបនឹងករណី OCSEA។
- ផ្តល់នូវការណែនាំអំពីការចូលប្រើប្រាស់ Chatbot (ពិសី) របស់អង្គការ APLE តាមរយៈទូរសព្ទកុំព្យូទ័រ ឬឧបករណ៍ចល័តដទៃទៀត។

# សារៈសំខាន់

សៀវភៅគោលស្តីពី «ការឆ្លើយតបនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)» ផ្តោតសំខាន់ទៅលើផ្នែកជាច្រើន ដែលចាំបាច់ត្រូវបំពេញបន្ថែមដល់វគ្គបណ្តុះបណ្តាលផ្សេងៗទាក់ទងនឹងដំណើរការនៃការអនុវត្តបែបកុមារមេត្រី និងភាពងាយរងគ្រោះរបស់កុមារនៅក្នុងប្រទេសកម្ពុជា នាយុគសម័យឌីជីថល។ មានកុមារជាច្រើននាក់នៅលើពិភពលោក និងនៅប្រទេសកម្ពុជា បានរងគ្រោះពីអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ និងកំពុងត្រូវការការគាំពារ។

ការរៀបចំចងក្រងឱ្យមានសៀវភៅគោលនេះ បានផ្តល់នូវអត្ថប្រយោជន៍ដល់សង្គមជាតិ ដោយបានជួយដល់រាជរដ្ឋាភិបាល ស្ថាប័នអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា និងអង្គការដៃគូជាតិ-អន្តរជាតិនានាដែលកំពុងយកចិត្តទុកដាក់លើបញ្ហាកុមាររងគ្រោះ និងងាយរងគ្រោះពី OCSEA និងតម្រង់ទិសសម្រាប់ជាគំនិតផ្តួចផ្តើមដល់ការបណ្តុះបណ្តាលមន្ត្រីនគរបាលឱ្យបានកាន់តែទូលំទូលាយ ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពខ្ពស់។

ក្នុងន័យនេះ ខ្លឹមសារសៀវភៅគោលបានផ្តល់នូវសារៈសំខាន់ជាច្រើនសម្រាប់ជាការឆ្លើយតបនឹងប្រភេទបទល្មើសថ្មីៗ ជាច្រើនដែលជនល្មើសកំពុងឆ្លៀតឱកាសប្រើប្រាស់បច្ចេកវិទ្យាធ្វើសកម្មភាពកេងប្រវ័ញ្ចកុមារលើប្រព័ន្ធអនឡាញដែលរួមមានជាអាទិ៍៖

- ជំរុញលើកទឹកចិត្តក្នុងការអនុវត្តបែបយុទ្ធសាស្ត្រ និងវប្បធម៌សំដៅឆ្លើយតបដោយផ្តោតលើសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និងគ្រួសាររបស់ពួកគេ។
- ជះឥទ្ធិពលលើដំណើរការក្នុងការរៀបចំផែនការសកម្មភាព ដើម្បីអនុវត្តការស៊ើបអង្កេតរបស់មន្ត្រីនគរបាលជាតិឱ្យមានភាពស៊ីចង្វាក់ប្រទាក់ក្រឡាគ្នា និងធ្វើអន្តរាគមន៍ឆ្លើយតបនឹង OCSEA ប្រកបដោយប្រសិទ្ធភាព និងបង្កភាពងាយស្រួលក្នុងការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។

- ភាពច្បាស់លាស់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធ រួមទាំងមន្ត្រីនគរបាលក្នុងក្របខណ្ឌជាតិ និងអាស៊ាន ដើម្បីអនុវត្តផែនការសកម្មភាពបង្ការ-ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញរបស់ ITU និង ASEAN ដោយធានាបានថា សិទ្ធិកុមារត្រូវបានគិតគូរដូចគ្នាទាំងនៅខាងក្រៅ និងលើប្រព័ន្ធអនឡាញ។
- ធ្វើឱ្យកុមារ និងក្មេងជំទង់នៅក្នុងសហគមន៍មានភាពក្លាហាន ជឿជាក់លើការឆ្លើយតបរបស់អាជ្ញាធរ និងមន្ត្រីនគរបាលជំនាញ។
- មន្ត្រីនគរបាលមានទំនុកចិត្តចែករំលែកបទពិសោធន៍ទាក់ទងនឹងករណី OCSEA ដែលពួកគេបានស៊ើបអង្កេត និងបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ ក្នុងគោលបំណងសិក្សាស្វែងយល់ និងកំណត់រកវិធីសាស្ត្រឆ្លើយតបដែលកាន់តែមានប្រសិទ្ធភាព។

## មេរៀនទី១៖

# បច្ចេកវិទ្យា និងពិភពនិម្មិត របស់កុមារ និងក្មេងជំទង់ក្នុងបរិបទកម្ពុជា

មុនសិក្សាស៊ីជម្រៅលើមេរៀនទាំងអស់ក្នុងសៀវភៅគោលនេះ យើងគួរយល់ដឹងអំពីពាក្យគន្លឹះ និយមន័យ និងបរិបទមូលដ្ឋានមួយចំនួនទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលជាមុនសិន។ ចំណេះដឹងទាំងនេះនឹងផ្តល់ឱ្យអ្នកនូវមូលដ្ឋានរឹងមាំដែលជួយដល់ការសិក្សាពិស្តារលើមេរៀននីមួយៗ ក៏ដូចជាភាពងាយស្រួលក្នុងការស្វែងយល់ពីរបៀបអនុវត្តដំណើរការស៊ើបអង្កេត និងធ្វើអន្តរាគមន៍ឆ្លើយតបចំពោះបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)។

## ក ពាក្យគន្លឹះ និងនិយមន័យ

ជាការពិត បច្ចេកវិទ្យាឌីជីថលកំពុងតែមានការវិវត្តទៅមុខឥតឈប់ឈរ។ ខណៈពេលដែលអ្នកកំពុងកាន់សៀវភៅនេះអាន ឬសិក្សា អាចនឹងមានពាក្យគន្លឹះ និងនិយមន័យមួយចំនួនដែលបានសរសេរនៅក្នុងសៀវភៅនេះប្រែប្រួល ចាស់ហួសសម័យកាល ឬលែងត្រូវនឹងការវិវឌ្ឍនៃបច្ចេកវិទ្យារួចទៅហើយ។ ទោះជាយ៉ាងណាក៏ដោយ យើងព្យាយាមដាក់បញ្ចូលពាក្យគន្លឹះដែលត្រូវប្រើប្រាស់ជាញឹកញាប់ និងអាចមានភាពពាក់ព័ន្ធស្ទើរគ្រប់សម័យកាលនៃបច្ចេកវិទ្យាឌីជីថល។

ប្រសិនបើមានពាក្យគន្លឹះ ឬនិយមន័យណាមួយដែលអ្នកពិបាកយល់ ឬមិនទាន់យល់ច្បាស់នៅពេលសិក្សាលើកដំបូងនេះ សូមកុំបារម្ភ ព្រោះអ្នកនឹងបានជួបជាច្រើនដងនៅក្នុងមេរៀនក្រោយៗ។ ដល់ពេលនោះ អ្នកអាចយល់បានយ៉ាងច្បាស់លាស់។

### ក.១- ឧបករណ៍អេឡិចត្រូនិក (Electronic Device)

ឧបករណ៍អេឡិចត្រូនិក សំដៅដល់ឧបករណ៍ទាំងឡាយណាដែលប្រើអគ្គិសនីដើម្បីបំពេញមុខងាររបស់វា។ ឧទាហរណ៍រួមមាន ទូរទស្សន៍ វិទ្យុ កុំព្យូទ័រ ។ល។ ឧបករណ៍ទាំងនេះប្រើសៀគ្វីអគ្គិសនីដើម្បីដំណើរការព័ត៌មាន ឬទិន្នន័យ។



### ក.២- ឧបករណ៍ឌីជីថល (Digital Device)

ឧបករណ៍ឌីជីថលសំដៅដល់ឧបករណ៍អេឡិចត្រូនិកដែលដំណើរការ និងរក្សាទុកព័ត៌មាន ឬទិន្នន័យក្នុងទម្រង់ឌីជីថល មានន័យថាវាប្រើលេខកូដគោលពីរ (0s និង 1s)។ ឧទាហរណ៍រួមមាន ស្មាតហ្វូន ថេប្លេត កាមេរ៉ាឌីជីថល ជាដើម។

### ក.៣- បច្ចេកវិទ្យាឌីជីថល (Digital Technology)

បច្ចេកវិទ្យាឌីជីថលសំដៅដល់ឧបករណ៍ និងប្រព័ន្ធដែលបង្កើត រក្សាទុក ឬដំណើរការទិន្នន័យក្នុងទម្រង់ឌីជីថល។ វារួមបញ្ចូលឧបករណ៍ដូចជា កុំព្យូទ័រ ថេប្លេត និងស្មាតហ្វូន ក៏ដូចជាកម្មវិធីអនឡាញ និងសេវាកម្មដែលមានមូលដ្ឋានលើអ៊ីនធឺណិត។

បច្ចេកវិទ្យាឌីជីថល ក៏សំដៅដល់បច្ចេកវិទ្យាអេឡិចត្រូនិកដែលត្រូវបានគេបង្កើតឡើង និងប្រើប្រាស់ដើម្បីរក្សាទុក ធ្វើដំណើរការ (បម្លែង និងវិភាគទិន្នន័យ) បញ្ជូន និងបង្ហាញព័ត៌មាន។ បច្ចេកវិទ្យាឌីជីថលបានផ្លាស់ប្តូរទិដ្ឋភាពផ្សេងៗនៃជីវិតរបស់អ្នកដូចជាការស្រាវជ្រាវ ការប្រាស្រ័យទាក់ទង ការកម្សាន្ត ការធ្វើអាជីវកម្ម និងការអប់រំ។ ពិភពឌីជីថលក៏បានផ្តល់នូវឱកាសសម្រាប់ការតភ្ជាប់ ច្នៃប្រឌិត និងបង្កើតមធ្យោបាយដ៏សម្បូរបែបក្នុងការប្រាស្រ័យទាក់ទងគ្នា និងការទទួលបានព័ត៌មាន។[1]




## ក.៤- ឧបករណ៍បណ្តាញ (Network Devices)

ឧបករណ៍បណ្តាញ សំដៅដល់ឧបករណ៍អេឡិចត្រូនិកដែលជួយកុំព្យូទ័រ និងឧបករណ៍ផ្សេងទៀតទំនាក់ទំនងគ្នាទៅវិញទៅមកតាមបណ្តាញ។ ឧទាហរណ៍រួមមាន៖

- **រ៉ោតទ័រ (Router)៖** ឧបករណ៍ដែលភ្ជាប់បណ្តាញកុំព្យូទ័រផ្សេងៗគ្នា ហើយវាដើរតួនាទីដូចជាអ្នកគ្រប់គ្រងចរាចរណ៍ ដឹកនាំទិន្នន័យ (ដូចជាអ៊ីមែល ឬគេហទំព័រ) រវាងឧបករណ៍មួយ (ដូចជាទូរសព្ទ និងកុំព្យូទ័រ) និងអ៊ីនធឺណិត។ វាធ្វើឱ្យប្រាកដថាព័ត៌មានទៅកន្លែងដែលវាត្រូវទៅ ដូចជាអ្នកផ្ញើសំបុត្របញ្ជូនសំបុត្រទៅអាសយដ្ឋានត្រឹមត្រូវ។
- **ជុំបម្លែង (Switch)៖** ឧបករណ៍ដែលប្រើក្នុងបណ្តាញកុំព្យូទ័រដើម្បីភ្ជាប់ឧបករណ៍ជាច្រើនដូចជាកុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និងម៉ាស៊ីនមេ នៅក្នុងបណ្តាញតែមួយ។ វាទទួលទិន្នន័យពីឧបករណ៍មួយ ហើយបន្ទាប់មកបញ្ជូនវាទៅឧបករណ៍ជាក់លាក់ ដោយធានាថាព័ត៌មានទៅដល់កន្លែងត្រឹមត្រូវ និងគ្មានការពង្រាយពាសពេញបណ្តាញទាំងមូល។

[1] អត្ថបទ និងរូបភាពនេះ ដកស្រង់ចេញពីសៀវភៅណែនាំបង្រៀនអំពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ កម្រិតមធ្យមសិក្សាបឋមភូមិ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលចេញផ្សាយនៅខែមីនា ឆ្នាំ២០២៤។

- **ម៉ូដឹម (Modem)៖** ឧបករណ៍ដែលភ្ជាប់បណ្តាញរបស់អ្នកទៅនឹងអ៊ីនធឺណិត។ វាបម្លែងសញ្ញាពីអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នកទៅជាទម្រង់មួយដែលឧបករណ៍របស់អ្នកអាចយល់ និងប្រើដើម្បីចូលទៅកាន់គេហទំព័រ។ បើគ្មានម៉ូដឹម អ្នកនឹងមិនអាចភ្ជាប់អ៊ីនធឺណិតបានទេ។
- **ចំណុចចូលដំណើរការ (Access Point)៖** ឧបករណ៍ដែលពង្រីករយៈចម្ងាយនៃបណ្តាញ Wi-Fi។ វាដើរតួនាទីដូចជាស្ពាន ដែលអនុញ្ញាតឱ្យឧបករណ៍ជាច្រើនភ្ជាប់ទៅបណ្តាញឥតខ្សែ ដូច្នេះអ្នកអាចមានអ៊ីនធឺណិតនៅក្នុងតំបន់ជាច្រើនទៀត ដូចជាបន្ទប់ផ្សេងៗគ្នានៅក្នុងផ្ទះ ឬផ្នែកនៃអគារការិយាល័យជាដើម។




### ក.៨- បច្ចេកវិទ្យាព័ត៌មាន (Information Technology "IT")

បច្ចេកវិទ្យាព័ត៌មាន ឬ IT សំដៅលើការប្រើប្រាស់កុំព្យូទ័រ កម្មវិធី បណ្តាញ និងឧបករណ៍អេឡិចត្រូនិកផ្សេងទៀត ដើម្បីរក្សាទុក ទាញយក បញ្ជូន និងរៀបចំទិន្នន័យ។ IT រួមបញ្ចូលផ្នែករឹង (ដូចជាកុំព្យូទ័រ "Computers" និងម៉ាស៊ីនមេ "Servers") និងផ្នែកទន់ (ដូចជាប្រព័ន្ធប្រតិបត្តិការ "Operating Systems" និងកម្មវិធីប្រើប្រាស់ទូទៅ "Applications") និងបណ្តាញ (ដូចជាអ៊ីនធឺណិត "Internet")។ ពាក្យ IT ត្រូវបានគេរកឃើញ និងប្រើប្រាស់មុនគេ នៅក្នុងអំឡុងពេលបច្ចេកវិទ្យាព័ត៌មានវិវត្តដំបូងៗ ពោលគឺវាកើតឡើងនៅមុនពេលពាក្យថា ICT (Information and Communications Technology) បានក្លាយជាការពេញនិយមដូចសព្វថ្ងៃនេះ។ ពាក្យ IT គឺផ្តោតលើបច្ចេកវិទ្យាខ្លួនឯង និងរបៀបដែលវាជួយក្នុងការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ដូច្នេះទើបកាលនោះគេនិយមហៅកាត់ថា IT ព្រោះស្រួលហៅ និងស្រួលចាំ។

## ក.៦- បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)

គឺសំដៅដល់ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងព័ត៌មាន និងសម្រួលការប្រាស្រ័យទាក់ទង។ ICT រួមបញ្ចូលទាំងឧបករណ៍ដូចជាកុំព្យូទ័រ ស្មាតហ្វូន កម្មវិធី និងបណ្ដាញ ដូចជាអ៊ីនធឺណិត ដែលអនុញ្ញាតឱ្យដំណើរការទិន្នន័យ ផ្ទុក និងផ្លាស់ប្ដូរទិន្នន័យប្រកបដោយប្រសិទ្ធភាព។ ICT មានសារៈសំខាន់ក្នុងវិស័យផ្សេងៗ រួមទាំងការអប់រំ ការថែទាំសុខភាព អាជីវកម្ម ការទំនាក់ទំនងប្រចាំថ្ងៃ ការលើកកម្ពស់ ការតភ្ជាប់ និងផលិតភាព។ ពាក្យ ICT នេះអាចចាត់ទុកថាជាការវិវត្តបន្តពី IT ជាពិសេសនៅពេលវិស័យ IT បានរីកចម្រើន និងត្រូវបានគេយកទៅប្រើប្រាស់ស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់នៅសង្គមមនុស្ស។

## ក.៧- ពិភពនិម្មិត (Virtual World)

សំដៅលើបរិយាកាសប្រឌិតឡើងដោយប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រដែលអ្នកប្រើប្រាស់អាចធ្វើអន្តរកម្មជាមួយគ្នា និងជាមួយឧបករណ៍ឌីជីថលតាមរយៈរូបភាពប្រឌិត។ បរិយាកាសនិម្មិតទាំងនេះអាចធ្វើត្រាប់តាមការកំណត់របស់ពិភពពិត ឬបង្កើតពិភពប្រឌិតទាំងស្រុង ដែលជារឿយៗត្រូវបានប្រើសម្រាប់ហ្គេម អន្តរកម្មសង្គម ការអប់រំ និងការបណ្ដុះបណ្ដាល។ ពិភពនិម្មិតផ្ដល់នូវបទពិសោធន៍ដ៏អស្ចារ្យដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់រុករក បង្កើត និងទំនាក់ទំនងក្នុងពិភពឌីជីថល។

## ក.៨- អ៊ីនធឺណិត (Internet)

គឺជាបណ្ដាញដែលតភ្ជាប់គ្នាជាប្រព័ន្ធ (មានសណ្ឋានប្រទាក់គ្នាដូចជាក្រឡាសំណាញ់ ឬសំបុកសត្វពីងពាង) ដែលធ្វើឱ្យកុំព្យូទ័រ ឬឧបករណ៍បច្ចេកវិទ្យាព័ត៌មានទាំងអស់ អាចតភ្ជាប់គ្នា និងទំនាក់ទំនងគ្នាបានងាយស្រួលនៅទូទាំងពិភពលោកយើងនេះ។ អ៊ីនធឺណិត ត្រូវបានបង្កើតឡើងដោយមានផ្នែកជាច្រើនរួមបញ្ចូលគ្នាជាប្រព័ន្ធ ជាពិសេស ការតភ្ជាប់គ្នាពីគេហទំព័រមួយទៅគេហទំព័រមួយទៀតនៅជុំវិញពិភពលោក ដែលហៅថា (World Wide Web)។ វាមានលំនាំដូចសំបុកពីងពាងហ៊ុំព័ទ្ធពិភពលោក ធ្វើឱ្យគ្រប់ផ្នែក គ្រប់គេហទំព័រ នៅគ្រប់ទីកន្លែងទាំងអស់ អាចតភ្ជាប់ និងស្គាល់គ្នាបានតាមច្រកទ្វារបច្ចេកវិទ្យាព័ត៌មាន ដែលយើងគ្រប់គ្នានិយមហៅកាត់ខ្លី នៅលើអាសយដ្ឋានគេហទំព័រនីមួយៗថា w.w.w ។ អ្នកប្រហែលជាធ្លាប់ឃើញអាសយដ្ឋានគេហទំព័រទាំងឡាយ ត្រូវបានគេសរសេរឡើង នាំមុខនូវតួអក្សរកាត់ w.w.w ទាំងនេះ។ ឧទាហរណ៍ www.aplecambodia.org ព្រោះថាពាក្យគន្លឹះ ឬអក្សរកាត់នេះ ដែលអនុញ្ញាតឱ្យគេហទំព័រមួយនោះ អាចតភ្ជាប់ទៅគេហទំព័រទាំងឡាយនៅលើពិភពលោក។

ដូច្នេះ "w.w.w" តំណាងឱ្យ (World Wide Web)។ វាជាប្រព័ន្ធនៃគេហទំព័រមានទំនាក់ទំនងគ្នា ដែលអ្នកអាចចូលប្រើប្រាស់បានតាមរយៈអ៊ីនធឺណិត។ នៅពេលអ្នកវាយអាសយដ្ឋានគេហទំព័រ ជាធម្មតា អ្នកកំពុងចូលប្រើ World Wide Web។ រហូតមកដល់សម័យបច្ចុប្បន្នេះ អ្នកប្រហែលជាឧស្សាហ៍ឃើញអក្សរកាត់ "https://" នៅពីមុខគេហទំព័រវិញផងដែរ។ តាមការពិត "https://" គឺជាផ្នែកមួយនៃអាសយដ្ឋានគេហទំព័រ។ វាតំណាងឱ្យ "Hypertext Transfer Protocol Secure"។ វាមានន័យថា គេហទំព័រមានសុវត្ថិភាព ហើយព័ត៌មានរបស់អ្នកត្រូវបានបម្លែង (Encrypted) ហើយវាជាគេហទំព័រ "w.w.w" ដែលធ្វើឱ្យវាមានសុវត្ថិភាពក្នុងការប្រើប្រាស់។ ដូច្នេះ រយៈពេលក្រោយមកនេះអ្នកប្រហែលជាមិនសូវឃើញអាសយដ្ឋានគេហទំព័រដែលផ្តើមដោយអក្សរ "w.w.w" ទៀតទេ ប៉ុន្តែប្រហែលជាឧស្សាហ៍ឃើញទម្រង់អក្សរកាត់នេះវិញ។ ឧទាហរណ៍៖ https://aplecambodia.org/ ។ វាមិនមែនមានន័យថា គេហទំព័រ (World Wide Web) ត្រូវបានគេលុបចោលឈប់ប្រើនោះទេ តាមការពិត "w.w.w" នៅតែមានវត្តមានដដែល ប៉ុន្តែវាគ្រាន់តែត្រូវបានគេបម្លែង ឬប្តូរឱ្យមានសុវត្ថិភាពជាងមុនតែប៉ុណ្ណោះ។

បណ្តាញ ឬប្រព័ន្ធអ៊ីនធឺណិត អនុញ្ញាតឱ្យមនុស្សរាប់ពាន់លាននាក់តភ្ជាប់គ្នា ហើយអាចទំនាក់ទំនងគ្នា និងបញ្ជូនទិន្នន័យទៅវិញទៅមកនៅក្នុងពេលដំណាលគ្នា ឬក្នុងពេលតែមួយជាមួយគ្នា។ បណ្តាញ ឬប្រព័ន្ធអ៊ីនធឺណិត សំដៅដល់បណ្តុំនៃបណ្តាញកុំព្យូទ័រ ឬឧបករណ៍បណ្តាញ (Network Devices) ជាច្រើនតភ្ជាប់គ្នានៅលើពិភពលោក។ ជាទូទៅពាក្យ "អ៊ីនធឺណិត" អាចត្រូវបានគេនិយាយថាជាបណ្តាញទំនាក់ទំនងគ្នាទៅវិញទៅមក ហើយបណ្តាញទាំងនេះតភ្ជាប់ពីកុំព្យូទ័រមួយទៅកុំព្យូទ័រមួយ ឬច្រើន ដែលអាចផ្លាស់ប្តូរព័ត៌មានយ៉ាងឆាប់រហ័សរវាងអន្តរបណ្តាញនៅទូទាំងពិភពលោក។

កុំព្យូទ័រភ្ជាប់គ្នាទៅវិញទៅមក និងភ្ជាប់ទៅនឹងអ៊ីនធឺណិតតាមរយៈខ្សែរលកវិទ្យុ និងប្រភេទហេដ្ឋារចនាសម្ព័ន្ធបណ្តាញផ្សេងទៀត។ ទិន្នន័យទាំងអស់ដែលបានផ្ញើតាមអ៊ីនធឺណិត ត្រូវបានបម្លែងទៅជារលកនៃពន្លឺ ឬអគ្គិសនី ហៅថា ប៊ីត (Bit) ហើយបន្ទាប់មកបម្លែងដោយកុំព្យូទ័រដែលទទួល។ ខ្សែ និងរលកវិទ្យុ ដំណើរការប៊ីតទាំងនេះក្នុងល្បឿនពន្លឺ។ នៅពេលណាដែលប៊ីតកាន់តែច្រើនឆ្លងកាត់ខ្សែទាំងនេះក្នុងពេលតែមួយ អ៊ីនធឺណិតដំណើរការកាន់តែលឿន។

សរុបសេចក្តីមក អ៊ីនធឺណិត (Internet) គឺជាបណ្តាញប្រព័ន្ធតភ្ជាប់កុំព្យូទ័រជាសកលដែលតភ្ជាប់គ្នាទៅវិញទៅមក ដែលអនុញ្ញាតឱ្យមនុស្សចែករំលែកព័ត៌មាន និងធ្វើការទំនាក់ទំនង។ វាប្រៀបដូចជាបណ្ណាល័យដ៏ធំមួយដែលអ្នកអាចស្វែងរកព័ត៌មានស្ទើរតែគ្រប់ប្រធានបទ។ អាស្រ័យដោយការអភិវឌ្ឍប្រព័ន្ធអ៊ីនធឺណិតទើបធ្វើឱ្យបច្ចេកវិទ្យាព័ត៌មានរីកចម្រើនលឿនទៅមុខ បង្កើតបាននូវទម្រង់បច្ចេកវិទ្យាព័ត៌មានថ្មីៗជាច្រើនទៀតផងដែរ។ សព្វថ្ងៃនេះ អ៊ីនធឺណិត (Internet) បានក្លាយជាតម្រូវការចាំបាច់របស់មនុស្សយើង ដូចជាទឹក ភ្លើង និងផ្លូវថ្នល់ធ្វើចរាចរ ជាដើម។

### ក.៩- អនឡាញ (Online)

សំដៅដល់ការភ្ជាប់ឧបករណ៍ឌីជីថលទៅនឹងបណ្ដាញអ៊ីនធឺណិតដែល ដែលអនុញ្ញាតឱ្យឧបករណ៍ទាំងនោះចូលប្រើប្រាស់កម្មវិធី ឬធនធាននៅលើអនឡាញបាន។ នៅពេលអ្នកស្ថិតលើ អនឡាញ មានន័យថាអ្នកបានភ្ជាប់ឧបករណ៍ឌីជីថលរបស់អ្នកទៅនឹងអ៊ីនធឺណិត ដើម្បីធ្វើអ្វីមួយនៅលើអនឡាញ។

"អនឡាញ" មានន័យថាត្រូវបានភ្ជាប់ទៅអ៊ីនធឺណិត។ នៅពេលអ្នកប្រើប្រាស់អ៊ីនធឺណិត អ្នកអាចចូលប្រើគេហទំព័រ ផ្ញើអ៊ីម៉ែល ប្រើវេទិកាអនឡាញ (ថ្នាលកម្មវិធី) ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ្វីៗជាច្រើនទៀត ដែលអនុញ្ញាតឱ្យអ្នកតភ្ជាប់ ភ្ជាប់ទំនាក់ទំនង ធ្វើអន្តរកម្មឆ្លើយឆ្លងភ្លាមៗ ឆ្លើយតបផ្ទាល់ទៅភាគីម្ខាងទៀតដែលកំពុងប្រាស្រ័យទាក់ទងនៅទីកន្លែងផ្សេង ឬជ្រុងម្ខាងទៀតនៃពិភពលោកបានភ្លាមៗយ៉ាងងាយស្រួល។ ប្រព័ន្ធអនឡាញអនុញ្ញាតឱ្យមនុស្សទំនាក់ទំនងគ្នា ស្ថិតនៅលើខ្សែតភ្ជាប់គ្នាក្នុងពេលតែមួយជាមួយគ្នា អាចនិយាយគ្នា ស្ដាប់ឮដោយផ្ទាល់ អាចមើលគ្នាឃើញតាមរយៈវីដេអូដោយផ្ទាល់ភ្លាមៗជាមួយគ្នា ទោះជាកំពុងស្ថិតនៅទីកន្លែង និងពេលវេលាខុសគ្នាក៏ដោយ។ ប្រព័ន្ធអនឡាញ អាចប្រៀបប្រដូចទៅអ្វីដែលយើងដោតភ្ជាប់ឧបករណ៍អេឡិចត្រូនិករបស់យើងទៅក្នុងបណ្ដាញដ៏ធំមួយ (អ៊ីនធឺណិត) ដែលអនុញ្ញាតឱ្យអ្នកទំនាក់ទំនង និងស្វែងរកព័ត៌មានពីគ្រប់ទីកន្លែងក្នុងពិភពលោក។

## ❷ ដំណើរការ ការប្រើប្រាស់ បង្កើត និងចែកចាយព័ត៌មានតាមអ៊ីនធឺណិត

### ខ.១- បណ្ដាញគេហទំព័រ ( World Wide Web)

ដូចបានជ្រាបខ្លះៗរួចមកហើយនៅក្នុងសេចក្ដីពន្យល់ក្នុងពាក្យគន្លឹះស្ដីពីអ៊ីនធឺណិតកាលពីវគ្គមុន គេហទំព័រ (W.W.W) មកពីពាក្យពេញ (World Wide Web)។ វាជាការតភ្ជាប់គ្នាពីគេហទំព័រមួយទៅគេហទំព័រមួយទៀតនៅជុំវិញពិភពលោក ដែលពាក្យពេញគេហៅថា (World Wide Web)។

បណ្ដាញគេហទំព័រជុំវិញពិភពលោក ( World Wide Web) អនុញ្ញាតឱ្យមនុស្សគ្រប់គ្នា បោះពុម្ពផ្សព្វផ្សាយ បង្កើតព័ត៌មាន ទិន្នន័យជាអត្ថបទ រូបភាព (ក្រាហ្វិក) សំឡេង វីដេអូ ឯកសារ និងកម្មវិធីក្នុងទម្រង់ជាឌីជីថល។ ពួកគេអាចធ្វើការផ្ញើ ចែកចាយ ទាញយកទៅប្រើប្រាស់ រក្សាទុក ចែកចាយបន្តផលិតឡើងវិញ ជាបន្តបន្ទាប់ដោយឥតដែនកំណត់។

គេហទំព័រគឺបានក្លាយទៅជាវិធីសាស្ត្រដ៏ពេញនិយមបំផុតក្នុងការបង្កើត និងការចែករំលែកព័ត៌មាននៅលើពិភពអ៊ីនធឺណិត ព្រោះមានតម្លៃថោកជាងបណ្ដាញព័ត៌មានបែបប្រពៃណី ដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្ដី ការបោះពុម្ពផ្សេងៗ។ ការអភិវឌ្ឍគេហទំព័រក៏កើនឡើងលឿន ដែលទាក់ទាញ

មនុស្សប្រើប្រាស់ និងមានគេហទំព័រកាន់តែច្រើនសម្បូណ៌បែបតាមប្រព័ន្ធអ៊ីនធឺណិត។ អ្នកផលិតគេហទំព័រមិនចាំបាច់ត្រូវការធនធាន ឬដើមទុនច្រើនដូចប្រព័ន្ធព័ត៌មានពីបុរាណឡើយ ដោយពួកគេអាចបង្កើត និងបង្ហោះផ្សព្វផ្សាយបានភ្លាមដោយគ្រាន់តែត្រូវការសេវាអ៊ីនធឺណិត ផ្តល់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (Internet Service Provider "ISP")។ អ្នកបង្កើតគេហទំព័រអាចផ្តល់នូវសេវាកម្មផ្សព្វផ្សាយពាណិជ្ជកម្មតាមអនឡាញ បានផងដែរ។

### ខ.២- អ្នកផ្តល់សេវាអ៊ីនធឺណិត (Internet Service Provider "ISP")

អ្នកផ្តល់សេវាអ៊ីនធឺណិត (Internet Service Provider) គឺជាក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតដែលផ្តល់ការចូលប្រើអ៊ីនធឺណិតដល់អតិថិជន។ ពួកគេភ្ជាប់សេវាតាមផ្ទះ និងអាជីវកម្មទៅអ៊ីនធឺណិតដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់រុករកគេហទំព័រ ផ្ញើអ៊ីម៉ែល និងមើលវីដេអូអនឡាញ។ ឧទាហរណ៍ក្រុមហ៊ុន ISP នៅលើពិភពលោករួមមាន AT&T, Comcast និង Verizon ។

ក្រុមហ៊ុន ISPs ទាំងនេះផ្តល់នូវកញ្ចប់អ៊ីនធឺណិតជាច្រើនដែលតម្រូវតាមតម្រូវការផ្សេងៗគ្នា ចាប់ពីការប្រើប្រាស់តាមផ្ទះជាមូលដ្ឋានរហូតដល់ការតភ្ជាប់អាជីវកម្មដែលមានល្បឿនលឿន។ ក្រុមហ៊ុន ISPs ផ្តល់នូវប្រភេទតភ្ជាប់អ៊ីនធឺណិតផ្សេងគ្នា រួមមានដូចជា៖

- **ឌីអេសអិល (DSL)៖** ប្រើខ្សែទូរស័ព្ទ។
- **ខ្សែកាប (Cable)៖** ប្រើខ្សែទូរទស្សន៍។
- **ហ្វៃប៊ឺ (Fiber-Optic)៖** ប្រើសញ្ញាពន្លឺសម្រាប់អ៊ីនធឺណិតល្បឿនលឿន។
- **ផ្កាយរណប (Satellites)៖** ប្រើផ្កាយរណបសម្រាប់តំបន់ដាច់ស្រយាល។

#### ខ.២.១- DSL ឬ Digital Subscriber Line

គឺជាប្រភេទនៃការតភ្ជាប់អ៊ីនធឺណិតដែលប្រើខ្សែទូរស័ព្ទស្តង់ដារ ដើម្បីផ្តល់ការចូលប្រើអ៊ីនធឺណិតល្បឿនលឿន។ មិនដូចការភ្ជាប់តាមលេខធម្មតាទេ DSL អនុញ្ញាតឱ្យអ្នកប្រើប្រាស់ប្រើអ៊ីនធឺណិត និងធ្វើការហៅទូរស័ព្ទក្នុងពេលដំណាលគ្នា ព្រោះវាដំណើរការលើប្រេកង់ផ្សេងៗគ្នាជាងការហៅជាសំឡេង។

#### ខ.២.២- ISDN (Integrated Services Digital Network)

គឺជាសំណុំនៃស្តង់ដារទំនាក់ទំនងសម្រាប់ការបញ្ជូនសំឡេង វីដេអូ ទិន្នន័យ និងសេវាកម្មបណ្តាញផ្សេងទៀតតាមបណ្តាញទូរស័ព្ទប្រពៃណី។ វាត្រូវបានណែនាំនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដើម្បីផ្តល់នូវការបញ្ជូនឌីជីថលលើខ្សែទូរស័ព្ទស្ពាន់ដែលមានស្រាប់ ដែលអនុញ្ញាតឱ្យមានគុណភាពខ្ពស់ជាង និងការបញ្ជូនទិន្នន័យលឿនជាងបើប្រៀបធៀបទៅនឹងប្រព័ន្ធអាណាឡូកប្រពៃណី។

ក្រុមហ៊ុន ISPs ផ្តល់ការចូលប្រើដោយផ្ទាល់ពីផ្ទះ ឬការិយាល័យរបស់អ្នកទៅកាន់អ៊ីនធឺណិតតាមរយៈទូរស័ព្ទស្មាតហ្វូន កុំព្យូទ័រ បណ្តាញឌីជីថលរួមបញ្ចូលគ្នា (ISDN) ខ្សែអតិថិជនឌីជីថល (DSL) ឬការតភ្ជាប់អ៊ីនធឺណិតពិសេស។ ISPs ភាគច្រើនផ្តល់នូវកម្មវិធីពេញនិយម រួមទាំងកម្មវិធីរុករកតាមអ៊ីនធឺណិត និងកម្មវិធីអ៊ីម៉ែល។ ទោះយ៉ាងណាក៏ដោយ ជាមួយនឹង ISPs អ្នកមានសេរីភាពក្នុងការប្រើប្រាស់កញ្ចប់កម្មវិធីអ៊ីនធឺណិតផ្សេងទៀតដែលមាន។

## ខ.៣- អាសយដ្ឋានអ៊ីនធឺណិត (Internet Protocol)

Internet Protocol ឬ IP សំដៅដល់អាសយដ្ឋានតែមួយគត់ដែលកំណត់ឧបករណ៍ (Device) នៅលើអ៊ីនធឺណិត ឬបណ្តាញខាងក្នុង (Local Network)។ IP ជាសំណុំនៃច្បាប់គ្រប់គ្រងទ្រង់ទ្រាយទិន្នន័យដែលបានផ្ញើតាមអ៊ីនធឺណិត ឬបណ្តាញខាងក្នុង។

សរុបមក IP គឺជាឧបករណ៍កំណត់អត្តសញ្ញាណដែលអនុញ្ញាតឱ្យបញ្ជូនព័ត៌មានរវាងឧបករណ៍នៅលើបណ្តាញ។ ពួកវាផ្ទុកព័ត៌មានទីតាំង និងធ្វើឱ្យឧបករណ៍អាចស្គាល់គ្នា និងចូលប្រើបាន។ អ៊ីនធឺណិតត្រូវការវិធីមួយដើម្បីប្រាប់ពីភាពខុសគ្នារវាងកុំព្យូទ័រ រ៉ោតទ័រ និងគេហទំព័រផ្សេងៗគ្នា។ IP ផ្តល់នូវវិធីធ្វើដូច្នេះ និងបង្កើតជាផ្នែកសំខាន់នៃរបៀបដែលអ៊ីនធឺណិតដំណើរការ។

IP មានសណ្ឋានជាលេខដែលបំបែកដោយសញ្ញាចុច ហើយ IP Address ត្រូវបានបង្ហាញជាសំណុំនៃចំនួនបួនប្លុក ឬបៃតឺ (Byte) នៃសំណុំលេខ IP។ ឧទាហរណ៍មួយអាចជា 192.158.1.38 ។ លេខនីមួយៗក្នុងសំណុំអាចមានចាប់ពី 0 ដល់ 255។ ដូច្នេះគម្លាត IP ទាំងមូល មានចាប់ពី 0.0.0.0 ដល់ 255.255.255.255 ។

អាសយដ្ឋាន IP មិនចៃដន្យទេ ពួកវាត្រូវបានបង្កើតតាមគណិតវិទ្យា និងបែងចែកដោយអាជ្ញាធរលេខដែលបានចាត់តាំងតាមអ៊ីនធឺណិត (Internet Assigned Numbers Authority "IANA") ដែលជាផ្នែកនៃសាជីវកម្មអ៊ីនធឺណិតសម្រាប់ឈ្មោះ និងលេខដែលបានកំណត់ (Internet Corporation for Assigned Names and Numbers "ICANN")។ ICANN គឺជាអង្គការមិនរកប្រាក់ចំណេញមួយដែលត្រូវបានបង្កើតឡើងនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៨ ដើម្បីជួយរក្សាសុវត្ថិភាពអ៊ីនធឺណិត និងអនុញ្ញាតឱ្យវាប្រើប្រាស់បានគ្រប់គ្នា។ រាល់ពេលដែលនរណាម្នាក់ចុះឈ្មោះដែននៅលើអ៊ីនធឺណិត ពួកគេឆ្លងកាត់អ្នកចុះបញ្ជីឈ្មោះដែន ដែលបង់ថ្លៃតិចតួចដល់ ICANN ដើម្បីចុះឈ្មោះដែន។

## ខ.៤- ហ្វៃអឺវ៉ល (Firewall )

ហ្វៃអឺវ៉ល (Firewall ជញ្ជាំងភ្លើង) គឺជាប្រព័ន្ធសុវត្ថិភាពដែលជួយការពារកុំព្យូទ័រ ឬបណ្តាញរបស់អ្នកពីការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត និងការគំរាមកំហែង ។

### ខ.៨.១- ជារបាំងការពារ

- ជញ្ជាំងភ្លើង (Firewall) ដើរតួនាទីដូចជារនាំងការពារកុំព្យូទ័រ ឬបណ្តាញអ៊ីនធឺណិត របស់អ្នក និងរារាំងចរាចរណ៍ទាំងឡាយណានៅលើអ៊ីនធឺណិតមិនឱ្យចូលមក ឬឆ្លងកាត់។ អ្នកអាចការពារ និងអនុញ្ញាតឱ្យការធ្វើចរាចរណ៍ណាដែលល្អ ឬទិន្នន័យសុវត្ថិភាពឆ្លងកាត់ ឬចូលមកក្នុងកុំព្យូទ័រ និងឧបករណ៍ឌីជីថលរបស់អ្នក។

### ខ.៨.២- ត្រួតពិនិត្យ (Monitor) និងច្រោះចម្រាញ់ (Fiters)

- វាត្រួតពិនិត្យទិន្នន័យ ដែលធ្វើចរាចរណ៍ចេញចូលលើប្រព័ន្ធអ៊ីនធឺណិត និងឧបករណ៍ឌីជីថលរបស់អ្នក ដោយច្រោះចម្រាញ់ចេញ ឬដកហូតចេញ ឬ រារាំងចរាចរណ៍នូវមាតិកាព័ត៌មានទិន្នន័យទាំងឡាយណាដែលបង្កគ្រោះថ្នាក់ ឬគួរឱ្យសង្ស័យចេញ ហើយអនុញ្ញាតឱ្យទិន្នន័យសុវត្ថិភាពចូល ឬចាកចេញពីប្រព័ន្ធដំណើរការ និងឧបករណ៍របស់អ្នក។
- ហ្វៃអឺវល (Firewall ជញ្ជាំងភ្លើង) គឺរួមបញ្ចូលទាំងឧបករណ៍ផ្នែករឹង (Hardware) និងផ្នែកទន់(Software) ដែលតភ្ជាប់នៅក្នុងប្រព័ន្ធបណ្តាញរបស់អ្នក (Local Area Network "LAN") ដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ ថេប្លេត (Tablet) អាយផេត (iPad) ទូរស័ព្ទដៃឆ្លាតវៃ (Smart Phone) និងរាល់ឧបករណ៍ឌីជីថល (Digital Devices) ទាំងអស់ ដែលតភ្ជាប់ប្រើប្រាស់អ៊ីនធឺណិត ក្នុងគោលបំណងការពារសុវត្ថិភាព។ អ្នកប្រើប្រាស់ ឬធ្វើចរាចរណ៍នៅលើអ៊ីនធឺណិត ដែលចូលប្រើបណ្តាញពីខាងក្រៅ មិនអាចធ្វើចូលទៅក្នុងប្រព័ន្ធបណ្តាញរបស់អ្នក (Local Area Network "LAN") បានទេ ព្រោះត្រូវរបង ឬជញ្ជាំងរបាំងការពារ (Firewall ជញ្ជាំងភ្លើង) ហាមឃាត់ ឬរារាំង។



**ឧទាហរណ៍៖** ហ្វៃអឺវល (Firewall ជញ្ជាំងភ្លើង) ប្រៀបដូចឆ្មាំសន្តិសុខ ដែលឈរចាំយាមតាមសន្តិសុខនៅច្រកចូលអគារ។ ឆ្មាំត្រួតពិនិត្យអ្នកគ្រប់គ្នាដែលចង់ចូល ដោយអនុញ្ញាតឱ្យតែមនុស្សដែលគួរឱ្យទុកចិត្តចូល និងការពារការគំរាមកំហែងដែលអាចកើតមាន។




### ខ.៤.៣- ប្រភេទនៃអឺវ៉ល (Firewall ជញ្ជាំងភ្លើង)

- **ហ្វៃអឺវលលើផ្នែករឹង (Hardware Firewall)៖** គឺជាឧបករណ៍រូបវន្តដែលភ្ជាប់រវាងបណ្តាញរបស់អ្នក និងអ៊ីនធឺណិត។
- **ហ្វៃអឺវលលើផ្នែកទន់ (Software Firewall)៖** ជាកម្មវិធី (Software) ដែលបានដំឡើងនៅលើកុំព្យូទ័ររបស់អ្នក ដែលការពារវាពីការគំរាមកំហែង។

### ខ.៤.៤. សារៈសំខាន់នៃការតំឡើង Firewarll

- **ការពារទិន្នន័យ៖** ជញ្ជាំងភ្លើងជួយរក្សាព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានរសើបរបស់អ្នកឱ្យមានសុវត្ថិភាពពីពួក Hacker និងមេរោគ។
- **ការពារការវាយប្រហារ៖** វារារាំងការវាយប្រហារដែលបង្កគ្រោះថ្នាក់ទៅដល់កុំព្យូទ័រ ឬបណ្តាញរបស់អ្នក។

### ខ.៥- ហ្វ្រីណិត Freenet

Freenet គឺជាសេវាកម្ម ឬកម្មវិធី ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការចូលប្រើសម្រាប់សហគមន៍។ គោលការណ៍នៅពីក្រោយ Freenet គឺស្រដៀងទៅនឹងបណ្ណាល័យសាធារណៈ ដែលអនុញ្ញាតឱ្យមនុស្សគ្រប់គ្នាចូលចែករំលែក ឬប្រើប្រាស់ព័ត៌មាន។

### ខ.៨.១- តើ Freenet ជាអ្វី?

Freenet គឺជាកម្មវិធីកុំព្យូទ័រមានលក្ខណៈបែបវិមជ្ឈការ (ផ្តល់នូវមុខងារ និងសិទ្ធិអំណាច) ទៅដល់បណ្តាកុំព្យូទ័រដែលតភ្ជាប់នៅលើបណ្តាញដូចគ្នា មានលក្ខណៈឯករាជ្យ មិនស្ថិតនៅក្រោមការត្រួតត្រា ឬគ្រប់គ្រងរបស់ម៉ាស៊ីនមេណាមួយឡើយ។ វាត្រូវបានគេបង្កើតឡើង និងបំពាក់នៅលើកុំព្យូទ័រដែលមានការតភ្ជាប់ទៅនឹងកុំព្យូទ័រមួយទៀតដែលមានសិទ្ធិប៉ុនគ្នាប្រហាក់ប្រហែលគ្នា ប្រៀបដូចមិត្តភក្តិភ្ជាប់ទំនាក់ទំនងគ្នាផងដែរ ដែលគេហៅថា Peer-to-Peer (P2P) ប៉ុន្តែអាចរក្សាឯកជនភាពផ្ទាល់ខ្លួនបាន ដូចជាការប្រើ Virtual Private Neteowrk (VPN) ដែលអាចភ្ជាប់គ្នា និងធ្វើការទំនាក់ទំនង និងចែករំលែកទិន្នន័យ ដោយមិនបញ្ចេញ អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។ វាអនុញ្ញាតឱ្យអ្នកប្រើប្រាស់ អាចគេចចេញផុតពីការត្រួតពិនិត្យតាមដានផ្សេងៗ។




- **បណ្តាញដែលមានលក្ខណៈបែបវិមជ្ឈការ (Decentralized Network)៖** Freenet ដំណើរការដោយគ្មានម៉ាស៊ីនមេ ឬទីស្នាក់ការកណ្តាល ដែលអាចគ្រប់គ្រង លើការប្រើបណ្តាញនៃកុំព្យូទ័រដែលមានទំនាក់ទំនងគ្នា (តំណ) ដើម្បីចែករំលែក និងរក្សាទុកទិន្នន័យបាននោះទេ។

- **លក្ខណៈបែបអនាមិក (Anonymous)៖** វាធានាភាពឯកជនរបស់អ្នកប្រើប្រាស់ ដោយរក្សាអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ដោយលាក់ទុក និងធ្វើឱ្យពិបាកក្នុងការតាមដានសកម្មភាពរបស់ពួកគេ។

- **ការផ្ទុកទិន្នន័យ (Data Storage)៖** ទិន្នន័យត្រូវបានបែងចែក និងចែកចាយនៅទូទាំងផ្នែកជាច្រើន ដែលធ្វើឱ្យវាពិបាកក្នុងការតាមដាន ឬលុបព័ត៌មានជាក់លាក់។

ឧទាហរណ៍៖

- **ការចែករំលែកអនាមិក (Anonymous Sharing)៖** ប្រសិនបើអ្នកចង់ចែករំលែកឯកសារដោយមិនបង្ហាញអត្តសញ្ញាណរបស់អ្នក ឬគ្មានហានិភ័យពីការត្រួតពិនិត្យ អ្នកអាចប្រើ Freenet។ ទិន្នន័យរបស់អ្នកនឹងត្រូវបានបំបែកជាបំណែកៗ ហើយរក្សាទុកនៅលើកុំព្យូទ័រផ្សេងៗក្នុងបណ្តាញ ហើយការពារភាពអនាមិករបស់អ្នក និងធានាថាឯកសារនៅតែអាចចូលប្រើប្រាស់បានដោយសុវត្ថិភាព។




### ខ.៥.២- សារ:សំខាន់

- **ការពារភាពឯកជន (Protect Privacy)៖** Freenet ផ្តល់មធ្យោបាយទំនាក់ទំនង និងចែករំលែកព័ត៌មានដោយមិនបង្ហាញអត្តសញ្ញាណផ្ទាល់ខ្លួន។
- **ធានានូវសេរីភាពនៃព័ត៌មាន៖** វាអនុញ្ញាតឱ្យព័ត៌មានត្រូវបានចែករំលែកដោយសេរី និងសុវត្ថិភាព ដោយមិនបារម្ភពីការត្រួតពិនិត្យតាមដាន ឬរារាំងនោះឡើយ។

### ខ.៦- កម្មវិធីប្រព័ន្ធប្រតិបត្តិការ (Operation System "OS")

- **កម្មវិធីប្រព័ន្ធប្រតិបត្តិការ (OS)៖** គឺជាកម្មវិធីដែលគ្រប់គ្រងធនធានផ្នែករឹងកុំព្យូទ័រ (Hardware) និងផ្នែកទន់ (Software) ព្រមទាំងផ្តល់សេវាកម្មសម្រាប់កម្មវិធីកុំព្យូទ័រ។
- **ការគ្រប់គ្រងប្រព័ន្ធ៖** ប្រព័ន្ធប្រតិបត្តិការគ្រប់គ្រងធនធានរបស់កុំព្យូទ័រ រួមទាំងអង្គចងចាំ (Memory) កន្លែងផ្ទុក (Hardi disk) អង្គដំណើរការ (CPU) និងគ្រឿងកុំព្យូទ័រ (ដូចជាម៉ាស៊ីនបោះពុម្ព "Printer" និងម៉ូនីទ័រ "Monitor")។

- **ផ្តល់មុខងារអ្នកប្រើប្រាស់៖** OS បានផ្តល់មុខងារដែលមានភាពងាយស្រួលដល់អ្នកប្រើប្រាស់ទូទៅ ដែលមិនមែនជាអ្នកផលិតកម្មវិធី ឬអ្នកសរសេរកូដកម្មវិធីអាចប្រើប្រាស់កុំព្យូទ័របាន។ OS បានផ្តល់នូវងាយស្រួលប្រើដែលអ្នកប្រើប្រាស់អាចធ្វើអន្តរកម្មជាមួយកុំព្យូទ័រ និងកម្មវិធីជាច្រើនមាននៅលើកុំព្យូទ័រ។

- **ការគ្រប់គ្រងកិច្ចការ៖** ប្រព័ន្ធប្រតិបត្តិការសម្របសម្រួលកិច្ចការ និងដំណើរការនានា នៅលើតួម៉ាស៊ីនផ្នែករឹង (Hardware) ដោយធានាថា ពួកវាដំណើរការដោយរលូនដោយមិនមានការរំខានដល់គ្នាទៅវិញទៅមក។ ប្រសិនបើគ្មាន OS ទេ គ្រប់អង្គផ្នែករឹង (Hardware) និងផ្នែកទន់ (Software) មិនអាចដំណើរជាមួយគ្នា ឬស្គាល់គ្នាបានទេ។ កម្មវិធី OS ផ្តល់នូវផ្ទាំងបញ្ជាសម្រាប់អ្នកប្រើប្រាស់ (Graphical User Interface) ឬផ្តល់នូវផ្ទាំងត្រួតបញ្ជាដោយសរសេរបញ្ជា (Command-line interface) ដើម្បីចូលទៅគ្រប់គ្រង ឬប្រើប្រាស់កម្មវិធីទាំងឡាយដែលដំណើរការនៅលើតួម៉ាស៊ីនកុំព្យូទ័រ និងឧបករណ៍ឌីជីថលទាំងអស់។

### ខ.៦.១-ប្រភេទនៃប្រព័ន្ធប្រតិបត្តិការ

- **ប្រព័ន្ធប្រតិបត្តិការលើកុំព្យូទ័រលើតុ (Desktop ឬ Personal Computer "PC")៖** ដូចជា Microsoft Windows, macOS (សម្រាប់កុំព្យូទ័រ Apple) និងការចែកចាយ Linux ដូចជា Ubuntu ។

- **ប្រព័ន្ធប្រតិបត្តិការនៅលើឧបករណ៍ឌីជីថលចល័ត (Mobile Devices)៖** ឧទាហរណ៍រួមមាន Android (Google), iOS (Apple) និង HarmonyOS (Huawei)។

- **ប្រព័ន្ធប្រតិបត្តិការរបស់ម៉ាស៊ីនមេ៖** ដូចជា Windows Server ការចែកចាយម៉ាស៊ីនមេ Linux (ឧ. CentOS, Ubuntu Server) ។

**ឧទាហរណ៍៖**

- **ប្រព័ន្ធប្រតិបត្តិការលើកុំព្យូទ័រលើតុ៖** នៅពេលអ្នកបើកកុំព្យូទ័ររបស់អ្នក ប្រព័ន្ធប្រតិបត្តិការនឹងដំណើរការ ហើយអ្នកអាចចាប់ផ្តើមប្រើប្រាស់កម្មវិធីដូចជា កម្មវិធីរុករកតាមអ៊ីនធឺណិត កម្មវិធីវាយអត្ថបទ និងហ្គេម។

- **ប្រព័ន្ធប្រតិបត្តិការនៅលើឧបករណ៍ឌីជីថលចល័ត៖** នៅលើស្មាតហ្វូន ប្រព័ន្ធប្រតិបត្តិការគ្រប់គ្រងកម្មវិធី ការតភ្ជាប់ និងមុខងារដូចជាកាមេរ៉ា និង GPS ជាដើម។

### ខ.៦.១- សារៈសំខាន់

- ការគ្រប់គ្រងធនធាន៖ ប្រព័ន្ធប្រតិបត្តិការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងធានស្ថិរភាព។
- បទពិសោធន៍អ្នកប្រើប្រាស់៖ OS បានផ្តល់នូវវេទិកាសម្រាប់ដំណើរការកម្មវិធី និងធ្វើអន្តរកម្មជាមួយផ្នែករឹងក្នុងលក្ខណៈងាយស្រួលប្រើ។
- សុវត្ថិភាព៖ ប្រព័ន្ធប្រតិបត្តិការជាច្រើនរួមមានមុខងារសុវត្ថិភាពដើម្បីការពារប្រឆាំងនឹងមេរោគ និងការចូលប្រើដោយគ្មានការអនុញ្ញាត។

សរុបមក ប្រព័ន្ធប្រតិបត្តិការ (OS) គឺជាកម្មវិធីសំខាន់ដែលគ្រប់គ្រងផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ ដោយបានផ្តល់ជាវេទិកា (Plateform) សម្រាប់ដំណើរការកម្មវិធី ធានាការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យអន្តរកម្មអ្នកប្រើប្រាស់ជាមួយកុំព្យូទ័រ ឬឧបករណ៍ផ្សេងៗទៀត។

### ខ.៧- កម្មវិធី (Application Software)

កម្មវិធី (Application) គឺជាប្រភេទនៃផ្នែកទន់ (Software) ដែលអាចដំឡើង និងដំណើរការលើកុំព្យូទ័រ ថេប្លេត ស្មាតហ្វូន ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀត។ Application Software ជាញឹកញាប់សំដៅលើកម្មវិធីដែលប្រើប្រាស់ឧបករណ៍ចល័ត ឬផ្នែកនៃ Software ដែលត្រូវបានដំឡើង និងប្រើប្រាស់នៅលើកុំព្យូទ័រ។ កម្មវិធី ត្រូវបានបង្កើតឡើងក្នុងគោលបំណងឱ្យអ្នកប្រើប្រាស់ទូទៅងាយស្រួលប្រើប្រាស់ដើម្បីបម្រើការងារប្រចាំថ្ងៃ។

ឧទាហរណ៍កម្មវិធីរួមមាន Miscrosoft Office Application ដែលមានកម្មវិធីប្រើប្រាស់ដើម្បីបំពេញកិច្ចការងារការិយាល័យ ដូចជា កម្មវិធី Miscrosoft Word ឬ Ms. Word កម្មវិធី Miscrosoft Excel ឬ Ms. Excel កម្មវិធី Ms. PowerPoint។ កម្មវិធីជាច្រើននៅលើវិស័យការងារខុសៗគ្នា ដូចជាកម្មវិធី Adobe Photoshop សម្រាប់កាត់តរូបភាព កម្មវិធី Adobe Premier សម្រាប់កាត់តរូបភាពវីដេអូ កម្មវិធី 3D-Design សម្រាប់រចនារូបភាព និងធ្វើប្លង់អាគារជាដើម។ល។

Applications ភាគច្រើនបង្កើតឡើងសម្រាប់ប្រើប្រាស់ ឬដំណើរការសម្រាប់តែកុំព្យូទ័រ ពីព្រោះ Applications មានទំហំធំនៃការដំឡើងធំ ឬធ្ងន់ ត្រូវការនូវកុំព្យូទ័រ ឬឧបករណ៍ឌីជីថលដែលមានថាសរឹង (Hard disk) ធំ អង្គចងចាំ (Memory) និងប្រព័ន្ធ (Central Proessing Unit "CPU") ដំណើរការខ្ពស់ និងល្បឿនលឿន។

បច្ចុប្បន្ននេះ Application Software បានវិវត្តឈានឡើងមួយកម្រិតទៀត ដែលអាចដំណើរការទាំងនៅលើកុំព្យូទ័រផង និងនៅលើគេហទំព័រ (Website) ផងដែរ។ កម្មវិធី (Application Software) ខ្លះ អាចមានលទ្ធភាពដំណើរការស្មើគ្នាទាំងនៅកុំព្យូទ័រ និងគេហទំព័រអនឡាញដំណាលគ្នា (Synchronize) ឬស្គាល់គ្នាទៅវិញមកផងដែរ។ លើសពីនេះទៀត ពួកគេក៏អាចដំណើរការបានទាំងនៅលើទូរសព្ទដៃ ឬឧបករណ៍ឌីជីថលចល័តផងដែរ ដែលគេហៅថា កម្មវិធីសម្រាប់គេហទំព័រ (Web Application)។

### ខ.៨- កម្មវិធី (Apps)

កម្មវិធី (App) គឺជាទម្រង់អក្សរកាត់ ឬហៅខ្លីចេញមកពីពាក្យកម្មវិធី (Application)។ កម្មវិធី App អាចនិយាយបានថាការវិវត្តន៍ដែលគេពេញនិយមនៅក្នុងយុគសម័យឧបករណ៍ឌីជីថលចល័ត (Mobile Digital Devices) ដូចជា ថេប្លេត (Tablet) ស្មាតហ្វូន (Smart Phone) នាឡិកាដៃអេឡិចត្រូនិក (IWatch) ឬឧបករណ៍អេឡិចត្រូនិកផ្សេងទៀត។ កម្មវិធី App ជាទូទៅដំណើរការល្អនៅលើតែឧបករណ៍ឌីជីថលចល័ត ប៉ុន្តែមិនសូវដំណើរការនៅលើកុំព្យូទ័រនោះទេ។ ជាទូទៅ គេនិយមហៅ App ថាជាកម្មវិធីទូរស័ព្ទដៃព្រោះភាគច្រើនត្រូវបានដំណើរការនៅលើទូរស័ព្ទដៃ។

កម្មវិធី App ដំណើរការស្រដៀងគ្នា ឬដូចគ្នាជាមួយនឹងកម្មវិធី (Application Software ) ដែលតែងតែតភ្ជាប់ទៅនឹងកម្មវិធីនៅលើប្រព័ន្ធអ៊ីនធឺណិត ឬភ្ជាប់ដំណើរការនៅលើ (Web Application) ដែរ។ កម្មវិធី (App) ខ្លះ អាចមានលទ្ធភាពដំណើរការស្មើគ្នាទាំងនៅលើប្រព័ន្ធប្រតិបត្តិការកុំព្យូទ័រ និងគេហទំព័រអនឡាញដំណាលគ្នា (Synchronize) ឬស្គាល់គ្នាទៅវិញទៅមកផងដែរ។

កម្មវិធី App ភាគច្រើនមានមុខងារជាក់លាក់ សាមញ្ញៗ ដើម្បីភាពងាយស្រួលប្រើនៅលើទូរស័ព្ទដៃសម្រាប់អ្នកប្រើប្រាស់ទូទៅ។ ឧទាហរណ៍ កម្មវិធី App ដឹកជញ្ជូនអាហារ ដូចជា Food Panda ឬ Nham24 ជាដើម។

### ខ.៩- គេហទំព័រ (Website)

គេហទំព័រគឺជាបណ្តុំទំព័រអេឡិចត្រូនិកដែលបង្ហោះនៅលើអ៊ីនធឺណិត ដែលទំព័រនីមួយៗមានអត្ថបទ រូបភាព វីដេអូ និង ព័ត៌មានផ្សេងទៀត។ អ្នកប្រើប្រាស់អាចចូលទៅប្រើតាមរយៈឈ្មោះតែមួយគត់ (ឧ. https://aplecambodia.org/)។ គេហទំព័របម្រើគោលបំណងចម្រុះដូចជាការចែករំលែកព័ត៌មានពាណិជ្ជកម្មអេឡិចត្រូនិក ការកម្សាន្ត ជាដើម។ វាអនុញ្ញាតឱ្យអាជីវកម្ម ស្ថាប័ន និងបុគ្គលនានាផ្សព្វផ្សាយទៅដល់ទស្សនិកជនទូទាំងពិភពលោក និងជួយសម្រួលដល់ការទំនាក់ទំនង ពាណិជ្ជកម្ម និងការអប់រំ។

### ខ.៩.១- តើគេហទំព័រខុសពីកម្មវិធី Application Software Program និងកម្មវិធី App ដូចម្តេចខ្លះ?

គេហទំព័រខុសពីកម្មវិធី Application Software និងកម្មវិធី App ផ្សេងទៀត ក្នុងការចែកចាយ និងការប្រើប្រាស់របស់វា។ មិនដូចកម្មវិធី Application Software ធម្មតាដែលបានដំឡើងនៅលើឧបករណ៍ទេ គេហទំព័រត្រូវបានចូលប្រើតាមរយៈកម្មវិធីរុករកតាមអ៊ីនធឺណិត ហើយទាមទារការតភ្ជាប់អ៊ីនធឺណិត។ ពួកគេផ្តល់នូវខ្លឹមសារច្រើនទូលំទូលាយ (Dynamic content) ដែលអាចត្រូវបានធ្វើបច្ចុប្បន្នភាពជាញឹកញាប់ និងអន្តរកម្ម ដែលធ្វើឱ្យពួកវាមានភាពចម្រុះសម្រាប់គោលបំណងផ្សេងៗ ដូចជាការទាញយកព័ត៌មានភ្លាមៗ (ឧ. គេហទំព័រព័ត៌មាន) ឧបករណ៍សហការ (ឧ. វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម) និងការទិញទំនិញតាមអ៊ីនធឺណិត។ គេហទំព័រក៏បើកដំណើរការអន្តរកម្មរបស់អ្នកប្រើដោយគ្មានថ្នាលលើឧបករណ៍ និងប្រព័ន្ធប្រតិបត្តិការផ្សេងៗ ដោយមិនចាំបាច់ដំឡើង បង្កើនភាពងាយស្រួល និងលទ្ធភាពប្រើប្រាស់សម្រាប់ទស្សនិកជនទូលំទូលាយ។

### ខ.៩.២- តើគេហទំព័រ កម្មវិធី និង App ទូទៅដំណើរការដូចម្តេច នៅលើ Internet?

ធម្មតា ការបង្ហោះ ឬការចែកចាយព័ត៌មាននៅលើអ៊ីនធឺណិត ឬការធ្វើចរាចរណ៍ទិន្នន័យលើអ៊ីនធឺណិត អាចដំណើការបានទៅល្អ និងមានភាពធន់ អាស្រ័យលើទីតាំងដែលគេហទំព័រស្ថិតនៅលើម៉ាស៊ីនមេ ដែលគេហៅថា Server។ កុំព្យូទ័រម៉ាស៊ីនមេគឺជាទីតាំងដែលផ្សាយព័ត៌មាន ឆ្លើយតប និងផ្តល់ព័ត៌មានទៅកអ្នកប្រើប្រាស់ ឬអ្នកដែលចូលមើលព័ត៌មានគ្រប់ពេលវេលាតាមរយៈតំណនៅលើអ៊ីនធឺណិត និងអាសយដ្ឋានរបស់គេហទំព័រ។ ល្បឿននៃការធ្វើចរាចរណ៍ព័ត៌មាន ទិន្នន័យ ការឆ្លើយតបទៅអ្នកប្រើប្រាស់វិញ អាស្រ័យលើល្បឿននៃអ៊ីនធឺណិតរបស់ម៉ាស៊ីនមេស្ថិតនៅ ទីតាំងចម្ងាយឆ្ងាយ ឬជិត និងព័ត៌មានទិន្នន័យដែលផ្ទុកនៅលើម៉ាស៊ីនមេនោះផងដែរ។ ដូច្នេះ ប្រសិនបើម៉ាស៊ីនមេ ដែលជាទីតាំងមជ្ឈមណ្ឌលផ្ទុក និងប្រមូលទាញទិន្នន័យមានបញ្ហា ដំណើរការល្បឿនអ៊ីនធឺណិតធ្លាក់ចុះ ដូច្នេះគ្រប់ផ្នែកទាំងអស់ទាក់ទងនឹងគេហទំព័រមួយនោះ ក៏មានសភាពធ្លាក់ចុះយឺតទៅតាមនោះផងដែរ ឬដំណើរការយឺត។ គេហទំព័រធំៗដែលមានផ្ទុកទិន្នន័យច្រើន ចរាចរណ៍ទិន្នន័យផ្ទាល់ ដំណើរការប្រតិបត្តិការអាជីវកម្ម ឬការងារផ្ទាល់នៅលើគេហទំព័រ ត្រូវការនូវម៉ាស៊ីនមេដែលមានទំហំធំ កម្លាំង ល្បឿន និងសមត្ថភាពខ្ពស់។ គេហទំព័រធំៗ ដែលប្រតិបត្តិការអាជីវកម្មផ្ទាល់ រមែងត្រូវការនូវម៉ាស៊ីនមេជាច្រើនដែលដំឡើងនៅទីតាំងផ្សេងៗគ្នានៃពិភពលោក ដើម្បីបង្កភាពងាយស្រួលក្នុងការធ្វើចរាចរណ៍ទិន្នន័យ និងហេតុផលសន្តិសុខផងដែរ។ ឧទាហរណ៍ប្រសិនបើម៉ាស៊ីនមេណាមួយត្រូវបានជាប់គាំង ឬធ្លាក់ចុះ ឬខូចខាត គេហទំព័រនោះនៅតែអាចដំណើរការប្រតិបត្តិការបានដដែល ដោយសារវាត្រូវបានផ្លាស់ប្តូរ និងដំណើរការជំនួសដោយម៉ាស៊ីនមេនៅទីតាំងផ្សេងទៀតភ្លាមតែម្តង។

### ខ.១០- អំពីគេហទំព័ររុករកនៅលើអ៊ីនធឺណិត (Internet Browser)

កម្មវិធីរុករកតាមអ៊ីនធឺណិត គឺជាកម្មវិធីដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចូលប្រើ ស្វែងរកព័ត៌មាន ទាញយកទិន្នន័យ បញ្ជូនទិន្នន័យ និងមើលព័ត៌មាននៅលើអ៊ីនធឺណិត។

គេហទំព័ររុករកនៅលើអ៊ីនធឺណិតដែលកំពុងពេញនិយមសព្វថ្ងៃនេះមានដូចរូបខាងក្រោមនេះ៖




តាមរយៈបណ្តាគេហទំព័ររុករកនៅលើអ៊ីនធឺណិត យើងអាចចូលទៅស្វែងរកគេហទំព័រណាមួយដែលស្គាល់អាស័យដ្ឋានបានដោយងាយស្រួល ដោយគ្រាន់តែវាយឈ្មោះអាសយដ្ឋានគេហទំព័រទាំងនោះនៅលើគេហទំព័ររុករកនៅលើអ៊ីនធឺណិតផ្ទាល់តែម្តង។

#### ខ.១០. ១- ការចូលប្រើគេហទំព័ររុករកនៅលើអ៊ីនធឺណិត

វាអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចូលទៅកាន់គេហទំព័រដោយបញ្ចូលអាសយដ្ឋានគេហទំព័រ (URLs) និងរុករក (Search) តាមគេហទំព័រ។

**ឧទាហរណ៍:** https://aplecambodia.org/en/

- **បង្ហាញមាតិកា៖** កម្មវិធីរុករកតាមអ៊ីនធឺណិតបង្ហាញអត្ថបទ រូបភាព វីដេអូ និងមាតិកា ពហុព័ត៌មានផ្សេងទៀតពីគេហទំព័រ ដោយផ្តល់នូវចំណុចប្រទាក់គ្នាសម្រាប់អន្តរកម្ម។
- **ឧបករណ៍រុករក៖** កម្មវិធីរុករកផ្តល់ឧបករណ៍សម្រាប់រុករកគេហទំព័រ ដូចជាប៊ូតុង (Backward Botton) ថយក្រោយ និងបញ្ជូនបន្ត (Forward Botton) ធ្វើឱ្យងាយស្រួលចំណាំ និងផ្ទាំងសម្រាប់បើកទំព័រច្រើនក្នុងពេលតែមួយ (Tabs) ធ្វើឱ្យការរុករកអ៊ីនធឺណិតកាន់តែងាយស្រួល។

#### ខ.១០.២- សារៈសំខាន់នៃការប្រើគេហទំព័ររុករកនៅលើអ៊ីនធឺណិត

- **ការចូលប្រើព័ត៌មាន៖** កម្មវិធីរុករកគឺចាំបាច់សម្រាប់ការចូលប្រើព័ត៌មានចំនួនដ៏ច្រើនដែលមាននៅលើអ៊ីនធឺណិត។

- **អន្តរកម្ម៖** ពួកគេអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើអន្តរកម្មជាមួយកម្មវិធីគេហទំព័រ បំពេញទម្រង់បែបបទ មើលវីដេអូ ការស្វែងរកព័ត៌មាន និងលេងហ្គេម។
- **ផលិតភាព៖** កម្មវិធីរុករកតាមអ៊ីនធឺណិតគាំទ្រផ្នែកបន្ថែម (Extensions) និងកម្មវិធីជំនួយផ្សេងៗដែលបង្កើនមុខងារ កែលម្អផលិតភាព និងបទពិសោធន៍អ្នកប្រើប្រាស់។

### ខ.១០.៣- ឧទាហរណ៍នៃការប្រើគេហទំព័ររុករកនៅលើអ៊ីនធឺណិត

- **កម្មវិធី Google Chrome៖** ត្រូវបានបង្កើតឡើងដោយ Google ហើយរចនាឡើងដើម្បីឱ្យមានល្បឿនលឿន មានសុវត្ថិភាព និងភាពសាមញ្ញរបស់ Chrome ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅលើឧបករណ៍ផ្សេងៗ។




ព័ត៌មានអំពីកម្មវិធី Google Chrome អ្នកអាចចូលទៅរកមើលតំណនេះ https://www.google.com/chrome/browser-tools/

- **កម្មវិធី Safari៖** កម្មវិធីរុករកតាមអ៊ីនធឺណិតលំនាំដើមសម្រាប់ឧបករណ៍ Apple (macOS, iOS, iPadOS)។ ត្រូវបានគេស្គាល់ថាសម្រាប់ល្បឿន ប្រសិទ្ធភាព និងផ្តោតលើភាពឯកជន វាជាជម្រើសដ៏ពេញនិយមក្នុងចំណោមអ្នកប្រើប្រាស់ Apple។




ព័ត៌មានអំពីកម្មវិធី Safari អ្នកអាចូលទៅរកមើលតំណនេះ https://www.apple.com/safari/

- **កម្មវិធី Microsoft Edge៖** កម្មវិធីរុករកតាមអ៊ីនធឺណិតទំនើបពី Microsoft ដែលជំនួស Internet Explorer ដោយផ្តល់នូវការរួមបញ្ចូលគ្នាជាមួយ Windows 10 និង 11។




ព័ត៌មានអំពីកម្មវិធី Microsoft Edge អ្នកអាចចូលទៅរកមើលតំណនេះ https://apps.microsoft.com/detail/xpfftq037jwmhs?hl=en-US&gl=US

- **កម្មវិធី Opera៖** មានមុខងារទប់ស្កាត់ការផ្សាយពាណិជ្ជកម្មដែលភ្ជាប់មកជាមួយ និង VPN សម្រាប់ការពង្រឹងភាពឯកជន និងសុវត្ថិភាព។

ព័ត៌មានអំពីកម្មវិធី Opera អ្នកអាចចូលទៅរកមើលតំណនេះ https://www.opera.com/

- **កម្មវិធី Mozilla Firefox៖** សង្កត់ធ្ងន់លើភាពឯកជនខ្លាំងរបស់អ្នកប្រើប្រាស់ និងការផ្លាស់ប្តូរតាមបំណង។ វាត្រូវបានបង្កើតឡើងដោយ Mozilla Foundation ដែលជាអង្គការមិនរកប្រាក់ចំណេញ។

ព័ត៌មានអំពីកម្មវិធី Mozilla Firefox អ្នកអាចចូលទៅរកមើលតំណនេះ https://www.mozilla.org/en-US/firefox/new/

| ១- OCSEA នៅកម្ពុជា គឺកម្រកើតមានណាស់ ហើយវាមិនមានផលប៉ះពាល់ដល់កុមារ និងយុវជនច្រើនទេ។ | ខុស (ទស្សនៈមិនត្រឹមត្រូវទេ)៖<br><br>ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាបង្ហាញថា កុមារដែលប្រើអ៊ីនធឺណិតមាន ១១% ដែលមានអាយុពីចន្លោះពី ១២-១៧ ឆ្នាំ ត្រូវបានជួបប្រទះនូវការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមអនឡាញនៅក្នុងឆ្នាំមុន។ បើគិតជាចំនួនប្រជាជន មានន័យថា មានកុមារ ១៦០.០០០នាក់ អាចនឹងរងផលប៉ះពាល់។<br><br>**ការពិតមួយចំនួនអំពីបទពិសោធន៍របស់កុមារ៖**<br><br>● នេះរាប់បញ្ចូលទាំងកុមារដែលត្រូវបាន Blackmailed (គម្រាមកំហែងផ្លូវភេទ) ក្នុងការចូលរួមក្នុងសកម្មភាពផ្លូវភេទ។<br><br>● កុមារដែលមានរូបភាពផ្លូវភេទរបស់ពួកគេ ត្រូវបានចែករំលែកដោយគ្មានការអនុញ្ញាតពីពួកគេ។<br><br>● ឬកុមារដែលត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទតាមរយៈការសន្យាឱ្យប្រាក់ ឬឱ្យជាអំណោយ។<br><br>● លើសពីនេះ ៩% នៃកុមារដែលប្រើអ៊ីនធឺណិតក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា ពួកគេបានចែករំលែករូបភាព ឬវីដេអូអាក្រាតដោយខ្លួនឯងតាមអនឡាញ។<br><br>● នៅក្នុងគំរូស្ទង់មតិតាមគ្រួសារ កុមារចំនួន ១៦១ នាក់ (១៦%) ត្រូវបានផ្ញើរូបភាពផ្លូវភេទដែលមិនចង់បានក្នុងឆ្នាំកន្លងទៅ។ |

| | |
|---|---|
| **២- ចន្លោះឆ្នាំ២០១៧ និង២០១៩ចំនួនរបាយការណ៍** ដែលសង្ស័យថា OCSEA បានរាយការណ៍ទៅមជ្ឈមណ្ឌលជាតិសម្រាប់ការបាត់ខ្លួន និងកុមារដែលត្រូវបានកេងប្រវ័ញ្ច (ដែលគេស្គាល់ថា CyberTips ) ទាក់ទងនឹងប្រទេសកម្ពុជាបានកើនឡើង៥០% ។ | **ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖**<br>តួលេខជាក់ស្តែង គឺកើនឡើង ២៦១% ចន្លោះឆ្នាំ ២០១៧ និង ២០១៩ នេះបង្ហាញថាវាជាបញ្ហាធ្ងន់ធ្ងរមួយ។ |
| **៣- ជនល្មើស ឬជនសង្ស័យ** នៃ OCSEA ភាគច្រើនជាជនមិនស្គាល់អត្តសញ្ញាណរបស់ជនរងគ្រោះ ហើយជាជនបរទេសដែលមិនមែនជាជនជាតិខ្មែរ។ | **ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖**<br>**យោងតាមការស្រាវជ្រាវ៖**<br>● ជនល្មើស OCSEA ភាគច្រើន គឺជាមនុស្សដែលស្គាល់កុមារ។<br>● ជារឿយៗបុគ្គលទាំងនេះគឺជាសមាជិកគ្រួសារ មិត្តភក្តិពេញវ័យ មិត្តភក្តិ ឬដៃគូស្នេហា។<br>● មនុស្សដែលមិនធ្លាប់ស្គាល់កុមារ ត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលទាក់ទងនឹង OCSEA ប្រហែល ២៥%។ |
| **៤- វាមិនងាយស្រួលទេសម្រាប់**កុមារក្នុងការលាតត្រដាងនៅពេលដែល (OCSEA) កើតឡើង។ | **ត្រូវ( ទស្សនៈគឺត្រឹមត្រូវ )៖**<br>● ជនរងគ្រោះតែងតែមានអារម្មណ៍អាម៉ាស់ ជួបប្រទះនឹងការស្តីបន្ទោសពីភាពរងគ្រោះ ឬបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។<br>● ជនល្មើសជាច្រើន គឺជាមនុស្សដែលកុមារស្គាល់ រួមទាំងគ្រួសារផងដែរ។ កត្តានេះ គឺជាឧបសគ្គចំពោះការរាយការណ៍។<br>● ជនរងគ្រោះអាចមានអារម្មណ៍ខ្មាស់អៀនក្នុងការនិយាយអំពីបញ្ហាផ្លូវភេទ។ ការប្រាប់នរណាម្នាក់អំពីរឿងនេះគឺពិបាកណាស់។<br>● ដូច្នេះ មន្ត្រីនគរបាលត្រូវមានជំនាញច្រើន មានចិត្តសណ្តោសមេត្តា និងការយល់ចិត្ត និងប្រព្រឹត្តចំពោះកុមារ និងអាណាព្យាបាល ដោយយកចិត្តទុកដាក់ និងដោយការគោរពនៅពេលសម្ភាសពួកគេ។ |

| | |
|---|---|
| ៥- នៅកម្ពុជា OCSEA ភាគច្រើនប៉ះពាល់ដល់ក្មេងស្រី និងយុវនារី។ | ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖<br>● នៅកម្ពុជាជនរងគ្រោះមានទាំងក្មេងប្រុស និងក្មេងស្រី។<br>● តាមរយៈការស្ទង់មតិតាមគ្រួសារ ក្នុងចំណោមក្មេងអាយុ ១២-១៧ឆ្នាំ ដែលប្រើអ៊ីនធឺណិត ក្មេងប្រុសត្រូវបានគេរាយការណ៍ច្រើនជាងក្មេងស្រីថាបានរងគ្រោះ ទទួលរងនូវ OCSEA គ្រប់ទម្រង់ដែលបានស៊ើបអង្កេត។ |
| ៦-ក្មេងប្រុសងាយស្រួលក្នុងការរាយការណ៍ជាងក្មេងស្រី ព្រោះពួកគេមានអារម្មណ៍មិនសូវខ្មាស់អៀន និងមិនចាំបាច់ខ្វល់ខ្វាយពីកេរ្តិ៍ឈ្មោះដូចក្មេងស្រីនោះទេ។ | ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖<br>● ក្មេងប្រុសប្រាប់យើងថា ពួកគេក៏មានភាពអាម៉ាស់ខ្លាំងផងដែរ ហើយថែមទាំងមានការប៉ះទង្គិច ដោយការកេងប្រវ័ញ្ច និង រំលោភបំពានផ្លូវភេទផងដែរ ទាំងក្រៅប្រព័ន្ធអនឡាញ និងលើប្រព័ន្ធអនឡាញ។<br>● ជាញឹកញយ ស្ថានភាពរបស់ពួកគេកាន់តែអាក្រក់ទៅៗ ដោយមានអ្នកគិតថា ការរំលោភបំពានលើក្មេងប្រុសមិនសូវធ្ងន់ធ្ងរ។<br>● មិនថាជនរងគ្រោះមានអត្តសញ្ញាណបែបណានោះទេ យើងត្រូវតែយកចិត្តទុកដាក់លើស្ថានភាពរបស់ពួកគេជានិច្ច។ |
| ៧- ផលប៉ះពាល់នៃ OCSEA អាចធ្ងន់ធ្ងរ - ប៉ុន្តែមិនធ្ងន់ធ្ងរដូច CSEA ដូច្នេះវាងាយស្រួលក្នុងការរាយការណ៍ និងសង្គ្រោះ។ | ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖<br>● ជនរងគ្រោះតែងតែបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។<br>● នេះអាចកាន់តែអាក្រក់ទៅៗដោយការភ័យខ្លាចនៃការលាតត្រដាង (រូបភាពផ្លូវភេទអាចត្រូវបានចែករំលែក និងបន្តនៅលើអ៊ីនធឺណិតរយៈពេលយូរ)។<br>● ការភ័យខ្លាចនេះអាចមានរយៈពេលយូរ។<br>● ផលប៉ះពាល់ជាច្រើនគឺដូចគ្នាទៅនឹងផលប៉ះពាល់ដែលកើតចេញពីការរំលោភបំពានលើបុគ្គលដែរ។<br>● OCSEA ជាច្រើនក៏ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានក្រៅប្រព័ន្ធអនឡាញ។<br>● នេះក៏អាចរាប់បញ្ចូលទាំងការធ្លាក់ទឹកចិត្ត ការធ្វើបាបខ្លួនឯង ការថប់បារម្ភ រោគសញ្ញាដែលទាក់ទងនឹងជំងឺស្ត្រេស ក្រោយការប៉ះទង្គិចផ្លូវចិត្ត និងការពិបាកក្នុងការជឿជាក់លើអ្នកដទៃ។ |

| | |
|---|---|
| ៨- នៅពេលដែល OCSEA កើតឡើង យុវជន និងកុមារ តែងតែដឹងអំពីរបៀប និងកន្លែង ដែលត្រូវរាយការណ៍ ហើយជាធម្មតាទាក់ទងទៅកាន់អាជ្ញាធរពាក់ព័ន្ធ ឬអង្គការមិនមែនរដ្ឋាភិបាល។ នេះមិនមែនជាការលំបាកសម្រាប់ពួកគេនោះទេ។ | ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖<br>● វាមិនងាយស្រួលទេ ក្នុងការរាយការណ៍អំពីទម្រង់នៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទទៅកាន់នរណាម្នាក់នោះទេ។<br>● មានឧបសគ្គជាច្រើនក្នុងការរាយការណ៍ រួមទាំងកង្វះចំណេះដឹងអំពីរបៀបរាយការណ៍ និងរាយការណ៍ពីណាទៅណា កង្វះទំនុកចិត្ត និងមិនដឹងថាអ្នកណាមានសុវត្ថិភាពក្នុងការប្រាប់ ឬរាយការណ៍។<br>● ក្នុងចំណោមកុមារដែលជួបប្រទះ OCSEA មានត្រឹមតែ ២.៥% បានទាក់ទងទៅបុគ្គលិកសង្គមកិច្ច ៣% បានទាក់ទងទៅបណ្តាញជំនួយ និង ២.៩% បានទាក់ទងមន្ត្រីនគរបាល។<br>● កុមារដែលជួបប្រទះឧក្រិដ្ឋកម្ម OCSEA ប្រសិនបើពួកគេជ្រើសរើសលាតត្រដាង ពួកគេទំនងជាប្រាប់មនុស្សនៅក្នុងបណ្តាញទំនាក់ទំនងបុគ្គលរបស់ពួកគេជាពិសេស មិត្តភក្តិ (៤០%) បងប្អូនបង្កើត (២៤%) និងម្នាក់ក្នុងចំណោមប្រាំនាក់ (២៥%) ដែលប្រាប់អាណាព្យាបាល។<br>● ទាក់ទងនឹងការពិត គឺថាប្រហែលមួយក្នុងចំណោមបីនាក់ (៣៤%) កុមារដែលបានជួបប្រទះ OCSEA មិនបានប្រាប់អ្នកណាម្នាក់ទាល់តែសោះ ហើយមិនមានភាពខុសគ្នាតាមអាយុ ឬរវាងក្មេងប្រុស និងក្មេងស្រីនោះទេ។ |
| ៩- នៅពេលដែលកុមារចូលប្រើប្រព័ន្ធអនឡាញ ហើយយល់ព្រមទាក់ទង ឬបង្កើតមិត្តភក្តិជាមួយនរណាម្នាក់ដែលប្រព្រឹត្ត OCSEA នៅពេលក្រោយ - កុមារនោះគួរតែទទួលខុសត្រូវខ្លះ ហើយស្តីបន្ទោសចំពោះអ្វីដែលបានកើតឡើង។ តាមរបៀបខ្លះយើងអាចនិយាយបានថាពួកគេ «ឱ្យដៃ»។ | ខុស( ទស្សនៈមិនត្រឹមត្រូវទេ )៖<br>● កុមារមិនមានជម្រើសទេ ក្រៅពីការចូលប្រើប្រព័ន្ធអនឡាញ។<br>● ប្រសិនបើមានអ្វីខុស កុមារជាច្រើនក៏ជឿលើគំនិតនេះ ហើយបន្ទោសខ្លួនឯងផងដែរ។<br>● ជនល្មើសក៏មានជំនាញខ្ពស់ក្នុងការលួងលោមជនរងគ្រោះ និងធ្វើឱ្យពួកគេមានអារម្មណ៍ថា ត្រូវទទួលការស្តីបន្ទោសនោះ។<br>● វាមិនមែនជាកំហុសរបស់កុមារទេ នៅពេលដែលពួកគេត្រូវបានគេកេងប្រវ័ញ្ច ឬរំលោភបំពានក្នុង ឬក្រៅប្រព័ន្ធអនឡាញនោះ។<br>● យើងត្រូវប្រាស្រ័យទាក់ទងយ៉ាងច្បាស់ជាមួយកុមារថា ពួកគេមិនត្រូវបន្ទោសខ្លួនឯងឡើយ។ |

| | |
|---|---|
| ១០- មនុស្សពេញវ័យ និងកុមារភាគច្រើនមិនមានការយល់ដឹងច្រើន OCSEA ទេ ហើយកត្តានេះធ្វើឱ្យពួកគេងាយចាញ់ការបោកបញ្ឆោតក្នុងការការកេងប្រវ័ញ្ច និងរំលោភបំពាន។ | ពិត (ទស្សនៈពិតជាត្រឹមត្រូវ)៖<br>● ល្បឿននៃការអភិវឌ្ឍបច្ចេកវិទ្យា និងពិភពឌីជីថលមានល្បឿនលឿន។<br>● ប៉ុន្តែការយល់ដឹងអំពីគ្រោះថ្នាក់ និងហានិភ័យនៃពិភពឌីជីថលនៅមានកម្រិតនៅឡើយ។<br>● មនុស្សជាច្រើនមិនដឹងអំពីគ្រោះថ្នាក់រហូតដល់មានរឿងអាក្រក់កើតឡើង។<br>● ជនល្មើសក៏ពូកែកសាងទំនុកចិត្ត និងបោកបញ្ឆោតមនុស្សផងដែរ<br>● ដូច្នេះនៅពេលដែលមានរឿងអាក្រក់កើតឡើង ជនរងគ្រោះតែងតែតក់ស្លុត ភ័យខ្លាច និងប៉ះទង្គិច ហើយបន្ទោសខ្លួនឯង។<br>● ដូច្នេះនៅពេលដែលពួកគេរាយការណ៍ វានឹងជួយពួកគេ ប្រសិនបើអ្នកអាចផ្តល់ព័ត៌មានត្រឹមត្រូវអំពី OCSEA ថាតើវាកើតឡើងយ៉ាងដូចម្តេច ហើយពន្យល់ថាពួកគេមិនត្រូវបន្ទោសខ្លួនឯងនោះទេ។ |
| ១១- ការបៀតបៀនផ្លូវភេទលើប្រព័ន្ធអនឡាញ គឺកម្រកើតមានណាស់ ព្រោះវាជារឿងដែលកើតឡើងក្រៅប្រព័ន្ធអនឡាញ (Offline) ច្រើនជាង ហើយវាមិនធ្ងន់ធ្ងរនោះទេ។ | ខុស (ទស្សនៈមិនត្រឹមត្រូវទេ)៖<br>**យោងតាមការស្ទង់មតិតាមគ្រួសារនៅកម្ពុជា៖**<br>● ស្ទើរតែ ១៦% នៃកុមារដែលប្រើអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជាបានជួបប្រទះការបៀតបៀន។<br>● នេះរាប់បញ្ចូលទាំងការចំអន់លេងសើច ប្រវត្តិកុមារ ឬកត់សម្គាល់អំពីរាងកាយ រូបរាង ឬសកម្មភាពផ្លូវភេទរបស់កុមារ។<br>● ក្មេងប្រុស និងក្មេងស្រីគឺជាកម្មវត្ថុ នៃការបញ្ចេញមតិយោបល់។<br>● កុមារតូចៗដែលមានអាយុពី ១២-១៥ ឆ្នាំ (១៧%) ជួបប្រទះការបៀតបៀន បើធៀបនឹង ១៣% នៃក្មេងអាយុពី១៦-១៧ឆ្នាំ។<br>● កុមារភាគច្រើនបានទទួលផលអវិជ្ជមាន ហើយជាទូទៅមានអារម្មណ៍អាម៉ាស់ ធុញថប់ ឬខឹងនឹងការប្រព្រឹត្តនេះ។ |
| ១២- រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ជាធម្មតាប៉ះពាល់ដល់កុមារវ័យជំទង់ | ខុស (ទស្សនៈមិនត្រឹមត្រូវទេ)៖<br>● ទិន្នន័យ Hotline ប្រាប់យើងថា សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (CSAM) កំពុងប៉ះពាល់ដល់កុមារគ្រប់វ័យ។ CSAM ពាក់ព័ន្ធនឹងកុមារទើបចេះដើរតេះតះ មាន ២៣% នៃរបាយការណ៍ទាំងអស់ក្នុងរយៈពេលបីឆ្នាំ។<br>● ភាគច្រើននៃរបាយការណ៍ទាំងនេះទាក់ទងនឹងក្មេងប្រុស (៨៨%) បន្ទាប់មក មានទាំងសម្ភារៈដែលពាក់ព័ន្ធនឹងក្មេងប្រុស និងក្មេងស្រី (៦%) និងសម្រាប់តែក្មេងស្រី (៦%)។ |

| | |
|---|---|
| ១៣- ពេលកុមារទៅជួបមន្ត្រីនគរបាលដើម្បីសម្ភាសន៍ វាមិនសំខាន់ទេ ប្រសិនបើមន្ត្រីសម្ភាសន៍ជាបុរស ឬស្ត្រីនោះ។ | ខុស (ទស្សនៈមិនត្រឹមត្រូវទេ)៖<br>**ការស្រាវជ្រាវ និងបទពិសោធន៍ប្រាប់យើងថា៖**<br>• កុមារជាច្រើនអាចមានការភ័យខ្លាចនៅពេលទំនាក់ទំនងជាមួយមន្ត្រីនគរបាល។<br>• ការនិយាយអំពីរឿងផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានគឺពិបាកណាស់សម្រាប់កុមារទាំងអស់។<br>• កុមារចូលចិត្តមានជម្រើសនៃភេទរបស់មន្ត្រី នៅពេលពួកគេត្រូវបានគេសម្ភាសន៍។<br>• ការផ្តល់ជម្រើសឱ្យពួកគេ ធ្វើឱ្យពួកគេមានអារម្មណ៍ថាមានសុវត្ថិភាពជាងមុន ហើយនឹងជួយឱ្យពួកគេមានទំនុកចិត្តកាន់តែច្រើនក្នុងការនិយាយ និងធ្វើសេចក្តីថ្លែងការណ៍។<br>• គោលការណ៍ជាមូលដ្ឋានមួយនៃការអនុវត្តកុមារមេត្រី គឺដើម្បីធានានូវដំណើរការ និងបរិយាកាសសុវត្ថិភាពសម្រាប់ការសម្ភាសហើយការផ្តល់ជម្រើសអាចជួយសម្រេចបាន។<br>• ក្នុងនាមជាមន្ត្រីនគរបាល អ្នកគួរតែធ្វើអ្វីគ្រប់យ៉ាងដែលអ្នកអាចធ្វើបាន ដើម្បីផ្តល់ជម្រើស។ |
| ១៤- ប្រសិនបើកុមារ ឬយុវវ័យជួបប្រទះរឿងអាក្រក់នៅលើប្រព័ន្ធអនឡាញ ពួកគេត្រូវទទួលខុសត្រូវ ព្រោះពួកគេជាផ្នែកមួយដែលត្រូវស្តីបន្ទោសចំពោះអ្វីដែលបានកើតឡើង។ | ខុស (ទស្សនៈមិនត្រឹមត្រូវទេ)៖<br>• កុមារ និងយុវវ័យមិនមានជម្រើសអ្វីក្រៅពីរស់នៅជាផ្នែកមួយនៃជីវិតរបស់ពួកគេលើប្រព័ន្ធអនឡាញ។<br>• នៅពេលដែលពួកគេជួបប្រទះការកេងប្រវ័ញ្ច និងរំលោភបំពានគ្រប់ប្រភេទ ពួកគេមិនគួរត្រូវបានស្តីបន្ទោសឡើយ។<br>• ជនរងគ្រោះមិនទទួលខុសត្រូវចំពោះអ្វីដែលកើតឡើងនោះទេ។ នោះគឺជាការទទួលខុសត្រូវរបស់ជនល្មើសតែប៉ុណ្ណោះ។<br>យើងមិនគួរប្រាប់ជនរងគ្រោះថាពួកគេត្រូវបន្ទោសខ្លួនឯងទេ។ |

នៅក្នុងមេរៀននេះ អ្នកបានរៀនអំពី OCSEA ជាទូទៅ នៅលើពិភពលោក និងកម្ពុជា។ អ្នកបានសិក្សាអំពីពាក្យពេចន៍គន្លឹះសំខាន់ៗ យល់ដឹងអំពីមូលហេតុ ឥរិយាបថ ការប្រព្រឹត្ត ឬសកម្មភាព ដែលនាំឱ្យប្រឈម ឬរងគ្រោះដោយ OCSEA។ លើសពីនេះ អ្នកបានយល់ដឹងថា នរណាខ្លះ ដែលអាចក្លាយជាជនរងគ្រោះ និងអ្នកណាជាជនល្មើស។ នៅក្នុងមេរៀន អ្នកបានរៀនសូត្រពីរបកគំហើញថ្មីៗតាមរយៈការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា យើង ដែលបង្ហាញថា កុមារដែលមានអាយុពីចន្លោះពី ១២ឆ្នាំ ដល់ ១៧ឆ្នាំ ប្រមាណជា ១៦០,០០០នាក់ (១១%) បានជួបប្រទះនូវ OCSEA និងរងផលប៉ះពាល់នៅក្នុងឆ្នាំមុន។ ជនរងគ្រោះមានទាំងក្មេងប្រុស និងក្មេងស្រី។ ពួកគេមានការពិបាករាយការណ៍។ ពួកមានឧបសគ្គជាច្រើនក្នុងការរាយការណ៍ រួមទាំងកង្វះចំណេះដឹងអំពីរបៀបរាយការណ៍ និងរាយការណ៍ពីណាទៅណា កង្វះទំនុកចិត្ត និងមិនដឹងថាអ្នកណាមានសុវត្ថិភាពក្នុងការប្រាប់ ឬរាយការណ៍នោះទេ។ លើសពីនេះទៀត យើងបានជជែកពិភាក្សាគ្នាអំពីទស្សនៈ ឬជំនឿមួយចំនួនពាក់ព័ន្ធនឹង OCSEA។ មនុស្សភាគច្រើនមានទស្សនៈ ឬជំនឿខុស ឬយល់ច្រឡំករណី OCSEA ។



មេរៀនទី៣៖

# ចរិតលក្ខណៈ និងផលប៉ះពាល់នៃការកេងប្រវញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

កាលពីមេរៀនវគ្គមុនអ្នកបានយល់ដឹងរួចមកហើយអំពីរបៀបនៃការយល់ដឹង របកគំហើញថ្មីៗនៃការសិក្សាស្រាវជ្រាវ និងអំពីទស្សនៈយល់ច្រឡំទាក់ទងនឹង OCSEA ក្នុងប្រទេសកម្ពុជា។ ដោយឡែកនៅក្នុងមេរៀននេះ អ្នកនឹងសិក្សាបន្ថែមទៀតអំពីនិយមន័យពិស្តារអំពីទម្រង់នីមួយៗនៃ OCSEA ស្វែងយល់អំពីឥរិយាបថ ការប្រព្រឹត្ត និងសកម្មភាពដែលអាចឱ្យអ្នករៀនសម្គាល់ពីប្រភេទ ឬទម្រង់ខុសៗគ្នា។ នៅពេលអ្នកយល់ដឹងនូវចំណុចទាំងអស់នេះ វានឹងក្លាយទៅជាគុណវុឌ្ឍដ៏សំខាន់សម្រាប់មន្ត្រីនគរបាល និងមន្ត្រីជំនាញផ្តល់សេវា ក្នុងការជួយផ្តល់បទអន្តរាគមន៍ ធ្វើការស៊ើបអង្កេត និងគាំទ្រដល់កុមាររងគ្រោះ និងកុមារដែលងាយរងផលប៉ះពាល់ដោយ OCSEA។ ការយល់ដឹងអំពីនិយមន័យនៃការរំលោភបំពានផ្លូវភេទលើកុមារ ការកេងប្រវញ្ចផ្លូវភេទកុមារ ដោយផ្ទាល់ ដោយប្រយោល ទាំងនៅក្នុងប្រព័ន្ធអនឡាញ និងក្រៅអនឡាញ ជាពិសេស អំពីរបៀបនៃទំនាក់ទំនងអន្តរកម្មគ្នាទៅវិញទៅមក គឺសមត្ថភាពដែលមន្ត្រីនគរបាល និងអ្នកផ្តល់សេវាទាំងឡាយត្រូវតែមាន ដើម្បីអាចវិភាគអំពីបរិបទ និងវិសាលភាពករណីបទល្មើសជាក់លាក់។

បច្ចេកវិទ្យាព័ត៌មានវិទ្យា ជាពិសេសប្រព័ន្ធអ៊ីនធឺណិត ផ្តល់អត្ថប្រយោជន៍ជាច្រើនក្នុងការងារវិស័យអប់រំ តាមរយៈប្រព័ន្ធអ៊ីនធឺណិត កុមារអាចធ្វើការសិក្សាស្រាវជ្រាវរុករកឯកសារ ព័ត៌មានទាក់ទងនឹងប្រធានបទដែលគេចង់ស្វែងរក។ កុមារអាចទទួលបាននូវព័ត៌មានដ៏សំបូរបែប ព្រោះថាអ៊ីនធឺណិតគឺជាបណ្ណាល័យឌីជីថលដ៏ធំជាងគេនៅលើពិភពលោកនេះ។ កុមារអាចមានភាពកាន់តែងាយស្រួលក្នុងការសិក្សា ដោយសារខ្លឹមសារមេរៀន និងប្រធានបទទាំងឡាយ មាននៅក្នុងទម្រង់ខ្លឹមសារជាច្រើនដូចជាអត្ថបទ ជារូបភាព ជាវីដេអូ ជាសំឡេង និងទម្រង់ផ្សេងទៀត ដែលងាយស្រួលទាញយកមកប្រើប្រាស់តាមសេចក្តីត្រូវការ។ លើសពីនេះទៀត តាមរយៈប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធអនឡាញ បានផ្តល់លទ្ធភាពឱ្យកុមារភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ ក្រុមគ្រួសារ និងអ្នកដទៃទៀតបានយ៉ាងឆាប់រហ័ស។ កុមារអាចនឹងចូលរួមប្រើប្រាស់គេហទំព័រ បណ្តាញព័ត៌មានសង្គម កម្មវិធីផ្ញើសារ និងវេទិកាជាច្រើនទៀត ដើម្បីក្នុងការប្រាស្រ័យទាក់ទង និងសន្ទនាគ្នា ក្នុងពេលជាមួយគ្នា កុមារអាចបង្កើត












ចែកចាយសារ មាតិកា ព្រមទាំងទទួលយក និងចែកបន្តផងដែរ។ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធអនឡាញកុមារ អាចធ្វើឱ្យកុមារមានបញ្ហាប្រឈម មានហានិភ័យនៃការរំលោភបំពាន។ ជនទុច្ចរិតអាចឆ្លៀតចូលទៅជិតកុមារ ភ្ជាប់ទំនាក់ទំនងកុមារ បន្ទាប់មកស្វែងរកមធ្យោបាយលួងលោមកុមារ និងប្រព្រឹត្តទង្វើរំលោភបំពាន និងកេងប្រវ័ញ្ចផ្សេងៗនៅក្នុង និងក្រៅប្រព័ន្ធអនឡាញ។

ជាទូទៅករណីបទល្មើស OCSEA គឺជាករណីស្មុគស្មាញសាំញ៉ាំ ព្រោះអាចកើតឡើងតាមរយៈអន្តរកម្មលើប្រព័ន្ធអនឡាញលាយបញ្ចូលគ្នា និងដោយផ្ទាល់រវាងជនល្មើស និងកុមារ។ ជួនកាលអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ អាចកើតឡើងយ៉ាងពេញលេញ ទាំងស្រុងលើប្រព័ន្ធអនឡាញ។ ប៉ុន្តែវាមិនបានទំនាក់ទំនងផ្ទាល់ ឬប៉ះពាល់ដោយផ្ទាល់លើរាងកាយ ដូចជាការជួបក្រៅប្រព័ន្ធអនឡាញរវាងជនល្មើស និងជនរងគ្រោះនោះទេ។ ករណីខ្លះទៀតវាអាចជាការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ដែលកើតឡើងក្រៅប្រព័ន្ធអនឡាញ (កើតឡើងផ្ទាល់ និងប៉ះពាល់ផ្ទាល់លើរាងកាយ) ប៉ុន្តែដំណើរដើមហេតុត្រូវបានកើតឡើងដោយប្រើបច្ចេកវិទ្យាឌីជីថលអនឡាញ។ ឧទាហរណ៍ជនល្មើសលួងលោមលើប្រព័ន្ធអនឡាញ បន្ទាប់មកណាត់ជួបធ្វើការរំលោភបំពានក្រៅប្រព័ន្ធអនឡាញ។

ទោះបីមានភាពសាំញ៉ាំស្មុគស្មាញយ៉ាងណាក៏ដោយ តាមរយៈមេរៀននេះអ្នកនឹងបានយល់យ៉ាងច្បាស់អំពីបរិបទផ្សេងគ្នានៃរូបភាពបទល្មើស អ្នកសិក្សាអំពីនិយមន័យនៃការរំលោភបំពានផ្លូវភេទកុមារដែលចែងក្នុងអង្គការសុខភាពពិភពលោក (WHO) និយមន័យដែលបានប្រើនៅក្នុងសៀវភៅណែនាំស្តីពីយុទ្ធសាស្ត្រ ឆ្លើយតបបែបកុមារមេត្រីចំពោះកុមាររងគ្រោះដែលផលិតដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) របកគំហើញ និងអនុសាសន៍ជាច្រើនដែលចង្អុលបង្ហាញដោយការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាយើង។ ជារឿងសំខាន់ ដែលយើងទាំងអស់ត្រូវតែចាំថា កុមារមិនយល់ដឹងបានពេញលេញនូវអ្វីដែលកើតឡើងនោះទេ ព្រោះកុមារមិនទាន់មានការអភិវឌ្ឍផ្នែកបញ្ញាស្មារតីគ្រប់គ្រាន់ កុមារមិនបានយល់ព្រមចំពោះការរំលោភបំពានផ្លូវភេទនោះទេ។ អ្នកនឹងរៀនស្គាល់អំពីប្រភេទនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ដែលកើតឡើងញឹកញាប់មានដូចជា ការផលិត ការកាន់កាប់ ឬការចែករំលែករូបភាពឬសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ការផ្សាយផ្ទាល់ពីការរំលោភបំពានផ្លូវភេទលើកុមារ ការលួងលោមលើប្រព័ន្ធអនឡាញសម្រាប់គោលបំណងរួមភេទ ការគំរាមកំហែងផ្លូវភេទលើកុមារ ការបៀតបៀនផ្លូវភេទរបស់កុមារ និងការឱ្យកុមារមើលឃើញមាតិកាផ្លូវភេទ ព្រមទាំងការចែកចាយខ្លឹមសារផ្លូវភេទដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារជាដើម។ យើងនឹងលើកយកមកពិភាក្សាផងដែរអំពីករណីសិក្សាដែលឆ្លុះបញ្ចាំងតាមប្រភេទនៃការរំលោភបំពានផងដែរ។

## ក និយមន័យនៃការរំលោភបំពានផ្លូវភេទលើកុមារ (CSA)

និយមន័យទាំងនេះ គឺផ្អែកលើពាក្យដែលបានប្រើនៅក្នុងសៀវភៅណែនាំស្តីពីយុទ្ធសាស្ត្រឆ្លើយតបបែបកុមារមេត្រីចំពោះកុមាររងគ្រោះ[4] ដែលផលិតដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ក្នុងឆ្នាំ ២០១៩។ និយមន័យត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពបន្តិចបន្តួចលើចំណុចដែលសមស្រប។ (ចំណាំថា៖ សកម្មភាព និងនិយមន័យដែលបានផ្តល់ខាងក្រោមអាចមិនត្រូវបានគ្របដណ្តប់ដោយច្បាប់ កម្ពុជានៅពេល នេះទេ ប៉ុន្តែវានឹងត្រូវបានលើកឡើងនៅក្នុងវគ្គសិក្សានាពេលខាងមុខ)។

[4] APLE Cambodia, សៀវភៅណែនាំបណ្តុះបណ្តាល៖ យុទ្ធសាស្ត្រឆ្លើយតបបែបកុមារមេត្រីជាមួយកុមាររងគ្រោះនៅក្នុងករណីនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ, ភ្នំពេញ, ឆ្នាំ ២០១៩។

### ក.១- អង្គការសុខភាពពិភពលោក (WHO) កំណត់ការរំលោភផ្លូវភេទលើកុមារថា ៖

> *“ការចូលរួមរបស់កុមារក្នុងសកម្មភាពផ្លូវភេទដែលគាត់មិនយល់ដឹងបានពេញលេញ មិនអាចផ្តល់ការយល់ព្រមជាមុន ឬដែលកុមារមិនទាន់មានការអភិវឌ្ឍផ្នែកបញ្ញាគ្រប់គ្រាន់ និងមិនអាចផ្តល់ការយល់ព្រម ឬដែលបំពានច្បាប់ ឬបម្រាមសង្គម។ ការរំលោភបំពានផ្លូវភេទលើកុមារត្រូវបានបង្ហាញដោយសកម្មភាពរវាងកុមារ និងមនុស្សពេញវ័យ ឬកុមារផ្សេងទៀតដែលតាមអាយុ ឬការអភិវឌ្ឍស្ថិតក្នុងទំនាក់ទំនងនៃទំនួលខុសត្រូវ ការជឿទុកចិត្ត ឬអំណាច សកម្មភាពដែលមានបំណងបំពេញចំណង់ផ្លូវភេទ ឬបំពេញតម្រូវការរបស់បុគ្គលផ្សេងទៀត”។[5]”*

**វាជារឿងសំខាន់ក្នុងការកត់សម្គាល់ថា កុមារមិនអាចយល់ព្រមចំពោះការរំលោភបំពានបានទេ។**

របាយការណ៍នៃការសិក្សាស្រាវជ្រាវបញ្ឈប់គ្រោះថ្នាក់ (The Disrupting Harm Research (DH) )**បន្ថែមថា៖**

> *“ការរំលោភបំពានផ្លូវភេទលើកុមារ សំដៅលើសកម្មភាពផ្លូវភេទផ្សេងៗដែលប្រព្រឹត្តចំពោះកុមារ(មនុស្សដែលមានអាយុក្រោម១៨ឆ្នាំ) ដោយមិនគិតពី ថាតើកុមារដឹងឬអត់ថាអ្វីដែលកំពុងកើតឡើងចំពោះពួកគេគឺមិនធម្មតា ឬអាចទទួលយកបាននោះទេ។ វាអាចត្រូវបានប្រព្រឹត្តដោយមនុស្សពេញវ័យឬមិត្តភក្តិ ហើយ ជាធម្មតាពាក់ព័ន្ធនឹងបុគ្គល ឬក្រុមដែលទាញយកអត្ថប្រយោជន៍ពីអតុល្យភាពនៃអំណាច។ វាអាចប្រព្រឹត្តទៅដោយគ្មានកម្លាំង ច្បាស់លាស់ដោយជនល្មើសតែងតែប្រើអំណាច ឧបាយកល ឬការបោកប្រាស់។”*

### ក.២- ការរំលោភបំពានផ្លូវភេទលើកុមារដោយផ្ទាល់ និងមិនផ្ទាល់ ការរំលោភបំពានលើរាងកាយ ឬការប៉ះពាល់ដោយផ្ទាល់រួមមាន៖

- ការស្ទាបអង្អែលកុមារដោយចេតនាផ្លូវភេទដោយមិនសមរម្យ (ដូចជាការលូកដៃ ស្ទាបអង្អែលថើប ឬប្រើមាត់លើរាងកាយរបស់កុមារ ជាពិសេសតំបន់ប្រដាប់បន្តពូជ ឬអ្វីដែលចាត់ទុកថាជា “ផ្នែកឯកជន”)
- ការប៉ះពាល់កុមារក្នុងវិធីដែលជំរុញឱ្យពួកគេមានអារម្មណ៍ផ្លូវភេទ និង/ឬសម្រេចកាមលើកុមារ (វាមិនតម្រូវឱ្យកុមារទទួលបានការឈានដល់ចំណុចកំពូល ឬការបញ្ចេញទឹកកាមដែលត្រូវបានចាត់ទុកថាសម្រេចកាមដោយខ្លួនឯងនោះទេ)

---

[5] អង្គការសុខភាពពិភពលោក។ (១៩៩៩)។ ការផ្លាស់ប្តូរសង្គម និងសុខភាពផ្លូវចិត្ត អំពើហិង្សា និងការការពាររបួស។ (ត្រូវបានដកស្រង់ផងដែរនៅក្នុងគោលការណ៍ណែនាំពាក្យភាសាលុចសំបួរ)

- ការឱ្យកុមារប៉ះពាល់ផ្នែកឯកជនរបស់អ្នកដទៃ សម្រេចកាមអោយអ្នកដទៃ ឬឱ្យកុមារធ្វើអំពើផ្លូវភេទលើបុគ្គលផ្សេងទៀត
- ការដាក់បញ្ចូលក្នុងផ្លូវភេទរបស់កុមារ (ការបញ្ចូលវត្ថុចូលទៅក្នុងទ្វារមាស ឬរន្ធគូថរបស់កុមារ ឬការបញ្ចូលឧបករណ៍ផ្លូវភេទទៅក្នុងមាត់កុមារ)
- ការរំលោភសេពសន្ថវៈលើកុមារ (ការរួមភេទតាមទ្វារមាស ការរួមភេទតាមរន្ធគូថនិងការរួមភេទតាមមាត់)
- ការប្រើកុមារជាវត្ថុអាសអាភាស (ឧទាហរណ៍ ការថតរូប និងវីដេអូនៃសកម្មភាពផ្លូវភេទជាមួយកុមារ)
- ការបង្ខំ បញ្ចុះបញ្ចូល ឬបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តអំពើផ្លូវភេទជាមួយកុមារដទៃទៀត
- ការបង្ខំ បញ្ចុះបញ្ចូល ឬបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តអំពើផ្លូវភេទជាមួយសត្វ។

### ក.៣- សកម្មភាពនៃការរំលោភបំពានផ្លូវភេទដែលមិនពាក់ព័ន្ធនឹងការប៉ះពាល់ផ្ទាល់អាចរួមមាន៖

- សកម្មភាពផ្លូវភេទ (សម្រេចកាមដោយខ្លួន ឬសកម្មភាពផ្លូវភេទផ្សេងទៀតជាមួយមនុស្សម្នាក់ទៀត) នៅចំពោះមុខកុមារ
- ការតាំងបង្ហាញ (ដូចជាការបង្ហាញលិង្គ ប្រដាប់ភេទ ឬសុដន់ដល់កុមារ)
- ការបញ្ចុះបញ្ចូលកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ និង/ឬលេង
- ការបង្ហាញរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (ភាពយន្ត គំនូរជីវចល រូបថត គំនូរ ឬគំនូរឌីជីថល) ដែលពណ៌នាអំពីសកម្មភាពផ្លូវភេទរបស់កុមារ ឬមនុស្សពេញវ័យផ្សេងទៀត
- ការប្រើកុមារជាវត្ថុអាសអាភាស (ដូចជាការថតរូបកុមារក្នុងឈុតហែលទឹកដើម្បីសម្រើបផ្លូវភេទ)
- ការមើល ឬទាញយករូបភាពផ្លូវភេទរបស់កុមារដើម្បីរក្សាទុក
- ការជជែកឬនិយាយជាមួយកុមារដោយប្រើភាសាផ្លូវភេទ
- ការចូលរួមរបស់កុមារក្នុងការសន្ទនាបែបផ្លូវភេទ [មិនសមរម្យ] ដែលអាចជាផ្នែកមួយនៃអំពើលួងលោមកុមារក្នុងគោលបំណងផ្លូវភេទ។

## ខ និយមន័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (CSE)

និយមន័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារអាចពិបាកយល់បន្តិច ទោះជាយ៉ាងណាក៏ដោយ វាអាចពាក់ព័ន្ធនឹងសកម្មភាពរំលោភបំពានដូចគ្នាជាច្រើនដែលបានពិពណ៌នាខាងលើ។ ហើយវាមានទំនាក់ទំនងជាមួយគ្នារវាងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ។

ទោះជាយ៉ាងណាក៏ដោយអ្វីដែលបែងចែកនិយមន័យគោលនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារពីទម្រង់ផ្សេងទៀតនៃការរំលោភបំពានផ្លូវភេទលើកុមារ គឺផ្តោតសំខាន់ទៅលើ ការដោះដូរ ដែលមាននៅក្នុងការកេងប្រវ័ញ្ច។ ការដោះដូរនេះអាចកើតឡើងក្នុងទម្រង់ផ្សេងៗ (ឧទាហរណ៍ លុយ ទីជម្រក ទំនិញ សម្ភារៈ ឬអ្វីដែលមើលមិនឃើញ ដូចជាការការពារ ការយកចិត្តទុកដាក់ ការស្រលាញ់ ឬទំនាក់ទំនង ឬសូម្បីតែការសន្យា)។

ការរំលោភបំពានផ្លូវភេទលើកុមារក៏ក្លាយជាការកេងប្រវ័ញ្ចផងដែរ នៅពេលដែលកុមារ ឬភាគីទីបីទទួលបានអត្ថប្រយោជន៍តាមរយៈប្រាក់ចំណេញ។

### ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា ២) បានកំណត់ទម្រង់បីនៃការកេងប្រវ័ញ្ចផ្លូវភេទ៖

១ ការលក់កុមារ កំណត់ថាជាសកម្មភាព ឬប្រតិបត្តិការណាមួយ ដែលកុមារត្រូវបានផ្ទេរដោយបុគ្គល ឬក្រុមមនុស្សណាមួយទៅឱ្យអ្នកផ្សេង ដើម្បីប្រាក់កម្រៃ ឬអ្វីផ្សេងទៀតណាមួយ។

២ ពេស្យាចារកុមារការប្រើប្រាស់កុមារក្នុងសកម្មភាពផ្លូវភេទ ដើម្បីផ្តល់ប្រាក់កម្រៃ ឬទម្រង់ផ្សេងៗនៃអ្វីមួយ។

៣ រូបភាព និងសម្ភារៈអាសអាភាសរបស់កុមារ តំណាងណាមួយ ទោះជាដោយមធ្យោបាយណាក៏ដោយ នៃកុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ឬក្លែងបន្លំ ឬតំណាងណាមួយនៃផ្នែកផ្លូវភេទរបស់កុមារសម្រាប់គោលបំណងផ្លូវភេទជាចម្បង។

## គ ការស្វែងយល់ និងនិយមន័យការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

OCSEA អាចនឹងពិបាកយល់ ដោយសាអ្នកចូលរួមនៅក្នុងការវាយតម្លៃតម្រូវការសម្រាប់វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលជំនាញ (TNA) បានសម្តែងការភ័ន្តច្រឡំមួយចំនួនអំពីអ្វីដែលជា OCSEA របៀបដែលវាទាក់ទងនឹងការកេងប្រវ័ញ្ច ឬការរំលោភបំពានផ្លូវភេទកុមារក្រៅប្រព័ន្ធអនឡាញ (CSA) និង (CSE) ភាពស្រដៀងគ្នា និងភាពខុសគ្នា។ សន្លឹកកិច្ចការនេះ និងពន្យល់បន្ថែម។

- OCSEA សំដៅលើស្ថានភាពនៃការរំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល អ៊ីនធឺណិត និងការប្រាស្រ័យទាក់ទង នៅចំណុចមួយចំនួនក្នុងអំឡុងពេលប្រព្រឹត្តអំពើរំលោភបំពាន ឬការកេងប្រវ័ញ្ច។
- OCSEA ក៏អាចកើតឡើងតាមរយៈអន្តរកម្មលើប្រព័ន្ធអនឡាញលាយបញ្ចូលគ្នា និងដោយផ្ទាល់រវាងជនល្មើស និងកុមារ។
- ប្រហែលជាការពិពណ៌នាអំពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានកុមារថាជាការរំលោភបំពាន «លើប្រព័ន្ធអនឡាញ » ឬ «ក្រៅប្រព័ន្ធអនឡាញ» ទាំងស្រុង ហើយទាំងនេះមិនបានជួយយើងឱ្យយល់ពីវិធីក្នុងការបង្ការ ឬឆ្លើយតបទៅនឹងបញ្ហាឡើយ។

ដូច្នេះ៖

- OCSEA អាចកើតឡើងយ៉ាងពេញលេញ [ឬទាំងស្រុង] លើប្រព័ន្ធអនឡាញ (មិនមានទំនាក់ទំនងរាងកាយ ឬការជួបក្រៅប្រព័ន្ធអនឡាញរវាងជនល្មើស និងជនរងគ្រោះ)។
- ប៉ុន្តែវាក៏អាចជាការរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ ដែលកើតឡើងក្រៅប្រព័ន្ធអនឡាញ-ប៉ុន្តែត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថលអនឡាញ។ (ឧ. លួងលោមលើប្រព័ន្ធអនឡាញ-បន្ទាប់មកបំពានក្រៅប្រព័ន្ធអនឡាញ)។
- ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានដែលត្រូវបានប្រព្រឹត្តក្រៅប្រព័ន្ធអនឡាញ ហើយបន្ទាប់មកផ្លាស់ទីទៅក្នុងប្រព័ន្ធអនឡាញតាមរយៈការចែករំលែករូបភាព ឬវីដេអូនៃការរំលោភបំពាន។
- ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាប្រាប់យើង ខណៈពេលដែលករណីទាំងអស់នៃ OCSEA រួមបញ្ចូលធាតុនៅលើប្រព័ន្ធអនឡាញ។ ការរំលោភបំពាន និងការកេងប្រវ័ញ្ចអាចកើតឡើង ហើយជារឿយៗកើតឡើងនៅចំណុចជាច្រើននៅជាប់គ្នារវាងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។
- ដូច្នេះ នេះមានន័យថា ការរំលោភបំពាន និងការកេងប្រវ័ញ្ចណាមួយអាចផ្លាស់ទីរវាង ក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញនៅចំណុចផ្សេងៗគ្នាតាមពេលវេលា។

នៅពេលដែលមន្ត្រីនគរបាលកំពុងស៊ើបអង្កេត និងគាំទ្រកុមារដែលទទួលរងដោយ OCSEA ដូច្នេះ អ្នកនឹងត្រូវស្វែងយល់ពីរបៀបដែលការរំលោភបំពាន និងការកេងប្រវ័ញ្ចបានកើតឡើង ដោយពិចារណាថា តើផ្នែកណានៃឧក្រិដ្ឋកម្មគឺជាធាតុផ្សំក្រៅប្រព័ន្ធអនឡាញ និងលើប្រព័ន្ធអនឡាញ។

ក្នុងនាមជាមន្ត្រីនគរបាលដែលកំពុងស៊ើបអង្កេត និងគាំទ្រកុមារ ដែលរងផលប៉ះពាល់ដោយ OCSEA ត្រូវស្វែងយល់ពីរបៀបដែលការរំលោភបំពាន និងការកេងប្រវ័ញ្ច បានកើតឡើងដោយពិចារណាថាតើជាតុផ្សំណាមួយកើតឡើងក្នុងឬក្រៅប្រព័ន្ធអនឡាញ។

- OCSEA អាចកើតឡើងយ៉ាងពេញលេញ (ឬទាំងស្រុង) តាមអ៊ីនធឺណិត (មិនមានទំនាក់ទំនងរាងកាយ ឬការជួបក្រៅបណ្តាញរវាងជនល្មើស និងជនរងគ្រោះ)។
- ប៉ុន្តែវាក៏អាចជាការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលកើតឡើងក្រៅប្រព័ន្ធអនឡាញ-ប៉ុន្តែត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថល។ (ឧ. ការលួងលោមតាមប្រព័ន្ធអ៊ីនធឺណិត- បន្ទាប់មកបំពាននៅក្រៅប្រព័ន្ធអនឡាញ)។
- ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ដែលត្រូវបានប្រព្រឹត្តក្រៅប្រព័ន្ធអនឡាញ ក៏អាចទៅជាក្នុងប្រព័ន្ធអនឡាញដែរនៅពេលដែល រូបភាព ឬវីដេអូ នៃការរំលោភបំពានត្រូវបានចែករំលែកលើប្រព័ន្ធអនឡាញ។
- ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាយើង ខណៈពេលដែលករណីទាំងអស់នៃ OCSEA រួមបញ្ចូលជាតុផ្សំ ការរំលោភបំពាន និងការកេងប្រវ័ញ្ច អាចកើតឡើងតាមអនឡាញ ហើយជារឿយៗកើតឡើងនៅចំណុចជាច្រើននៅជាប់គ្នារវាងអនឡាញ និងក្រៅអនឡាញ។
- ដូចនេះមានន័យថា ការរំលោភបំពាន និងការកេងប្រវ័ញ្ចណាមួយអាចផ្លាស់ប្តូរពីអនឡាញ និងក្រៅអនឡាញ នៅចំណុចផ្សេងៗគ្នាតាមពេលវេលា។

## ឃ តើ OCSEA មានលក្ខណៈបែបណា?

ទង្វើ និងឥរិយាបថខាងក្រោមពិពណ៌នាយ៉ាងខ្លីអំពីអ្វីដែលត្រូវបានចាត់ទុកថា ជា OCSEA នេះ បើយោងតាមរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Distrupting Harm Global Study in Cambodia) ហើយត្រូវបានផ្អែកលើការណែនាំវាក្យស័ព្ទរបស់លុចឲ្យសំបួរ ។

សូមចំណាំថា ចំពោះនិយមន័យផ្លូវច្បាប់ បើយោងតាមច្បាប់កម្ពុជា អាចមានភាពខុសគ្នាបន្តិចបន្តួច ប្រហែលជាមិនត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មនោះទេ។ និយមន័យ និងការពិចារណាផ្អែកច្បាប់នឹងត្រូវបានពិភាក្សានៅក្នុងវគ្គសិក្សា។ ទង្វើ និងសកម្មភាពទាំងអស់នោះមានទម្រង់ដូចខាងក្រោម៖

## ឃ.១- ការផលិត ការកាន់កាប់ ឬការចែកចាយរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM)

- CSAM គឺសំដៅដល់មាតិកាដែលអាចមើលឃើញ (Visual) ឬជាសំឡេង (Audio) ដែលបង្ហាញពីសកម្មភាពផ្លូវភេទ ឬកេរភេទដែលពាក់ព័ន្ធនឹងកុមារ។ រូបភាព-សម្ភារៈអាសអាភាសនៃកុមារនៅក្នុងច្បាប់កម្ពុជា សំដៅដល់សម្ភារៈដែលអាចមើលឃើញនឹងភ្នែក ដូចជារូបថត ខ្សែវីដេអូ និងសម្ភារៈអេឡិចត្រូនិក។ វាមិនមែនត្រឹមតែជារូបភាព និងវីដេអូប៉ុណ្ណោះទេ ប៉ុន្តែអាចជាមាតិកាដែលត្រូវបានបង្កើត ឬកែច្នៃជាលក្ខណៈឌីជីថលផងដែរ ដែលបង្ហាញពីរូបអាក្រាតរបស់កុមារដែលធ្វើឱ្យរំជើបរំជួលដល់ចំណង់ផ្លូវភេទ។

- CSAM ត្រូវបានចាត់ទុកថាខុសច្បាប់យ៉ាងធ្ងន់ធ្ងរនៅក្នុងបរិបទផ្លូវច្បាប់។ វាសំខាន់ណាស់ក្នុងការកត់សម្គាល់ថា សម្ភារៈបែបនេះខុសច្បាប់ និងបង្កផលវិបាកផ្លូវច្បាប់យ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលផលិត ចែកចាយ ឬអ្នកកាន់កាប់ (រក្សាទុក) វាសម្រាប់ការចែកចាយ។ ប្រទេសជាច្រើនបានអនុវត្តច្បាប់ដ៏តឹងរ៉ឹង ដើម្បីប្រយុទ្ធប្រឆាំងនឹងការផលិត និងចែកចាយ CSAM។ វាអាចឆ្លុះបញ្ចាំងបានថា ជនរងគ្រោះមិនអាចយល់ព្រមចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចរបស់ពួកគេ។ បញ្ហាប្រឈមដ៏សំខាន់ គឺ CSAM អាចស្វែងរកបានដោយងាយនៅលើអនឡាញ ដោយសារតែជនល្មើសតែងតែប្រើអ៊ីនធឺណិត ដើម្បីចែករំលែក ចែកចាយ និងបញ្ជូនអោយគ្នាទៅវិញទៅមកនូវរូបភាព-សម្ភារៈទាំងនេះទូទាំងពិភពលោក។[6]

### ឃ.១.១- ការបៀតបៀនផ្លូវភេទរបស់កុមារ និង/ឬ ការឱ្យកុមារមើលឃើញមាតិកាផ្លូវភេទ៖

- ទាំងពីរនេះអាចត្រូវបានចាត់ទុកថាជា អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ឬឥរិយាបថដែលអាចនាំឱ្យមាន OCSEA នៅក្នុងករណីមួយចំនួន។

- ជាឧទាហរណ៍ ជនល្មើសអាចបង្ហាញកុមារដោយចេតនាចំពោះខ្លឹមសារផ្លូវភេទ ដែលជាផ្នែកនៃយុទ្ធសាស្ត្រនៃកលល្បិចលួងលោម ដែលត្រូវបានរចនាឡើងដើម្បីបន្សាំពួកគេនឹងសកម្មភាពផ្លូវភេទ។

- យ៉ាងណាមិញ វាជារឿងសំខាន់ក្នុងការទទួលស្គាល់ថាមានភាពខុសគ្នារវាងការមើលដោយស្ម័គ្រចិត្តនៃខ្លឹមសារផ្លូវភេទដោយកុមារ និងការមើលដែលត្រូវបានបង្ខិតបង្ខំ។

- ការមើលដោយស្ម័គ្រចិត្តនៃខ្លឹមសារផ្លូវភេទមិនត្រូវបានរួមបញ្ចូលក្នុងនិយមន័យនៃ អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ដែលប្រើក្នុងរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នោះទេ។

---

[6] ដកស្រង់ចេញពីសៀវភៅណែនាំការបណ្តុះបណ្តាលការស៊ើបអង្កេតលើបណ្តាញអ៊ីនធឺណិត ឧក្រិដ្ឋកម្មផ្លូវភេទ ប្រឆាំងនឹងកុមារ (ទំព័រទី៤)

- អាស្រ័យលើអាយុរបស់កុមារ និងខ្លឹមសារផ្លូវភេទ (ឧទាហរណ៍. វីដេអូ) វាអាចមិនត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋទេ ប៉ុន្តែអាចបង្កគ្រោះថ្នាក់ដល់កុមារទាក់ទងនឹងការអភិវឌ្ឍន៍របស់ពួកគេ និងការយល់ដឹងអំពីការយល់ព្រមលើទំនាក់ទំនងផ្លូវភេទ។ (ឧទាហរណ៍. ក្មេងអាយុមួយឆ្នាំមើលវីដេអូហិង្សា និង/ឬផ្លូវភេទ)

### ឃ.១.២- ការចែករំលែកខ្លឹមសារផ្លូវភេទដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ៖

- កន្លែងដែលយុវជនពីរនាក់ (ឧទាហរណ៍. ដៃគូអាយុ១៧ឆ្នាំក្នុងទំនាក់ទំនង) យល់ព្រមក្នុងការចែករំលែករូបភាពផ្ទាល់ខ្លួនប្រហែលជាមិនត្រូវបានចាត់ទុកថាជា អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ទេ។

  ទោះបីជាយ៉ាងណាក៏ដោយ វាអាចនាំទៅដល់ ឬជាផ្នែកមួយនៃ OCSEA ប្រសិនបើវាត្រូវបានបញ្ជូនបន្តដោយគ្មានការអនុញ្ញាតពីអ្នកពាក់ព័ន្ធណាម្នាក់ ឬទាំងពីរ ឬប្រសិនបើវាត្រូវបានទទួលតាមរយៈការបោកប្រាស់ ឬការបង្ខិតបង្ខំតាមគ្រប់មធ្យោបាយ ។

## ឃ.២- ការលួងលោមកុមារតាមអនឡាញក្នុងគោលបំណងផ្លូវភេទ (Grooming of Children for Sexual Purposes)

- ការលួងលោមកុមារតាមអនឡាញសម្រាប់គោលបំណងជាចម្បង សំដៅដល់ដំណើរការ ឬសកម្មភាពដែលជនល្មើសប្រាស្រ័យទាក់ទងជាមួយកុមារតាមអ៊ីនធឺណិត ក្នុងចេតនារំលោភបំពានផ្លូវភេទ ឬកេងប្រវ័ញ្ចផ្លូវភេទ។ សកម្មភាពទាំងនោះ រាប់បញ្ចូលទាំងរបៀបដែលជនល្មើសកសាងទំនាក់ទំនងជាបន្តបន្ទាប់ជាមួយកុមារ ធ្វើឱ្យកុមារជឿទុកចិត្ត ហើយបន្ទាប់មកនាំពួកគេទៅដល់ការប្រព្រឹត្តផ្លូវភេទ។ ការលួងលោមកុមារតាមអនឡាញ អាចកើតឡើងដោយជនល្មើសមិនចាំបាច់ជួបកុមារផ្ទាល់។ ជាទូទៅ ជនល្មើសជាច្រើន ប្រើបច្ចេកវិទ្យាឌីជីថលដើម្បីកេងប្រវ័ញ្ចកុមារដោយមិនចាំបាច់ជួបកុមារផ្ទាល់។ ឧទាហរណ៍ ជនល្មើសរៀបចំ ឬបញ្ចុះបញ្ចូលឱ្យកុមារឱ្យបង្កើតនូវសម្ភារៈ (រូបថត វីដេអូ...) ដោយខ្លួនឯង រួចហើយណែនាំឱ្យកុមារចែករំលែករូបភាពទាំងនោះតាមអនឡាញ រីឯជនល្មើសមិនចាំបាច់ចូលរួម និងបំពានដោយផ្ទាល់ឡើយ។
- ការលួងលោមកុមារតាមអនឡាញ៖ ជនលួងលោមកុមារ ព្យាយាមស្វែងយល់ និងបំពេញតម្រូវការរបស់កុមារ ផ្តល់ការយកចិត្តទុកដាក់ចំពោះកុមារ ដើម្បីធ្វើឱ្យមានជំនឿទុកចិត្តកាន់តែខ្លាំង។ បន្ទាប់មកជននោះលួងលោមកុមារប្រើវិធីសាស្ត្រចែករំលែកមាតិកា ដែលគួរឱ្យទាក់ទាញការចាប់អារម្មណ៍របស់កុមារ បន្តិចម្តងៗ គេចាប់ផ្តើមបង្ហាញកុមារនូវរូបភាពបែប

ស្រើបស្រាល និងឈានទៅដល់លក្ខណៈអាសអាភាសដល់កុមារ។ គេប្រើវិធីសាស្ត្របែបបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ កាត់បន្ថយភាពអៀនខ្មាស់ ព្រមទាំងលួងលោមកុមារឱ្យហ៊ានថតរូបភាព ថតវីដេអូផ្ទាល់ខ្លួន និងផ្ញើទៅជនលួងលោមនោះវិញ។

- ការលួងលោមកុមារតាមអនឡាញ៖ អាចកើតឡើងយ៉ាងលឿន ងាយស្រួល និងឆាប់រហ័សបំផុត ពីព្រោះតែភាពជឿនលឿននៃបច្ចេកវិទ្យាឌីជីថល ដែលលទ្ធភាពឱ្យជនល្មើសអាចលួងលោមកុមារដោយផ្ទាល់ និងធ្វើឱ្យកុមារជឿទុកចិត្តបានខ្លាំង។ ជាទូទៅ ជនលួងលោមប្រាស្រ័យទាក់ទងជាមួយកុមារក្នុងកម្មវិធី វេទិកា គេហទំព័រ ជជែកកម្សាន្ត បញ្ចេញមតិយោបល់ បន្ទាប់មកពួកគេបន្តជជែកគ្នា ឬចាប់ផ្តើមទំនាក់ទំនងគ្នាជាលក្ខណៈបុគ្គល ទៅវិញទៅមកភ្លាមៗ ដោយផ្ទាល់ជាលក្ខណៈឯកជនវិញ។

- វាគឺជាការចាំបាច់ណាស់ សម្រាប់ពង្រឹងការអនុវត្តច្បាប់ ដើម្បីស្វែងយល់ពីកលល្បិច ដែលជនលួងលោមកុមារប្រើប្រាស់ ដូចជាបង្កើតពាក្យចចាមអារ៉ាម ការក្លែងបន្លំខ្លួនជាបុគ្គលណាម្នាក់ ដែលកុមារស្គាល់ ធ្វើឱ្យកុមារជឿទុកចិត្ត និងមានអារម្មណ៍សុវត្ថិភាព ឬផ្តល់នូវផលប្រយោជន៍ផ្សេងៗ។ ដូច្នេះ ការយល់ដឹងអំពី អាកប្បកិរិយា និងការប្រព្រឹត្តទាំងនោះ គឺអាចជួយដល់ការពង្រឹងការអនុវត្តច្បាប់ ការផ្តល់បទអន្តរាគមន៍ និងធ្វើការទប់ស្កាត់ការរំលោភបំពានបានទាន់ពេលវេលា។

## ឃ.៣- ការផ្ញើសារបែបផ្លូវភេទ

- ការផ្ញើសារបែបផ្លូវភេទ (Sexting) សំដៅដល់សកម្មភាពផ្ញើ ឬទទួលសារជារូបភាព ឬវីដេអូដែលបង្ហាញផ្នែករាងកាយឯកជន រូបរាងអាក្រាត ឬសំណេរដែលមានលក្ខណៈផ្លូវភេទ រវាងបុគ្គលពីរនាក់ ឬច្រើន(ជាបុគ្គល ឬជាក្រុម) តាមរយៈកម្មវិធីនៅលើទូរស័ព្ទដៃ ឬឧបករណ៍ផ្សេងៗ ដែលភ្ជាប់ទៅនឹងអ៊ីនធឺណិត។ ជាទូទៅ ការផ្ញើ ឬទទួលបានសារបែបនេះកើតឡើងដោយការស្ម័គ្រចិត្ត ឬធ្វើឡើងបន្ទាប់ពីនរណាម្នាក់ទទួលរងការគំរាមកំហែង ដោយមានការដាក់សម្ពាធ និងការរៀបចំឡើងដោយនរណាម្នាក់ទៀត។

- ការផ្ញើសារបែបផ្លូវភេទច្រើនកើតឡើងក្នុងចំណោមក្មេងជំទង់ ដែលកំពុងមានទំនាក់ទំនងជិតស្និទ្ធ ហើយស្ម័គ្រចិត្តចែករំលែករូបភាពឯកជនរបស់ខ្លួន ឬសារដែលមានលក្ខណៈផ្លូវភេទឱ្យគ្នាទៅវិញទៅមក។ ជារឿយៗ កុមារ និងក្មេងជំទង់មិនបានដឹងថា អ្វីដែលពួកគេចែករំលែកនៅលើអ៊ីនធឺណិត វាពិបាកនឹងយកមកវិញ ឬលុបចេញ ជាពិសេសនៅពេលដែលរូបភាពនោះត្រូវបានផ្ញើចេញ និងត្រូវបានគេចម្លង ឬចែករំលែកបន្តពីម្នាក់ទៅម្នាក់។

- វាជាការសំខាន់ណាស់ដែលត្រូវដឹងថា កុមារមិនគួរពាក់ព័ន្ធនឹងការផ្ញើសារបែបផ្លូវភេទទេ ពីព្រោះវា ជារឿងមិនសមស្របនឹងអាយុ និងការអភិវឌ្ឍរបស់ពួកគេ។ នៅពេលកុមារចូលរួម សកម្មភាពពាក់ព័ន្ធ នឹងផ្លូវភេទ ពួកគេប្រហែលជាមិនយល់ច្បាស់ពីហានិភ័យ និងគ្រោះថ្នាក់ ដែលអាចកើតឡើង។
- នៅពេលដែលអ្នកផ្ញើរូបភាព ឬសារបែបផ្លូវភេទអ្នកនឹងមិនអាចគ្រប់គ្រងកន្លែងដែលវាទៅ ឬនរណាមើលឃើញវាទេ។ រូបភាពទាំងនោះអាចត្រូវបានគេចែករំលែកជាមួយអ្នកដទៃដោយ គ្មានការអនុញ្ញាតពីអ្នក ហើយវាពិតជាគួរឱ្យអាម៉ាស់ និងឈឺចាប់ណាស់។ វាក៏សំខាន់ផងដែរ ក្នុងការចងចាំថាការចែករំលែកមាតិកាដែលមានលក្ខណៈអាសអាភាសទោះបីវាជារបស់អ្នក ក៏ដោយវាក៏អាចប្រឈមនឹងច្បាប់ផងដែរ។

## ឃ.៤- ការគំរាមទាក់ទងនឹងផ្លូវភេទ (Sextortion)

- Sextortion គឺជាទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទដែលពាក់ព័ន្ធនឹងការគំរាមនរណាម្នាក់ឱ្យផ្ញើ រូបថត ឬវីដេអូអាក្រាតរបស់ខ្លួន ឬគំរាមឱ្យនរណាម្នាក់ចូលរួមសកម្មភាពផ្លូវភេទតាមអនឡាញ ឬដោយផ្ទាល់ ដោយគំរាមថា ខ្លួននឹងបង្ហោះរូបភាពទាំងនោះ ប្រសិនបើមិនធ្វើតាមការទាមទារ ចង់បានរបស់ពួកគេ។
- Sextortion៖ ជួនកាលគេហៅថា «ការជំរិតផ្លូវភេទ» នេះសំដៅលើការប្រើប្រាស់ការគំរាម ទារប្រយោជន៍ ឬគំរាមកំហែងដើម្បីទាញយករូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ឬ អត្ថប្រយោជន៍ផ្សេងទៀត (ឧទាហរណ៍ ប្រាក់ ឬរបស់មានតម្លៃ) ពីកុមារ ដែលជារឿយៗប្រើ មាតិកាបែបផ្លូវភេទ ឬរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ដែលត្រូវបានចែករំលែក ពីមុន។ ដើមឡើយ សារ ឬរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទទាំងនោះ ត្រូវបានចែករំលែក ដោយស្ម័គ្រចិត្តដោយកុមាររងគ្រោះ ប៉ុន្តែក្រោយមក ត្រូវបានប្រើប្រាស់ដើម្បីគំរាមកំហែង ពួកគេ ឬប្រហែលជាត្រូវបានប្រើប្រាស់ដោយអ្នកផ្សេង ដើម្បីគំរាមជនរងគ្រោះ។ អ្នកគំរាម ក៏អាចទាមទារជនរងគ្រោះឱ្យផ្តល់រូបថត ឬវីដេអូផ្លូវភេទ បន្ថែមទៀត ឬជំរិតទារប្រាក់ ជាថ្នូរ នឹងការសន្យាមិនបង្ហោះរូបភាពទាំងនោះ។
- ជាទូទៅ អ្នកគំរាមប្រើប្រាស់រូបភាពអាក្រាត ឬរូបភាពផ្លូវភេទ ដែលខ្លួនទទួលបានពីជនរងគ្រោះ តាមរយៈការផ្ញើ ឬបញ្ជូនសារដោយការស្ម័គ្រចិត្ត ដើម្បីគំរាមជនរងគ្រោះ។ ការគំរាម ទាក់ទងនឹងផ្លូវភេទនេះ ជាធម្មតា កើតឡើងនៅលើវេទិកាអនឡាញ ហើយអាចបង្កផលវិបាក យ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះ។ ដើម្បីទទួលបានទំនុកចិត្ត និងរូបភាពឯកជនរបស់ជនរងគ្រោះ ជនល្មើសនៃការគំរាមទាក់ទងនឹងផ្លូវភេទ អាចប្រើកលល្បិចផ្សេងៗ ដូចខាងក្រោម៖

- ស្វែងរកជនរងគ្រោះនៅលើវេទិកាអនឡាញ ដូចជាកម្មវិធីបណ្តាញទំនាក់ទំនងសង្គម ហ្គេមអនឡាញ ឬកម្មវិធីផ្ញើសារ។
- បង្កើតគណនីក្លែងក្លាយ ឬបន្លំគណនីរបស់អ្នកដទៃ ដើម្បីទាក់ទងកុមារ ឬជនរងគ្រោះ។ លួងលោមកុមារក្នុងចេតនាបង្កើតទំនាក់ទំនង និងការជឿទុកចិត្ត ហើយបញ្ចុះបញ្ចូលកុមារឱ្យយល់ព្រមផ្ញើរូបថត ឬវីដេអូអាក្រាតរបស់ខ្លួន។
- លួចចូលប្រើឧបករណ៍ផ្ទាល់ខ្លួន ឬគណនីបណ្តាញទំនាក់ទំនងសង្គមរបស់កុមារតាមរយៈការផ្ញើតំណភ្ជាប់ដែលមានមេរោគបច្ចេកវិទ្យា។ នៅពេលចុចលើតំណភ្ជាប់ កម្មវិធីមេរោគនឹងដំឡើងដោយស្វ័យប្រវត្តិ ហើយលួចយកទិន្នន័យក្នុងឧបករណ៍ឬលួចបញ្ជាកាមេរ៉ាក្នុងឧបករណ៍ដើម្បី ទទួលបានរូបភាពអាក្រាតរបស់កុមារ ដែលមាននៅក្នុងឧបករណ៍នោះ។

- ជនរងគ្រោះនៃការគំរាមទាក់ទងនឹងផ្លូវភេទ អាចជាក្មេងស្រី ឬក្មេងប្រុស។ ពួកគេនឹងកើតមាន អារម្មណ៍សោកសៅ បញ្ហាផ្លូវចិត្ត ការភ័យខ្លាច និងការអស់សង្ឃឹម។ ក្នុងករណីខ្លះជនល្មើសក៏ទាមទារ ការធ្វើសកម្មភាពផ្លូវភេទលើជនរងគ្រោះដោយផ្ទាល់ ដែលអាចបង្កផលប៉ះពាល់កាន់តែធ្ងន់ធ្ងរ។

### ឃ.៨- ការផ្សាយផ្ទាល់អំពីការរំលោភបំពានផ្លូវភេទលើកុមារ (Live Streaming)

- Live Streaming គឺសំដៅលើការផ្សាយផ្ទាល់ ឬ បង្ហាញវីដេអូផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទកុមារ ដែលអនុញ្ញាតឱ្យអ្នកដទៃចូលមើលឃើញក្នុងពេលតែមួយពីចម្ងាយ តាមរយៈកម្មវិធីអនឡាញដែលមានមុខងារ អាចផ្សាយផ្ទាល់បាន។
- កុមារត្រូវបានគេបង្ខំឱ្យសម្តែងបែបផ្លូវភេទនៅមុខកាម៉េរ៉ា (អាចក្នុងសកម្មភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ ...) ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទពីពួកគេ។ ជនល្មើសស្វែងរកអ្នកចូលមើល ការចាក់ផ្សាយផ្ទាល់ ដើម្បីលក់ដូរវីដេអូបន្តផ្ទាល់ទាំងនោះ។ ពេលខ្លះជនល្មើសអាចផ្តល់ជាប្រាក់ដល់កុមារ អ្នកសម្របសម្រួល ឬអន្តរការី ដើម្បីដោះដូរជាមួយនឹងការរៀបចំសកម្មភាពផ្លូវភេទទាំងនោះ។
- ការរំលោភបំពានផ្លូវភេទលើកុមារដែលត្រូវបានប្រព្រឹត្ត និងមើលក្នុងពេលជាក់ស្តែងតាមរយៈឧបករណ៍ប្រាស្រ័យទាក់ទង ឧបករណ៍សន្និសីទវីដេអូ និង/ឬកម្មវិធីជជែក។
- ក្នុងករណីភាគច្រើន ជនល្មើសដែលស្នើសុំការរំលោភបំពានជាថ្នូរនឹងការបង់ប្រាក់ ឬអត្ថប្រយោជន៍ជាសម្ភារៈផ្សេងទៀត គឺស្ថិតនៅក្នុងទីតាំងផ្សេងពីកុមារ និងអ្នកសម្របសម្រួលនៃការរំលោភបំពាននេះ។

ការស្រាវជ្រាវ និងរបាយការណ៍ពីកុមារ និងយុវជនក៏កំណត់នូវសកម្មភាពបន្ថែមដែលអាច ឬអាចត្រូវបានចាត់ទុកថា អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) អាស្រ័យលើកាលៈទេសៈជាក់លាក់។

## ង ផលប៉ះពាល់នៃ OCSEA

ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញមានប៉ះពាល់យ៉ាងខ្លាំង និងប៉ះទង្គិចពេញមួយជីវិត ទាំងផ្លូវចិត្ត សង្គម និងសុខភាពរាងកាយរបស់កុមារ។ កុមារដែលទទួលរងនូវការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ មានផលប៉ះពាល់ និងបញ្ហាប្រឈមធ្ងន់ធ្ងរជាច្រើន ដូចខាងក្រោម៖

- **បញ្ហាផ្លូវចិត្ត និងបញ្ហាស្មារតី៖** កុមារដែលត្រូវបានគេរំលោភបំពានលើប្រព័ន្ធអនឡាញនឹងប្រឈមនឹងបញ្ហា ដូចជាភាពជាភ័យខ្លាច ធុញថប់ កង្វល់ និងមានសកម្មភាពផ្លាស់ប្តូរគួរឱ្យព្រួយបារម្ភជាខ្លាំង ជាពិសេសផ្លូវចិត្ត និងស្មារតី។ វាបណ្តាលឱ្យកុមារមានការរីកលូតលាស់រាងកាយ ការអភិវឌ្ឍបញ្ញា ការគិតឃើតយ៉ាវ ជួបផលវិបាក ពិបាកផ្ចង់ស្មារតី ថប់បារម្ភ និងប្រឈមនឹងជំងឺបាក់ទឹកចិត្ត។ កុមាររងគ្រោះភ័យខ្លាចរូបភាពរបស់ខ្លួនត្រូវបានគេយកទៅផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតកាន់តែច្រើន។ រាល់ទង្វើ និងការចែកចាយរូបភាពកុមាររងគ្រោះម្តងនៅលើប្រព័ន្ធអ៊ីនធឺណិត គឺធ្វើឱ្យមានភាពឈឺចាប់តានតឹងបន្ថែមទៀត។
- **បញ្ហាសង្គម៖** កុមារដែលជាករណីប៉ះពាល់ដោយ OCSEA មានប្រតិកម្មខ្លាំងដល់ជីវិតសង្គមរបស់ពួកគេ។ ពួកគេអាចមានការភ័យខ្លាចក្នុងការទំនាក់ទំនងជាមួយមិត្តភក្តិ ក្រុមគ្រួសារ ឬបុគ្គលជាសាធារណៈ បណ្តាលឱ្យមានភាពឯកាសង្គម និងធ្វើឱ្យពួកគេឈប់ចូលរួមក្នុងសកម្មភាពកម្សាន្តផ្សេងៗ។ កុមារដែលទទួលរងនូវការកេងប្រវ័ញ្ច និងរំលោភបំពានលើប្រព័ន្ធអនឡាញ អាចដកខ្លួនចេញកាន់តែឆ្ងាយពីការចូលរួមក្នុងសង្គមគ្រួសារ សាធារណៈ និងសកម្មភាពអនឡាញដោយឯងផងដែរ។
- **បញ្ហាផ្លូវច្បាប់៖** ការផលិត និងការចែកចាយ CSAM (រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ) គឺជាការប្រព្រឹត្តដែលប្រឈមនឹងការមានទោសធ្ងន់។
- **បញ្ហាសុខភាព៖** កុមាររងរងគ្រោះ អាចប្រឈមនឹងសុខភាពផ្លូវចិត្ត និងសុខភាពរាងកាយ។

សរុបសេចក្ដីមកនៅមេរៀននេះ អ្នកបានយល់ដឹងពីភាពខុសគ្នា CSACSEOCSEA តាមរយៈការកំណត់និយមន័យ និងរៀនសម្គាល់នូវឥរិយាបថ ការប្រព្រឹត្ត និងសកម្មភាពរបស់ជនល្មើសដែលត្រូវតាមនិយមន័យនីមួយៗ។ លើសពីនេះទៀត អ្នកនឹងស្វែងយល់ពីទំនាក់ទំនងរវាង OCSEA និង CSEA ព្រមទាំងរៀនចេះសម្គាល់យ៉ាងច្បាស់លាស់នូវឥរិយាបថ ការប្រព្រឹត្ត និងសកម្មភាពដែលត្រូវបានចាត់ទុកថាជា OCSEA ដែលប្រព្រឹត្តដោយអ្នកណាម្នាក់ ឬជនណាមួយតាមរយៈឧទាហរណ៍ករណីសិក្សានីមួយៗ។

ពេលនេះ ក្នុងនាមជាមន្ត្រីនគរបាល មានសមត្ថភាព អាចធ្វើការស៊ើបអង្កេត និងគាំទ្រកុមារ ដែលរងផលប៉ះពាល់ដោយ OCSEA ពីព្រោះអ្នកបានយល់ដឹងពីរបៀបដែលការរំលោភបំពាន និងការកេងប្រវ័ញ្ច អ្នកអាចពិចារណាបានថាតើធាតុផ្សំណាមួយកើតឡើងក្នុង ឬក្រៅប្រព័ន្ធអនឡាញ ឬជាករណីដែលកើតឡើងអន្តរកម្មទៅវិញទៅមក។



មេរៀនទី៤៖

# មាត្រាច្បាប់ និងសូចនាករពាក់ព័ន្ធនឹងការកេងប្រវញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

តាមរយៈមេរៀនមុនៗ និងរបកគំហើញនៃការសិក្សាស្រាវជ្រាវជាច្រើន យើងបានដឹងថា ក្នុងចំណោមអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត កុមារជាជនដែលងាយរងគ្រោះជាងគេ។ នៅលើអនឡាញ កុមារអាចងាយប្រឈមទៅនឹងការកេងប្រវញ្ច រំលោភបំពាន ធ្វើបាប សម្លុតគំរាមកំហែង លួងលោមតាមអនឡាញ ចែករំលែករូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទ ហើយកុមារក៏ងាយនឹងធ្វើតាមឥរិយាបថមិនល្អ ជាដើម។ ដើម្បីចូលរួមទប់ស្កាត់ និងកាត់បន្ថយបញ្ហាប្រឈមដែលបានរៀបរាប់មកនេះ រាជរដ្ឋាភិបាលបានរៀបចំបង្កើត និងអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ និងយន្តការជាច្រើន រួមមានទាំងការអនុវត្តច្បាប់ ការលើកកម្ពស់ការយល់ដឹង និងការលើកទឹកចិត្តឱ្យភាគីពាក់ព័ន្ធចូលរួមនៅក្នុងកិច្ចការពារកុមារ ជាពិសេសឳពុកម្ដាយ អាណាព្យាបាល គ្រូបង្រៀន អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋនៅក្នុងសហគមន៍នានា។

ឥឡូវនេះ អ្នកយល់កាន់តែច្បាស់អំពីប្រភេទនៃសកម្មភាព ឥរិយាបថ និងការប្រព្រឹត្តណាខ្លះ ដែលត្រូវបានចាត់ទុកថាជា OCSEA។ តទៅនេះអ្នកស្វែងយល់បន្ថែមទៀត អំពីផ្នែកច្បាប់ដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយសម្រួលដល់ការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ និងការស្តារឡើងវិញនូវកុមារដែលរងផលប៉ះពាល់ដោយ OCSEA។

ថ្វីត្បិតប្រទេសកម្ពុជាមិនទាន់មានច្បាប់ដោយឡែកស្តីពី OCSEA យើងមានមាត្រាជាច្រើននៅក្នុងក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឯកសារគតិយុត្តក្របខណ្ឌគោលនយោបាយជាតិជាច្រើន សម្រាប់ឆ្លើយតបទៅនឹងបរិបទនាពេលបច្ចុប្បន្ន។

យើងត្រូវយល់ដឹងអំពីច្បាប់ និងក្របខណ្ឌគោលនយោបាយជាតិ អន្តរជាតិ ទាំងឡាយដែលពាក់ព័ន្ធនឹងការការពារកុមារ ដើម្បីធានានូវកិច្ចគាំពារគ្រប់គ្រាន់ដល់កុមាររងគ្រោះ និងការទទួលបាននូវការសង្គ្រោះ និងអន្តរាគមន៍ផ្សេងៗបានទាន់ពេលវេលា ដូចជាការស្តានីតិសម្បទា ការប្រឹក្សាយោបល់ជម្រកសុវត្ថិភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាដើម។ សកម្មភាពមន្ត្រីនគរបាល ជាការអនុវត្តច្បាប់ដែលរួមចំណែកដ៏សំខាន់ទៅដល់កិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់បទល្មើសរបស់អាជ្ញាធរផងដែរ។



ឥរិយាបថ សកម្មភាព ឬការប្រព្រឹត្តដែលពាក់ព័ន្ធនឹង OCSEA ដែលរួមមានបញ្ចូលទាំងការលួងលោមកុមារតាមអនឡាញ ការផលិត ការកាន់កាប់ ឬការចែកចាយរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ និងការគំរាមកំហែងខាងផ្លូវភេទកុមារ។ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏អាចមានជាប់ពាក់ព័ន្ធនឹងមាត្រាខ្លះនៃក្រមព្រហ្មទណ្ឌ (ការបំពានឯកជនភាព ការចែកចាយពីរូបភាពរបស់បុគ្គលដែលត្រូវបានថតទុក) ក៏អាចត្រូវបានកាត់ទោសផងដែរ។

## ក ការគាំទ្រផ្លូវច្បាប់

ផ្នែកច្បាប់ដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវការធានាមួយដល់ការការពារ និងគាំទ្រដល់ជនរងគ្រោះ។ វាជួយគាំពារជនរងគ្រោះ ទទួលបាននូវការសង្គ្រោះ និងបទអន្តរាគមន៍ផ្សេងៗបានទាន់ពេលវេលា ដូចជា ការស្តានីតិសម្បទា ទទួលបានការព្យាបាលពីអ្នកជំនាញ ការប្រឹក្សាយោបល់ជម្រកសុវត្ថិភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។ ការអនុវត្តច្បាប់ក៏រួមចំណែកដ៏សំខាន់ទៅដល់កិច្ចខិតខំប្រឹងប្រែងបង្ការទប់ស្កាត់បទល្មើសរបស់អាជ្ញាធរផងដែរ។

ប្រសិនបើកុមារត្រូវបានគេកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ ហើយត្រូវការជំនួយផ្នែកច្បាប់ នេះគឺជាជំហាន មួយចំនួន ដែលពួកគេអាចអនុវត្តបាន៖

- **ជំរុញឱ្យកុមាររាយការណ៍ទៅលើវេទិកាដែលខ្លួនកំពុងប្រើ៖** ការរាយការណ៍ពីអាកប្បកិរិយាមិនសមរម្យ ឬគួរឱ្យសង្ស័យណាមួយនៅលើអនឡាញ អាចធ្វើឱ្យកុមារមានសុវត្ថិភាព និងជួយទប់ស្កាត់គ្រោះថ្នាក់ណាមួយចំពោះអ្នកដទៃ។ វេទិកាភាគច្រើនមានមុខងារ រាយការណ៍ដើម្បីដោះស្រាយបញ្ហាបែបនេះ ហើយអ្នកគួរប្រើមុខងារទាំងនោះ ដើម្បីរាយការណ៍ករណីណាមួយនៃការកេងប្រវ័ញ្ចផ្លូវភេទ ឬការរុកកួនឆាឆៅតាមអនឡាញ។ ហេតុអ្វីបានជាអ្នកគួររាយការណ៍? ការរាយការណ៍គឺជាវិធីមួយបានបង្កើនលទ្ធភាពនៃការលុបបំបាត់មាតិការំលោភបំពានពីគេហទំព័រ និងជួយបញ្ឈប់ការរំលោភបំពានដោយផ្ទាល់ និងលើប្រព័ន្ធអនឡាញ។ វេទិកា និងកម្មវិធីបណ្តាញទំនាក់ទំនងសង្គមភាគច្រើនមានឧបករណ៍ ឬមុខងាររាយការណ៍នៅក្នុងនោះប្រសិនបើអ្នកឃើញមាតិកាផ្លូវភេទ ឬមិនសមរម្យនៅលើអនឡាញ ឬមានអារម្មណ៍ថា កុមារ អាចស្ថិតនៅក្នុងស្ថានភាពមួយដែលធ្វើឱ្យពួកគេជួបគ្រោះថ្នាក់នៅលើអនឡាញ អ្នកត្រូវដឹងអំពីទីកន្លែង ដើម្បី រាយការណ៍អំពីបញ្ហាទាំងនោះ។
- **ជំរុញឱ្យកុមារ និងគ្រួសារទាក់ទងមន្ត្រីនគរបាល៖** រាយការណ៍អំពីការកេងប្រវ័ញ្ចលើអ៊ីនធឺណិតទៅមន្ត្រីនគរបាលក្នុងតំបន់ ឬមូលដ្ឋានរបស់អ្នក។ មន្ត្រីនគរបាលដែលមានសមត្ថកិច្ចនឹងស៊ើបអង្កេត ព្រមទាំងចាត់វិធានការចំពោះជនល្មើស។ អ្នកគួរ/ត្រូវផ្តល់ឱ្យពួកគេនូវភស្តុតាង ឬព័ត៌មានណាមួយដែលអ្នកមាន ដូចជារូបថតអេក្រង់ (Screenshot) ឬសារជាដើម។
- **ជំរុញលើកទឹកចិត្តឱ្យកុមារនិយាយជាមួយមនុស្សពេញវ័យដែលខ្លួនអាចទុកចិត្តបាន៖** ទាក់ទងមនុស្សពេញវ័យណាម្នាក់ដែលគួរឱ្យទុកចិត្ត ដូចជាឪពុកម្តាយ អាណាព្យាបាល គ្រូបង្រៀន ឬអ្នកប្រឹក្សាយោបល់ជាដើម។ ប្រាប់ពួកគេអំពីរឿងរ៉ាវនៃការកេងប្រវ័ញ្ច ហើយអ្នកត្រូវការជំនួយផ្នែកច្បាប់។ ពួកគេអាចណែនាំអ្នកអំពីដំណើរការ និងជួយអ្នកស្វែងរកជំនួយផ្នែកច្បាប់ត្រឹមត្រូវ។

- **ជំរុញឱ្យចូលរួមជាមួយមេធាវី៖** ស្វែងរកជំនួយពីមេធាវីដែលមានជំនាញក្នុងការការពារករណីពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើអ៊ីនធឺណិត ឬជំនាញការការពារកុមារ។ មនុស្សពេញវ័យដែលជឿទុកចិត្តរបស់អ្នកអាចជួយអ្នកស្វែងរកមេធាវីដែលអាចផ្តល់ដំបូន្មានផ្នែកច្បាប់ និងតំណាងឱ្យផលប្រយោជន៍របស់អ្នកក្នុងដំណើរការផ្លូវច្បាប់។
- **រក្សាឯកសារភស្តុតាង៖** រក្សាទុកភស្តុតាងដែលទាក់ទងនឹងការកេងប្រវ័ញ្ចលើប្រព័ន្ធអនឡាញ។ ភស្តុតាងអាចរួមបញ្ចូលរូបថតអេក្រង់ (Screenshot) សារ ឬទម្រង់ទំនាក់ទំនងណាមួយផ្សេងទៀត។ មេធាវីរបស់អ្នកនឹងត្រូវការភស្តុតាងទាំងនោះ ដើម្បី ប្រឆាំងនឹងជនល្មើស។

### ពាក្យគន្លឹះ

- **គណនី (Account)៖** សំដៅដល់ព័ត៌មានផ្ទាល់ខ្លួន ដែលបានបង្កើតលើប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ក្នុងបណ្តាញទំនាក់ទំនង។
- **សុវត្ថិភាព (Safety)៖** សុវត្ថិភាពសំដៅដល់ការរក្សាបានភាពសុខសាន្តក្នុងពេលប្រើប្រាស់បច្ចេកវិទ្យា។
- **ការរាំងខ្ទប់ (Block)៖** សំដៅទៅដល់ការបិទសកម្មភាពរបស់ជនណាម្នាក់ដែលមានបំណងមិនត្រឹមត្រូវបៀតបៀនមកលើគណនីរបស់ខ្លួន។

## ២ មាត្រាច្បាប់ពាក់ព័ន្ធកម្ពុជាពាក់ព័ន្ធនឹង OCSEA

ខាងក្រោមនេះ គឺទម្រង់ជាតារាង និងផ្តល់នូវខ្លឹមសារសង្ខេបនៃមាត្រាច្បាប់នៅកម្ពុជា ដែលពាក់ព័ន្ធខ្លះៗទៅនឹង OCSEA នៅក្នុងប្រទេស កម្ពុជា។

**សូមចំណាំថា៖** តារាង និងសេចក្តីសង្ខេបនេះ រៀបរៀងនៅអំឡុង (ខែឧសភា ឆ្នាំ២០២៣) ដូច្នេះសម្រាប់ឯកសារគតិយុត្តថ្មីៗ ដែលចេញក្រោយនេះ អាចនឹងមិនមាននៅក្នុងតារាងសង្ខេបនេះទេ។

ផ្នែកនៃច្បាប់កម្ពុជាដែលពាក់ព័ន្ធខ្លាំងបំផុតនឹងការកេងប្រវ័ញ្ចផ្លូវភេទជាទូទៅ ដែលរួមបញ្ចូលទាំងបទឧក្រិដ្ឋ នៃ OCSEA គឺមានច្បាប់ស្តីពី ការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។ បន្ថែមលើនេះទៀត ក្រមព្រហ្មទណ្ឌក៏ដាក់ទោសបទល្មើសមួយចំនួនទាក់ទងនឹង OCSEA ដែរ។

សូមចំណាំថា បទប្បញ្ញត្តិច្បាប់ថ្មីៗនៅក្នុងសេចក្តីព្រាងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា ដែលកំពុងត្រូវបានរៀបចំឡើង អាចនឹងបំពេញបន្ថែមលើការការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ។ ក្នុងនោះក៏មានក្នុងមាត្រាខ្លះនៃ ក្រមព្រហ្មទណ្ឌផងដែរ ដើម្បីដាក់ទោសឧក្រិដ្ឋកម្មនៃការរំលោភបំពានផ្លូវភេទដែលមិនពាក់ព័ន្ធលើរូបរាងកាយ។ នៅពេលដែលការកែប្រែទាំងនោះត្រូវបានធ្វើឡើង នោះក៏មានឆ្លុះបញ្ចាំងនៅក្នុងឯកសារនេះដែរ។

| តើវិយាបថពាក់ព័ន្ធនឹង OCSEA | តើមានមាត្រាច្បាប់នៅកម្ពុជាចែងដូចម្ដេច? | កំណត់សម្គាល់បន្ថែម |
|---|---|---|
| ការលួងលោមកុមារលើប្រព័ន្ធអនឡាញ | តាមន័យបច្ចេកទេស នេះមិនទាន់ត្រូវបានដាក់ទោសទណ្ឌទេ។<br>ទោះបីជាក្រមព្រហ្មទណ្ឌមិនមានចែងពីការលួងលោមកុមារលើប្រព័ន្ធអនឡាញ សម្រាប់គោលបំណងផ្លូវភេទ (ការលួងលោមលើប្រព័ន្ធអនឡាញ) ថាជាបទល្មើសក៏ដោយក្ដី ក៏ច្បាប់នេះដាក់ទោសលើ «អំពើរបស់នីតិជនដែលរៀបចំការជួបជុំដែលរួមមានការបង្ហាញភេទ ឬមានទំនាក់ទំនងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬចូលរួមផងនោះ» តាមមាត្រា៣៤៦។ | ទោះបីជាមានការដាក់ទោសទណ្ឌលើលទ្ធផលដែលអាចកើតមានចេញពីដំណើរការលួងលោម (ឧទាហរណ៍ការចូលរួមក្នុងសកម្មភាពផ្លូវភេទក្នុងអំឡុងពេលជួបដោយផ្ទាល់)-បទប្បញ្ញត្តិបច្ចុប្បន្នមិនបានដាក់ទោសទណ្ឌលើដំណើរការកសាងទំនុកចិត្តរវាងជនល្មើស និងកុមារ ក៏ដូចជាស្ថានភាពដែលការរំលោភបំពានផ្លូវភេទកើតឡើងតាមអ៊ីនធឺណិតនៅឡើយ។(ឧទាហរណ៍ ប្រសិនបើកុមារត្រូវបានស្នើសុំឱ្យផ្ញើខ្លឹមសារផ្លូវភេទទៅកាន់ជនល្មើសតាមរយៈវេទិកាអនឡាញ)។<br>**ច្បាប់នាពេលអនាគត៖** ច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា ត្រូវបានគេរំពឹងថានឹងដាក់ទោសទណ្ឌលើការលួងលោមកុមារសម្រាប់គោលបំណងផ្លូវភេទ (ជារឿយៗហៅថា «ការអូសទាញ» នៅក្នុងច្បាប់) រួមទាំងតាមរយៈអ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថលទំនាក់ទំនងផ្សេងទៀត ដើម្បីជួយសម្រួលដល់ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិត ឬក្រៅអ៊ីនធឺណិត។<br>ការលួងលោម កុមារក្នុងគោលបំណងផ្លូវភេទ៖ សេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារឆ្នាំ ២០២២៖<br>ការលួងលោម ដូចដែលបានកំណត់នៅក្នុងសេចក្ដីព្រាងច្បាប់ស្តីពីការការពារកុមារ សំដៅលើថាតាមអ៊ីនធឺណិត ឬក្រៅបណ្ដាញអ៊ីនធឺណិត ការរាប់អានកុមារ ឬសមាជិកផ្សេងទៀតនៃគ្រួសារកុមារ និងការកសាងទំនុកចិត្តរបស់ពួកគេដោយចេតនាកេងប្រវ័ញ្ចកុមារ និងបង្កគ្រោះថ្នាក់ដល់ពួកគេ។ នៅពេលអនុម័តច្បាប់នឹងហាមប្រាមបុគ្គលម្នាក់មិនឱ្យប្រាស្រ័យទាក់ទងគ្នាតាមរយៈមធ្យោបាយអេឡិចត្រូនិក ដើម្បី (ក) បោកបញ្ឆោត បង្ខំ ឬដាក់សម្ពាធលើកុមារឱ្យចូលរួមក្នុងអំពើផ្លូវភេទ។ ឬ (ខ) បង្កើតទំនាក់ទំនងសម្រាប់គោលបំណងបែបនេះ។ |

| តើឥរិយាបថពាក់ព័ន្ធនឹង OCSEA | តើមានមាត្រាច្បាប់នៅកម្ពុជាចែងដូចម្តេច? | កំណត់សម្គាល់បន្ថែម |
|---|---|---|
| ការផលិត ការកាន់កាប់ ឬការចែកចាយ CSAM | នៅក្នុងបរិបទកម្ពុជា ការកាន់កាប់មិនមែនជាបទឧក្រិដ្ឋទេ។ ប៉ុន្តែការផលិត និងការចែកចាយ គឺជាបទឧក្រិដ្ឋ។ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ<br>មាត្រា ៣៩៖ រូបភាព និងសម្ភារៈអាសអាភាស នៃច្បាប់ស្តីពីការបង្ក្រាប ។ល។<br>ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ថ្ងៃ ទៅ ១ខែ និងពិន័យជាប្រាក់ពី ១០០.០០០រៀល ទៅ ២០០.០០០រៀល។<br>ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាស អាភាសន៍ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ខាងលើ។<br>ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែដល់១ឆ្នាំ និងពិន័យជាប្រាក់ពី២០០.០០០ទៅ ២.០០០.០០០លានរៀល។ | **ច្បាប់ដែលអាចមាននាពេលអនាគត៖**<br>សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារ លើ CSAM ឆ្នាំ ២០២២<br>និយមន័យ «ការតំណាងណាមួយ ទោះជាដោយមធ្យោបាយណាក៏ដោយ របស់កុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ឬប្រដូច ឬការតំណាងឱ្យផ្នែកផ្លូវភេទរបស់កុមារ សម្រាប់គោលដៅផ្លូវភេទជាចម្បង រួមទាំងការផ្សាយបន្តផ្ទាល់» |

| ឥរិយាបថពាក់ព័ន្ធនឹង OCSEA | តើមានមាត្រាច្បាប់នៅកម្ពុជាចែងដូចម្តេច? | កំណត់សម្គាល់បន្ថែម |
|---|---|---|
| ការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ | តាមន័យបច្ចេកទេស នេះមិនទាន់ត្រូវបានដាក់ទោសទណ្ឌទេ។ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ក៏ដូចជាក្រមព្រហ្មទណ្ឌ មិនទាន់មានមាត្រាជាក់លាក់ក្នុងការដាក់ទោសទណ្ឌលើការគំរាមកំហែងខាងផ្លូវភេទលើកុមារតាមអ៊ីនធឺណិត និងការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទលើកុមារទេ។ | **ច្បាប់នាពេលអនាគត៖**<br>សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មអ៊ីនធឺណិត៖ ការតំណាងណាក៏ដោយ តាមមធ្យោបាយណាក៏ដោយ កុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ឬប្រដូច ឬតំណាងឱ្យផ្នែកផ្លូវភេទរបស់កុមារសម្រាប់គោលបំណងផ្លូវភេទជាចម្បង រួមទាំងការផ្សាយបន្តផ្ទាល់។ |
| ការចែករំលែកខ្លឹមសារពាក់ព័ន្ធនឹងភេទ ឬរូបភាពអាសអាភាសរបស់ពួកគេដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ | មិនមែនជាបទឧក្រិដ្ឋសម្រាប់យុវជនពីរនាក់ក្នុងការចែករំលែករវាងខ្លួនគេទេ ប៉ុន្តែក្លាយជាបទឧក្រិដ្ឋប្រសិនបើអ្នកណាម្នាក់ប្រើវាដើម្បីជំរិតទារ ឬគំរាមកំហែង ឬបៀតបៀន។<br>ក្រមព្រហ្មទណ្ឌ មាត្រា ៣០២ (ការបំពានឯកជនភាព ការចែកចាយពីរូបភាពរបស់បុគ្គលម្នាក់ដែលត្រូវបានថតទុក) ក៏អាចត្រូវបានកាត់ទោសផងដែរ យោងទៅតាមការចែកចាយរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ CSAM (សូមមើលខាងលើ) ឬការបៀតបៀនផ្លូវភេទ។ (សូមមើលខាងក្រោម) | រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទរបស់កុមារ «ដែលបង្កើតដោយខ្លួនឯង» គឺជាបញ្ហាដែលកំពុងកើនឡើងសម្រាប់សុវត្ថិភាពរបស់កុមារនៅលើអ៊ីនធឺណិត។ វាគឺជាពេលដែលកុមារ និងយុវវ័យថតរូប និង វីដេអូដោយប្រើស្មាតហ្វូន ឬកាមេរ៉ាកុំព្យូទ័រ ហើយបន្ទាប់មកចែករំលែកវានៅលើវេទិកាអនឡាញ។ ខណៈពេលដែលវាអាចជាទម្រង់នៃការបញ្ចេញមតិសម្រាប់កុមារមួយចំនួន វាក៏មានភ្ជាប់មកជាមួយនូវហានិភ័យជាច្រើននៃការរំលោភបំពាន និងការកេងប្រវ័ញ្ចលើអ៊ីនធឺណិត។<br>កុមារអាចត្រូវបានលួងលោម បោកបញ្ឆោត ឬជំរិតបង្ខំឱ្យផលិត និងចែកចាយរូបភាព ឬវីដេអូផ្លូវភេទរបស់ពួកគេ ជារឿយៗដោយនរណាម្នាក់នៅលើអ៊ីនធឺណិត។ រូបភាពអាចនឹងត្រូវបានប្រើប្រាស់ដើម្បីបង្ខិតបង្ខំ ឬគំរាមរកប្រយោជន៍ពីកុមារបន្ថែមទៀត ហើយអាចត្រូវបានប្រើប្រាស់ខុស ឬផ្សព្វផ្សាយដោយគ្មានការយល់ព្រម។<br>នៅឆ្នាំ ២០២២ មូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ីនធឺណិតបានរកឃើញមាន ១៩៩.៣៦៣ទំព័រដែលមានរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទរបស់កុមារ «បង្កើតដោយខ្លួនឯង» - ដោយកើនឡើង ៩ ភាគរយពីឆ្នាំ ២០២១។ |

| ឥរិយាបថពាក់ព័ន្ធនឹង OCSEA | តើមានមាត្រាច្បាប់នៅកម្ពុជាចែងដូចម្ដេច? | កំណត់សម្គាល់បន្ថែម |
|---|---|---|
| ការគំរាមកំហែងខាងផ្លូវភេទលើកុមារ | ក្រមព្រហ្មទណ្ឌ<br>ផ្នែកទី៣៖<br>មាត្រា ២៣១ ៖ បទគំរាមកំហែង<br>មាត្រា ២៣២ ៖បទគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ។<br>ពេលខ្លះព្រះរាជអាជ្ញាអាចប្រើមាត្រា៖ ៣៧២ ទាក់ទងនឹងការគំរាមកំហែងហែកកេរ្ដិ៍។ | ទាំងច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ និងក្រមព្រហ្មទណ្ឌដាក់ទោសទណ្ឌលើការជំរិតទារផ្លូវភេទលើប្រព័ន្ធអនឡាញ និង ការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទលើកុមារនៅពេលនេះដែរ។ |
| ការបៀតបៀនផ្លូវភេទលើកុមារ | ក្រមព្រហ្មទណ្ឌ<br>ផ្នែកទី២៖ មាត្រា៖ ២៤៦<br>គ្រប់អំពើប៉ះពាល់ ស្ទាបអង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងតែ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើ តតិយបុគ្គលក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស។<br>អំពើប្រទូស្តកេរខ្មាសត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ (ពីរលាន) រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន) រៀល។ | ក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិដែលកំណត់ឧក្រិដ្ឋកម្មលើការបៀតបៀនផ្លូវភេទ ទោះបីជាមិនជាក់លាក់ថានៅលើប្រព័ន្ធអនឡាញ ឬប្រឆាំងនឹងកុមារក៏ដោយ។<br>ទោសនៃឧក្រិដ្ឋកម្មនេះ (ដាក់ពន្ធនាគារពីប្រាំមួយថ្ងៃទៅបីខែ និងពិន័យជាប្រាក់ពី ១០,០០០ រៀល ទៅ ៥០០,០០០ រៀល ស្មើនឹងចន្លោះពី ២,៥០ ទៅ ១២៥ ដុល្លារអាមេរិក)មិនឆ្លុះបញ្ចាំងពី លក្ខណៈធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ជាពិសេសនៅពេលប្រព្រឹត្តលើកុមារ។ |

| ឥរិយាបថពាក់ព័ន្ធនឹង OCSEA | តើមានមាត្រាច្បាប់នៅកម្ពុជាចែងដូចម្តេច? | កំណត់សម្គាល់បន្ថែម |
|---|---|---|
| ការប៉ះពាល់ ឬការបៀតបៀនផ្លូវភេទលើកុមារ | នេះអាស្រ័យលើចេតនានៃគោលបំណងនៃការចែករំលែក តម្រូវឱ្យបញ្ជាក់ថា វាសម្រាប់គោលបំណងផ្លូវភេទ។ (ឧ. ប្រើដើម្បីល្បួង ឬលួងលោមកុមារ ឬយុវជន)<br>ក្រមព្រហ្មទណ្ឌ៖ ឯកសារយោងនៅក្នុងក្រមព្រហ្មទណ្ឌចែងថា (មាត្រា៤៖ ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។)<br>ប៉ុន្តែ ក្នុងករណីដែលច្បាប់ចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។ | ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ៖ មាត្រា៤១ - រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ<br>ជនណាចែកចាយ លក់ ជួល ដាក់តាំងបញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ (បួនលាន) រៀល ដល់ ១០,០០០,០០០ (ដប់លាន) រៀល។<br>ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើត្រូវផ្តន្ទាទោសដូចគ្នា។<br>ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ដល់ ១០ (ដប់) ឆ្នាំ។<br>ជនណាផលិត រូបភាព និង សម្ភារៈអាសអាភាសនៃកុមារក្នុងគោលដៅយកទៅប្រើនៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ និងទី២ ខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ។ |

## គ កំណាត់សម្គាល់ពិសេស

- ផ្នែកពាក់ព័ន្ធបំផុតនៃច្បាប់កម្ពុជាស្តីពីការកេងប្រវ័ញ្ចផ្លូវភេទជាទូទៅ ដែលរួមបញ្ចូលឧក្រិដ្ឋកម្ម OCSEA គឺច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨។ លើសពីនេះ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់បទល្មើសមួយចំនួនទាក់ទងនឹង OCSEA ផងដែរ។

- លើសពីនេះ សេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងសេចក្តីព្រាងច្បាប់ស្តីពីប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន រួមជាមួយនឹង ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវឧបករណ៍នីតិប្បញ្ញត្តិជាតិសំខាន់ៗ។

- នៅពេលដែលសេចក្តីព្រាងច្បាប់ត្រូវបានឱ្យសច្ចានុម័ត និងដាក់ឱ្យដំណើរការ ឯកសារបណ្តុះបណ្តាលនឹងត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍ទាំងនោះ។

- នៅថ្នាក់តំបន់ ផែនការសកម្មភាពក្នុងតំបន់អាស៊ាន ដើម្បីការពារកុមារទាំងអស់ពីការកេងប្រវ័ញ្ច និងការរំលោភបំពានលើប្រព័ន្ធអនឡាញ រៀបរាប់លម្អិតយ៉ាងច្បាស់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងមន្ត្រីនគរបាល និងក្របខ័ណ្ឌការពារកុមារលើប្រព័ន្ធអនឡាញរបស់ ITU/ASEAN ផងដែរ។

- នៅកម្រិតថ្នាក់ជាតិ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានកុមារលើប្រព័ន្ធអនឡាញ និងផែនការអនុវត្តយុទ្ធសាស្ត្រការការពារកុមារកម្ពុជាឆ្នាំ២០២២-២០២៦ (កំពុងព្រាង) មានឯកសារយោងលើតួនាទីនៃការអនុវត្តច្បាប់។

ទោះបីជាប្រទេសកម្ពុជាយើងមិនទាន់មានច្បាប់ដោយឡែកស្តីពី OCSEA តែយើងមានមាត្រាជាច្រើន ដូចជា ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ។ ពេលអនាគតយើងនឹងមានច្បាប់មួយចំនួនដែលកំពុងតែស្ថិតនៅក្នុងសេចក្តីព្រាងដូចជា ច្បាប់ការពារកុមារ និងសេចក្តីព្រាងច្បាប់ស្តីពីប្រឆាំងបទល្មើស បច្ចេកវិទ្យាព័ត៌មាន រួមជាមួយនឹង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវឧបករណ៍នីតិប្បញ្ញត្តិជាតិសំខាន់ៗ។

មេរៀនទី៥៖

# សិទ្ធិកុមារនៅក្នុងពិភពឌីជីថល

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើកិច្ចការពារកុមារទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ច និងរំលោភបំពានលើកុមារនៅគ្រប់ស្ថានភាព និងបរិបទ។ កិច្ចការពារកុមារនៅក្នុងបរិបទឌីជីថល ជាបញ្ហាស្មុគស្មាញ ដើម្បីសម្របសម្រួល និងទទួលខុសត្រូវភាគីជាច្រើនទាំងរដ្ឋាភិបាល និងវិស័យឯកជន។ ស្ថាប័នដែលដើរតួនាទីសំខាន់ក្នុងកិច្ចការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារដូចជា ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធកំពុងជំរុញការអនុវត្តកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ គឺជាការទប់ស្កាត់ និងឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃអំពើហិង្សា កេងប្រវ័ញ្ច និងរំលោភបំពាននៅក្នុងលំហឌីជីថល។ យើងទាំងអស់គ្នាទទួលស្គាល់ថា អ្វីដែលកើតឡើងនៅលើអនឡាញ មិនមែនត្រឹមតែមាននៅក្នុងលំហឌីជីថលទេ ប៉ុន្តែវាមានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយនឹងអ្វីដែលកើតឡើងនៅក្រៅប្រព័ន្ធអនឡាញ។ ដូចដែលយើងបានសិក្សាមេរៀនមុនៗរួចមក ហើយ ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាឌីជីថល ភ្ជាប់ជាមួយពិភពលំហឌីជីថល ពិភពអ៊ីនធឺណិតដ៏ធំទូលំទូលាយឥតដែនកំណត់ បានបង្កគ្រោះហានិភ័យជាខ្លាំងសម្រាប់កុមារ។ នេះមានន័យថាយើងទាំងអស់គ្នាដែលជាមនុស្សពេញវ័យ ដែលជាអ្នកមានសិទ្ធិ និងកាតព្វកិច្ចការពារកុមារមិនទាន់បានធានានូវសុវត្ថិភាពគ្រប់គ្រាន់សម្រាប់កុមារទាំងអស់នៅលើអ៊ីនធឺណិត។ យើងទាំងអស់គ្នាត្រូវតែរួមគ្នា ដើម្បីបង្កើតកន្លែងអ៊ីនធឺណិតដែលមានសុវត្ថិភាពជាងមុនសម្រាប់កុមាររបស់យើង ក្នុងការប្រើប្រាស់អ៊ីនធឺណិតឱ្យបានត្រឹមត្រូវដូចជាការទាក់ទងគ្នាជាមួយគ្រួសារ មិត្តភក្តិ និងគ្រូបង្រៀន និងការរុករកក្នុងការរៀនសូត្រ។

ក្នុងនាមជាមន្ត្រីនគរបាល យើងមានតួនាទីយ៉ាងសំខាន់ក្នុងការការពារ និងលើកកម្ពស់សិទ្ធិកុមារក្នុងគ្រប់ទិដ្ឋភាពនៃការងាររបស់ពួកយើង។ វាមិនជារឿងងាយស្រួលក្នុងការអនុវត្តនោះទេ ប៉ុន្តែវាជារឿងដែលចាំបាច់ខ្លាំងណាស់។ កុមារ និងយុវជនដែលទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ចបាត់បង់សិទ្ធិរបស់ពួកគេ ហើយពិបាកនឹងជឿទុកចិត្តលើបុគ្គលណាម្នាក់ រួមទាំងមន្ត្រីនគរបាលផងដែរ។ តាមរយៈវិធីសាស្ត្រដោយផ្អែកលើសិទ្ធិ ការគោរព និងការលើកកម្ពស់សិទ្ធិរបស់ពួកគេ យើងកសាង

ទំនុកចិត្ត ជាមួយកុមាររងគ្រោះ សាក្សី និងក្រុមគ្រួសាររបស់ពួកគេបាន។ ប្រសិនបើយើងបង្កើន ទំនុកចិត្តពួកគេកាន់តែខ្លាំងជាងមុន នោះកុមាររងគ្រោះនឹងមានអារម្មណ៍ថាមានសុវត្ថិភាពជាងមុន។ ការណ៍នេះនឹងនាំឱ្យមានកិច្ចសហការ និងកិច្ចសហការកាន់តែប្រសើរឡើង ហើយការរាយការណ៍ និង ភស្តុតាងដែលពួកគេផ្តល់ឱ្យនឹង កាន់តែប្រសើរជាងមុនផងដែរ។

ការស្វែងយល់អំពីអនុសញ្ញាស្តីពីសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ គឺជាកិច្ចព្រមព្រៀងដ៏សំខាន់ របស់ប្រទេសជាហត្ថលេខីដែលបានសន្យាការពារសិទ្ធិរបស់កុមារ ដែលមានចែងទាំង៥៤មាត្រានឹង ជួយឱ្យមន្ត្រីនគរបាលមានមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ ក្នុងការលើកកម្ពស់សិទ្ធិកុមារក៏ដូចជាធ្វើបទអន្តរាគមន៍ ការឆ្លើយតបទៅបទល្មើសដែលរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ។ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅក្នុងឆ្នាំ១៩៩២ ព្រមទាំងបានផ្តល់ សច្ចាប័ន ដល់អនុសញ្ញានេះនៅក្នុងឆ្នាំនោះផងដែរ។ នេះមានន័យថា ប្រទេសកម្ពុជាយើងបាន យល់ព្រមទទួលយកអនុសញ្ញានេះមកអនុវត្តជាផ្លូវការនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ កុមារក៏ដូច មនុស្សគ្រប់រូបដែរ តែងមានសិទ្ធិ ដូចនេះសិទ្ធិ គឺអ្វីៗដែលមនុស្សត្រូវការចាំបាច់ ដើម្បីរស់នៅឱ្យបាន សមរម្យ និងថ្លៃថ្នូរ។ សិទ្ធិមនុស្ស គឺជាអំណាចស្របច្បាប់ ដែលមនុស្សមានជាស្រេចតាំងពីកំណើត មក។ ពោលជីវិតមនុស្សយើងគឺមានសេរីភាព ដែលមិនអាចដកហូតបាន។ ដូចនេះ កុមារមានសិទ្ធិ ដែលអភិវឌ្ឍន៍ស្របតាមវ័យរបស់ពួកគេ។ សិទ្ធិចំបងៗរបស់កុមារ រួមមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិ ក្នុងការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិក្នុងការចូលរួមជាដើម។

មាត្រា៤៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា «មាតាបិតាមានកាតព្វកិច្ច ចិញ្ចឹម ថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ»។ កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សា មាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ»។ មាត្រា៤៨ បានចែងថា «រដ្ឋធានាការពារសិទ្ធិ របស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការ អប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍សង្គ្រាម និងការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ»។ «រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយណា ដែលអាចធ្វើឱ្យខូច ដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពកុមារ»។

នៅក្នុងបរិបទឌីជីថលមានន័យថា កុមារមានសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ច និង រំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) និងគ្រប់ទម្រង់នៃអំពើហិង្សាដែល សម្របសម្រួលដោយបច្ចេកវិទ្យា ដោយគ្មានការនិយាយអំពីសិទ្ធិរបស់កុមារ។ ការប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យានៅក្នុងជីវិតរបស់កុមារកាន់តែសំខាន់ឡើងៗ និងឱកាសដែលវាផ្តល់ឱ្យ មានន័យថា

ខណៈពេលដែលជានាថាកុមារត្រូវបានការពារលើប្រព័ន្ធអនឡាញ ឱកាសពេញលេញដែលពិភពឌីជីថលបង្ហាញដល់កុមារ មិនត្រូវបានកំណត់ ឬដកចេញពីពួកគេនោះទេ។ ជាឧទាហរណ៍ សិទ្ធិទទួលបានសុវត្ថិភាពលើប្រព័ន្ធអនឡាញ មិនគួរប៉ះពាល់លើសិទ្ធិទទួលការអប់រំ ព័ត៌មាន ឬការថែទាំសុខភាពនោះទេ ជាឧទាហរណ៍ កុមារទាំងអស់អាចចូលប្រើប្រាស់ប្រព័ន្ធអនឡាញបាន ហើយពឹងផ្អែកលើវា។ ដូចគ្នាដែរ ការស្រាវជ្រាវពីជុំវិញពិភពលោកបានបង្ហាញថា នៅពេលដែលកុមារមិនមានសុវត្ថិភាពលើប្រព័ន្ធអនឡាញ នោះពួកគេមិនអាចដឹងច្បាស់អំពីអត្ថប្រយោជន៍ដែលមានសម្រាប់ពួកគេតាមរយៈអ៊ីនធឺណិត និងបច្ចេកវិទ្យានោះទេ។

## ក ស្វែងយល់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ គឺជាកិច្ចព្រមព្រៀងដ៏សំខាន់របស់ប្រទេសជាហត្ថលេខីដែលបានសន្យាការពារសិទ្ធិរបស់កុមារ

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) ទទួលស្គាល់ថាកុមារត្រូវការជាពិសេសការការពារ និងថែរក្សាគ្រប់ទិដ្ឋភាពនៃជីវិតរបស់ពួកគេ។ អនុសញ្ញារៀបរាប់ពីនរណាជាកុមារ សិទ្ធិដែលពួកគេទទួលបាន និងការទទួលខុសត្រូវនៃរដ្ឋាភិបាល។ សិទ្ធិទាំងអស់គឺពាក់ព័ន្ធគ្នា មានសារៈសំខាន់ដូចគ្នា ហើយមិនអាចយកចេញពីកុមារបាននោះទេ។

អនុសញ្ញាស្តីពីសិទ្ធិកុមារបានដាក់កាតព្វកិច្ចដល់រដ្ឋាភិបាល ដែលរដ្ឋភាគីនីមួយៗនៃអនុសញ្ញាសិទ្ធិកុមារមួយចំនួន អនុម័តច្បាប់ គោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីធានាការអនុវត្ត និងការទទួលបានសិទ្ធិដែលមានចែងក្នុងអនុសញ្ញាសិទ្ធិកុមារ (មាត្រា៤) ចាត់វិធានការច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតឱ្យបានសមស្របទៅ និងកម្រិតអតិបរមានៃធនធានដែលមានរបស់ប្រទេសខ្លួន និងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។ នេះមានន័យថា កំណត់អាទិភាព និងទុកកុមារជាចំបង (មាត្រា៤)។ លើកកម្ពស់ការយល់ដឹងពីអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា៤២) បញ្ជូនរបាយការណ៍ស្តីពីស្ថានភាពរបស់កុមារ និងភាពរីកចម្រើននៃការអនុវត្ត អនុសញ្ញាស្តីពីសិទ្ធិកុមារ ទៅឱ្យគណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ពីរឆ្នាំក្រោយពីការផ្តល់សច្ចាប័នលើអនុសញ្ញានេះ និងរៀងរាល់៥ឆ្នាំម្តងបន្តបន្ទាប់មកទៀត (មាត្រា៤៤)។

អនុសញ្ញានេះ អនុវត្តនៅប្រទេសកម្ពុជា ដែលបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២ ជារដ្ឋភាគីនៃពិធីសារបន្ថែមប្រឆាំងនឹងការជួញដូរកុមារ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០២ និងជារដ្ឋភាគីនៃពិធីសារបន្ថែមស្តីពីការពាក់ព័ន្ធកុមារនៅក្នុងជម្លោះប្រដាប់អាវុធ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦។

មាត្រា៣១នៃរដ្ឋធម្មនុញ្ញធានាការពារអនុសញ្ញានេះ ជាមួយនឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀតថាជាផ្នែកមួយនៃច្បាប់កម្ពុជា។ មាត្រា៤៨ គូសបញ្ជាក់បន្ថែមទៀតថា «រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលបានគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។[7]

## អនុសញ្ញាស្តីពីសិទ្ធិកុមារ៖ ឯកសារសម្រាប់ធ្វើការស្វែងយល់

- **មាត្រា១-និយមន័យកុមារ៖** កុមារសំដៅលើជនទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។
- **មាត្រា២-គ្មានការរើសអើង៖** កុមារគ្រប់គ្នាសុទ្ធតែមានសិទ្ធិទាំងនេះ មិនថាពួកគេជានរណា ពួកគេរស់នៅទីណា ពួកគេនិយាយភាសាអ្វី ពួកគេកាន់សាសនាមួយណា ពួកគេគិតអំពីអ្វី ពួកគេមានរូបរាងបែបណា មិនថាពួកគេជាក្មេងប្រុស ឬក្មេងស្រី មានពិការភាព ឬគ្មានពិការភាព មានជីវភាពក្រីក្រ ឬ-ធូរធារ និងមានថាឪពុកម្ដាយ ឬគ្រួសាររបស់ពួកគេជានរណា ឬថាតើឪពុកម្ដាយ ឬគ្រួសាររបស់ពួកគេជឿលើអ្វី ឬធ្វើអ្វីឡើយ។ មិនគួរមានកុមារណាម្នាក់ គួរត្រូវបានគេប្រតិបត្តិដាក់ដោយមិនត្រឹមត្រូវនោះឡើយ ទោះជាដោយសារមូលហេតុអ្វីក៏ដោយ។
- **មាត្រា៣-ឧត្តមប្រយោជន៍កុមារ៖** នៅពេលដែលមនុស្សពេញវ័យធ្វើសេចក្ដីសម្រេចចិត្ត ពួកគេគួរគិតថាតើការសម្រេចចិត្តរបស់ពួកគេនឹងបង្កផលប៉ះពាល់អ្វីខ្លះដល់កុមារ។ មនុស្សពេញវ័យគ្រប់រូបគួរធ្វើអ្វីៗ ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ រាជរដ្ឋាភិបាលគួរធានាឱ្យកុមារទទួលបានការការពារ និងការថែទាំពីឪពុកម្ដាយរបស់ពួកគេ ឬពីអ្នកផ្សេងទៀត នៅពេលដែលចាំបាច់។ រាជរដ្ឋាភិបាលគួរធានាថា មនុស្ស និងកន្លែងដែលទទួលខុសត្រូវមើលថែទាំកុមារ ពិតជាកំពុងផ្ដល់ការថែទាំដល់កុមារបានល្អ។
- **មាត្រា៤-ការបង្កើតសិទ្ធិពិតប្រាកដ៖** រាជរដ្ឋាភិបាលត្រូវធ្វើអ្វីៗគ្រប់បែបយ៉ាងដែលអាចធ្វើបានដើម្បីធានាថាកុមារគ្រប់រូបនៅក្នុងប្រទេសរបស់ពួកគេ អាចទទួលបានសិទ្ធិទាំងអស់ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។
- **មាត្រា៥-ការណែនាំស្របតាមវ័យរបស់កុមារ៖** រាជរដ្ឋាភិបាលគួរផ្ដល់ឱកាសឱ្យគ្រួសារ និងសហគមន៍ផ្ដល់ការណែនាំដល់កូនៗរបស់ពួកគេ ដើម្បីឱ្យនៅពេលដែលពួកគេធំឡើង ពួកគេរៀនប្រើប្រាស់សិទ្ធិរបស់ពួកគេបានល្អបំផុត។ នៅពេលដែលកុមារកាន់តែចម្រើនវ័យ ពួកគេត្រូវការការណែនាំកាន់តែតិច។

[7] ដកស្រង់ចេញពី អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម

- **មាត្រា៦-ជីវិត ការរស់រានមានជីវិត និងការអភិវឌ្ឍ៖** កុមារគ្រប់រូបមានសិទ្ធិរស់រាន។ រាជរដ្ឋាភិបាលត្រូវធានាថា កុមាររស់រាន និងអភិវឌ្ឍន៍បានល្អបំផុត។

- **មាត្រា៧-ឈ្មោះ និងសញ្ជាតិ៖** ត្រូវមានការចុះសំបុត្រកំណើតឱ្យកុមារ នៅពេលដែលពួកគេកើតមក និងទទួលបានឈ្មោះដែលមានការទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាល។ កុមារត្រូវមានសញ្ជាតិ (ជាពលរដ្ឋរបស់ប្រទេសណាមួយ)។ នៅពេលដែលអាចធ្វើទៅបាន កុមារគួរស្គាល់ឪពុកម្តាយរបស់ពួកគេ និងទទួលបានការថែទាំពីឪពុកម្តាយរបស់ពួកគេ។

- **មាត្រា៨-អត្តសញ្ញាណ៖** កុមារមានសិទ្ធិមានអត្តសញ្ញាណផ្ទាល់ខ្លួន ជាឯកសារផ្លូវការដែលកំណត់ថាតើពួកគេជានរណា ដោយក្នុងនោះមានឈ្មោះ សញ្ជាតិ និងទំនាក់ទំនងគ្រួសាររបស់ពួកគេ។ ពុំគួរមាននរណាម្នាក់ដកហូតសិទ្ធិនេះពីពួកគេឡើយ ប៉ុន្តែប្រសិនបើមានការដកហូតសិទ្ធិបែបនេះ រាជរដ្ឋាភិបាលត្រូវជួយឱ្យកុមារទទួលបានអត្តសញ្ញាណពួកគេមកវិញឱ្យបានឆាប់រហ័ស។

- **មាត្រា៩-ការរស់នៅជួបជុំគ្រួសារ៖** គេមិនគួរបំបែកកុមារចេញពីឪពុកម្តាយរបស់ពួកគេឡើយ លើកលែងតែក្នុងករណីដែលកុមារពុំបានទទួលបានការថែទាំឱ្យបានត្រឹមត្រូវ។ ឧទាហរណ៍ ប្រសិនបើឪពុកម្តាយធ្វើឱ្យពួកគេទទួលរងការឈឺចាប់ ឬមិនបានថែទាំកុមារ ជាដើម។ កុមារដែលឪពុកម្តាយមិនរស់ជាមួយគ្នា គួរបន្តទំនាក់ទំនងជាមួយនឹងឪពុកម្តាយទាំងពីរ លើកលែងតែការធ្វើបែបនេះអាចបង្កគ្រោះថ្នាក់ដល់កុមារនោះ។

- **មាត្រា១០-ទំនាក់ទំនងជាមួយឪពុកម្តាយឆ្លងប្រទេស៖** ប្រសិនបើកុមាររស់នៅក្នុងប្រទេសផ្សេងពីឪពុកម្តាយរបស់ពួកគេ រាជរដ្ឋាភិបាលត្រូវផ្តល់ឱកាសឱ្យកុមារ និងឪពុកម្តាយធ្វើដំណើរ ដើម្បីឱ្យពួកគេអាចបន្តទំនាក់ទំនង និងបាននៅជុំគ្នា។

- **មាត្រា១១-ការការពារពីការចាប់ជំរិត៖** រាជរដ្ឋាភិបាលត្រូវចាត់វិធានការ ដើម្បីកុំឱ្យមានការយកកុមារចេញទៅក្រៅប្រទេស នៅពេលដែលការធ្វើបែបនេះជាទង្វើផ្ទុយនឹងច្បាប់ ឧទាហរណ៍ ត្រូវបានចាប់ជំរិតដោយនរណាម្នាក់ ឬត្រូវបានរក្សាទុកនៅក្រៅប្រទេស ដោយឪពុក ឬម្តាយ នៅពេលដែល ម្តាយ ឬឪពុកម្ខាងទៀតមិនយល់ស្រប។

- **មាត្រា១២-ការគោរពទស្សនៈ៖** កុមារមានសិទ្ធិបង្ហាញពីការយល់ឃើញរបស់ពួកគេដោយសេរីអំពីបញ្ហានានា ដែលបង្កផលប៉ះពាល់ដល់ពួកគេ។ មនុស្សពេញវ័យគួរស្តាប់ដោយយកចិត្តទុកដាក់ចំពោះមតិយោបល់របស់កុមារ។

- **មាត្រា១៣-ការចែករំលែកគំនិតដោយសេរី៖** កុមារមានសិទ្ធិចែករំលែកដោយសេរីជាមួយនឹងអ្នកដទៃទៀតអំពីអ្វីដែលពួកគេបានរៀន ការគិត និងអារម្មណ៍របស់ពួកគេ តាមរយៈការនិយាយ ការគូររូប ការសរសេរ ឬតាមរបៀបផ្សេងទៀត ដរាបណាវាមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

- **មាត្រា១៤-សេរីភាពនៃជំនឿ និងសាសនា៖** កុមារអាចជ្រើសរើសគំនិត ការយល់ឃើញ និងសាសនារបស់ពួកគេ ប៉ុន្តែការធ្វើបែបនេះមិនគួររារាំងអ្នកដទៃទៀត ក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេឡើយ។ ឪពុកម្តាយអាចផ្តល់ការណែនាំដល់កូន ដើម្បីឱ្យនៅពេលដែលពួកគេធំឡើង ពួកគេរៀនប្រើប្រាស់សិទ្ធិនេះឱ្យបានត្រឹមត្រូវ។

- **មាត្រា១៥-ការបង្កើត ឬចូលរួមក្រុម៖** កុមារអាចចូលរួម ឬបង្កើតក្រុម ឬអង្គការ ហើយពួកគេអាចជួបប្រជុំជាមួយនឹងអ្នកដទៃទៀត ដរាបណាការធ្វើបែបនេះមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

- **មាត្រា១៦- ការការពារឯកជនភាព៖** កុមារគ្រប់រូបមានសិទ្ធិទទួលបានឯកជនភាព។ ច្បាប់ត្រូវការពារឯកជនភាព គ្រួសារ គេហដ្ឋាន ការទំនាក់ទំនង និងកេរ្តិ៍ឈ្មោះ(កិត្តិសព្ទ)របស់កុមារពីការវាយប្រហារនានា។

- **មាត្រា១៧-សិទ្ធិទទួលបានព័ត៌មាន៖** កុមារមានសិទ្ធិទទួលបានព័ត៌មានពីអ៊ីនធឺណិត វិទ្យុ ទូរទស្សន៍ សារព័ត៌មាន សៀវភៅ និងប្រភពផ្សេងទៀត។ មនុស្សពេញវ័យគួរធានាថា ព័ត៌មានដែលកុមារទទួលបានមិនបង្កគ្រោះថ្នាក់ដល់ពួកគេឡើយ។ រាជរដ្ឋាភិបាលគួរលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយធ្វើការផ្សព្វផ្សាយព័ត៌មានពីប្រភពផ្សេងៗឱ្យបានច្រើន ជាភាសាដែលកុមារគ្រប់រូបអាចយល់បាន។

- **មាត្រា១៨-ទំនួលខុសត្រូវរបស់ឪពុកម្តាយ៖** ឪពុកម្តាយគឺជាមនុស្សសំខាន់ជាងគេ ដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កុមារ។ នៅពេលដែលកុមារមិនមានឪពុកម្តាយ មនុស្សពេញវ័យម្នាក់ទៀតត្រូវបំពេញការទទួលខុសត្រូវហើយ ដែលគេហៅថា "អាណាព្យាបាល"។ ឪពុកម្តាយ និងអាណាព្យាបាលជានិច្ចកាល គួរធ្វើអ្វី ដើម្បីឧត្តមប្រយោជន៍របស់កុមារនោះ។ រាជរដ្ឋាភិបាលគួរជួយដល់ឪពុកម្តាយ និងអាណាព្យាបាលទាំងនោះ។ នៅពេលដែលកុមារម្នាក់មានទាំងឪពុក ទាំងម្តាយ ពួកគេទាំងពីរនាក់គួរជាអ្នកទទួលខុសត្រូវលើការចិញ្ចឹមបីបាច់កុមារនេះ។

- **មាត្រា១៩-ការការពារពីអំពើហិង្សា៖** រាជរដ្ឋាភិបាលត្រូវការពារកុមារពីអំពើហិង្សា ការរំលោភបំពាន និងការមិនអើពើពីអ្នកដែលត្រូវមើលថែទាំពួកគេ។

- **មាត្រា២០-កុមារកំព្រា៖** កុមារគ្រប់រូបដែលមិនអាចទទួលបានការថែទាំពីគ្រួសាររបស់ខ្លួន មានសិទ្ធិទទួលបានការថែទាំឱ្យបានសមស្របពីមនុស្សដែលគោរពសាសនា វប្បធម៌ ភាសារបស់កុមារ និងទិដ្ឋភាពផ្សេងទៀតនៅក្នុងជីវិតរបស់ពួកគេ។

- **មាត្រា២១-កុមារដែលគេយកទៅចិញ្ចឹម៖** នៅពេលដែលកុមារត្រូវបានគេយកទៅចិញ្ចឹម ចំណុចសំខាន់ជាងគេ គឺត្រូវធ្វើអ្វី ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ ប្រសិនបើកុមារម្នាក់មិនអាចទទួលបានការថែទាំឱ្យបានសមស្របនៅក្នុងប្រទេសរបស់ខ្លួន ឧទាហរណ៍ តាមរយៈការរស់នៅជាមួយនឹងគ្រួសារមួយទៀត នោះកុមារនេះអាចត្រូវបានគេយកទៅចិញ្ចឹមនៅក្នុងប្រទេសមួយផ្សេងទៀត។
- **មាត្រា២២-កុមារជនភៀសខ្លួន៖** កុមារដែលចាកចេញពីប្រទេសកំណើតទៅប្រទេសមួយទៀត ក្នុងនាមជាជនភៀសខ្លួន (ដោយសារតែពួកគេមិនមានសុវត្ថិភាពក្នុងការបន្តស្នាក់នៅក្នុងប្រទេសរបស់ខ្លួន) គួរទទួលបានជំនួយ និងការការពារ និងមានសិទ្ធិដូចកុមារដែលកើតនៅក្នុងប្រទេសនោះដែរ។
- **មាត្រា២៣-កុមារពិការ៖** កុមារដែលមានពិការភាពគ្រប់រូប គួរទទួលបានជីវិតល្អបំផុតដែលអាចមាននៅក្នុងសង្គម។ រាជរដ្ឋាភិបាលគួរលុបបំបាត់រាល់ឧបសគ្គទាំងអស់ដែលកុមារមានពិការភាពជួបប្រទះ ដើម្បីឱ្យពួកគេមានភាពម្ចាស់ការដោយខ្លួនឯង និងចូលរួមឱ្យបានសកម្មនៅក្នុងសហគមន៍។
- **មាត្រា២៤- សុខភាព ទឹកស្អាត អាហារ បរិស្ថាន៖** កុមារមានសិទ្ធិទទួលបានសេវាថែទាំសុខភាពល្អបំផុតតាមដែលអាចធ្វើទៅបាន ទឹកស្អាតសម្រាប់ផឹក អាហារដែលទ្រទ្រង់សុខភាព និងបរិយាកាសរស់នៅស្អាតប្រកបដោយសុវត្ថិភាព។ មនុស្សពេញវ័យ និងកុមារគ្រប់រូប គួរទទួលបានព័ត៌មានអំពីការរក្សាសុវត្ថិភាព និងសុខភាពរបស់ពួកគេឱ្យនៅមាំមួន។
- **មាត្រា២៥-ការពិនិត្យឡើងវិញនូវស្ថានភាពរស់នៅរបស់កុមារ៖** កុមារគ្រប់រូបដែលត្រូវបានយកទៅដាក់នៅកន្លែងផ្សេងក្រៅតែពីផ្ទះរបស់ពួកគេ ដើម្បីទទួលបានការថែទាំ ការការពារ ឬសេវាសុខភាព គួរមានការពិនិត្យស្ថានភាពរស់នៅរបស់ពួកគេឱ្យបានជាទៀងទាត់ ដើម្បីពិនិត្យថាតើអ្វីៗដំណើរការទៅបានល្អដែរឬទេ និងថាតើកន្លែងនោះនៅតែជាកន្លែងដែលល្អបំផុតសម្រាប់កុមារដែរឬទេ។
- **មាត្រា២៦-ជំនួយផ្នែកសង្គម និងសេដ្ឋកិច្ច៖** រាជរដ្ឋាភិបាលគួរផ្តល់ថវិកា ឬការឧបត្ថម្ភដទៃទៀត ដើម្បីជួយកុមារមកពីគ្រួសារក្រីក្រ។
- **មាត្រា២៧-អាហារ សម្លៀកបំពាក់ លំនៅឋានសុវត្ថិភាព៖** កុមារមានសិទ្ធិទទួលបានអាហារ សម្លៀកបំពាក់ និងកន្លែងរស់នៅដែលមានសុវត្ថិភាព ដើម្បីឱ្យពួកគេអាចអភិវឌ្ឍបានល្អបំផុត។ រាជរដ្ឋាភិបាលគួរជួយដល់គ្រួសារ និងកុមារដែលពុំមានលទ្ធភាពទទួលបានសេវាទាំងនេះ។

- **មាត្រា២៨-សិទ្ធិទទួលបានការអប់រំ៖** កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ។ ការអប់រំបឋមសិក្សាគួរផ្តល់ដោយឥតគិតថ្លៃ។ ការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា គួរមានសម្រាប់កុមារគ្រប់រូប។ គួរមានការលើកទឹកចិត្តកុមារទៅសាលារៀន ដើម្បីរៀនបានខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន។ ការដាក់វិន័យនៅក្នុងសាលារៀនគួរគោរពសិទ្ធិរបស់កុមារ ហើយមិនត្រូវមានការប្រើប្រាស់អំពើហិង្សាជាដាច់ខាត។
- **មាត្រា៣១- សម្រាក កម្សាន្ត វប្បធម៌ សិល្បៈ៖** កុមារគ្រប់រូបមានសិទ្ធិសម្រាក លំហែកាយ លេងកម្សាន្ត និងចូលរួមក្នុងសកម្មភាពវប្បធម៌ និងកម្សាន្តនានា។
- **មាត្រា៣៤- ការការពារពីការរំលោភបំពានផ្លូវភេទ៖** រាជរដ្ឋាភិបាលគួរការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ (ត្រូវបានគេធ្វើអាជីវកម្ម) និងរំលោភបំពានផ្លូវភេទ ដូចជា ការប្រព្រឹត្តដោយមនុស្សដែលបង្ខំកុមារឱ្យរួមភេទ ដើម្បីទទួលបានប្រាក់កម្រៃ ឬថតរូបភាពយន្តអាសអាភាសរបស់កុមារជាដើម។
- **មាត្រា៣៥- ការការពារពីការជួញដូរ៖** រាជរដ្ឋាភិបាលត្រូវធានាថា កុមារមិនត្រូវបានគេចាប់ជំរិត ឬលក់ ឬនាំទៅកាន់ប្រទេស ឬកន្លែងផ្សេងទៀត ដើម្បីកេងប្រវ័ញ្ច (ធ្វើអាជីវកម្មលើ) នោះឡើយ។
- **មាត្រា៣៦- ការការពារពីការកេងប្រវ័ញ្ច៖** កុមារមានសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចគ្រប់ប្រភេទដទៃទៀត បើទោះជាការកេងប្រវ័ញ្ចទាំងនេះមិនត្រូវបានលើកឡើងឱ្យបានជាក់លាក់នៅក្នុងអនុសញ្ញានេះក៏ដោយ។
- **មាត្រា៣៩-ការព្យាបាល និងការស្តារឡើងវិញ៖** កុមារមានសិទ្ធិទទួលបានជំនួយ ប្រសិនបើពួកគេទទួលរងការឈឺចាប់ ត្រូវបានគេទុកចោល ទទួលបានការធ្វើបាប ឬទទួលរងផលប៉ះពាល់ដោយសារសង្គ្រាម ដើម្បីឱ្យពួកគេអាចទទួលបាននូវសុខភាព សេចក្តីថ្លៃថ្នូរមកវិញ។

## រូបភាពសង្ខេបពី៥៤មាត្រានៃអនុសញ្ញាសិទ្ធិកុមារ[8]




[8] ដកស្រង់ចេញពីគេហទំព័រអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា

## ខ ស្វែងយល់អំពីសិទ្ធិកុមារក្នុងបរិយាកាសឌីជីថល

មុនពេលយើងស្វែងយល់ពីបញ្ហាសិទ្ធិកុមារក្នុងបរិយាកាសឌីជីថល - នេះជាសាវតារខ្លះៗអំពីសិទ្ធិកុមារ និង អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ UNCRC៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៩ ហើយត្រូវបានចុះហត្ថលេខាដោយភាគីចំនួន ១៨៩ ប្រទេសរួមទាំងប្រទេសកម្ពុជាផងដែរ។ មេដឹកនាំពិភពលោកបានរួមគ្នាធ្វើកិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រនេះ ដោយធ្វើការសន្យាដល់កុមារគ្រប់រូបថាពួកគេនឹងធ្វើអ្វីគ្រប់យ៉ាងដែលពួកគេអាចធ្វើបានដើម្បីការពារ និងបំពេញសិទ្ធិរបស់កុមារ។
- សិទ្ធិទាំងនេះអនុវត្តន៍ចំពោះកុមារទាំងអស់ ហើយរដ្ឋភាគីត្រូវបានរំពឹងថានឹងធានាថា មានការចាត់វិធានការវិជ្ជមានដើម្បីការពារសិទ្ធិទាំងនេះ។
- CRC បានកំណត់នូវសិទ្ធិជាក់លាក់ចំនួន៣២ ដែលកុមារមានសិទ្ធិ និងដែលត្រូវបានធានាចំពោះពួកគេ។
- សិទ្ធិសំខាន់ៗមួយចំនួនដែលទាក់ទងនឹងអ្នកក្នុងនាមជាមន្ត្រីនគរបាលមានរៀបរាប់ដូចខាងក្រោម
- នៅកន្លែងដែលមានប្រអប់អត្ថបទ អ្នកអាចធ្វើកំណត់ចំណាំបន្ថែមទាក់ទងនឹងរឿងនេះសម្រាប់មន្ត្រីនគរបាល (នេះមានន័យថាយើងត្រូវធ្វើយ៉ាងណាដើម្បីប្រាកដថាសិទ្ធិរបស់កុមារត្រូវបានគោរព)

**មាត្រា ១ (និយមន័យកុមារ)៖** មនុស្សគ្រប់រូបដែលមានអាយុក្រោម១៨ឆ្នាំមានសិទ្ធិទាំងអស់នៅក្នុងអនុសញ្ញា។

**មាត្រា ២ (គ្មានការរើសអើង)៖** អនុសញ្ញានេះអនុវត្តចំពោះកុមារគ្រប់រូបដោយមិនមានការរើសអើង មិនថាជាជនជាតិ ភេទ សាសនា ភាសាមួយណា សមត្ថភាព ឬស្ថានភាពផ្សេងទៀត មិនថាអ្វីពួកគេគិត ឬនិយាយអ្វីក៏ដោយ ឬប្រវត្តិគ្រួសាររបស់ពួកគេយ៉ាងណាក៏ដោយ។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖**

**មាត្រា ៣ (ឧត្តមប្រយោជន៍កុមារ)៖** ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាអាទិភាពចម្បងក្នុងការសម្រេចចិត្ត និងសកម្មភាពទាំងអស់ដែលប៉ះពាល់ដល់កុមារ។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖**

**មាត្រា ១២ (ការគោរពទស្សនៈរបស់កុមារ)៖** កុមារគ្រប់រូបមានសិទ្ធិបញ្ចេញទស្សនៈ អារម្មណ៍ និងបំណងប្រាថ្នារបស់ខ្លួនក្នុងគ្រប់បញ្ហាដែលប៉ះពាល់ដល់ពួកគេ ហើយត្រូវយកទស្សនៈរបស់ពួកគេមកពិចារណា និងយកចិត្តទុកដាក់ខ្លាំង។ សិទ្ធិនេះត្រូវបានអនុវត្តន៍គ្រប់ពេលវេលា ឧទាហរណ៍ ក្នុងអំឡុងពេលដំណើរការអន្តោប្រវេសន៍ ការសម្រេចចិត្តលើលំនៅដ្ឋាន ឬជីវិតរស់នៅប្រចាំថ្ងៃរបស់កុមារ។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖**

**មាត្រា ១៣ (ការចែករំលែកគំនិតដោយសេរី)៖** កុមារគ្រប់រូបត្រូវមានសេរីភាពក្នុងការបញ្ចេញមតិយោបល់ និងអាចទទួលបានព័ត៌មានគ្រប់ប្រភេទ ដរាបណាវាស្ថិតនៅក្នុងច្បាប់។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖**

**មាត្រា ១៦ (សិទ្ធិឯកជនភាព)៖** កុមារគ្រប់រូបមានសិទ្ធិឯកជនភាព។ ច្បាប់គួរតែការពារជីវិតឯកជន គ្រួសារ និងការរស់នៅរបស់កុមារ រួមទាំងការការពារកុមារពីការវាយប្រហារដោយខុសច្បាប់ដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ពួកគេ។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖**

**មាត្រា ១៩ (ការការពារពីអំពើហិង្សា ការរំលោភបំពាន និងការធ្វេសប្រហែស)៖** រាជរដ្ឋាភិបាលត្រូវធ្វើអស់ពីសមត្ថភាព ដើម្បីធានាថាកុមារត្រូវបានការពារពីអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់ ការព្រងើយកន្តើយ និងការធ្វើបាបពីឪពុកម្តាយរបស់ពួកគេ ឬអ្នកផ្សេងទៀតដែលមើលថែពួកគេ។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖**

**មាត្រា ២៣ (កុមារពិការ)៖** កុមារពិការមានសិទ្ធិរស់នៅក្នុងជីវិតពេញលេញ និងសមរម្យប្រកបដោយសេចក្តីថ្លៃថ្នូរ និងឯករាជ្យភាព និងចូលរួមយ៉ាងសកម្មក្នុងសហគមន៍តាមដែលអាចធ្វើទៅបាន។ រដ្ឋាភិបាលត្រូវតែធ្វើឱ្យអស់ពីសមត្ថភាពដើម្បីជួយគាំទ្រដល់កុមារពិការ និងគ្រួសាររបស់ពួកគេ។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖**

**មាត្រា ៣៤ (ការកេងប្រវ័ញ្ចផ្លូវភេទ)៖** រាជរដ្ឋាភិបាលត្រូវតែការពារកុមារពីគ្រប់ទម្រង់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទទាំងអស់។

**ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖**

មាត្រា ៣៥ (ការចាប់ពង្រត់ ការលក់ និងការជួញដូរ)៖ រាជរដ្ឋាភិបាលត្រូវការពារកុមារពីការចាប់ពង្រត់ លក់ ឬផ្លាស់ទីដោយខុសច្បាប់ទៅកន្លែងផ្សេងក្នុង ឬក្រៅប្រទេសក្នុងគោលបំណងកេងប្រវ័ញ្ច។

ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

មាត្រា ៣៩ (ការព្យាបាល និងការស្ដារឡើងវិញពីការប៉ះទង្គិច)៖ កុមារដែលបានជួបប្រទះការធ្វេសប្រហែស ការរំលោភបំពាន ការកេងប្រវ័ញ្ច ការធ្វើទារុណកម្ម ឬជាជនរងគ្រោះនៃសង្គ្រាមត្រូវតែទទួលបានការគាំទ្រពិសេស ដើម្បីជួយពួកគេឱ្យស្ដារសុខភាព សេចក្ដីថ្លៃថ្នូរ ការគោរពខ្លួនឯង និងជីវិតសង្គមរបស់ពួកគេឡើងវិញ។

ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

មាត្រា ៤១ (ការគោរពបទដ្ឋានជាតិខ្ពស់ជាង)៖ ប្រសិនបើប្រទេសមួយមានច្បាប់ និងបទដ្ឋានដែលលើសពីអនុសញ្ញាបច្ចុប្បន្ន ប្រទេសនោះត្រូវតែគោរពតាមច្បាប់ទាំងនេះ។

ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

មាត្រា ៤២ (ចំណេះដឹងអំពីសិទ្ធិ)៖ រាជរដ្ឋាភិបាលត្រូវតែធ្វើការយ៉ាងសកម្មដើម្បីធ្វើឱ្យប្រាកដថាកុមារ និងមនុស្សពេញវ័យបានដឹងអំពីអនុសញ្ញានេះ។

ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

កំណត់ចំណាំ៖ អនុសញ្ញានេះមានមាត្រាសរុបចំនួន ៥៤មាត្រា។ មាត្រា ៤៣-៥៤ និយាយអំពីរបៀបដែលមនុស្សពេញវ័យ និងរាជរដ្ឋាភិបាលត្រូវធ្វើការរួមគ្នា ដើម្បីប្រាកដថាកុមារទាំងអស់អាចទទួលបានសិទ្ធិទាំងអស់របស់ពួកគេ។

### តើសិទ្ធិកុមារត្រូវបានអនុវត្តយ៉ាងដូចម្ដេចនៅក្នុងបរិយាកាសឌីជីថល?

- សុវត្ថិភាព និងសុខុមាលភាពរបស់កុមារលើប្រព័ន្ធអនឡាញមិនអាចបំបែកចេញពីសិទ្ធិទូលំទូលាយដែលកុមារមាននោះទេ។ **សិទ្ធិកុមារគឺដូចគ្នាទាំងនៅលើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។**
- មូលដ្ឋានសុវត្ថិភាពរបស់កុមារ គឺជាសិទ្ធិដែលកុមារទាំងអស់មាន ដូចមានចែងក្នុង CRC ដើម្បីការពារគ្រោះថ្នាក់គ្រប់ទម្រង់ទាំងអស់ (មាត្រា ១៩) និងពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភ

បំពានផ្លូវភេទគ្រប់ទម្រង់ ពីការចាប់ពង្រត់ដើម្បីយកទៅលក់ ឬការជួញដូរ និង ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត (មាត្រា ៣៤-៣៥)។

- ដូច្នេះវាមិនអាចទៅរួចទេ ក្នុងការនិយាយអំពីការការពារកុមារពី OCSEA និងគ្រប់ទម្រង់នៃអំពើហិង្សាដែលសម្របសម្រួលដោយបច្ចេកវិទ្យា ដោយគ្មានការនិយាយអំពីសិទ្ធិរបស់កុមារ។
- ការប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យានៅក្នុងជីវិតរបស់កុមារកាន់តែសំខាន់ឡើងៗ និងឱកាសដែលវាផ្តល់ឱ្យ (ការពិភាក្សាក្នុងវគ្គទី១ នៃវគ្គបណ្តុះបណ្តាលនេះ) មានន័យថា ខណៈពេលដែលធានាថាកុមារត្រូវបានការពារលើប្រព័ន្ធអនឡាញ ឱកាសពេញលេញដែលពិភពឌីជីថលបង្ហាញដល់កុមារ មិនត្រូវបានកំណត់ ឬដកចេញពីពួកគេនោះទេ។
- ជាឧទាហរណ៍ សិទ្ធិទទួលបានសុវត្ថិភាពលើប្រព័ន្ធអនឡាញ មិនគួរប៉ះពាល់លើសិទ្ធិទទួលការអប់រំព័ត៌មាន ឬការថែទាំសុខភាពនោះទេ។ ជាឧទាហរណ៍ កុមារទាំងអស់អាចចូលប្រើប្រាស់ប្រព័ន្ធអនឡាញបាន ហើយពឹងផ្អែកលើវា។
- ដូចគ្នាដែរ ការស្រាវជ្រាវពីជុំវិញពិភពលោកបានបង្ហាញថា នៅពេលដែលកុមារមិនមានសុវត្ថិភាពលើប្រព័ន្ធអនឡាញ នោះពួកគេមិនអាចដឹងច្បាស់អំពីអត្ថប្រយោជន៍ដែលមានសម្រាប់ពួកគេតាមរយៈអ៊ីនធឺណិត និងបច្ចេកវិទ្យានោះទេ។

## គ ការអភិវឌ្ឍសំខាន់ៗ

- នៅខែមករា ឆ្នាំ២០២១ CRC បានអនុម័តនូវអ្វីដែលហៅថា **មតិទូទៅ២៥** (GC.25) ដោយកត់សម្គាល់ថា **សិទ្ធិរបស់កុមារទាំងអស់អនុវត្តន៍ស្មើៗគ្នាទាំងនៅលើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ**
- អ្វីដែលសំខាន់នោះគឺ មតិទូទៅក៏ផ្តល់ការណែនាំអំពីរបៀបដែលសិទ្ធិរបស់កុមារនៅក្នុងពិភពឌីជីថលអាចត្រូវបានបំពេញ។
- តម្រូវការក្នុងការធ្វើឱ្យមានតុល្យភាពនៃសិទ្ធិទទួលបានសុវត្ថិភាព និងការការពារលើប្រព័ន្ធអនឡាញជាមួយនឹងឱកាសដែលត្រូវបានបង្ហាញ និងបង្ហាញនៅក្នុងការបកស្រាយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- GC.25 ក៏ផ្តល់នូវ**គោលការណ៍អន្តរវិស័យ** ដែលជាចំណុចសំខាន់ក្នុងការសម្រេចបាននូវសិទ្ធិរបស់កុមារនៅក្នុងពិភពឌីជីថល ដែលមានដូចជា៖

- គោលការណ៍មិនរើសអើង៖

ដើម្បីរក្សាសិទ្ធិមិនរើសអើងកុមារ នេះមានន័យថាក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

- គោលការណ៍ដើម្បីលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារជានិច្ច៖

ដើម្បីរក្សា និងលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

- សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍ៖

ដើម្បីរក្សាសិទ្ធិមិនរើសអើងកុមារ នេះមានន័យថាក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

- ការគោរពចំពោះទស្សនៈរបស់កុមារ៖

ដើម្បីរក្សា និងលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

## ឃ សេចក្ដីសំយោគអំពីសិទ្ធិកុមារសំខាន់ៗក្នុងពិភពឌីជីថល



សព្វថ្ងៃនេះ កុមារចំណាយពេលកាន់តែច្រើននៅលើអ៊ីនធឺណិត ដូច្នេះហើយសិទ្ធិឌីជីថលរបស់ពួកគេត្រូវតែទទួលបានការគោរព។ ផ្អែកលើអនុសាសន៍ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិលេខ២៥ ស្តីពីសិទ្ធិកុមារក្នុងពិភពឌីជីថល (UNCRC General Comment No.25) បានចែងលម្អិតអំពីកាតព្វកិច្ចរបស់សមាជិកក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដើម្បីធានាបាថា សិទ្ធិកុមារត្រូវបានគេគិតគូរដូចគ្នាទាំងនៅក្រៅ និងលើប្រព័ន្ធឌីជីថល។ យើងត្រូវរួមគ្នាដើម្បីធានាសុវត្ថិភាព និងការពារសិទ្ធិកុមារ ទាំងសិទ្ធិក្នុងការទទួលបានការការពារពីគ្រោះថ្នាក់ សិទ្ធិក្នុងការទទួលបានព័ត៌មាន សិទ្ធិក្នុងការចូលរួម និងសិទ្ធិទទួលបានការអប់រំ។[9] សិទ្ធិឌីជីថលរបស់កុមាររួមបញ្ចូលទាំងការចូលប្រើមាតិកា ការទទួលបានព័ត៌មានដែលសមស្របតាមអាយុរបស់ពួកគេ ការការពារឯកជនភាពទិន្នន័យផ្ទាល់ខ្លួនការការពារពីគ្រោះថ្នាក់ ឬអំពើកេងប្រវ័ញ្ចលើអ៊ីនធឺណិត ការអប់រំដែលរួមបញ្ចូលអក្ខរកម្ម និងជំនាញឌីជីថល ព្រមទាំងសេរីភាពក្នុងការបញ្ចេញមតិយោបល់ ដោយគ្មានការរើសអើង។[10]

### ឃ.១- សិទ្ធិចូលប្រើប្រាស់មាតិកា និងទទួលបានព័ត៌មាន

កុមារមានសិទ្ធិទទួលបានព័ត៌មាន ឬចូលប្រើប្រាស់មាតិកាអនឡាញដែលសមស្របនឹងអាយុ និងដំណាក់កាលនៃការអភិវឌ្ឍរបស់ពួកគេ ដែលមាតិកាទាំងនេះអាចជួយពួកគេរៀន និងអភិវឌ្ឍន៍ខ្លួន។ គេហទំព័រ និងកម្មវិធីអនឡាញគួរតែផ្តល់នូវមាតិកា ដែលមានសុវត្ថិភាព ការអប់រំ និងភាពសមរម្យសម្រាប់កុមារព្រោះអាចជួយការពារពួកគេពីមាតិកាមិនល្អ ឬមាតិកាដែលអាចបង្កគ្រោះថ្នាក់។

### ឃ.២- សិទ្ធិទទួលបានការការពារឯកជនភាព និងអត្តសញ្ញាណ

កុមារមានសិទ្ធិឯកជនភាព និងការការពារព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ នៅពេលពួកគេប្រើប្រាស់អ៊ីនធឺណិត។ ទិន្នន័យផ្ទាល់ខ្លួន និងអត្តសញ្ញាណឌីជីថលរបស់កុមារ ត្រូវបានការពារពីការប្រើប្រាស់ខុសការកេងប្រវ័ញ្ចដោយបុគ្គល ឬក្រុមណាមួយ ក្នុងគោលបំណងផ្ទាល់ខ្លួន ឬពាណិជ្ជកម្ម ឬការគំរាមកំហែងផ្សេងទៀត។

- **ព័ត៌មានផ្ទាល់ខ្លួន៖** ដូចនៅក្នុងពិភពពិតដែរ កុមារមានសិទ្ធិរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេជាឯកជននៅពេលកំពុងប្រើប្រាស់អ៊ីនធឺណិត។ ព័ត៌មានផ្ទាល់ខ្លួនរួមមានដូចជាឈ្មោះ អាយុ អាសយដ្ឋានសាលារៀន លេខទូរស័ព្ទ និងរូបថតរបស់ពួកគេ ដែលមិនគួរមានការចែករំលែកនៅលើអ៊ីនធឺណិត ដើម្បីការពារឯកជនភាព និងសុវត្ថិភាព។

[9] ដកស្រង់ចេញពីគោលការណ៍ស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា (២០២៣) របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ត្រង់ទំព័រទី ៦ និងទី៧។

[10] ដកស្រង់ចេញពីសៀវភៅណែនាំបង្រៀនអំពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញកម្រិតបឋមសិក្សាបឋមភូមិ

- **ការយល់ព្រម និងការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន៖** កុមារមានសិទ្ធិគ្រប់គ្រងលើព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ និងផ្តល់ការយល់ព្រមសម្រាប់ការប្រើប្រាស់ព័ត៌មានទាំងនោះ។ គេហទំព័រ កម្មវិធី និងវេទិកាអនឡាញ គួរតែស្នើសុំការអនុញ្ញាតមុនពេលប្រមូល ប្រើប្រាស់ ឬចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ។ កុមារ រួមជាមួយនឹងឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេគួរតែមានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តអំពីរបៀបដែលព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានប្រើប្រាស់ដោយកម្មវិធីអនឡាញ។
- **ដានឌីជីថល៖** សកម្មភាពអនឡាញតែងបន្សល់ទុកដានឌីជីថល ដូច្នេះអ្វីៗដែលកុមារបង្ហោះ ចែករំលែកឬបញ្ចេញមតិអាចមើលឃើញដោយអ្នកដទៃហើយអាចមានផលវិបាករយៈពេលវែង។ កុមារគួរត្រូវបានលើកទឹកចិត្តឱ្យគិតមុនពេលពួកគេចែករំលែក ដើម្បីជួយការពារឯកជនភាព និងកេរ្តិ៍ឈ្មោះរបស់ពួកគេ។

**សិទ្ធិទទួលបានការការពារ**ពីគ្រោះថ្នាក់ ឬអំពើកេងប្រវ័ញ្ចលើអ៊ីនធឺណិត កុមារត្រូវរួចផុតពីការគំរាមកំហែង បន្លំ ឆបោក លួងលោម ញុះញង់ រំលោភបំពាន និងអាកប្បកិរិយា ដែលអាចបង្កគ្រោះថ្នាក់ផ្សេងទៀតនៅលើ អ៊ីនធឺណិត។ កុមារមានសិទ្ធិទទួលបានការការពារពីការផលិត ចែកចាយ លក់ដូររូបភាពអាសអាភាស រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទ មាតិកាហិង្សា និងការកេងប្រវ័ញ្ចគ្រប់រូបភាពលើប្រព័ន្ធអនឡាញ។

ការការពារឯកជនភាពរបស់កុមារនៅលើអ៊ីនធឺណិតក៏ជាផ្នែកមួយ នៃការការពារពួកគេពីការគំរាមកំហែងតាមអ៊ីនធឺណិតផងដែរ។ មាតាបិតា អាណាព្យាបាល និងវេទិកាអនឡាញគួរតែចាត់វិធានការដើម្បីធានាសុវត្ថិភាពលើអ៊ីនធឺណិតរបស់កុមារដូចជាការកំណត់ឯកជនភាព ការត្រួតពិនិត្យសកម្មភាពអនឡាញ និងការអប់រំកុមារអំពីវិធានសុវត្ថិភាពដែលគួរអនុវត្តលើអនឡាញ។

### ឃ.៣- សិទ្ធិបញ្ចេញមតិ និងការគោរពទស្សនៈ

កុមារមានសិទ្ធិចូលរួម និងបញ្ចេញមតិយោបល់លើបញ្ហាផ្សេងៗដែលអាចជះឥទ្ធិពល (ទាំងវិជ្ជមាន និងអវិជ្ជមាន) ដល់ពួកគេ។ នៅពេលមានអាយុ និងសមត្ថភាពសមស្រប កុមារមានសិទ្ធិចូលរួមចំណែក និងចែករំលែកមាតិកានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបង្ហាញពីភាពច្នៃប្រតិដ្ឋ បទពិសោធន៍ កង្វល់ និងភាពជាបុគ្គលរបស់ពួកគេ។

នៅពេលមាតាបិតា អាណាព្យាបាលកុមារ បុគ្គលិកអប់រំ និងសង្គមទាំងមូលមានការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិកុមារក្នុងពិភពឌីជីថលទាំងនោះពួកគេកាន់តែអាចជួយគាំទ្រ និងផ្តល់សិទ្ធិអំណាចដល់កុមារឱ្យទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងជួយការពារសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញបានកាន់តែប្រសើរ។

## ង សេចក្តីសង្ខេបពីអនុសាសន៍ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិលេខ២៥ ស្តីពីសិទ្ធិកុមារក្នុងស្ថានភាពឌីជីថល[11]

### ង.១- បញ្ហាប្រឈម និងឱកាស

ពិភពឌីជីថលបង្ហាញពីទិដ្ឋភាពដ៏ស្មុគស្មាញសម្រាប់សិទ្ធិកុមារ។ វាផ្តល់ឱកាសយ៉ាងច្រើនសម្រាប់ការរៀនសូត្រ ការទំនាក់ទំនង និងការចូលរួម។ ទោះជាយ៉ាងណាក៏ដោយ វាក៏ធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យដូចជាការគំរាមកំហែងតាមអ៊ីនធឺណិត ការបំពានឯកជនភាព និងខ្លឹមសារដែលបង្កគ្រោះថ្នាក់។

### ង.២- គោលការណ៍សំខាន់ៗសម្រាប់សិទ្ធិកុមារតាមអ៊ីនធឺណិត

- *ឯកសារនេះសង្កត់ធ្ងន់លើគោលការណ៍ស្នូលមួយចំនួន៖*
  - **ការមិនរើសអើង៖** កុមារទាំងអស់មានសិទ្ធិស្មើគ្នានៅក្នុងពិភពឌីជីថល ដោយមិនគិតពីសាវតា ឬសមត្ថភាព។
  - **ចំណាប់អារម្មណ៍ល្អបំផុតរបស់កុមារ៖** ការអនុវត្ត និងគោលនយោបាយលើអ៊ីនធឺណិតទាំងអស់គួរតែផ្តល់អាទិភាពដល់សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ។
  - **សិទ្ធិទទួលបានជីវិត ការរស់រានមានជីវិត និងការអភិវឌ្ឍ៖** នេះរួមបញ្ចូលទាំងការធានាសុវត្ថិភាពរបស់កុមារ និងការទទួលបានព័ត៌មាន និងធនធានតាមអ៊ីនធឺណិត។
  - **ការគោរពចំពោះទស្សនៈរបស់កុមារ៖** កុមារគួរមានសន្ទរកថាក្នុងការរៀបចំគោលនយោបាយ និងការអនុវត្តដែលប៉ះពាល់ដល់បទពិសោធន៍ឌីជីថលរបស់ពួកគេ។ គណៈកម្មាធិការសង្កត់ធ្ងន់លើសារៈសំខាន់នៃការពិចារណាលើសមត្ថភាពវិវឌ្ឍន៍របស់កុមារ នៅពេលរចនាការការពារតាមអ៊ីនធឺណិត។ កុមារតូចៗអាចត្រូវការការការពារច្រើនជាងបើធៀបនឹងមនុស្សវ័យជំទង់ដែលមានវ័យចំណាស់។

### ង.៣- កាតព្វកិច្ចរដ្ឋ

- *ឯកសារនេះបង្ហាញពីការទទួលខុសត្រូវរបស់រដ្ឋ (ប្រទេស) ក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ក្នុងវិស័យឌីជីថល។ នេះរួមបញ្ចូល៖*

---

[11] ដកស្រង់ចេញពីមតិទូទៅលេខ២៥ (UNCRC General Comment No.25) ចូលមើលនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ ឯកសារនេះអាចស្វែងរកឃើញតាមតំណនេះ https://docstore.ohchr.org/SelfServices/FilesHandler.FilesHandler.x?enc=6QkG1d%2FPPRiCAqhKb7yhsqIkirKQZLK2M58RF%2F5F0vEG%2BcAAx34gC78FwvnmZXGFUI9nJBDpKR1dfKekJxW2w7O%2B3nRpHZVnUfEOn49xuIgBmsRD7nyWwxR%2FYnIpnMdh

- **ច្បាប់ និងគោលនយោបាយ៖** រដ្ឋគួរតែបង្កើតច្បាប់ និងគោលនយោបាយដែលដោះស្រាយការការពារទិន្នន័យ សុវត្ថិភាពតាមអ៊ីនធឺណិត និងការទទួលបានព័ត៌មានសម្រាប់កុមារ។
- **កិច្ចសហការ៖** រដ្ឋគួរតែធ្វើការជាមួយអាជីវកម្ម អង្គការសង្គមស៊ីវិល និងឪពុកម្ដាយ ដើម្បីបង្កើតបរិយាកាសឌីជីថលដែលមានសុវត្ថិភាពជាងមុនសម្រាប់កុមារ។

### ង.៨- វិធានការសម្រាប់ការអនុវត្ត

- *ឯកសារបង្ហាញពីវិធានការផ្សេងៗដែលរដ្ឋអាចអនុវត្តន៍បាន៖*
  - **ការប្រមូលទិន្នន័យ និងការស្រាវជ្រាវ៖** វាពាក់ព័ន្ធនឹងការប្រមូលព័ត៌មានអំពីបទពិសោធន៍លើអ៊ីនធឺណិតរបស់កុមារ រួមទាំងទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាន។
  - **ការត្រួតពិនិត្យឯករាជ្យ៖** រដ្ឋគួរតែបង្កើតស្ថាប័នឯករាជ្យ ដើម្បីតាមដានបរិយាកាសអនឡាញ និងកំណត់ហានិភ័យដែលអាចកើតមាន។
  - **ការយល់ដឹង និងការបណ្ដុះបណ្ដាល៖** ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដើម្បីអប់រំកុមារ ឪពុកម្ដាយ និងអ្នកជំនាញអំពីសុវត្ថិភាពអនឡាញ និងសញ្ញាតឌីជីថលដែលមានការទទួលខុសត្រូវ។
  - **សិទ្ធិទទួលបានយុត្តិធម៌៖** កុមារដែលជួបប្រទះគ្រោះថ្នាក់តាមអ៊ីនធឺណិត គួរតែមានផ្លូវច្បាស់លាស់ក្នុងការស្វែងរកជំនួយ និងដំណោះស្រាយ។

### ង.៩- តុល្យភាពសិទ្ធិ៖ ការចូលប្រើទល់នឹងការការពារ

- ឯកសារនេះទទួលស្គាល់សារៈសំខាន់នៃការធានាសិទ្ធិទទួលបានព័ត៌មានរបស់កុមារ និងសេរីភាពនៃការបញ្ចេញមតិតាមអ៊ីនធឺណិត។ ទោះជាយ៉ាងណាក៏ដោយ វាក៏បញ្ជាក់ពីតម្រូវការក្នុងការការពារពួកគេពីខ្លឹមសារដែលបង្កគ្រោះថ្នាក់ ដូចជារូបភាពអាសអាភាស អំពើហិង្សា និងការនិយាយស្អប់។ រដ្ឋត្រូវស្វែងរកតុល្យភាពរវាងសិទ្ធិទាំងពីរនេះ។

- មតិទូទៅលេខ២៥ ដើរតួនាទីជាផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋនានា ដើម្បីធានាថា សិទ្ធិរបស់កុមារត្រូវបានការពារ និងបំពេញនៅក្នុងពិភពឌីជីថល។ វាបង្ហាញពីតម្រូវការសម្រាប់វិធីសាស្ត្រពហុភាគីដែលពាក់ព័ន្ធនឹងរាជរដ្ឋាភិបាល អាជីវកម្ម និងសង្គមស៊ីវិល ដើម្បីបង្កើតកន្លែងឌីជីថលដែលមានសុវត្ថិភាព និងផ្ដល់សិទ្ធិអំណាចដល់កុមារទាំងអស់។

តាមរយៈមេរៀននេះ អ្នកបានបានយល់ដឹងអំពីសិទ្ធិកុមារទាំងចំនួន៥៤ ដែលមានចែងនូវក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ គឺជាកិច្ចព្រមព្រៀងដ៏សំខាន់របស់ប្រទេសជាហត្ថលេខី ដែលបានសន្យាការពារសិទ្ធិរបស់កុមារ។ អ្នកក៏បានសិក្សាផងដែរអំពីសិទ្ធិកុមារនៅក្នុងពិភពឌីជីថល ដែលផ្អែកទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ព្រមទាំងចំណុចទាំងឡាយដើម្បីគាំពារជានាសុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញ ដូចជា សិទ្ធិរក្សាព័ត៌មានផ្ទាល់ខ្លួន រក្សាឯកជនភាព ការយល់ព្រម និងគ្រប់គ្រងនូវផ្ទាល់ខ្លួន សិទ្ធិចូលប្រើមាតិកា និងទទួលបាននូវព័ត៌មានតាមអនឡាញ ដែលសមស្រប ទៅតាមអាយុ និងដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ។ កុមារក៏មានសិទ្ធិបញ្ចេញនូវមតិយោបល់ និងទស្សនៈរបស់ខ្លួនផងដែរ នៅលើបញ្ហាផ្សេងៗ ដែលជះឥទ្ធិពលដល់ពួកគេ។ នៅពេលកុមារមាន អាយុ និងសមត្ថភាពសមស្រប កុមារមានសិទ្ធិចូលរួមចំណែក និងចែករំលែកមាតិកានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបង្ហាញពីភាពច្នៃប្រឌិត បទពិសោធន៍ និងភាពជាបុគ្គលរបស់ពួកគេ។ ពួកគេក៏មានសិទ្ធិទទួលបានការពារពេញលេញទាំងនៅក្នុង និងក្រៅប្រព័ន្ធអនឡាញផងដែរ។

អនុសាសន៍ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិលេខ២៥ ស្តីពីសិទ្ធិកុមារ ទាក់ទងនឹងស្ថានភាពឌីជីថល បានចែងពីកាតព្វកិច្ចរបស់ប្រទេសជាសមាជិក ដើម្បីធានាថា សិទ្ធិកុមារត្រូវបានគោរពទាំងនៅក្រៅបណ្តាញ និងលើបណ្តាញ។ វាធ្វើការលើកទឹកចិត្តដើម្បីការពារកុមារពីគ្រោះថ្នាក់ ផ្តល់ឱ្យពួកគេនូវការទទួលដំណឹង សិទ្ធិចូលរួម និងការអប់រំ។ សិទ្ធិឌីជីថលរបស់កុមាររួមមាន ការចូលប្រើមាតិកា តាមអាយុពួកគេ ការពារព័ត៌មានផ្ទាល់ខ្លួន ការពារពីគ្រោះថ្នាក់ ឬអំពើបំពានលើអ៊ីនធឺណិត ការអប់រំស្តីពីអក្ខរកម្ម និងជំនាញឌីជីថល ព្រមទាំងសេរីភាពក្នុងការបញ្ចេញមតិយោបល់ ដោយគ្មានការរើសអើង។

# គោលការណ៍អនុវត្តបែបកុមារមេត្រី

អ្នកបានសិក្សារួចហើយអំពីសិទ្ធិរបស់កុមារ ដែលមានចែងនូវក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ និងសិទ្ធិកុមារដែលមានក្នុងពិភពឌីជីថល។ វាមិនថាទោះស្ថិតនៅក្នុងស្ថានភាពឬកាលៈទេសៈបែបណាក៏ដោយនោះទេ កុមាររងគ្រោះដោយសារអំពើរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ ត្រូវតែទទួលបានការការពារ និងការទទួលបានជំនួយពិសេសពីអ្នកផ្តល់សេវានៅគ្រប់មុខជំនាញអង្គភាពពាក់ព័ន្ធ ជាពិសេសសេវាគាំទ្រផ្នែកច្បាប់។ ដើម្បីបំពេញភារកិច្ចនេះបានត្រឹមត្រូវមន្ត្រីនគរបាល អនុវត្តច្បាប់ និងផ្តល់សេវាជំនាញ ជាពិសេសមន្ត្រីនគរបាល ត្រូវរៀនសូត្រ និងអនុវត្តតាមគោលការណ៍ប្រតិបត្តិបែបកុមារមេត្រី ដែលផ្តោតលើការទទួលខុសត្រូវផ្នែកសីលធម៌ និងអាកប្បកិរិយារបស់មន្ត្រីនគរបាល និងភាគីពាក់ព័ន្ធ ដើម្បីធានា ថាកុមារ និងគ្រួសារទទួលបានការការពារសិទ្ធិ និងឧត្តមប្រយោជន៍យ៉ាងល្អបំផុតតាមដែលអាចធ្វើទៅបាន។

ក្នុងមេរៀននេះ អ្នកសិក្សាអំពីគោលការណ៍សំខាន់ៗនៃការអនុវត្តបែបកុមារមេត្រី និងពង្រឹងសមត្ថភាព និងជំនាញដល់មន្ត្រីនគរបាល ក្នុងការងារស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើសផ្លូវភេទលើកុមារ ដោយផ្តោតលើការគិតគូរដល់ជនរងគ្រោះ តាមរយៈការធានាការគោរពសិទ្ធិកុមារពេញលេញ និងការការពារដ៏ល្អ បំផុតដែលអាចធ្វើទៅបានចំពោះកុមាររងគ្រោះ។

កុមាររងគ្រោះនៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ត្រូវការការការពារ និងការទទួលបានជំនួយ ពិសេសក៏ដូចជាភាពងាយស្រួលក្នុងការទទួលបាននូវយុត្តិធម៌បែបកុមារមេត្រី។ គោលការណ៍ប្រតិបត្តិ បែបកុមារមេត្រី ជាវិធីសាស្ត្រមួយដែលបានទទួលស្គាល់ជាទូទៅ ព្រោះវាត្រូវបានពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ជាមួយមន្ត្រីនគរបាល នៅកម្រិតផ្សេងៗគ្នា និងត្រូវបានតាក់តែង ដោយសមស្របទៅ នឹងបរិបទនៃប្រទេសកម្ពុជា និងស្របតាមស្តង់ដារអន្តរជាតិ។ គោលការណ៍ ប្រតិបត្តិបែបកុមារមេត្រី មានគោលបំណង ពង្រឹងសមត្ថភាព និងជំនាញដល់មន្ត្រីនគរបាល ក្នុងការងារស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើស ផ្លូវភេទលើកុមារ ដោយផ្តោតលើការគិតគូរដល់ជនរងគ្រោះតាមរយៈការធានាការគោរពសិទ្ធិកុមារពេញលេញ និងការពារដ៏ល្អបំផុតដែលអាចធ្វើទៅបានចំពោះកុមាររងគ្រោះ។



បន្ទាប់ពីបានសិក្សាមេរៀននេះចប់មន្ត្រីនគរបាល និងផ្ដល់សេវាគាំពារដល់កុមាររងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទ និងកេងប្រវញ្ចផ្លូវភេទកុមារទាំងអស់ នឹងអាចអនុវត្តការងាររបស់ខ្លួនបានល្អប្រសើរ និងមានប្រសិទ្ធិភាពជាងមុន ជាពិសេសចេះទទួលខុសត្រូវ គោរពក្រមសីលធម៌ មានឥរិយាបថអាកប្បកិរិយា និងការប្រព្រឹត្តដែលមានភាពស្និទ្ធស្នាល ដែលធានាឱ្យកុមារ និងក្រុមគ្រួសាររបស់ពួកគេមានភាពកក់ក្ដៅ ទទួលបានការជឿទុកចិត្ត ពីព្រោះសិទ្ធិរបស់ពួកគេត្រូវបានការពារ និងឧត្តមប្រយោជន៍របស់ពួកត្រូវបានយកចិត្តទុកដាក់ខ្ពស់។

## ក ការអនុវត្តបែបកុមារមេត្រី

គោលគំនិតនៃ «ការអនុវត្តបែបកុមារមេត្រី» សម្រាប់មន្ត្រីនគរបាល មានន័យថាជាការអនុវត្តដែលធានាថា ពេលដែលកុមារមកទាក់ទងជាមួយមន្ត្រីនគរបាល និងប្រព័ន្ធយុត្តិធម៌ ពួកគេនឹងទទួលបានការប្រព្រឹត្តតាមរបៀបមួយដែលត្រឹមត្រូវ សមរម្យ និងមិនបង្កគ្រោះថ្នាក់ដល់ពួកគេទេ។

គោលការណ៍ប្រតិបត្តិបែបកុមារមេត្រីនេះ[12] គឺផ្ដោតលើការទទួលខុសត្រូវផ្នែកសីលធម៌ និងអាកប្បកិរិយារបស់មន្ត្រីនគរបាល និងភាគីពាក់ព័ន្ធដើម្បីធានាថាកុមារ និងគ្រួសារទទួលបានការការពារសិទ្ធិ និងឧត្តមប្រយោជន៍យ៉ាងល្អបំផុតតាមដែលអាចធ្វើទៅបាន។ គោលការណ៍ប្រតិបត្តិបែបកុមារមេត្រីនេះ ផ្ដោតសំខាន់ ទៅលើការអនុវត្តល្អបំផុត ដែលមានចែងក្នុងគោលការណ៍ណែនាំស្ដីពីការ

[12] ប្រភព៖ ដកស្រង់ចេញពីសៀវភៅគោលការណ៍ប្រតិបត្តិកុមារមេត្រីរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

ឆ្លើយតប និងការទប់ស្កាត់អំពើ ហិង្សាផ្លូវភេទ របស់ឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួន នៃអង្គការសហប្រជាជាតិ (UNHCR) យុត្តិធម៌ សម្រាប់កុមារនៃអង្គការយូនីសេហ្វ និងការអនុវត្តល្អបំផុតរបស់កម្ពុជាក្នុងការពិគ្រោះយោបល់ ជាមួយមន្ត្រី នគរបាលជាតិ ក្នុងបរិបទប្រទេសកម្ពុជា និងការកែតម្រូវតាមស្តង់ដារអន្តរជាតិ។

### ក.១- ការលើកកម្ពស់សិទ្ធិកុមារ-វិធីសាស្ត្រផ្តោតលើការគោរពសិទ្ធិ

កុមារគ្រប់រូបគួរតែទទួលបានការថែទាំ និងការព្យាបាលដែលមានគុណភាពខ្ពស់ ដោយមិនប្រកាន់ពូជ សាសន៍ ពណ៌សម្បុរ សាសនា ភេទ ស្ថានភាពគ្រួសារ ឬឋានៈអ្នកថែទាំរបស់ពួកគាត់ សាវតាវប្បធម៌ ស្ថានភាពហិរញ្ញវត្ថុ សមត្ថភាពពិសេស ឬពិការភាពឡើយ។ ជនរងគ្រោះមានសិទ្ធិទទួលបានការការពារ ការប្រឹក្សាយោបល់ និងការជូនដំណឹងអំពីវិធានការទាំងអស់ ដែលត្រូវបានគេយកទៅប្រើប្រាស់។ កុមារ មានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តរាល់សកម្មភាពទាំងឡាយដែលមានផលប៉ះពាល់ដល់ជីវិតរបស់ពួកគាត់។

ព័ត៌មានអំពីបទពិសោធន៍នៃការរំលោភបំពានលើកុមារ គួរត្រូវបានប្រមូលប្រើប្រាស់រួមគ្នា និងរក្សាទុកក្នុង លក្ខខណ្ឌរក្សាការសម្ងាត់។ ឧត្តមប្រយោជន៍របស់កុមារគួរជាអាទិភាពដំបូងនៅក្នុងការសម្រេចចិត្តណាមួយ ដែលធ្វើឡើងដោយមន្ត្រីនគរបាល ព្រះរាជអាជ្ញា ចៅក្រម និងភាគីពាក់ព័ន្ធផ្សេងទៀត។

### ក.២- ការអនុវត្តនីតិវិធីតាមបែបកុមារមេត្រី-វិធីសាស្ត្រផ្តោតលើកុមារ

សកម្មភាពណាមួយដែលត្រូវបានផ្តួចផ្តើម ដោយមន្ត្រីនគរបាលគួរតែធានាថាកុមារដែលចូលរួមក្នុង នីតិវិធីទទួលបានការគិតគូរជាចម្បង។ ក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងកុមាររងគ្រោះ ឬកុមារជាសាក្សី វិធានការ និងការការពារ គួរតែត្រូវអនុវត្តដើម្បីការពារពួកគាត់ពីការភ័យខ្លាច ការសងសឹក ឬការប៉ះទង្គិច ដោយប្រយោល ពេលដែលពួកគាត់ចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌។ ឧទាហរណ៍៖ សម្រាប់ កុមាររងគ្រោះ (១)-មិនត្រូវបានគេចាត់ទុកថាជាជនល្មើស (២)-មិនត្រូវក្លាយជាជនរងគ្រោះឡើងវិញម្តងទៀត (៣)-មិនត្រូវបានគេស្អប់ខ្ពើម និង(៤)-មានសិទ្ធិទទួលបានជំនួយគាំទ្រ។

### ក.៣- ការរួមបញ្ចូលសេវាកម្មពហុវិស័យ-វិធីសាស្ត្រពហុជំនាញ

មន្ត្រីនគរបាលនិងភាគីពាក់ព័ន្ធគួរធ្វើការរួមគ្នា ដោយមានទំនួលខុសត្រូវ និងគណនេយ្យភាពរួមគ្នា ក្នុងការគ្រប់គ្រង និងផ្តល់សេវាគាំទ្រសមស្របដល់កុមារ នៅក្នុងបរិបទនៃគ្រួសារ សហគមន៍ និងសង្គម។ ការគ្រប់គ្រងករណីរំលោភបំពានលើកុមារ គឺជាការងារពហុវិស័យ (ភ្នាក់ងាររាជរដ្ឋាភិបាល

ថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គភាព សាសនា សង្គមស៊ីវិល និង ឯកជន) និង ពហុជំនាញ (មន្ត្រីនគរបាល ព្រះរាជអាជ្ញា ចៅក្រម មេធាវី បុគ្គលិកសង្គមកិច្ច អ្នកផ្តល់សេវាវេជ្ជសាស្ត្រ និងអ្នកជំនាញ ផ្នែកផ្លូវចិត្ត អ្នកឯកទេសខាងវិកលចរិត ជំងឺចិត្តវិកល និងមន្ត្រីពាក់ព័ន្ធដទៃផ្សេងៗទៀត) ធ្វើការរួមគ្នា ជាក្រុមតែមួយ ដើម្បីផ្តល់ការការពារ សេវាច្បាប់ និងសេវាសង្គម ដល់កុមាររងគ្រោះពីការរំលោភបំពាន ការមិនអើពើ និង ការកេងប្រវ័ញ្ច។ មន្ត្រីនគរបាលចាំបាច់ត្រូវសម្របសម្រួល ជាមួយភាគី ពាក់ព័ន្ធទាំងនេះ ដើម្បីធ្វើការរួមគ្នា និងភាពជាដៃគូ ។

### ក.៨- ការដោះស្រាយបញ្ហាយេនឌ័រ-វិធីសាស្ត្រផ្តោតលើយេនឌ័រ

វិធីសាស្ត្រនេះទទួលស្គាល់ថា ការយល់ឃើញ បទពិសោធន៍ និងចំណាប់អារម្មណ៍របស់ស្ត្រី និង កុមារ អាចខុសគ្នាពីការយល់ឃើញរបស់បុរស ដែលកើតចេញពីការយល់ដឹងពីតួនាទីសង្គម និងតួនាទីយេនឌ័ររបស់ពួកគាត់។ ការផ្តល់សេវាដែលផ្តោតលើយេនឌ័រដល់កុមារ ដែលត្រូវគេរំលោភបំពាន ចាំបាច់ត្រូវមានវិធី សាស្ត្រផ្អែកលើសិទ្ធិ ពោលគឺឆ្លើយតបទៅនឹងតម្រូវការពិសេសរបស់ជនរងគ្រោះគ្រប់ពេលវេលា និងគ្រប់ ដំណាក់កាលដោយយោងទៅតាមការគោរព និងការលើកកម្ពស់សេចក្តីថ្លៃថ្នូរជាសិទ្ធិដែលមានមកពីកំណើតរបស់ពួកគាត់។ មន្ត្រីនគរបាលទទួលស្គាល់ និងដោះស្រាយបញ្ហាលម្អៀងផ្នែកយេនឌ័រ ដែលមានចំពោះជនរងគ្រោះជាកុមារ។

### ក.៩- ការពង្រឹងភាពអត់ធ្មត់របស់កុមារ-វិធីសាស្ត្រផ្តោតលើគ្រួសារ និងសហគមន៍

វិធីសាស្ត្រនេះទទួលស្គាល់ថា គ្រួសារ និងសហគមន៍ គឺជាអាទិភាពឆ្លើយតបដំបូងក្នុងការដោះស្រាយបញ្ហារបស់កុមារ ដូច្នេះការអន្តរាគមន៍នានា គួរតែពង្រឹងសមត្ថភាពគ្រួសារ និងសហគមន៍ ដើម្បីថែទាំពួកគាត់ ។

## ខ តើពួកគេគិតថា ការអនុវត្តបែបកុមារមេត្រីអាចមានអត្ថប្រយោជន៍អ្វីខ្លះដល់កុមារ?

### ខ.១- គោលការណ៍ទូទៅ៖

- ការប្រើនីតិវិធីក្នុងការអនុវត្តបែបកុមារមេត្រី-វិធីសាស្ត្រដោយផ្តោតលើកុមារជាសំខាន់
- ធ្វើការក្នុងភាពជាដៃគូ ដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាព
- មានវិធីសាស្ត្រដោយគិតអំពីយេនឌ័រ
- **ការសម្ភាសៈ** ផ្តល់អាទិភាពដល់សុខុមាលភាព និងប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ

### ខ.២- តម្រូវការចាំបាច់៖

- ការបង្កើតបរិយាកាសបែបកុមារមេត្រី
- មានវត្តមានរបស់អ្នកគាំទ្រ
- មានវត្តមានមន្ត្រីសង្គមកិច្ច
- កុមារដែលមានពិការភាព
- យេនឌ័ររបស់មន្ត្រីនគរបាលដែលធ្វើបទសម្ភាសន៍
- មិនឱ្យកុមារទំនាក់ទំនងជាមួយនឹងជនសង្ស័យ
- កែសម្រួលការប្រើប្រាស់ភាសាស្របទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារ

## គ បង្កើតបរិយាកាសបែបកុមារមេត្រី៖

- ការសម្ភាសជាមួយកុមារគួរតែធ្វើឡើងក្នុងកន្លែងឯកជន ប្រកបដោយផាសុកភាព ដែលមិនមានការរំខាន (ឧទាហរណ៍៖ សំឡេងទូរស័ព្ទរោទ៍ មនុស្សដើរចេញចូល) និងមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តសម្រាប់កុមារ និងសមាជិកគ្រួសារ។
- ការសម្ភាសជាមួយកុមាររងគ្រោះ និងកុមារជាសាក្សី មិនគួរណាធ្វើឡើងនៅក្នុងការិយាល័យដ៏មមាញឹក ដែលមានមនុស្សអាចមើលឃើញកុមារ និងស្តាប់ឮអ្វីដែលពួកគេនិយាយនោះទេ។
- ប្រដាប់ប្រដាក្មេងលេង និងហ្គេមអាចមានប្រយោជន៍ពេលកុមារកំពុងរង់ចាំមុនពេលសម្ភាសន៍ ប៉ុន្តែគួរតែត្រូវបានយកទុកវិញក្នុងពេលសម្ភាសន៍ ដើម្បីកុំឱ្យមានការរំខានដល់កុមារ។
- ប្រសិនបើមិនមានកន្លែងបែបកុមារមេត្រីនៅក្នុងប៉ុស្តិ៍នគរបាលសម្រាប់កុមារទេ សូមស្នើសុំប្រើប្រាស់កន្លែងដែលមានសុវត្ថិភាពសម្រាប់កុមាររបស់ភាគីដែលពាក់ព័ន្ធផ្សេងទៀត (ដូចជាកន្លែងរបស់បុគ្គលិកសង្គមកិច្ច ឬអង្គការមិនមែនរដ្ឋាភិបាល)។
- មន្ត្រីនគរបាលគួរជៀសវាងពាក់ឯកសណ្ឋានពេញលេញជានគរបាល ព្រោះជារឿយៗវាអាចធ្វើឱ្យកុមារ មានអារម្មណ៍ភ័យខ្លាច (គួរស្លៀកសំលៀកបំពាក់ស៊ីវិល)។
- មន្ត្រីនគរបាលគួរតែអង្គុយក្បែរកុមារ ជាជាងអង្គុយនៅចំពីមុខកុមារ ដើម្បីជៀសវាងការប្រឈមមុខដាក់គាត់។

### អ្វីដែលគួរឱ្យចាប់អារម្មណ៍ និង/ឬការរៀនសូត្រ៖

- មានកន្លែងឯកជន អាចធ្វើឱ្យកុមារ និងគ្រួសាររបស់ពួកគេមានអារម្មណ៍ សុវត្ថិភាព
- ការយល់ដឹងថាកន្លែងបែបកុមារមេត្រី អាចជួយឱ្យកុមារមានអារម្មណ៍ធូរស្រាលជាងមុន
- ឯកសណ្ឋានរបស់មន្ត្រីនគរបាលក៏អាចជាការរារាំងដល់កុមារ
- ប្រើកន្លែងនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាល ប្រសិនបើមិនមានកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារ។ វាអាចមិនសូវស្រួល ប៉ុន្តែមានប្រយោជន៍សម្រាប់កុមារ។

### អត្ថប្រយោជន៍សម្រាប់កុមារ៖

- *ប្រសិនបើពួកគេមានអារម្មណ៍ថាមានសុវត្ថិភាពជាងនេះ តើពួកគេអាចចែករំលែកបានច្រើនជាងនេះដែរឬទេ?*

ដើម្បីធានាថាមានការអនុវត្តតាមគោលការណ៍ នៃការមានសុវត្ថិភាពសម្រាប់កុមារ ក្នុងនាមយើងជាមន្ត្រីនគរបាលយើងគួរ៖

*យើងអាចស្នើសុំធនធានសម្រាប់បន្ទប់កុមារមេត្រី នៅការិយាល័យរបស់យើង ប្រសិនបើមិនមានទេ យើងអាចធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រើប្រាស់កន្លែងឯកជនប្រសិនបើពួកគេមាន ដូចជាបន្ទប់កុមារមេត្រីដែលរៀបចំដោយអង្គការសកម្មភាពដើម្បីកុមារនៅតាមរាជធានី ខេត្តគោលដៅ ដូចជា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនៅតាមស្នងការដ្ឋាននគរបាល ខេត្តសៀមរាប បាត់ដំបង កណ្តាល និងកំពតជាដើម ។*

## ឃ នីតិវិធីប្រតិបត្តិបែបកុមារមេត្រី[13]

### ឃ.១- ចរិតលក្ខណៈនៃនីតិវិធីប្រតិបត្តិការបែបកុមារមេត្រី

- សុខុមាលភាពរបស់កុមារជាអាទិភាព

ប្រសិនបើកុមាររងគ្រោះមានការបារម្ភខ្លាំងក្នុងការសម្ភាសភ្លាមៗ សូមពន្យារពេលសម្ភាសន៍រហូតដល់កុមារត្រៀមខ្លួនបានរួចរាល់។ សម្របសម្រួលជាមួយឪពុកម្តាយ ឬ អាណាព្យាបាលរបស់កុមារ និងមន្ត្រីជំនួយផ្នែកសុខុមាលភាពសង្គម ឬវិជ្ជាជីវៈ ដើម្បីកំណត់ថា កុមារអាចផ្តល់បទសម្ភាសដោយសុវត្ថិភាព។ ត្រូវធ្វើការសម្ភាសឱ្យបានហ្មត់ចត់ដើម្បីជៀសវាងការសម្ភាសច្រើនដង និងសម្រាកក្នុងអំឡុងពេលសម្ភាសន៍តាមតម្រូវការរបស់កុមារ។

[13] ប្រភព៖ ដកស្រង់ចេញពីសៀវភៅគោលការណ៍ប្រតិបត្តិកុមារមេត្រីរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

## ● បង្កើតបរិយាកាសបែបកុមារមេត្រី

ការសម្ភាសជាមួយកុមារ គួរត្រូវបានធ្វើឡើងនៅក្នុងកន្លែងឯកជនដែលមានផាសុកភាព ជៀសវាងពីការរំខាន (ឧទាហរណ៍៖ ទូរស័ព្ទពេទ៌ មនុស្សដើរចេញ ដើរចូលជាដើម) និងមានទាំងសុវត្ថិភាពខាងរាងកាយ ផ្លូវចិត្ត សម្រាប់កុមារ និងគ្រួសារ។ សម្ភារៈក្មេងលេងមានប្រយោជន៍ និងធ្វើឱ្យកុមារមានផាសុកភាព និង ភាពងាយស្រួល ខណៈពេលដែលពួកគាត់កំពុងអង្គុយរង់ចាំ ប៉ុន្តែត្រូវយកសម្ភារៈទាំងនោះចេញវិញ ក្នុងអំឡុងពេលសម្ភាសន៍ ដើម្បីជៀសវាងការរំខាន។ ប្រសិនបើគ្មានកន្លែងសមរម្យសម្រាប់កុមារនៅប៉ុស្តិ៍នគរបាល គួរស្នើសុំប្រើប្រាស់កន្លែង កុមារមេត្រីពីភាគីពាក់ព័ន្ធផ្សេងៗទៀត ដូចជាកន្លែងមន្ទីរសង្គមកិច្ច ឬ អង្គការមិនមែនរដ្ឋាភិបាលជាដើម)។ មន្ត្រីនគរបាលគួរតែអង្គុយនៅក្បែរកុមារជាជាងអង្គុយទល់មុខផ្ទាល់ជា មួយកុមារ។

## ● រៀបចំឱ្យមានវត្តមានអ្នកគាំទ្រ

ឪពុកម្តាយ អាណាព្យាបាល ឬសាច់ញាតិរបស់កុមារ ត្រូវមានវត្តមានជាមួយកុមារសម្រាប់ការសម្ភាស ដើម្បីសម្រួលដល់កុមារ។ សាកសួរកុមារ ប្រសិនបើកុមារត្រូវការអ្នកអម នោះឪពុកម្តាយ អាណាព្យាបាល សាច់ញាតិ ឬអ្នកគាំទ្រ អាចអង្គុយក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងការសម្ភាស។ ប្រសិនបើឪពុកម្តាយ ឬ អាណាព្យាបាលមានវត្តមាន សូមចាំថា ការផ្តោតអារម្មណ៍នៃការសម្ភាសចំពោះតែកុមាររងគ្រោះ និង/ឬកុមារ ជាសាក្សីតែប៉ុណ្ណោះ មិនមែនផ្តោតទៅលើឪពុកម្តាយ ឬអាណាព្យាបាលនោះទេ។ មនុស្សពេញវ័យផ្សេងៗទៀត ដែលមិនពាក់ព័ន្ធ មិនគួរចូលរួមយ៉ាងសកម្មក្នុងការសម្ភាសទេ។ ឪពុកម្តាយ ឬអ្នកគាំទ្រផ្សេងៗទៀត មិនត្រូវមានវត្តមានទេ ប្រសិនបើនគរបាលមានការបារម្ភថាពួកគាត់អាចប៉ះពាល់ដល់កុមារក្នុងពេលផ្តល់សក្ខីកម្ម។

## ● អនុញ្ញាតឱ្យកម្លាំងសេវាសង្គមចូលរួមក្នុងការសម្ភាស

តាមដែលអាចធ្វើទៅបាន ការសម្ភាសគួរតែត្រូវបានធ្វើឡើង ដោយមានវត្តមានរបស់មន្ត្រីផ្នែកសុខុមាលភាពសង្គម ដើម្បីកាត់បន្ថយការប៉ះពាល់អារម្មណ៍ផ្លូវចិត្ត ដែលកើតចេញពីការសម្ភាស និងដើម្បីផ្តល់ការគាំទ្រ ដល់កុមារតាមតម្រូវការ។ ប្រសិនបើកុមារមានពិការភាព ដែលប៉ះពាល់ដល់សមត្ថភាពក្នុងការប្រាស្រ័យទាក់ទងរបស់ពួកគេ វាជាការចាំបាច់ណាស់ក្នុងការរៀបចំឱ្យមានអ្នកឯកទេសចូលរួម (ឧទាហរណ៍៖ អ្នកបកប្រែភាសាសញ្ញា អ្នកចិត្តសាស្ត្រ។ល។) ក្នុងករណីដែលកុមាររងគ្រោះជាកុមារី នោះអ្នកចូលរួមគាំទ្រ និងមន្ត្រី សម្ភាសន៍គួរតែជាស្ត្រី។

### ● កាត់បន្ថយទំនាក់ទំនងរវាងកុមារ និងជនសង្ស័យ

ក្នុងស្ថានភាពណាក៏ដោយ មន្ត្រីនគរបាលមិនត្រូវអនុញ្ញាតឱ្យជនសង្ស័យ និងកុមារមានវត្តមាននៅ ក្នុងបន្ទប់ជាមួយគ្នានោះទេ។ ការសម្ភាសមិនគួរត្រូវបានធ្វើឡើងដោយមានវត្តមានជនសង្ស័យ ឬអ្នកដែលមិនពាក់ព័ន្ធឡើយ។ ប្រសិនបើមានតម្រូវការឱ្យកុមារចង្អុលបង្ហាញអត្តសញ្ញាណជនសង្ស័យ គួរតែត្រូវបានធ្វើឡើង តាមរយៈរូបថត ឬតាមផ្ទាំងកញ្ចក់ដែលកុមារអាចមើលឃើញជនសង្ស័យ ប៉ុន្តែជនសង្ស័យមិនអាចមើលឃើញកុមារទេ។

### ● ប្រើប្រាស់ភាសាសមស្របទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារ

មន្ត្រីនគរបាលគួររៀបចំកម្រងសំណួរ ដែលមានលក្ខណៈសមស្របទៅនឹងអាយុ និងកម្រិតយល់ដឹងរបស់កុមារ ហើយសំណួរគួរតែសួរខ្លី សាមញ្ញ ចំៗ និងងាយយល់។

### ● ត្រូវធានានូវទំនុកចិត្ត និងមិនធ្វើបុរេវិនិច្ឆ័យ

មន្ត្រីនគរបាលគួរពិចារណាស្លៀកសំលៀកបំពាក់ស៊ីវិលប្រសិនបើវាជួយក្នុងការធ្វើឱ្យកុមារមានអារម្មណ៍ល្អផ្តល់ឱ្យកុមារនូវការយកចិត្តទុកដាក់ បង្ហាញថាអ្នកកំពុងស្តាប់ និងចាប់អារម្មណ៍លើកុមារ។ មន្ត្រីនគរបាល មិនត្រូវបង្ហាញការភ្ញាក់ផ្អើល ការមិនជឿទុកចិត្ត ការខឹង ការស្អប់ខ្ពើម ឬការបង្ហាញប្រតិកម្មផ្លូវចិត្ត ផ្សេងទៀតចំពោះអ្វីដែលអ្នកស្តាប់ឮពីកុមារនោះទេ។ ត្រូវដឹងពីតម្រូវការ និងអារម្មណ៍របស់កុមារ ហើយមិនត្រូវព្យាយាមផ្តល់យោបល់អវិជ្ជមាន ឬការវាយតម្លៃជាមុននោះទេ។

### ● ការប្រើប្រាស់ឧបករណ៍ជំនួយ ឬឧបករណ៍អេឡិចត្រូនិកក្នុងការសម្ភាស

គោលដៅនៃការសម្ភាសនេះ គឺដើម្បីឱ្យកុមារអាចនិយាយរៀបរាប់ពីបទពិសោធន៍របស់ពួកគេ ប៉ុន្តែ ប្រសិនបើកុមារ មិនអាចនិយាយរៀបរាប់ជាពាក្យសំដីបានទេ មន្ត្រីនគរបាលគួរតែប្រើប្រាស់ឧបករណ៍ជំនួយក្នុងការសម្ភាស ដូចជាក្រដាសពណ៌ ហ្វឺត គំនូររាងកាយ ឬតុក្កតាក្នុងអំឡុងពេលសម្ភាសន៍ដើម្បីជួយសម្រួលដល់ការពិពណ៌នារបស់កុមារ។ ឧបករណ៍ ថតសម្លេងអេឡិចត្រូនិក គឺជាមធ្យោបាយពេញលេញ និងត្រឹមត្រូវបំផុតក្នុងការសម្ភាស ដោយវាអាចថតបានការសន្ទនារវាងកុមារ និងអ្នកសម្ភាសន៍ ដូចជាពាក្យសម្តី គន្លឹះច្បាស់លាស់នៃការសាកសួរ និងកាត់បន្ថយចំនួនដងនៃការសម្ភាស។

- **ស្នើសុំឱ្យកុមារចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត**

កុមារមានសិទ្ធិចូលរួមយ៉ាងសកម្ម នៅក្នុងការសម្រេចចិត្តដែលពាក់ព័ន្ធនឹងពួកគាត់។ នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាល រួមបញ្ចូលទាំងការជូនដំណឹងដល់កុមារអំពីដំណាក់កាល និងគោលបំណងនៃការសម្ភាស និងផ្តល់ឱកាសឱ្យកុមារចូលរួមក្នុងការសម្រេចចិត្តថា តើនរណាអាចនឹងមានវត្តមាន របៀបសម្ភាសន៍បែបណាអាចត្រូវបានធ្វើឡើង ស្របតាមតម្រូវការរបស់ពួកគាត់ និងអ្វីដែលនឹងកើតឡើងទៀតបន្ទាប់ពីការសម្ភាស។

### ឃ.២- ការពិចារណាលើការធ្វើការជាមួយកុមាររងគ្រោះ

កុមារ ជាពិសេសកុមារដែលមានវ័យក្មេងមានការប្រាស្រ័យទាក់ទងខុសគ្នាពីមនុស្សពេញវ័យ កុមារខ្លះអាច និងកុមារខ្លះមិនអាចបង្ហាញពីគំនិត ការចងចាំ យោបល់ និងការគិត តាមរបៀបដូចគ្នាទៅនឹងមនុស្សពេញវ័យបានទេ។ ការមានចំណេះដឹងអំពីកុមារ អាចធ្វើឱ្យមន្ត្រីនគរបាលងាយស្រួលធ្វើការងារ ជាមួយកុមារ ដោយមិនចាំបាច់សួរសំណួរបញ្ជាក់ថាតើ "នរណា"? ដែលសំដៅទៅនោះទេ។ មន្ត្រីនគរបាល មានព័ត៌មានកាន់តែច្រើននៃបញ្ហាដែលកើតមានឡើងចំពោះកុមារ នាំឱ្យមន្ត្រីនគរបាលអាចកសាងទំនាក់ទំនងល្អជាមួយ កុមារ និងលើកឡើងបញ្ហានោះដោយមិនប្រើប្រាស់សំណួរនាំមុខ។

#### ឃ.២.១- ចរិតលក្ខណៈនៃការរំលោភបំពាន

មានកត្តាជាក់លាក់មួយចំនួន ដែលប៉ះពាល់ភាពធ្ងន់ធ្ងរនៃប្រតិកម្មចំពោះការរំលោភបំពានដូចជាៈ ជនល្មើសនៃការរំលោភបំពាន ទោះបីជាមាន ឬគ្មានអំពើហិង្សាក៏ដោយ តើរយៈពេលនៃការរំលោភបំពានបាន កើតឡើងយូរប៉ុណ្ណា? តើកុមារបានផ្តល់ព័ត៌មានប្រាប់នរណាម្នាក់ឬទេ? ហើយតើមានអ្វីកើតឡើងបន្ទាប់ពីការរំលោភបំពាននោះ? កុមាររងគ្រោះនៃការរំលោភបំពានប្រហែលមានអារម្មណ៍ជិតដាម ដក់ជាប់ចំពោះអ្នករំលោភបំពាន ឬបាត់បង់ ទំនុកចិត្តចំពោះមនុស្សពេញវ័យទាំងស្រុងដោយសារតែបទពិសោធន៍របស់ពួកគាត់។ ក្នុងករណីទាំងនេះ មន្ត្រីនគរបាលត្រូវយកចិត្តទុកដាក់លើតម្រូវការនានារបស់កុមារ រួមទាំងតម្រូវការសម្ភាសផងដែរ ដើម្បីបង្កើតទំនាក់ទំនងជាមួយកុមារ និងទទួលបានទំនុកចិត្តពីកុមារដើម្បីឱ្យគាត់មានអារម្មណ៍ល្អ ស្រួលនិយាយការពិត។

#### ឃ.២.២- ការឆ្លើយតបរបស់កុមារចំពោះការប៉ះទង្គិចផ្លូវចិត្ត

កុមាររងគ្រោះ ឬកុមារជាសាក្សីនៃអំពើរំលោភបំពាន និងអំពើកេងប្រវញ្ចផ្លូវភេទ អាចមានប្រតិកម្មប្លែក ចំពោះបទពិសោធន៍របស់ពួកគាត់។ រោគសញ្ញានៃការប៉ះទង្គិចអាចបង្អាក់សមត្ថភាពរបស់កុមារ ឬធន្ទះក្នុង ការរាយការណ៍ ព័ត៌មានអំពីឧប្បត្តិហេតុនោះ។ កុមារដែលទទួលរងនូវការប៉ះទង្គិចធ្ងន់ធ្ងរបំផុត អាចត្រូវបានធ្វើឱ្យប៉ះពាល់ ឬខូចខាតដល់ការចងចាំរបស់ពួកគាត់។ មន្ត្រីនគរបាលគួរតែជៀស

វាងការសាកសួរ ដើម្បី តែទទួលបាននូវចម្លើយពីកុមារ តាមការរំពឹងទុករបស់ខ្លួន នៅពេលដែលកុមារកំពុងមានអារម្មណ៍តានតឹងធ្ងន់ធ្ងរ។ ការបន្តសាកសួរនៅក្នុងស្ថានភាពបែបនេះអាចធ្វើឱ្យកុមារប៉ះទង្គិចផ្លូវអារម្មណ៍កាន់តែខ្លាំង ឬអាចធ្វើឱ្យកុមាររងគ្រោះឡើងវិញ ហើយចម្លើយដែលទទួលបានក៏ពុំមានសុក្រឹតភាពដែរ។

### ឃ.២.៣- អាយុ និងការលូតលាស់ផ្នែកសមត្ថភាពរបស់កុមារ

អាយុ និងសមត្ថភាពនៃការលូតលាស់របស់កុមារ មានឥទ្ធិពលលើការយល់ឃើញរបស់ពួកគាត់អំពីបទពិសោធន៍ និងបរិមាណព័ត៌មាន ដែលគាត់អាចរក្សាទុកក្នុងការចងចាំរយៈពេលវែង។ កុមារតូចៗមានការពិបាកក្នុងការផ្តោតអារម្មណ៍ និងរំឭកនូវការចងចាំបានល្អ នៅពេលពួកគាត់ត្រូវបានសម្ភាសន៍។ ការវាយ តម្លៃកម្រិតនៃការយល់ដឹងរបស់កុមារនៅដំណាក់កាលនេះ និងនៅពេលចាប់ផ្តើមការសម្ភាសត្រូវផ្តោតលើ ការអភិវឌ្ឍរបស់កុមារ ភាសានិយាយការផ្តល់យោបល់ ភាពជឿជាក់ និងទម្លាប់ឆ្លើយតបរបស់កុមារ។ កុំធ្វើអ្វី លើសពីសមត្ថភាពរបស់កុមារ ប្រសិនបើគាត់មិនយល់ សូមសួរសំណួរសាមញ្ញ និងងាយយល់។

### ឃ.២.៤- យេនឌ័រ ជនជាតិ និងការគិតគូរអំពីវប្បធម៌

ត្រូវយល់ដឹងពីភាពខុសគ្នា អំពីភាសា និងវប្បធម៌ នៅក្នុងសហគមន៍ និងយេនឌ័រ ដែលអាចជះឥទ្ធិពល ដល់ការធ្វើការជាមួយនឹងកុមារ។ គ្រួសាររបស់កុមារ ទំនាក់ទំនងសង្គម បរិស្ថានសង្គម និងវប្បធម៌ មាន ឥទ្ធិពល ទៅលើការអភិវឌ្ឍ បែបបទភាសា ការយល់ដឹងពីបទពិសោធន៍ និងសមត្ថភាពក្នុងការផ្តោត ការយកចិត្តទុកដាក់របស់កុមារ។ ភាពខុសគ្នារវាង វប្បធម៌ ភេទ និងភាសា ក៏បង្ហាញពីបញ្ហាប្រឈម នៃការប្រាស្រ័យទាក់ទងគ្នា និងអាចនាំឱ្យមានការយល់ច្រឡំក្នុងអំឡុងពេលសម្ភាសន៍ផងដែរ។ មន្ត្រីនគរបាល គួរមានផែនការដើម្បីដោះស្រាយចំពោះភាពខុសគ្នា ផ្នែកភាសា និងវប្បធម៌ ដូចជាការប្រើសមាជិកសហគមន៍ ជាអ្នកបកប្រែផ្ទាល់មាត់។ ក្នុងករណីមិនមានសមាជិកសហគមន៍បកប្រែទេ គប្បី ពិចារណាសមាជិកគ្រួសារក្នុងការ បកប្រែជំនួស តែត្រូវយកចិត្តទុកដាក់លើភេទរបស់កុមារ ឬតាមការ សម្រេចចិត្តរបស់កុមារ។

## ឃ.៣-ការឆ្លើយតបបែបកុមារមេត្រី

### ឃ.៣.១-ការឆ្លើយតបបឋម

រាល់របាយការណ៍ករណីសង្ស័យនៃការរំលោភបំពានផ្លូវភេទលើកុមារ ត្រូវបានកត់ត្រាទុក និងបានស៊ើបអង្កេតយ៉ាងពេញលេញ បើទោះបីជាការរំលោភបំពានបានកើតឡើងជាច្រើនខែ ឬច្រើនឆ្នាំក៏ដោយ។ រាល់ករណីសង្ស័យ នៃការរំលោភបំពានផ្លូវភេទលើកុមារ ការមិនយកចិត្តទុកដាក់ព្រងើយកន្តើយ ការកេងប្រវញ្ច ការបោះបង់ចោល ឬការជួញដូរ មន្ត្រីនគរបាលត្រូវតែធ្វើការស៊ើបអង្កេតឱ្យបាន

ឆាប់តាមដែលអាចធ្វើទៅបាន ដោយគ្មានការពន្យារពេលឡើយ។ ការរាយការណ៍ អាចត្រូវបានធ្វើឡើង តាមរយៈទូរស័ព្ទពីកុមាររងគ្រោះផ្ទាល់ ឬ តតិយជន។

មន្ត្រីនគរបាលដែលជាអ្នកឆ្លើយតបដំបូងគួរយកចិត្តទុកដាក់ និងផ្តល់ទំនុកចិត្ត ហើយធានាថា ជនរងគ្រោះនឹងមិនត្រូវបានធ្វើការវិនិច្ឆ័យជាមុនទេ។ ប្រសិនបើមន្ត្រីនគរបាលមានការគោរពសិទ្ធិ និង ឧត្តមប្រយោជន៍កុមារ និងគ្រួសារនោះពួកគាត់នឹងមានទំនុកចិត្តលើមន្ត្រីនគរបាល និងចូលរួមក្នុងដំណើរ ការស៊ើបអង្កេត។ អ្នកឆ្លើយតបដំបូងមិនគួរសម្ភាសន៍ពេញលេញជាមួយកុមារទេ ដើម្បីកាត់បន្ថយ ចំនួនដង ដែលកុមារត្រូវផ្តល់ព័ត៌មានអំពីអង្គហេតុ។ មន្ត្រីនគរបាលគួរទទួលបានព័ត៌មានទូទៅអំពី បទល្មើស ប៉ុន្តែមិនមែនជាព័ត៌មានលម្អិតទេ។

### ឃ.៣.២-ព័ត៌មានដែលត្រូវប្រមូលដំបូងរួមមាន៖

- ឈ្មោះរបស់ជនរងគ្រោះ អាយុ អាសយដ្ឋាន លេខទូរស័ព្ទ
- ពេលវេលា និងទីកន្លែងកើតហេតុ
- ឈ្មោះ និង/ឬការពិពណ៌នាអំពីជនល្មើស
- មធ្យោបាយ ទិសដៅ និងពេលចាកចេញរបស់ជនល្មើស។

មន្ត្រីនគរបាលអាចយកព័ត៌មានពីឪពុកម្តាយ ឬអាណាព្យាបាលផងដែរ។ ព័ត៌មានទំនាក់ទំនង ឬលេខទូរស័ព្ទរបស់មន្ត្រីនគរបាលដែលទទួលខុសត្រូវ គួរត្រូវបានផ្តល់ជូនដល់ជនរងគ្រោះ និងក្រុម គ្រួសារ សម្រាប់ទំនាក់ទំនងបន្ទាន់ ប្រសិនបើមានបញ្ហាសុវត្ថិភាព។

## ក្នុងករណីណាក៏ដោយ ការពិចារណាចម្បង គឺសុខុមាលភាព និងសុវត្ថិភាពរបស់កុមារ៖

១- ប្រសិនបើកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ សូមរៀបចំឱ្យមានមន្ត្រីនគរបាលល្បាតហើយ យកកុមារចេញពីកន្លែងកើតហេតុបន្ទាន់ភ្លាមៗ។ នៅពេលដែលកុមារទៅដល់ប៉ុស្តិ៍នគរបាល គួរនាំគាត់ទៅបន្ទប់បែបកុមារមេត្រី ឬ កន្លែងដែលមានឯកជនភាព។

២- ក្នុងករណីកុមារនៅតែម្នាក់ឯង សូមទាក់ទងឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីឱ្យមកប៉ុស្តិ៍ នគរបាលឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ប្រសិនបើឪពុកម្តាយ ឬអាណាព្យាបាលមិន ជាប់សង្ស័យទេនោះ។ សូមសួរកុមារថា គាត់ស្គាល់មនុស្សពេញវ័យ ឬសាច់ញាតិណាដែល អាចទាក់ទងបានដើម្បីទៅចូលរួមជាមួយគាត់ឬទេ ប្រសិនបើជនសង្ស័យ គឺជាឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ។ ប្រសិនបើគ្មាននរណាម្នាក់អាចទាក់ទងបានទេ សូមទំនាក់

ទំនងមកក្រសួង ឬមន្ទីរពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឱ្យទៅជាមួយកុមារ។ សូមរង់ចាំរហូតដល់ឪពុកម្តាយ ឬអាណាព្យាបាល ឬសាច់ញាតិ ឬមន្ត្រីពាក់ព័ន្ធមកដល់ សូមកុំទុកកុមារឱ្យ នៅតែម្នាក់ឯង។

៣- សូមធ្វើការប៉ាន់ប្រមាណលើតម្រូវការពេញលេញ និងផែនការសុវត្ថិភាព ដោយពិគ្រោះជាមួយក្រុមពហុជំនាញ ដើម្បីផ្តល់នូវការថែទាំ និងសេវាគាំទ្រសមស្រប និងចាំបាច់ដល់កុមារ (ឧទាហរណ៍៖ ការគាំទ្រ ជំនួយផ្នែកច្បាប់ ផ្នែកវេជ្ជសាស្ត្រ ឬទីជម្រកជាដើម)។

មន្ត្រីនគរបាលត្រូវជូនដំណឹងអំពីការរក្សាភស្តុតាង និងផ្តល់ដំបូន្មានដល់កុមាររងគ្រោះ កុំឱ្យផ្លាស់ប្តូរសម្លៀកបំពាក់ ឬលាងសម្អាតខ្លួនប្រាណឡើយ(សំដៅរក្សាភស្តុតាង)។ ប្រភេទនៃភស្តុតាងរួមមាន៖ ទឹកកាម សារធាតុរាវ ដែលចេញពីរាងកាយ ឈាម ទឹកមាត់ សក់ សរសៃអំបោះ ស្រោមអនាម័យ ស្រោមដៃ ស្នាមម្រាមដៃ វត្ថុនានា។ ឧបករណ៍ផ្សេងទៀតដែលត្រូវបានប្រើប្រាស់ពេល រំលោភបំពាន ឧទាហរណ៍៖ ខ្សែចង វត្ថុខ្ទប់ អាវុធ វត្ថុនានា និងពូក ឬសម្ភារៈសម្រាប់ដេក កន្សែង ក្រណាត់ សម្លៀកបំពាក់ ជាលិកា ឬវត្ថុណាមួយផ្សេងទៀត ដែលអាចជាភស្តុតាង DNA។ កុមាររងគ្រោះគួរត្រូវបានលើកទឹកចិត្តឱ្យរង់ចាំ ការចូលរួមរបស់មន្ត្រីនគរបាល និងការពិនិត្យកោសលវិច័យវេជ្ជសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើកុមាររងគ្រោះទទូចចង់ងូតទឹក ផឹកទឹក ឬចូលទៅក្នុងបង្គន់នោះ គប្បីត្រូវអនុញ្ញាត។

សុខុមាលភាពរបស់កុមាររងគ្រោះគឺសំខាន់បំផុត។ ប្រសិនបើកុមាររងគ្រោះចង់ងូតទឹក ឬផ្លាស់ប្តូរសម្លៀកបំពាក់ មន្ត្រីនគរបាលគួរតែណែនាំពួកគាត់ អំពីរបៀបទុកសម្លៀកបំពាក់ ពេលគឺមានថង់ដាច់ដោយឡែក សម្រាប់ដាក់របស់នីមួយៗ ដើម្បីកាត់បន្ថយការបាត់បង់ភស្តុតាង។ ការពិនិត្យកោសលវិច័យផ្នែកវេជ្ជសាស្ត្រត្រូវស្នើសុំនៅពេលចាំបាច់ ហើយគួរមានការរំខានតិចតួចបំផុត។ គួរមានការត្រួតពិនិត្យ តែម្តងប៉ុណ្ណោះ និងផ្តល់ជូនកុមាររងគ្រោះដោយឥតគិតថ្លៃ។ ប្រសិនបើការត្រួតពិនិត្យកោសលវិច័យ ទំនងជាផ្តល់ភស្តុតាងស៊ីចង្វាក់ សូមពន្យល់ថាការពិនិត្យកោសលវិច័យវេជ្ជសាស្ត្រគឺចាំបាច់។

ការពិនិត្យត្រូវមានការយល់ព្រមពីកុមារ និងឪពុកម្តាយ ឬពីអាណាព្យាបាលស្របច្បាប់របស់ពួកគាត់។ ការអនុវត្តទាំងអស់ចាំបាច់ត្រូវធ្វើតាមបែបកុមារមេត្រី។ ឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកគាំទ្ររបស់កុមារមានវត្តមានបានលុះត្រាតែកុមារខ្លួនឯងផ្ទាល់សម្រេចចិត្តអនុញ្ញាត។ ប្រសិនបើកុមារត្រូវការថែទាំផ្នែកវេជ្ជសាស្ត្រ ឬការគាំទ្រខាងចិត្តសាស្ត្រ ត្រូវជានាថាគាត់ទទួលបានភ្លាមៗ ដោយការនាំកុមារទៅមន្ទីរពេទ្យ គ្លីនិក ឬការិយាល័យវេជ្ជសាស្ត្រ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ និងដោយឥតគិតថ្លៃ។

មន្ត្រីនគរបាលគួរផ្តល់ព័ត៌មានដល់កុមាររងគ្រោះអំពីការបន្តនីតិវិធីនៅតុលាការ ដើម្បីឱ្យកុមារធ្វើការ សម្រេចចិត្តបានល្អប្រសើរ និងធ្វើឱ្យពួកគាត់មានអារម្មណ៍ថាអ្វីៗស្ថិតនៅក្រោមការគ្រប់គ្រងល្អ។ មន្ត្រីនគរបាល គួរតែពិភាក្សាអំពីជម្រើសផ្សេងៗដល់កុមាររងគ្រោះ និងសារៈសំខាន់នៃព័ត៌មានដែលទទួលបានពីកុមារ ដោយកុមារមិនចាំបាច់គិតថា តើការស៊ើបអង្កេតអាចដំណើរការបន្តបានឬអត់។

នៅក្នុងមេរៀននេះអ្នកបានសិក្សាអំពីគោលការណ៍អនុវត្តបែបកុមារមេត្រី សម្រាប់មន្ត្រីនគរបាលក្នុងការអនុវត្តការងាររបស់ខ្លួនជាមួយកុមារ ដើម្បីធានាបានការប្រព្រឹត្តតាមរបៀបត្រឹមត្រូវសមរម្យ និងមិនបង្កគ្រោះថ្នាក់ដល់ពួកគេ។ គោលការណ៍អនុវត្តបែបកុមារមេត្រី រួមបញ្ចូលការលើកកម្ពស់សិទ្ធិកុមារ វិធីសាស្ត្រ ផ្តោតលើការគោរពសិទ្ធិ ការអនុវត្តនីតិវិធីផ្តោតយកចិត្តទុកដាក់ ចំពោះកុមារដែលត្រូវប្រើនូវពហុជំនាញជាច្រើន ផ្តល់តម្លៃយេនឌ័រ ការចូលរួមពីក្រុមគ្រួសារ និងសហគមន៍ផងដែរ។ គោលការណ៍បែបកុមារមេត្រី ផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ដែលមានរៀបរាប់ពីគោលការណ៍ទូទៅ និងគោលការណ៍ឆ្លើយតបតាមតម្រូវការដាច់ដោយឡែកចំពោះកុមារ។ ក្នុងនាមជាមន្ត្រីនគរបាលពេលធ្វើការពាក់ព័ន្ធជាមួយកុមារត្រូវតែប្រកាន់ការអនុវត្តនីតិវិធីកុមារមេត្រីឱ្យបានខ្ជាប់ខ្ជួន ដែលរួមមាន ផ្តោតអាទិភាពលើសុខុមាលភាពកុមារបង្កើតបរិយាកាសសុវត្ថិភាព ធានាឱ្យមានអ្នកគាំទ្រកុមារនៅជិត អនុញ្ញាតឱ្យកម្លាំងសេវាសង្គមចូលរួមក្នុងការធ្វើការសម្ភាស ធានានូវការទុកចិត្ត និងមិនធ្វើការវិនិច្ឆ័យ។ល។

## មេរៀនទី៧៖

# ការស៊ើបអង្កេតបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

អ្នកបានសិក្សារួចហើយអំពី ការអនុវត្តតាមបែប កុមារមេត្រី ដែលមន្ត្រីនគរបាលត្រូវប្រកាន់យកក្នុងអំឡុងពេលធ្វើការជាមួយកុមារ។ ដោយឡែកនៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីនីតិវិធី និងដំហាននៃការស៊ើបអង្កេតករណី OCSEA។ វារួមបញ្ចូលទាំងគោលការណ៍រួមនៃការស៊ើបអង្កេតតាមបែបកុមារមេត្រី ការសម្ភាសតាមបែបកុមារមេត្រី និងដំហានដំណាក់កាលលម្អិតមួយចំនួន ដែលរាប់ចាប់តាំងពីការទទួលពាក្យបណ្តឹង ដំណាក់កាលស៊ើបអង្កេតបឋម ដំណាក់កាលឆែកឆេរ ដំណាក់កាលស្រង់ចម្លើយ(ជនរងគ្រោះ សាក្សី) ដំណាក់កាលស្តាប់ចម្លើយជនសង្ស័យ ប្រមូលភស្តុតាង ការរៀបចំរបាយការណ៍ ដំណាក់កាលព្រះរាជអាជ្ញា ដំណាក់កាលចៅក្រមស៊ើបអង្កេត និងចុងក្រោយគឺដំណាក់កាលសវនាការ។

ជាធម្មតានៅក្នុងដំណើរការស៊ើបអង្កេត នឹងត្រូវធ្វើឡើងតាមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យមន្ត្រីនគរបាលគោរពអនុវត្តតាម ដូចជាការកំណត់អត្តសញ្ញាណជនសង្ស័យ កំណត់ពីទិដ្ឋភាពនៃការបង្ខិតបង្ខំ កំណត់ពីមូលហេតុនៃការយល់ព្រម ស្វែងរកប្រមូលភស្តុតាងពីកុមាររងគ្រោះ ជនរងគ្រោះ កន្លែងកើតហេតុ និងសាក្សី។ ជាងនេះទៅទៀត មន្ត្រីនគរបាលត្រូវតែចេះប៉ាន់ប្រមាណអំពីស្ថានភាពកុមារ ពីព្រោះកុមាររងគ្រោះងាយនឹងរងការភិតភ័យ ជាងជនរងគ្រោះដែលជាមនុស្សពេញវ័យ។ ដូច្នេះត្រូវតែធានាថាធ្វើឱ្យកុមារមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ដូចជាស្នើឱ្យមានឪពុកម្តាយ អាណាព្យាបាល ឬសាច់ញាតិរបស់កុមារ ត្រូវមានវត្តមានជាមួយកុមារសម្រាប់ការសម្ភាស ដើម្បីសម្រួលដល់កុមារ។ សាកសួរកុមារប្រសិនបើកុមារត្រូវការអ្នកអម នោះឪពុកម្តាយ អាណាព្យាបាល សាច់ញាតិ ឬអ្នកគាំទ្រ អាចអង្គុយក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងការសម្ភាស។ ការសម្ភាសជាមួយកុមារគួរត្រូវបានធ្វើឡើងនៅក្នុងកន្លែងឯកជនដែលមានផាសុកភាព ជៀសវាងពីការរំខាន (ឧទាហរណ៍៖ ទូរស័ព្ទពេទ្យ មនុស្សដើរចេញ ដើរចូលជាដើម) និងមានទាំងសុវត្ថិភាពខាងរាងកាយ ផ្លូវចិត្ត សម្រាប់កុមារ និងគ្រួសារ។



សេចក្ដីបរិយាយនេះគឺ គ្រាន់តែជាគោលគំនិតខ្លះៗនៃការអនុវត្តជំហាននៃការស៊ើបអង្កេតបទល្មើសទាក់ទងនឹង OCSEA ដែលផ្អែកតាមគោលការណ៍ប្រតិបត្តិបែបកុមារមេត្រីប៉ុណ្ណោះ។ ប៉ុន្តែតម្រូវឱ្យមន្ត្រីនគរបាលអនុវត្ត និងគោរពតាមការណែនាំជាច្រើនផ្សេងទៀត ដូចជាការលើកកម្ពស់សិទ្ធិកុមារ ការប្រើវិធីសាស្ត្រដែលផ្ដោតលើការគោរពសិទ្ធិ និងឧត្ដមប្រយោជន៍របស់កុមារជាចម្បង ឥរិយាបថប្រព្រឹត្តបែបកុមារមេត្រីដោយប្រើជំនាញផ្សេងៗគ្នា ជាពិសេសជំនាញប្រាស្រ័យទាក់ទង កសាងទំនាក់ទំនង សម្ភាសកុមារ ដោះស្រាយបញ្ហា ឬការផ្ដោតយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ការយល់ដឹងអំពីបរិបទនៃជំនឿ និងទស្សនៈយល់ច្រឡំ ព្រមទាំងការរក្សាបាននូវអព្យាក្រឹតភាព ការផ្ដោតការយកចិត្តទុកដាក់ចំពោះពិការភាពជាដើម។

## ក ដំណាក់កាលនៃការស៊ើបអង្កេត

បទឧក្រិដ្ឋនៃ CSEA និង OCSEA មួយចំនួន អាចកើតឡើងលើប្រព័ន្ធអនឡាញ**ទាំងស្រុង** ហើយក្នុងករណីខ្លះនៃបទឧក្រិដ្ឋកើតឡើងនៅ**លើប្រព័ន្ធអនឡាញ** និងផ្នែកខ្លះទៀតកើតឡើង**ក្រៅប្រព័ន្ធអនឡាញ**។ ភារកិច្ចរបស់មន្ត្រីនគរបាលអាចប្រែប្រួល អាចមានភារកិច្ចផ្សេងៗ និងយោងទៅតាមករណីនីមួយៗជាក់ស្ដែង ហើយទាមទារការយកចិត្តទុកដាក់ខ្ពស់។

នៅក្នុងដំណើរស៊ើបអង្កេតករណី មន្ត្រីនគរបាលត្រូវតែយកចិត្តទុកដាក់លើការលើកកម្ពស់សិទ្ធិកុមារ ការរក្សាឧត្តមប្រយោជន៍កុមារ និងការអនុវត្តបែបកុមារមេត្រី។ សូមចាំថា ការលើកកម្ពស់**សិទ្ធិកុមារ ឧត្តមប្រយោជន៍កុមារ និងការអនុវត្តបែបកុមារមេត្រីគឺ** ជាតួនាទីដ៏សំខាន់មួយសម្រាប់មន្ត្រីនគរបាលទាំងអស់ ក្នុងគ្រប់ភារកិច្ចទាំងអស់ដែលមន្ត្រីនគរបាលត្រូវធ្វើ។ មន្ត្រីនគរបាលគួរតែពិចារណាគ្រប់ពេលវេលាអំពីរបៀបដែលមន្ត្រីនគរបាលគួរធ្វើសកម្មភាព និងគួរប្រព្រឹត្តចំពោះកុមារស្របតាមតម្រូវការទាំងនេះ។

### ក.១- ការទទួលពាក្យបណ្តឹង

**ភារកិច្ចសម្រាប់មន្ត្រីនគរបាល៖**

- ជួបជាមួយអ្នកដាក់ពាក្យបណ្តឹង និងអាណាព្យាបាល/គ្រួសារ (ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដំបូង ឬមនុស្សផ្សេងទៀត)
- ទទួលយកសេចក្តីថ្លែងការណ៍ដំបូងពីដើមបណ្តឹង កុមាររងគ្រោះ និងសាក្សី ឬអ្នករាយការណ៍ព័ត៌មាន
- ប្រសិនបើករណីទាំងនេះជា «បទល្មើសជាក់ស្តែង» មន្ត្រីនគរបាលអាចចាប់ខ្លួនជនសង្ស័យភ្លាមៗ ប៉ុន្តែប្រសិនបើមិនមែនជាបទល្មើសជាក់ស្តែងទេ មន្ត្រីនគរបាលនឹងស្នើសុំការស៊ើបអង្កេតស្រាវជ្រាវបឋមពីថ្នាក់ដឹកនាំ ឬព្រះរាជអាជ្ញា។

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះដោយយោងតាមការណែនាំអំពីការអនុវត្តកុមារមេត្រី។ សូមមើលឯកសារស្តីអំពីសិទ្ធិកុមារជាឯកសារយោង។**

## ក.២- ដំណាក់កាលស៊ើបអង្កេតបឋម

### ភារកិច្ចរបស់មន្ត្រីនគរបាល៖

- រៀបចំលិខិត ព័ត៌មានសង្ខេបអង្គហេតុ ដើម្បីស្នើសុំទៅថ្នាក់ដឹកនាំរបស់ខ្លួន ឬ ព្រះរាជអាជ្ញា ដើម្បីធ្វើការស៊ើបអង្កេតបឋម
- ការកំណត់អត្តសញ្ញាណជនរងគ្រោះ *(ការសម្ភាសជនរងគ្រោះ ការសម្ភាសសាក្សី យោងទៅតាមការណែនាំស្តីអំពីការអនុវត្តកុមារមេត្រី)*
- ការពិនិត្យសុខភាព *(ប្រសិនបើចាំបាច់ - ករណីខ្លះប្រហែលជាមិនចាំបាច់ទេ ហើយបទល្មើស* OCSEA *ខ្លះក៏មិនចាំបាច់ដែរ)*
- ការប្រមូលភស្តុតាងរូបវន្តដំបូង *(ប្រសិនបើពាក់ព័ន្ធ - ប្រហែលជាមិនចាំបាច់ទេក្នុងករណីដែលកើតឡើងលើប្រព័ន្ធអនឡាញទាំងស្រុង)*
- ការប្រមូលលើកដំបូងនៃការរឹបអូស និងការរក្សាទុកប្រកបដោយសុវត្ថិភាព/ការរក្សាទុកភស្តុតាងឌីជីថល/ឧបករណ៍ *(ការធ្វើបែបនេះតម្រូវឱ្យមានការបណ្តុះបណ្តាលអ្នកឯកទេសបច្ចេកទេស/ឌីជីថលបន្ថែមទៀត - មិនទាន់ធ្វើចប់សព្វគ្រប់នៅឡើយទេ)*
- ការកំណត់អត្តសញ្ញាណជនសង្ស័យ *(ឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត សញ្ជាតិ មុខរបរ អាសយដ្ឋាន...។ល។)*
- ប្រសិនបើ និងពេលប្រមូលបានភស្តុតាងគ្រប់គ្រាន់
- សហការណ៍ជាមួយភាគីពាក់ព័ន្ធក្នុងការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ
- មានព័ត៌មានពីកញ្ចប់សេវាសម្រាប់ជួយជនរងគ្រោះ និងគ្រួសារដែលរងផលប៉ះពាល់ដោយអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ

សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះដោយយោងតាមការណែនាំអំពីការអនុវត្តកុមារមេត្រី។

សូមមើលឯកសារស្តីអំពីសិទ្ធិកុមារជាឯកសារយោង។

## ក.៣- ដំណាក់កាលស្ដាប់ចម្លើយ និងប្រមូលភស្តុតាង

**ភារកិច្ចមន្ត្រីនគរបាល៖** *(សូមកត់ចំណាំ៖ ការបណ្ដុះបណ្ដាលជាក់លាក់ និងការផ្ដោតទៅលើការកំណត់អត្តសញ្ញាណ ការរឹបអូស និងការរក្សាទុកឧបករណ៍ឌីជីថល និងភស្តុតាងត្រូវបានគ្រោងទុករួចហើយ ទោះបីមិនទាន់បានកើតឡើងនៅឡើយក៏ដោយ)។*

- ការស្ដាប់ចម្លើយជនសង្ស័យដោយផ្អែកលើបទល្មើសព្រហ្មទណ្ឌ ធ្វើឱ្យស្របតាមនីតិវិធីច្បាប់
- កំណត់រកកន្លែងកើតហេតុ *(ក្នុងករណី OCSEA ខ្លះ - «កន្លែងកើតហេតុ» អាចមានទាំងនៅលើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ)*
- ការស្វែងរកកន្លែងកើតហេតុឌីជីថលលើកដំបូង *(មានតែក្នុងករណីលើប្រព័ន្ធអនឡាញតែប៉ុណ្ណោះ អាចជាឧបករណ៍អេឡិចត្រូនិក និងឌីជីថល កម្មវិធី វេទិកា នៅលើក្ដោដ ឧបករណ៍ផ្ទុកឯកសារ គណនីអ៊ីម៉ែលជាដើម... ដូច្នេះអាចទាមទារការបណ្ដុះបណ្ដាល និងជំនាញបន្ថែមរួមទាំងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពជំនាញពាក់ព័ន្ធផងដែរ។)*
- រាយការណ៍ទៅថ្នាក់ដឹកនាំ ឬព្រះរាជអាជ្ញា ដើម្បីសុំគោលការណ៍ចង្អុលបង្ហាញ ឬដឹកនាំបន្ថែម ។

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះដោយយោងតាមការណែនាំអំពីការអនុវត្តកុមារមេត្រី។ សូមមើល ឯកសារស្ដីអំពីសិទ្ធិកុមារជាឯកសារយោង។**

## ក.៤- ការរៀបចំរបាយការណ៍

**ភារកិច្ច៖**

- សរសេររបាយការណ៍សំណុំរឿង និងរៀបចំកញ្ចប់ភស្តុតាងតាមនីតិវិធីច្បាប់ ដើម្បីបញ្ជូនទៅថ្នាក់ដឹកនាំពិនិត្យ មុនសម្រេចបញ្ជូនទៅតុលាការ
- ភ្ជាប់ឯកសារគាំទ្រទាំងអស់ *(ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង សេចក្ដីថ្លែងការណ៍របស់ជនរងគ្រោះ សាក្សី និងជនសង្ស័យ កំណត់ហេតុឃាត់ខ្លួន ......។ល។)*
- វិញ្ញាបនប័ត្រវេជ្ជសាស្ត្រ *(ប្រសិនបើមាន)*
- ភស្តុតាងគាំទ្រផ្សេងទៀត - ភស្តុតាងឌីជីថល *(ត្រូវទាមទារការបណ្ដុះបណ្ដាលបន្ថែមស្ដីអំពីរបៀបកំណត់អត្តសញ្ញាណ ការរក្សាទុកប្រកបដោយសុវត្ថិភាព និងការរក្សាទុកភស្តុតាងឌីជីថល)*
- បញ្ជូនភស្តុតាង និងឯកសារគាំទ្រទាំងអស់ទៅព្រះរាជអាជ្ញា

### ក.៥- ដំណាក់កាលព្រះរាជអាជ្ញា

**ភារកិច្ច (ព្រះរាជអាជ្ញា)៖**

- ពិនិត្យមើលរបាយការណ៍អំពីដំណើររឿង សេចក្តីថ្លែងការណ៍ និងភស្តុតាងគាំទ្រទាំងអស់ (ភស្តុតាងជាក់ស្តែង និងឌីជីថល)
- សម្ភាសន៍កុមាររងគ្រោះ *(ការនេះអាច ឬមិនអាចកើតឡើង វាអាស្រ័យលើព្រះរាជអាជ្ញា)*
- ស្តាប់ចម្លើយជនសង្ស័យ
- បញ្ជូនភស្តុតាងគាំទ្រទាំងអស់ និងជនល្មើសទៅចៅក្រមស៊ើបអង្កេត

### ក.៦- ដំណាក់កាលចៅក្រមស៊ើបអង្កេត

**ភារកិច្ច (ចៅក្រម)៖**

- ពិនិត្យភស្តុតាងគាំទ្រទាំងអស់
- សម្ភាសន៍ជនសង្ស័យ
- អាចសម្ភាសន៍ជនរងគ្រោះ/សាក្សី
- ប្រសិនបើចៅក្រមស៊ើបអង្កេតជឿថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីកាត់ទោសជនជាប់ចោទហើយ គាត់នឹងចេញដីកាឃុំខ្លួន ហើយជនសង្ស័យនឹងត្រូវបញ្ជូនទៅតុលាការដើម្បីកាត់ទោស *(អាស្រ័យលើភាពធ្ងន់ធ្ងរនៃបទល្មើស ជនល្មើសអាចត្រូវឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង)*។

### ក.៧- សវនាការ៖

**ភារកិច្ចមន្ត្រីនគរបាល៖**

- អាចតម្រូវឱ្យចូលតុលាការក្នុងនាមជាសាក្សី ហើយនិយាយជាមួយ និង/ឬពន្យល់ភស្តុតាងរបស់ពួកគេ
- អាចតម្រូវឱ្យឆ្លងកាត់ការពិនិត្យដោយមេធាវីការពារក្តី
- អាចតម្រូវឱ្យឆ្លើយសំណួរបន្ថែមដែលសួរដោយចៅក្រម

# ខ បច្ចេកទេសស៊ើបអង្កេតបទល្មើសទាក់ទងនឹង OCSEA

## ខ.១- ការប្រមូលភស្តុតាងឌីជីថល

### ខ.១.១- វិធីសាស្ត្រសម្រាប់ប្រមូល និងរក្សាទុកភស្តុតាងឌីជីថល

ការប្រមូល និងរក្សាទុកភស្តុតាងឌីជីថលមានសារៈសំខាន់ណាស់នៅពេលស៊ើបអង្កេតបទល្មើសផ្លូវភេទតាមអ៊ីនធឺណិត។ ពេលមកដល់កន្លែងកើតហេតុភ្លាម មន្ត្រីនគរបាលត្រូវតែប្រញាប់ពិនិត្យមើល និងប្រមូលនូវឧបករណ៍ទាំងឡាយ ដែលអាចជាភស្តុតាង ដោយធានាថា វត្ថុតាងទាំងនោះ អាចចងក្រងធ្វើជាឯកសារ ជាលក្ខខណ្ឌ និងការរៀបចំរបាយការណ៍បានត្រឹមត្រូវ។

ការរក្សាទុកភស្តុតាងពាក់ព័ន្ធនឹងការប្រព្រឹត្តសំខាន់ៗមួយចំនួន ដូចជាការថតរូបកន្លែងកើតហេតុ ការកត់ត្រាស្ថានភាពឧបករណ៍ និងការអនុវត្តតាមនីតិវិធីត្រឹមត្រូវសម្រាប់ការគ្រប់គ្រងឧបករណ៍ ដូចជា កុំព្យូទ័រ និងទូរស័ព្ទជាដើម។

### ខ.១.២- បច្ចេកទេសធ្វើកោសលវិច័យសម្រាប់ការទាញយកមកវិញនូវទិន្នន័យ (Data Recovery)

ការប្រើប្រាស់ឧបករណ៍ធ្វើកោសលវិច័យអនុញ្ញាតឱ្យមន្ត្រីនគបាលស៊ើបអង្កេតទាញយកទិន្នន័យ ដោយមិនផ្លាស់ប្តូរភស្តុតាងដើម។ មន្ត្រីនគរបាលគួរតែទប់ស្កាត់ និងបង្ការចូលលុប និងបម្លែងទិន្នន័យ ដើម្បីរក្សាភាពត្រឹមត្រូវនៃទិន្នន័យអំឡុងពេលដែលទាញយក ឬដកមករក្សាទុក។

ស្នើឱ្យអ្នកជំនាញ ប្រើបច្ចេកទេសផ្សេងៗ ដើម្បីប្រមូលយក និងរុករកឯកសារ ទិន្នន័យ ដែលត្រូវបានលុបចោល ឬឯកសារដែលគេបានបំបែកជាបំណែកផ្សេងៗ ហើយលាក់ទុកនៅកន្លែងផ្សេងៗគ្នា នៅតាមបណ្ដាឧបករណ៍ឌីជីថល និងប្រព័ន្ធអ៊ីនធឺណិត។ ការធ្វើដូច្នេះ ដើម្បីឈានទៅការប្រមូលបាននូវព័ត៌មានពេលលេញ។

## ខ.២-ធ្វើការស៊ើបអង្កេតតាមអនឡាញ

### ខ.២.១- បច្ចេកទេសសម្រាប់តាមដានសកម្មភាពអនឡាញ

ការស៊ើបអង្កេតលើអ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាពពឹងផ្អែកលើសមត្ថភាពក្នុងការត្រួតពិនិត្យមើលនៅលើលំហឌីជីថល ( Digital Space ) ដែលបទល្មើសអាចកើតឡើង។

ការស៊ើបអង្កេតលើអ៊ីនធឺណិត ឬអនឡាញទាមទារជំនាញ និងឧបករណ៍ពិសេស។ មន្ត្រីនគរបាលស៊ើបអង្កេតតាមដានសកម្មភាពតាមអ៊ីនធឺណិត ដើម្បីកំណត់អត្តសញ្ញាណជនល្មើសដែលអាចកើតមាន និងប្រមូលភស្តុតាងនៃអាកប្បកិរិយាបទល្មើស។ កិច្ចការនេះអាចរួមបញ្ចូលការយល់ដឹងពីវេទិកាអនឡាញជាច្រើន រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Meida) វេទិកា (Platforms) និងគេហទំព័រដែលផ្តល់ជាទីកន្លែងជជែកកំសាន្ត (Chat Room) ដែលជាទូទៅវាគឺជាទីកន្លែងដំបូងនៃការលួងលោមផ្តួចផ្តើមឡើងជាលើកដំបូង ។

បច្ចេកទេសដ៏មានប្រសិទ្ធភាពមួយគឺការស៊ើបការណ៍សម្ងាត់ប្រភពបើកចំហ (OSINT) ដែលអ្នកស៊ើបអង្កេតប្រើប្រាស់ព័ត៌មានដែលមានជាសាធារណៈ ដើម្បីបង្កើតទម្រង់លើបុគ្គល។ បច្ចេកទេសនេះអាចពាក់ព័ន្ធនឹងការពិនិត្យមើលគណនីប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជនល្មើសតែងតែចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់គេ ឬប្រើប្រាស់ដើម្បីប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ។ ថ្វីត្បិតបើ OSINT អាចផ្តល់នូវការយល់ដឹងដ៏មានតម្លៃ មន្ត្រីនរគបាលស៊ើបអង្កេតត្រូវតែមានការប្រុងប្រយ័ត្នផងដែរ ព្រោះវាធ្វើឱ្យបាត់ដានឌីជីថល (Digital Footprints) ផងដែរ ដែលអាចធ្វើឱ្យជនល្មើសរួចខ្លួន។

បច្ចេកទេសមួយទៀត មន្ត្រីនគរបាលគួរតែស្នើសុំការសហការពីក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត (ISP) ។ ការអនុវត្តច្បាប់អាចស្នើសុំទិន្នន័យអ្នកប្រើប្រាស់ទាក់ទងនឹងគណនីជាក់លាក់ ដែលទាក់ទងនឹងសកម្មភាពបទល្មើស។ នៅក្នុងយុត្តាធិការមួយចំនួន ច្បាប់អាចអនុញ្ញាតឱ្យមានការត្រួតពិនិត្យពេលវេលាជាក់ស្តែងនៃការទំនាក់ទំនងតាមអ៊ីនធឺណិត ជាមួយនឹងនីតិវិធីច្បាប់ត្រឹមត្រូវ ដូចជាការធានាជាដើម។

### ខ.៣- ការយល់ដឹងអំពីវេទិកាទំនាក់ទំនងឌីជីថល

មន្ត្រីនគរបាលស៊ើបអង្កេត ត្រូវតែមានភាពប៉ិនប្រសប់ក្នុងការរុករកតាមវេទិកាទំនាក់ទំនងឌីជីថលផ្សេងៗ ព្រោះជាញឹកញាប់កន្លែងទាំងនេះ គឺជាកន្លែងដែលមានប្រព្រឹត្តបទល្មើសផ្លូវភេទ ដែលបើកដំណើរការតាមអ៊ីនធឺណិតកើតឡើង។ ការយល់ដឹងអំពីមុខងារជាក់លាក់ និងការកំណត់ឯកជនភាពនៃវេទិកាទាំងនោះ គឺចាំបាច់សម្រាប់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ វេទិកាប្រព័ន្ធព័ត៌មានសង្គម (Social Meida) អាចផ្តល់ឧបករណ៍សម្រាប់រាយការណ៍អំពីការរំលោភបំពាន និងការយាយី រីឯបន្ទប់ជជែកវិញ ជាញឹកញាប់មានប្រព័ន្ធត្រួតពិនិត្យផ្ទាល់ខ្លួនរបស់ពួកគេ ដែលអាចជួយក្នុងការកំណត់អត្តសញ្ញាណអាកប្បកិរិយាមិនសមរម្យ។

មន្ត្រីនគរបាលត្រូវស្វែងយល់ និងស៊ាំនឹងការប្រើប្រាស់មុខងារចាំបាច់នៅតាមវេទិកាអនឡាញនីមួយៗ ដើម្បីងាយស្រួលកំណត់បានអំពីសញ្ញាណនៃការគំរាមកំហែង និងបទល្មើសដែលអាចកើតមាន។ ឧទាហរណ៍ យល់ដឹងពីមុខងារបំលែងសញ្ញា (Encryption) និងរបៀបផ្លាស់ប្តូរអត្តសញ្ញាណទៅជាអនាមិក ដែលជនល្មើសអាចប្រើប្រាស់ជាដើម។

### ខ.៨- បច្ចេកទេសស៊ើបអង្កេតតាមអនឡាញកម្រិតខ្ពស់

### ប្រតិបត្តិការលាក់កំបាំង និងការស៊ើបអង្កេតបុរេសកម្ម (Proactive Investigations)

### បច្ចេកទេសស្វែងរកអាថ៌កំបាំងនៅក្នុងពិភពអ៊ីនធឺណិត

តាមរយៈកិច្ចសហប្រតិបត្តិការលាក់កំបាំងនេះ អនុញ្ញាតឱ្យសមត្ថកិច្ចទទួលបានព័ត៌មាន និងយល់ដឹងអំពីរបៀបដែលជនល្មើសទំនាក់ទំនងគ្នាតាមអ៊ីនធឺណិត។ មន្ត្រីនគរបាលអាចបង្កើតអត្តសញ្ញាណក្លែងក្លាយ ដែលអាចឱ្យពួកគេចូលរួមជាមួយជនល្មើស ដោយមិនបង្កការភ្ញាក់ផ្អើលដល់ ជនល្មើស។

មន្ត្រីនគរបាលគួរស្វែងយល់អំពីដំណើរការប្រតិបត្តិការដូចជា របៀបសម្គាល់ និងល្បិចកលលួងលោមរបស់ជនល្មើស។ មន្ត្រីនគរបាលអាចរៀនបង្កើតបុគ្គលិកលក្ខណៈដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធ ដើម្បីងាយស្រួលប្រមូលនូវភស្តុតាងប្រកបដោយប្រសិទ្ធភាព។

## គ ផលប៉ះពាល់ផ្នែកច្បាប់ និងយកចិត្តទុកដាក់អំពីក្រមសីលធម៌

ការអនុវត្តប្រតិបត្តិការលាក់កំបាំង ត្រូវតែប្រកាន់ខ្ជាប់នូវស្តង់ដារក្រមសីលធម៌ និងច្បាប់ដែលបានបង្កើតឡើង ដើម្បីរក្សាភាពត្រឹមត្រូវនៃការស៊ើបអង្កេត។ លើសពីនេះ មន្ត្រីនគរបាលត្រូវដឹងអំពីផលប៉ះពាល់នៃអត្តសញ្ញាណលាក់កំបាំងរបស់ខ្លួនក្នុងការស៊ើបអង្កេត។

ការបណ្តុះបណ្តាលអំពីការធ្វើប្រតិបត្តិការលាក់កំបាំង គួរតែធ្វើឡើងទៀងទាត់ សង្កត់ធ្ងន់លើនីតិវិធីនៃការអនុវត្តប្រកបដោយក្រមសីលធម៌ ការពារផលប្រយោជន៍របស់ជនរងគ្រោះ និងរក្សាភាពជឿជាក់នៃកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់។

### គ.១- ការវិភាគលំនាំអាកប្បកិរិយានៅលើបណ្តាញវេទិកាអនឡាញ

#### គ.១.១- ការយល់ដឹងអំពីអាកប្បកិរិយា និងល្បិចកលដែលប្រើដោយជនល្មើស

អាកប្បកិរិយាលួងលោម និងល្បិចកល មានច្រើនទម្រង់ ដែលតម្រូវឱ្យមានការត្រួតពិនិត្យតាមដានយ៉ាងសកម្ម និងរៀនសម្គាល់យ៉ាងម៉ត់ចត់។ ការយល់ដឹងអំពីរបៀបលួងលោម ដែលជនល្មើសឧស្សាហ៍ប្រើប្រាស់ អាចជួយឱ្យមន្ត្រីនគរបាលអនុវត្តបទអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព។

ការបណ្តុះបណ្តាល គួរតែផ្តល់ឱ្យមន្ត្រីនគរបាលនូវទម្រង់សេណារីយ៉ូផ្សេងៗ ដែលរៀបរាប់អំពីយុទ្ធសាស្ត្រផ្សេងៗដែលជនល្មើសអាចប្រើប្រាស់ ដើម្បីកេងប្រវ័ញ្ចលើកុមារ។ វាជួយឱ្យមន្ត្រីនគរបាលធាប់យល់ដឹង និងអាចរកឃើញតម្រុយ លំនាំ អាកប្បកិរិយា ឬការប្រព្រឹត្តទាំងនោះ នៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់ខ្លួន។

### គ.១.២- ការប្រើប្រាស់ទិន្នន័យវិភាគសម្រាប់ការរកឃើញលំនាំក្នុងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត

ការវិភាគទិន្នន័យដើរតួនាទីយ៉ាងសំខាន់ ក្នុងការកំណត់អត្តសញ្ញាណ និន្នាការក្នុងសកម្មភាពឧក្រិដ្ឋកម្មដែលអាចកើតមាន។ ការអនុវត្តច្បាប់ត្រូវតែប្រើប្រាស់ដំណោះស្រាយបច្ចេកវិទ្យាទំនើប ដើម្បីវិភាគអន្តរកម្មលើវេទិកាឌីជីថលផ្សេងៗ។

ការប្រើបច្ចេកទេសស្វែងរក កំណត់ទិន្នន័យតាមបែបទំនើប និងរាវរកព័ត៌មាន ដោយផ្តូផ្តងតាមបែបម៉ាស៊ីនរៀនសូត្រ (Machine Learning Algorithms) អាចជាវិធីសាស្ត្រដែលជួយកំណត់បានពីរបៀបប្រាស្រ័យទាក់ទង (អន្តរកម្ម) ខុសប្រក្រតី ដែលបង្ហាញពីអាកប្បកិរិយា ការប្រព្រឹត្តរបស់ជនល្មើសផងដែរ។

## ឃ គោលការណ៍រួមក្នុងការស៊ើបអង្កេតតាមបែបកុមារមេត្រី[14]

ជនល្មើសផ្លូវភេទលើកុមារអាចត្រូវបានគេស្គាល់ និងមិនស្គាល់អត្តសញ្ញាណទោះបីដូច្នេះក៏ដោយ មន្ត្រីនគរបាល ត្រូវធ្វើការស៊ើបអង្កេតហ្មត់ចត់ដើម្បីកំណត់ (១)-អត្តសញ្ញាណជនសង្ស័យ (២)-សកម្មភាពការបង្ខិតបង្ខំ និង (៣)-មូលហេតុ នៃការយល់ព្រម។ ការស៊ើបអង្កេតក៏រួមបញ្ចូលផងដែរនូវការប្រមូល និងរក្សាទុក ភស្តុតាង ហើយអាចប្រើវាបាននៅក្នុងនីតិវិធីតុលាការ។ ភស្តុតាងអាចត្រូវបានប្រមូលពីកុមាររងគ្រោះ គ្រួសារ ជនសង្ស័យ កន្លែងកើតហេតុ និងសាក្សីជាដើម។

### ឃ.១- កុមាររងគ្រោះគួរត្រូវបានកំណត់អត្តសញ្ញាណ

វាមានសារៈសំខាន់ណាស់ ក្នុងការធ្វើការប៉ាន់ស្មានអាយុបឋមនៅនឹងកន្លែងកើតហេតុ ដើម្បីបែងចែកឱ្យដាច់រវាងកុមាររងគ្រោះ និងជនរងគ្រោះជាមនុស្សពេញវ័យ។ កុមារអាចស្ថិតក្រោមការគំរាមកំហែងការបង្ខិតបង្ខំ ឬការបង្គាប់ប្រាប់ថាខ្លួនជាមនុស្សពេញវ័យ។ ដូច្នេះមន្ត្រីនគរបាលត្រូវវាយតម្លៃអាយុរបស់កុមារ ដោយផ្អែកលើសំបុត្រកំណើត សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតបញ្ជាក់អត្តសញ្ញាណដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ ប្រសិនបើគ្មានឯកសារទាំងនោះទេ ការកំណត់អាយុរបស់កុមាររងគ្រោះត្រូវធ្វើឡើងដោយអ្នកឯកទេសខាងវេជ្ជសាស្ត្រឱ្យទាន់ពេលវេលា។

### ឃ.២- ព័ត៌មានត្រូវត្រួតពិនិត្យឡើងវិញ និងត្រូវរក្សាជាការសម្ងាត់

មន្ត្រីនគរបាលគួរផ្ទៀងផ្ទាត់ប្រភពព័ត៌មានជាច្រើន តាមដែលអាចធ្វើទៅបាន រួមបញ្ចូលទាំងព័ត៌មានទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល បណ្តាញទូរស័ព្ទឆ្លើយតបជំនួយបន្ទាន់ ឬពីសហគមន៍។ ការប្រមូល ព័ត៌មានទាក់ទងនឹងជនរងគ្រោះ បុគ្គលពាក់ព័ន្ធ និងចរិតលក្ខណៈនៃបទល្មើស គួរតែត្រូវបាន

[14] ប្រភព៖ ដកស្រង់ចេញពីសៀវភៅគោលការណ៍ប្រតិបត្តិកុមារមេត្រីរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

ធ្វើឡើង តាមបែបកុមារមេត្រី ដោយគ្មានការបង្ខិតបង្ខំ ឬការសន្យា ឬដាក់សម្ពាធ ដើម្បីទទួលបានព័ត៌មាន ហើយព័ត៌មានទាំងនោះត្រូវរក្សាទុក និងទុកជាការសម្ងាត់។ ព័ត៌មានពាក់ព័ន្ធនឹងទីកន្លែងរបស់កុមារដូចជា អាសយដ្ឋាន ទីជម្រកបណ្ដោះអាសន្នដែលកុមារកំពុងស្នាក់នៅ ឬសាលារៀនរបស់កុមារ ។ល។ គួរតែត្រូវបានបិទបាំង និងមិនត្រូវបានផ្សព្វផ្សាយឡើយ។

### ឃ.៣- បង្ការកុំឱ្យមានទំនាក់ទំនងគ្នារវាងកុមាររងគ្រោះ និងជនសង្ស័យ

ប្រសិនបើការកំណត់អត្តសញ្ញាណជាផ្លូវការរបស់ជនសង្ស័យ ជាការចាំបាច់គួរតែត្រូវធ្វើឡើងនៅពេលក្រោយតាមរយៈការផ្ដល់ឱ្យកុមារមើលជារូបថតរបស់ជនសង្ស័យ មិនមែនមើលដោយជួបផ្ទាល់ទេ។ មិនថាក្នុងស្ថានភាពណាក៏ដោយ មិនត្រូវដឹកជញ្ជូនកុមាររងគ្រោះ និងជនសង្ស័យ ដោយប្រើប្រាស់មធ្យោបាយ នៅក្នុងរថយន្តតែមួយជាមួយគ្នានោះទេ។

## ង គោលការណ៍នៃការសម្ភាសតាមបែបកុមារមេត្រី[15]

ការសម្ភាសពេញលេញ នឹងត្រូវបានធ្វើឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីទទួលបានព័ត៌មានបឋមអំពីការរំលោភបំពាន ប៉ុន្តែលុះត្រាតែស្ថានភាពស្មារតីរបស់កុមារអំណោយផលមានការគាំទ្រផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រចាំបាច់ទាំងអស់ ដែលអាចសម្របសម្រួលផ្ដល់ជូនកុមាររងគ្រោះ។ ការសម្ភាសកោសលវិច័យ គឺជាចិត្តសាស្ត្រ និងវិធីសាស្ត្រត្រឹមត្រូវ ក្នុងការប្រមូលព័ត៌មានពិត ដែលទាក់ទងនឹងការរំលោភបំពាន។

### ការសម្ភាសកោសលវិច័យមានគោលដៅចម្បងបីគឺ៖

- កាត់បន្ថយការប៉ះទង្គិចណាមួយ ដែលកុមារអាចជួបប្រទះអំឡុងពេលសម្ភាសន៍
- បង្កើនបរិមាណ និងគុណភាពនៃព័ត៌មាន ដែលទទួលបានពីកុមារ និងកាត់បន្ថយព័ត៌មានមិនចាំបាច់
- រក្សានូវភាពសុចរិត នៃដំណើរការស៊ើបអង្កេត សម្រាប់ការសម្ភាស

[15] ប្រភព៖ ដកស្រង់ចេញពីសៀវភៅគោលការណ៍ប្រតិបត្តិកុមារមេត្រីរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

# ព័ត៌មានដែលត្រូវប្រមូលមុនពេលសម្ភាសន៍




**អត្តសញ្ញាណ**

ស្ថានភាពកុមារ (បញ្ហាផ្សេងៗ ដូចជា ការលំបាកក្នុងការរៀនសូត្រ ការលំបាកខាងភាសា បញ្ហាក្នុងការស្តាប់ ឬអក្ខរកម្ម ការលំបាកខាង អាកប្បកិរិយាជាដើម)។

**វប្បធម៌/ភាសា/សាសនា**

តើកុមារបានផ្តល់សក្ខីកម្មណាមួយរួចហើយ ដែលពួកគាត់បង្ហាញ ការគិត ឬមានអារម្មណ៍យ៉ាងណា ចំពោះអ្វីដែលបានកើតឡើង។ បញ្ហា អាកប្បកិរិយាពីមុន (ឧទាហរណ៍៖ ការក្រេវក្រោធ អាកប្បកិរិយាបែបផ្លូវភេទ ឬការផ្លាស់ប្តូរឥរិយាបថភ្លាមៗ ដោយមិនអាចពន្យល់បានជាដើម)។

តើកុមារជាមនុស្សស្ងប់ស្ងៀមមិននិយាយស្តី ឬនិយាយលេងច្រើន លើសពីនេះទៅទៀតតើពួកគាត់ទាក់ទងនឹងអ្នកដទៃ ជាពិសេស អ្នកដែល មិនស្គាល់មុខដោយរបៀបណា។




គ្រួសារ ការរស់នៅនាពេលបច្ចុប្បន្ន និងអតីតកាលប្រវត្តិនៃអំពើហិង្សា ឬការរំលោភបំពាន ជាមនុស្សគ្មានទីលំនៅពិតប្រាកដ មានមនុស្ស ពេញវ័យច្រើននាក់រស់នៅក្នុងផ្ទះ ដែលមានការរំលោភបំពានផ្លូវភេទជាដើម។

ការរៀនសូត្រ មិត្តភក្តិ តើកុមារមានមិត្តភក្តិដែរឬទេ? តើពួកគេស្និទ្ធស្នាលនឹងគ្នាកម្រិតណា? ការរំលោភបំពានពីអតីតកាល

| | |
|---|---|
|  | តើកុមារបានប្រាប់ពីការរំលោភបំពានដែរឬទេ?<br>តើវាកើតឡើង ដោយចេតនា ឬដោយចៃដន្យ?<br>តើពួកគាត់បានប្រាប់នរណាខ្លះ? នៅពេលណា? និងក្នុងកាលៈទេសៈណា?<br>តើបុគ្គលនោះនិយាយអ្វីដល់គាត់?<br>តើបុគ្គលនោះធ្វើអ្វីខ្លះ? តើបុគ្គលនោះមានប្រតិកម្មយ៉ាងណា?<br>ប្រសិនបើកុមារមិនបាននិយាយពីការរំលោភបំពាន តើស្ថិតក្នុងស្ថានភាពហានិភ័យដែរឬទេ? |
|  | តើជនល្មើសជានរណា? តើគេមានទំនាក់ទំនងដូចម្តេចជាមួយកុមារ និងជាមួយគ្រួសារ?<br>តើជនល្មើសបានស្គាល់កុមារ និងគ្រួសាររបស់កុមារយូរប៉ុណ្ណាហើយ? ក្រុមគ្រួសារយល់យ៉ាងណាចំពោះជនល្មើស មុនពេលការរំលោភបំពានត្រូវបានលាតត្រដាង?<br>តើជនល្មើសអាចទាក់ទងជាមួយកុមារកន្លងមកយ៉ាងដូចម្តេច |
|  | តើអ្វីទៅជាបរិបទនៃការប្រព្រឹត្តបទល្មើស?<br>តើអ្វីដែលអ្នកអាចរកឃើញអំពីទម្លាប់នៃការប្រព្រឹត្តបទល្មើសដូចជា៖ ការលួងលោម ការដាក់គោលដៅ?<br>តើវាកើតមានឡើងញឹកញាប់ដែរឬទេ? តើវាកើតឡើងនៅពេលណា?<br>តើមានកុមាររងគ្រោះផ្សេងទៀតដែរឬទេ?<br>តើសកម្មភាពផ្លូវភេទដែលបានកើតឡើងមានការវិវឌ្ឍយ៉ាងដូចម្តេច? |

### ង.១- បង្កើតបរិយាកាសបែបកុមារមេត្រី

ការសម្ភាសគួរតែត្រូវបានធ្វើឡើងនៅក្នុងកន្លែងឯកជន មានផាសុកភាព គ្មានការគំរាមកំហែង គ្មានការរំខាន និងមានសុវត្ថិភាពទាំងខាងផ្លូវកាយ និងផ្លូវចិត្តសម្រាប់កុមារ និងគ្រួសារដែលមិនជាប់ពាក់ព័ន្ធនឹង បទល្មើស។

ប្រសិនបើនៅប៉ុស្តិ៍នគរបាលគ្មានបរិយាកាសបែបកុមារមេត្រីទេ សូមស្នើសុំប្រើប្រាស់បន្ទប់បែបកុមារមេត្រីនៅ ទីកន្លែងផ្សេងៗទៀតដូចជា៖ ស្ថាប័នសង្គមកិច្ច ឬអង្គការមិនមែនរដ្ឋាភិបាល ឬទីកន្លែងដែលមានឯកជនភាព និងគ្មានការបំភិតបំភ័យដល់កុមារ។ សម្ភារៈក្មេងលេងមានប្រយោជន៍ក្នុងការធ្វើឱ្យកុមារគ្រប់គ្រងអារម្មណ៍បាន ខណៈពេលដែលពួកគាត់កំពុងរង់ចាំ ប៉ុន្តែគួរតែយកសម្ភារៈទាំងនោះចេញក្នុងអំឡុងពេល សម្ភាសន៍ដើម្បីជៀសវាងការរំខាន។ កៅអីគួរតែមានផាសុកភាព និងត្រូវដាក់ទល់មុខគ្នាក្នុងកម្រិតមុំ១២០ដឺក្រេ។ តាមវិធីនេះវាអនុញ្ញាតឱ្យអ្នកសម្ភាសន៍ អាចដឹងពីភាសាកាយវិការរបស់កុមារ ក៏ដូចជាធ្វើឱ្យកុមារអាចដឹងពីភាសាកាយវិការរបស់អ្នកសម្ភាសន៍វិញដែរ។ ការដាក់កៅអីអង្គុយឱ្យទល់មុខគ្នា និង ការអង្គុយក្បែរគ្នា អាចធ្វើឱ្យការសន្ទនាប្រព្រឹត្តទៅមិនរលូនទេ។

សម្ភារៈក្មេងលេងមានប្រយោជន៍ក្នុងការធ្វើឱ្យកុមារគ្រប់គ្រងអារម្មណ៍បាន ខណៈពេលដែលពួកគាត់កំពុងរង់ចាំ ប៉ុន្តែគួរតែយកសម្ភារៈទាំងនោះចេញក្នុងអំឡុងពេលសម្ភាសន៍ដើម្បីជៀសវាងការរំខាន។ កៅអីគួរតែមានផាសុកភាព និង ត្រូវដាក់ទល់មុខគ្នាក្នុងកម្រិតមុំ១២០ដឺក្រេ។ តាមវិធីនេះវាអនុញ្ញាតឱ្យអ្នកសម្ភាសន៍ អាចដឹងពីភាសាកាយវិការរបស់កុមារ ក៏ដូចជាធ្វើឱ្យកុមារអាចដឹងពីភាសាកាយវិការរបស់អ្នកសម្ភាសន៍វិញដែរ។ ការដាក់កៅអីអង្គុយឱ្យទល់មុខគ្នា និងការអង្គុយក្បែរគ្នា អាចធ្វើឱ្យការសន្ទនាប្រព្រឹត្តទៅមិនរលូនទេ។

⇒ សូមកុំទុករបស់អ្វីៗនៅលើតុចន្លោះរវាងអ្នកសម្ភាសន៍ និងកុមារ។ ត្រូវធានាថាមានកន្លែងដាក់ក្រដាស នៅជិតកន្លែងអង្គុយរបស់អ្នកសម្ភាសន៍ និងសូមកុំយករបស់មិនចាំបាច់ចូលក្នុងបន្ទប់សម្ភាសន៍។ សឺមី ដែលដាក់ក្រដាសឯកសារពេញអាចរំខានដល់កុមារ ប្រសិនបើអ្នកសម្ភាសន៍ត្រូវការប្រើក្រដាសឯកសារណាមួយ សូមប្រាកដថាវានៅជិតដៃស្រួលយក (សូមមើលគោលការណ៍ណែនាំស្តីពី ការប្រើប្រាស់បន្ទប់សម្ភាសន៍បែបកុមារ មេត្រីរបស់អង្គការ APLE)។

### ង.២- ការរៀបចំរបស់អ្នកសម្ភាសន៍

⇒ អ្នកសម្ភាសន៍ត្រូវរៀបចំខ្លួនឱ្យបានសមរម្យសម្រាប់ការសម្ភាស ព្រមទាំងការគ្រប់គ្រងអារម្មណ៍ចំពោះ ការបំភ្លឺអំពីការរំលោភបំពានផ្លូវភេទរបស់កុមារ។ អ្នកសម្ភាសន៍គួរបិទទូរស័ព្ទដៃ មិនត្រូវស្លៀកពាក់ឯកសណ្ឋាន ឬក៏យកអាវុធ ឬខ្នោះដៃចូលក្នុងបន្ទប់សម្ភាសន៍កុមារឡើយ។ មិនត្រូវស្លៀកពាក់សម្លៀកបំពាក់ណាដែលមានភាពសិចស៊ី (សម្រាប់អ្នកសម្ភាសន៍ជាស្ត្រី) និងកុំពាក់

គ្រឿងអលង្ការដែលមើលទៅ ទាក់ភ្នែក។ល។

⇒ អ្នកសម្ភាសន៍ត្រូវរក្សាគំនិតបើកទូលាយ និងមិនមាននូវភាពលម្អៀងណាមួយដែលគាត់មានចំពោះកុមារ។ ដោយមានបទពិសោធន៍ច្រើនផ្នែកនេះ អ្នកសម្ភាសន៍អាចធ្វើការសន្និដ្ឋានលើករណីដែលការសន្និដ្ឋានបែបនេះ អាចប៉ះពាល់ដល់លទ្ធផលនៃការសម្ភាស និងរបៀបដែលអ្នកសម្ភាសន៍ ប្រតិកម្មតបទៅនឹងកុមារ ក្នុងអំឡុងពេលសម្ភាសន៍។ ប្រសិនបើព័ត៌មានដែលផ្តល់ដោយកុមារ មិនសមស្របទៅនឹងអ្វីដែលអ្នកសម្ភាសន៍មាន ឬបានដឹងអំពីករណីនេះ ត្រូវពិនិត្យនិងសួរផ្ទៀងផ្ទាត់ព័ត៌មាន មុននឹងធ្វើការសន្និដ្ឋានថាកុមារកំពុងនិយាយកុហក។

អ្នកសម្ភាសន៍គួររៀបចំកម្រងសំណួរចាំបាច់នានាមុននឹងចាប់ផ្តើមការសម្ភាស។ ការសម្ភាសជាមួយកុមារត្រូវមានកម្រិត ដើម្បីប្រមូលព័ត៌មានជាភស្តុតាង ដែលព័ត៌មាននោះមិនអាចប្រមូលបានតាមវិធីផ្សេងៗទៀត។ កុមារអាចផ្តល់ព័ត៌មានមានកម្រិតសម្រាប់ការសម្ភាសដោយមូលហេតុ រយៈពេលនៃការផ្តោតការយកចិត្តទុកដាក់ សមត្ថភាពក្នុងការរៀបរាប់អង្គហេតុជាដើម។ ខណៈដែលការផ្តល់ព័ត៌មានរបស់កុមារមានកម្រិត អ្នកសម្ភាសន៍គួរផ្តោតលើទិដ្ឋភាពសំខាន់បំផុតនៃការសម្ភាស ហើយមិនត្រូវខ្វះខ្វាយនូវព័ត៌មានដែលគួរឱ្យចាប់អារម្មណ៍ដែលអាចទទួលបានក្រៅពីការសម្ភាសឡើយ។

### ង.៣- ការរៀបចំអ្នកចូលរួមផ្សេងទៀត

⇒ ប្រសិនបើមានមនុស្សផ្សេងៗទៀតដូចជា អ្នកបកប្រែ បុគ្គលិកសង្គមកិច្ច ឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីចូលរួមនៅក្នុងការសម្ភាសនេះ មន្ត្រីនគរបាលត្រូវពន្យល់លម្អិតពីអ្វីដែលរំពឹងទុកពីអ្នកចូលរួមទាំងនោះ។ ក្នុងនោះរួមមានទាំងព័ត៌មានលម្អិតដូចជា កន្លែងអង្គុយ អ្វីគួរ ឬមិនគួរនិយាយឬធ្វើ និងរបៀបដែលពួកគាត់ត្រូវឆ្លើយតបប្រសិនបើកុមារនិយាយសំដៅទៅកាន់ពួកគាត់ដោយផ្ទាល់។

បុគ្គលដទៃនៅក្នុងការិយាល័យទាំងអស់គួរតែត្រូវបានជូនដំណឹងអំពីការសម្ភាស ដើម្បីឱ្យពួកគាត់អាចបន្ថយ សម្លេងរំខាន ឬជៀសវាងការរំខានផ្សេងៗ។

នៅក្នុងមេរៀននេះ អ្នកបានរៀនអំពីគោលការណ៍គ្រឹះទូទៅនៃការស៊ើបអង្កេតបែបកុមារមេត្រី ការសម្ភាសជាមួយកុមារតាមបែបកុមារមេត្រី ព្រមទាំងជំហានលម្អិតទាំង៧ដំណាក់កាលនៃការស៊ើបអង្កេតការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ដែលរាប់ចាប់តាំងពីការទទួលពាក្យបណ្តឹង ដំណាក់កាលស៊ើបអង្កេតបឋមដំណាក់កាលសួរចម្លើយ ប្រមូលភស្តុតាង ការរៀបចំរបាយការណ៍ ដំណាក់កាលព្រះរាជអាជ្ញា ដំណាក់កាលចៅក្រមស៊ើបអង្កេត និងចុងក្រោយគឺដំណាក់កាលសវនាការ។ អំពីបច្ចេកទេសស៊ើបអង្កេតបទល្មើសផ្លូវភេទតាមអ៊ីនធឺណិត ដែលមានចាប់តាំងពីការប្រមូល និងរក្សាទុកភស្តុតាងឌីជីថល ធ្វើការស៊ើបអង្កេតតាមអនឡាញ បច្ចេកទេស

តាមដានសកម្មភាពជនល្មើសតាមអនឡាញ និងការយល់ដឹងអំពីការប្រើប្រាស់វេទិកាទំនាក់ទំនងជាដើម។ រីឯបច្ចេកទេសស៊ើបអង្កេតកម្រិតខ្ពស់ ស៊ីជម្រៅវិញ មានដូចជា ការអនុវត្តប្រតិបត្តិការបែបលាក់កំបាំង និងការស៊ើបអង្កេតបុរេសកម្ម បច្ចេកទេសស្វែងរកអាថ៌កំបាំងនៅលើ ឬនៅក្នុងបរិស្ថានអ៊ីនធឺណិត យល់ដឹងពីផលប៉ះពាល់ផ្នែកច្បាប់ និងក្រមសីលធម៌ក្នុងដំណើរការស៊ើបអង្កេត ការវិភាគអាកប្បកិរិយា ការប្រព្រឹត្តរបស់ជនសង្ស័យ ឬជនល្មើសនៅលើអនឡាញ។

នៅក្នុងមេរៀនអ្នករៀនផងដែរអំពីគោលការណ៍អនុវត្តការស៊ើបអង្កេតបែបកុមារមេត្រី ដូចជាការគោរពអត្តសញ្ញាណជនរងគ្រោះ ការរក្សាការសម្ងាត់ ទប់ស្កាត់ទំនាក់ទំនងរបស់ជនរងគ្រោះ និងជនសង្ស័យ។ លើសពីនេះ អ្នករៀនផងដែរអំពីនីតិវិធី ឬវិធីសាស្ត្រនៃការសម្ភាសតាមបែបកុមារមេត្រី ដែលរួមមានទាំងការវិធីសាស្ត្របង្កើតបរិយាកាសសុវត្ថិភាព ចាប់តាំងពីមុនការសម្ភាស អំឡុងពេលសម្ភាសន៍ និងចំណុចដែលត្រូវយកចិត្តទុកដាក់ជាច្រើនទៀត ដើម្បីផ្តល់ការគាំទ្រដល់កុមារងាយរងគ្រោះ ឬជនរងគ្រោះ។



មេរៀនទី៨៖

# វិធីសាស្ត្រ ឆ្លើយតបការគេងប្រវញ្ញា និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

តាមរយៈរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវនៅកម្ពុជា ទាក់ទងនឹងបទពិសោធន៍របស់កុមារក្នុងការស្វែងរកជំនួយពីមន្ត្រីនគរបាល និងអ្នកផ្តល់សេវាទាក់ទងនឹង OCSEA បានបង្ហាញប្រាប់យើងថា កុមារ មានតម្រូវការជាច្រើន ដែលទាមទារឱ្យមន្ត្រីនគរបាលខិតខំបន្ថែមទៀត ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាព និងស្ថានភាពកាន់តែល្អប្រសើរឡើងថែមទៀត។ មន្ត្រីនគរបាលត្រូវធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយភាគីពាក់ព័ន្ធ ដូចជាឪពុកម្តាយរបស់កុមាររងគ្រោះ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ បុគ្គលិកសង្គមកិច្ច និងមន្ត្រីសង្គមកិច្ចជាដើម។ ការឆ្លើយតបត្រូវតែគោរពតាមការអនុវត្តបែបកុមារមេត្រី ដែលធ្វើឱ្យកុមារមានអារម្មណ៍ថាមានសុវត្ថិភាព និងទុកចិត្តអ្នកកាន់តែច្រើន។ វាធ្វើឱ្យកុមារមានអារម្មណ៍ជឿជាក់ជាងមុន និងអាចសហការកាន់តែជិតស្និទ្ធជាមួយអ្នក ដំណើរការកាន់តែលឿន និងបង្កើនលទ្ធភាពនៃលទ្ធផលជោគជ័យសម្រាប់អ្នកក្នុងនាមជាមន្ត្រីនគរបាល។ ដូច្នេះ របៀបដែលអ្នក និងមនុស្សផ្សេងទៀតប្រព្រឹត្តក៏អាចមានឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើរបៀបដែលពួកគេព្យាបាលកុមារ។

អ្នកត្រូវយល់ដឹងអំពីយន្តការនៃការរាយការណ៍ ការឆ្លើយតប និងការបញ្ជូនដែលត្រូវបានគេអនុវត្តជាទូទៅរាប់ចាប់តាំងពីអាជ្ញាធរមូលដ្ឋាននៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិផងដែរ។ យន្តការនៃការរាយការណ៍រាប់ចាប់តាំងពីរបៀបកំណត់ករណី វិសាលភាព និងការទទួលខុសត្រូវរបស់អង្គភាពស្ថាប័នក្នុងការឆ្លើយតប ព្រមទាំងស្វែងយល់ពីយន្តការការងាររបស់អ្នកពាក់ព័ន្ធនៅសហគមន៍ពាក់ព័ន្ធនឹងកិច្ចអន្តរាគមន៍ជួយសង្គ្រោះកុមារ។ យន្តការឆ្លើយតប និងនីតិវិធីឆ្លើយតប មានដូចជា ករណីព្រហ្មទណ្ឌត្រូវបញ្ជូនបន្តទៅអាជ្ញាធរមានសមត្ថកិច្ច ដែលដោះស្រាយតាមនីតិវិធីច្បាប់ជាដើម។

ការយល់ដឹងអំពីយន្តការ និងនីតិវិធីឆ្លើយតបទាំងអស់នេះច្បាស់លាស់ មន្ត្រីនគរបាលអាចសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាលជំនាញ ដូចជា វេជ្ជបណ្ឌិតអាចធ្វើជាអ្នកផ្តល់ប្រឹក្សាយោបល់ និងជាអ្នកអប់រំដល់គ្រួសារ ឬជាអ្នកគាំទ្រកុមារដ៏មានឥទ្ធិពល និងជាសមាជិកសំខាន់ៗនៃក្រុមអ្នកជំនាញ។ បុគ្គលិកសង្គមកិច្ច ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ក្នុងការចូលទៅជិតកុមារ កសាងទំនាក់ទំនងជាមួយកុមារ និងការយល់ដឹងពីស្ថានភាពគ្រួសារ ឬប្រវត្តិគ្រួសាររបស់កុមារ។ បុគ្គលិកអង្គការមិនមែន

រដ្ឋាភិបាល ក៏អាចផ្តល់ព័ត៌មានបន្ថែមអំពីបរិបទនៃបរិស្ថានជុំវិញ ឧទាហរណ៍ សាលារៀនសហគមន៍ជាដើម កន្លែងដែលកុមាររស់នៅ ដែលជនល្មើសទាក់ទងជាមួយពួកគេជាដើម។ ទោះបីជាការស៊ើបអង្កេត គឺជាការងារចម្បងរបស់មន្ត្រីនគរបាលក៏ដោយ ក៏ការទំនាក់ទំនងជាមួយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬសមាជិក សហគមន៍ អាចជួយមន្ត្រីនគរបាលទទួលបានព័ត៌មានបន្ថែមទៀតដោយផ្ទាល់ផងដែរ។

ដូច្នេះពេលអ្នកសិក្សាមេរៀននេះចប់ អ្នកអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងអនុវត្តយុទ្ធសាស្ត្រឆ្លើយតបនឹង OCSEA។

មេរៀននេះ ឆ្លុះបញ្ចាំងពីរបកគំហើញនៃការសិក្សាទាក់ទងនឹងបទពិសោធន៍របស់កុមារក្នុងការស្វែងរកជំនួយ និងការសហការជាមួយមន្ត្រីនគរបាលទាក់ទងនឹង OCSEA នៅក្នុងប្រទេសកម្ពុជាយើង។ អ្វីដែលកុមាររងគ្រោះចង់បានពីមន្ត្រីនគរបាលនិងអ្នកផ្តល់សេវាពាក់ព័ន្ធដទៃទៀត ព្រមទាំងបទពិសោធន៍នៃការអនុវត្តគំរូល្អទាក់ទងនឹងការឆ្លើយតបចំពោះករណី OCSEA (គំរូផ្ទះបាណាហាស "Barnahus" ) ក៏ត្រូវបានរំលេចឡើងផងដែរ។

## ក បទពិសោធន៍របស់កុមារក្នុងការស្វែងរកជំនួយ និងការសហការជាមួយមន្ត្រីនគរបាលទាក់ទងនឹង OCSEA៖

### ក.១- បទពិសោធន៍ល្អៗរបស់កុមារ និងគ្រួសារក្នុងការស្វែករក និងទទួលបានជំនួយពីមន្ត្រីនគរបាល

> “ គាត់ជួយខ្ញុំឱ្យនិយាយ... នៅពេលគាត់សម្ភាសខ្ញុំ គាត់ក៏លើកទឹកចិត្តខ្ញុំដែរ... ហើយខ្ញុំអាចនិយាយបានដោយមិនភ័យខ្លាច... ខ្ញុំនិយាយអ្វីគ្រប់យ៉ាងដែលខ្ញុំដឹង... គាត់និយាយត្រង់ៗចំៗចំណុច... គាត់មិននិយាយពាក្យបច្ចេកទេសទេ គាត់ប្រើតែពាក្យថា ខ្ញុំដឹង (យល់)... គាត់ធាប់យល់គាត់ប្រើភាសាដែលខ្ញុំប្រើរាល់ថ្ងៃ។ ”

> “ ប៉ូលិសនិយាយថា៖ ពួកគេ (ប៉ូលិស)នៅតែបន្តនិយាយ ហើយប្រាស្រ័យទាក់ទងជាមួយយើង (កុមារ) ព្រោះពួកគេមិនទាន់ចាប់បានជនសង្ស័យទេ។ ដូច្នេះយើងត្រូវបន្តទាក់ទងជាមួយពួកគេ បញ្ជូនភស្តុតាង និងឯកសារទៅពួកគេ... ដើម្បីធ្វើឱ្យវាងាយស្រួល។ របៀបដែលពួកគេនិយាយគឺស្ងប់ស្ងាត់ ធ្វើឱ្យខ្ញុំទុកចិត្ត និងជួយខ្ញុំឱ្យមានភាពក្លាហាន ហ៊ាននិយាយអំពីអ្វីដែលពិតជាបានកើតឡើងចំពោះខ្ញុំ។ ”

"វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការមាន "ការលើកទឹកចិត្ត គាំទ្រ និងយល់ចិត្ត" ពីប៉ូលិស និងអ្នកដែលមានការពាក់ព័ន្ធ...... គឺជួយឱ្យមានការជឿជាក់ និងទំនុកចិត្តនៅក្នុងដំណើរការនេះ ហើយក៏ជួយសម្រាលការថប់បារម្ភរបស់យើងផងដែរ"

"វាពិតជាមានប្រយោជន៍ខ្លាំងណាស់ក្នុងការទំនាក់ទំនង និងធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីករណីនេះ ហើយនៅពេលដែលប៉ូលិស និងអ្នកផ្សេងទៀតប្រើភាសាចំៗ និងងាយយល់។"

"វាមានប្រយោជន៍ខ្លាំងណាស់ នៅពេលដែលនគរបាលណែនាំយើងដល់បុគ្គលិកផ្តល់សេវាគាំទ្រ ពីអង្គការមិនមែនរដ្ឋាភិបាល និងមេធាវី។ វាជួយយើងឱ្យយល់កាន់តែច្បាស់ និងមានទំនុកចិត្តក្នុងដំណើរការ។ ការជួបជាមួយប៉ូលិស សូម្បីតែជនរងគ្រោះអាចជាការពិបាកខ្លាំងណាស់ ហើយវាជា ដំណើរការមួយដែលស្មុគស្មាញ ដូច្នេះយើងសូមកោតសរសើរចំពោះការគាំទ្ររបស់ពួកគេចំពោះបញ្ហានេះ។ វាជួយយើងឱ្យសហការគ្នាកាន់តែល្អ។"

"ពួកគាត់ (ប៉ូលិស) ស្វាគមន៍ និងសហការល្អជាមួយយើង... ប៉ូលិសបានពន្យល់ពីសិទ្ធិរបស់ឪពុក និងសិទ្ធិរបស់កុមារ... ដំណើរការនីតិវិធីរបស់ប៉ូលិសមានការប្រុងប្រយ័ត្ន សម្ងាត់ និងមានសុវត្ថិភាព។"

"ដើម្បីធ្វើឱ្យវាកាន់តែងាយស្រួល សូមកុំបំភ័យពួកគេ [កុមារ] នៅពេលពួកគេនិយាយ។ នៅពេលកុមារសួរសំណួរ សូមឆ្លើយ ឬប្រសិនបើ ពួកគេឆ្ងល់អំពីអ្វីមួយ សូមអនុញ្ញាតឱ្យពួកគេសួរសំណួរឱ្យបានច្រើន ហ៊ាននិយាយ... ប្រាប់ពួកគេអំពីរឿងដែលនឹងកើតឡើង។ វានឹងធ្វើឱ្យកាន់តែងាយស្រួល ព្រោះវាកាន់តែមានការស្វាគមន៍។ សូមឱ្យពួកគេគិតអំពីការទទួលស្វាគមន៍ មិនធ្វើឱ្យកុមារភ័យខ្លាចនោះទេ។ គឺបែបនោះ!"

"ខ្ញុំគិតថាប៉ូលិស គួរតែធ្វើអ្វីដែលពួកគេអាចធ្វើបាន ដើម្បីលើកទឹកចិត្តកុមារកុំឱ្យភ័យខ្លាច នៅពេលពួកគេពន្យល់ពីអ្វីមួយ... ហើយញញឹម... ធ្វើអ្វីគ្រប់យ៉ាងដើម្បីជួយធ្វើឱ្យការភ័យខ្លាចបាត់ទៅវិញ។"

“ ខ្ញុំមានសារមួយដល់ប៉ូលិសគឺ ត្រូវយកចិត្តទុកដាក់ ចាត់ទុកកុមារដូចជាកូនរបស់ពួកគាត់ ឬដូចជនរងគ្រោះជាកូនរបស់ពួកគាត់ ដូច្នេះសូមរកយុត្តិធម៌ឱ្យពួកគេឱ្យបានឆាប់។ ហើយសូមពួកគេគិតថាកុមារជនរងគ្រោះ ដូចជាមនុស្សចាស់ទេ ” (ឪពុកម្តាយ)

“ ខ្ញុំសង្ឃឹមថាពួកគេអាចផ្លាស់ប្តូរឥរិយាបថ និងរបៀបដែលសួរសំណួរ... ហើយនៅពេលដែលពួកគេសួរសំណួរ ពួកគេគួរតែសួរមួយៗ មិនលឿនពេក ហើយសួរឱ្យបានច្បាស់ ដើម្បីកុំឱ្យច្រឡំនូវអ្វីដែលពួកគេកំពុងសួរ។ ”

“ សម្រាប់ប៉ូលិស ពួកគេគួរតែរកកន្លែងស្ងាត់បំផុតដែលអាចសួរ ឬនិយាយ សួរ និងឆ្លើយ ដើម្បីកុំឱ្យកុមារទាំងនោះពិបាក។ ដោយសារតែក្មេងខ្លះ អាម៉ាស់ ភ័យខ្លាច ហើយនិយាយមិនចេញ។ ដូច្នេះ គេគួររកកន្លែងស្ងាត់ ដើម្បីងាយស្រួលក្នុងការនិយាយ និងសួរអ្វីក៏បាន។ ”

“ ដំបូងឡើយ ពេលខ្ញុំជួបគេដំបូង ខ្ញុំមានអារម្មណ៍ភ័យខ្លាច។ ខ្ញុំនិយាយទាំងអាក់អួល បន្ទាប់មកជាលើកទី២ មានអង្គការមិនមែនរដ្ឋាភិបាលជួយលើកទឹកចិត្តឱ្យខ្ញុំនិយាយ។

ខ្ញុំនិយាយដូចខ្លាច

ខ្ញុំនិយាយលឿន មិនចាំអ្វីៗនោះទេ... ខ្ញុំត្រជិត ឈប់ ហើយចាប់ផ្តើម ភ្លេចអ្វីៗទាំងអស់។ ពួកគេបានពន្យល់យ៉ាងច្បាស់ ហើយលើកទឹកចិត្តខ្ញុំឱ្យមានភាពក្លាហានក្នុងការនិយាយ... ហើយខ្ញុំក៏មានទំនុកចិត្តក្នុងការនិយាយ។ ខ្ញុំអាចក្លាហានបានដោយសារតែពួកគេនៅពីក្រោយខ្ញុំ។ ”

### ក.២- បទពិសោធន៍កត្តាប្រឈម និងការលំបាករបស់កុមារ

“ ប្រសិនបើមានរឿងបែបនេះកើតឡើងម្តងទៀតចំពោះអ្នកផ្សេងទៀត ប៉ូលិសគួរតែរក្សាការសម្ងាត់... ពួកគេ(ប៉ូលិស)មិនគួរបើកចំហអ្វីគ្រប់យ៉ាងដើម្បីឱ្យពួកគេដឹងនោះទេ។ ព្រោះនៅក្នុងបន្ទប់ដែលគាត់សួរយើង វាមិនគ្រាន់តែ មានគាត់និងជនរងគ្រោះទេ គឺមានមនុស្សជាច្រើននាក់ទៀតនៅទីនោះដែរ។ ”

“ពេលខ្លះ ប៉ូលិសខ្លះខឹង ពួកគេនិយាយថា ពួកគេមានទឹកចិត្តល្អ ប៉ុន្តែទឹកមុខរបស់ពួកគេពេញដោយកំហឹង។ ដូច្នេះវាពិបាក។”

“មានបន្ទប់មួយ ប៉ូលិសកំពុងរំខានគ្នាទៅវិញទៅមក... ប៉ូលិសនិយាយបានល្អ ប៉ុន្តែហាក់ដូចជាមិនដឹងអ្វីសោះ ពួកគេនិយាយដូចជា មិនយល់... ហើយនៅពេលដែលខ្ញុំទៅប៉ុស្តិ៍ ពួកគេពិបាកនឹងពន្យល់ ... ពួកគេនិយាយដូចជា... ពួកគេប្រើពាក្យដែលពិបាកយល់... ខ្ញុំមិនយល់ពីអត្ថន័យទេ។”

“ពាក្យមានន័យជ្រៅ ហើយវាពិបាកយល់ និងគិត មិនងាយស្រួលទេ។ ខ្ញុំត្រូវគិតយូរ ហើយខ្ញុំពិបាកឆ្លើយណាស់។”

“ខ្ញុំពិបាកនិយាយ ពេលជួបប៉ូលិសប្រុសៗ។ ពួកគេជាប្រុស ហើយខ្ញុំជាក្មេងស្រី ហើយវាធ្វើឱ្យខ្ញុំពិបាកប្រាប់គាត់ ហើយឆ្លើយសំណួរផ្សេងៗ។”

“ខ្ញុំចង់បានប៉ូលិសស្រី ដោយសារនិយាយជាមួយស្រីៗដូចគ្នា ខ្ញុំមិនសូវខ្មាស” (កុមារ)

“ខ្ញុំចាំថាខ្ញុំខ្លាចកូនស្រីរបស់ខ្ញុំខ្មាសគេ ដោយសារតែការនិយាយសាច់រឿងបែបនោះជាមួយប្រុសៗ គឺធ្វើឱ្យអាម៉ាស់តែម្តង” (ម្តាយរបស់កុមារ)

“នៅពេលខ្ញុំនិយាយ ខ្ញុំខ្លាចពួកគេខ្លះគិតដល់វា ហើយសើច ធ្វើឱ្យខ្ញុំអាម៉ាស់ មើលងាយខ្ញុំ ហើយរើសអើងខ្ញុំ... ខ្ញុំភ័យ... វាធ្វើឱ្យខ្ញុំគិត នៅពេលដែលពួកគេសួរ ហើយខ្ញុំឆ្លើយ។ ខ្ញុំឆ្លើយ តែនៅពេលដែលពួកគេស្រែក ខ្ញុំនិយាយមិនចេញទេ វាធ្វើឱ្យខ្ញុំគាំង ហើយមិនដឹងថាត្រូវធ្វើអ្វី។”

“ខ្ញុំចង់ឱ្យបន្ទប់ដែលប្រើសម្រាប់ការសម្ភាសគួរតែមានអ្នកដែលចាំបាច់ដែលត្រូវធ្វើការសម្ភាសនៅទីនោះបានហើយ... មានអ្នកសម្ភាសន៍តែម្នាក់ គឺវាគ្រប់គ្រាន់ហើយ។ សូមកុំធ្វើដូចគេធ្វើជាមួយយើង មានមនុស្សច្រើននៅទីនោះ មានច្រើនណាស់ មិនមែនត្រឹមតែពីរបីនាក់នោះទេ។”

"នៅពេលខ្ញុំត្រូវបានសម្ភាសន៍ ហើយប៉ូលិសបានបង្ហាញរូបថតមកខ្ញុំ មន្ត្រីផ្សេងទៀតនៅក្នុងបន្ទប់កំពុងស្តាប់ ហើយសើចចំអកដាក់ខ្ញុំ។ ខ្ញុំគ្រាន់តែចង់ឱ្យពួកគេឈប់សើច ហើយឈប់រើសអើងខ្ញុំ"

"ពួកគេបានស្តីបន្ទោសខ្ញុំចំពោះស្ថានភាពរបស់ខ្ញុំ ដោយនិយាយថាមកពីខ្ញុំចង់បានវា (ដោយប្រើកម្មវិធីអនឡាញ) ហើយពួកគេសួរថា ហេតុអ្វីបានជាខ្ញុំទៅរាយការណ៍ទៅវិញ។"

"វាហាក់ដូចជាពួកគេកំពុងតែបន្ទោសខ្ញុំ។ ប៉ូលិសបាននិយាយថា វាយឺតពេលហើយ ហេតុអ្វីបានជាខ្ញុំមិននៅផ្ទះ? ខ្ញុំបានពន្យល់ពួកគេពីអ្វីដែលបានកើតឡើង។ បន្ទាប់មកពួកគេនិយាយថា «ហេតុអ្វីបានជាខ្ញុំដើរចេញក្រៅនៅពេលយប់?» ពួកគេហាក់ដូចជាចង់បន្ទោសខ្ញុំ សម្រាប់អ្វីដែលបានកើតឡើង។"

### ក.៣- ករណីសិក្សា

បទពិសោធន៍វិជ្ជមានរបស់កុមារកម្ពុជានៃការស្វែងរកជំនួយពីមន្ត្រីនគរបាល ករណីសិក្សានេះដកស្រង់ចេញពីការស្រាវជ្រាវបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disrupting Harm Cambodia 2022)។ វាផ្អែកលើបទពិសោធន៍របស់ក្មេងស្រីខ្មែរម្នាក់ ដែលជាជនរងគ្រោះនៃ OCSEA។

ករណីនេះត្រូវបានបង្ហាញសម្រាប់អ្នកចូលរួម ដើម្បីកំណត់នូវការឆ្លើយតបជាវិជ្ជមាន និងមានប្រយោជន៍របស់មន្ត្រីនគរបាល និងដើម្បីបង្ហាញពីអ្វីដែល «ការអនុវត្តល្អ» នៃការគោរពសិទ្ធិ និងឧត្តមប្រយោជន៍សម្រាប់កុមារ និងការអនុវត្តតាមនីតិវិធីដែលមានលក្ខណៈកុមារមេត្រី ដែលអាចផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នាដែលពាក់ព័ន្ធ និងនាំឱ្យទទួលបានលទ្ធផលជោគជ័យ។

## ករណីសិក្សា ស្រីលីន

ស្រីលីន (មិនមែនឈ្មោះពិត) ជាជនរងគ្រោះនៃអំពើ OCSEA ដែលត្រូវបានសម្ភាសជាផ្នែកមួយនៃការស្រាវជ្រាវបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disrupting Harm Global Study in Cambodia)។ ឪពុករបស់នាងក៏ត្រូវបានសម្ភាសន៍ដោយមន្ត្រីនគរបាល និងផ្តល់គុណតម្លៃសម្រាប់គាត់។ យើងអាចរៀនសូត្របានច្រើនពីបទពិសោធន៍វិជ្ជមាន និងការយល់ដឹង ហើយនឹងអ្វីដែលជាការអនុវត្តល្អ។

សរុបមក ទាំងកូនស្រី និងឪពុកបានពិពណ៌នាអំពីករណីមួយដែលត្រូវបានដោះស្រាយយ៉ាងល្អដោយ អាជ្ញាធរដែលបង្ហាញពីវិជ្ជាជីវៈ និង «ការអនុវត្តល្អ» ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។

### ការរាយការណ៍

- ឪពុកបានទៅជួបមន្ត្រីនគរបាល ហើយបានរៀបរាប់ថា មានការលើកទឹកចិត្តយ៉ាងខ្លាំងចំពោះការឆ្លើយតបរបស់ពួកគេ ដែលគាត់បានពិពណ៌នាថា ងាយស្រួល និងរក្សាការសម្ងាត់។
- គាត់និយាយថា៖ មន្ត្រីនគរបាលបានស្វាគមន៍ និងរាក់ទាក់ជាក់គាត់ មានការសហការល្អ មន្ត្រីនគរបាលបានពន្យល់ពីតួនាទី និងសិទ្ធិរបស់ឪពុកជាដើមបណ្តឹង និងសិទ្ធិកុមារជាជនរងគ្រោះ ហើយនីតិវិធីរបស់មន្ត្រីនគរបាល មានការប្រុងប្រយ័ត្នខ្ពស់ និងមានសុវត្ថិភាព។

### ការរក្សាព័ត៌មានសម្ងាត់ និងការអនុវត្តតាមនីតិវិធីកុមារមេត្រី

- ប៉ុស្តិ៍នគរបាលដែលពួកគេដាក់ពាក្យបណ្តឹង កុមារនិងឪពុករបស់នាង ត្រូវបានសម្ភាសន៍នៅក្នុងបន្ទប់ស្ងាត់ និងរក្សាការសម្ងាត់ ដោយមិនមានការរំខានអ្វីឡើយ។
- កុមារត្រូវបានប្រព្រឹត្តដោយសប្បុរស និងដោយការគោរពគ្រប់ពេលវេលា។
- មន្ត្រីនគរបាលបានប្រើភាសាសមរម្យ និងងាយយល់សម្រាប់កុមារយល់។
- មន្ត្រីនគរបាលបានផ្តល់ព័ត៌មានត្រឹមត្រូវអំពីច្បាប់ និងដំណើរការច្បាប់។
- មន្ត្រីនគរបាលបានផ្តល់ព័ត៌មានពេញលេញអំពីសិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិរបស់អាណាព្យាបាល
- ឪពុកបានចូលរួមមកក្នុងការសម្ភាសរបស់កូនស្រីជាមួយនឹងមន្ត្រីនគរបាល ដែលអាចឱ្យគាត់មានលទ្ធភាពផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់កូន។

- មន្ត្រីនគរបាលបានឆ្លើយតបទៅនឹងសំណួររបស់ពួកគាត់។
- មន្ត្រីនគរបាលបានផ្តល់ព័ត៌មានពេញលេញទាក់ទងទៅនឹងកញ្ចប់សេវាកម្ម ដែលអាចស្វែងរកបានពីស្ថាប័នផ្សេងៗ( ឧទា. មេធាវី អ្នកប្រឹក្សាយោបល់ និងបុគ្គលិកសង្គមកិច្ចជាដើម...។)
- មន្ត្រីនគរបាលបានធ្វើការទំនាក់ទំនងជាប្រចាំជាមួយខ្ញុំជាឪពុក ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាព និងដំណើរការនៃករណី។

### ជួបជាមួយចៅក្រមស៊ើបសួរ

ស្រីលីន បានរៀបរាប់ថា «នៅពេលខ្ញុំជួបចៅក្រមស៊ើបសួរ គ្មានអ្វីត្រូវពន្យល់ទៀតទេ ព្រោះគាត់មានឯកសាររបស់ខ្ញុំរួចហើយ ដូច្នេះគាត់មានសំណួរដែលគាត់សួរ ហើយអានអ្វីដែលជនសង្ស័យនិយាយ ហើយគាត់សួរសំណួរដើម្បីបញ្ជាក់។ តើជាការពិត ឬមិនមែនជាការពិត។ ពេលនោះមិនមានអ្វីពិបាកទេ ហើយក៏មិនសូវមានមនុស្សច្រើនដែរ ពេលដែលយើងជួបនោះមានតែខាងគាត់ និងយើង»។

### នីតិវិធីក្នុងពេលសវនាការ

«តុលាការដែលមិនអនុញ្ញាតឱ្យពួកគេចូលមើលសវនាការ សម្រាប់ខ្លួនខ្ញុំផ្ទាល់ មានបន្ទប់មួយនៅខាងក្រៅ ហើយខ្ញុំអាចអង្គុយនៅទីនោះរង់ចាំស្តាប់។ នៅពេលដែលពួកគេត្រូវការសេចក្តីថ្លែងការណ៍របស់ខ្ញុំ ខ្ញុំបានចូលទៅ ហើយពួកគេបានដាក់អេក្រង់នៅពីមុខខ្ញុំ ដើម្បីកុំឱ្យនរណាម្នាក់ឃើញមុខរបស់ខ្ញុំ។ ដូច្នេះ វាពិតជាងាយស្រួលសម្រាប់ខ្ញុំ" ។

### ជោគជ័យក្នុងសំណុំរឿង

- ជនសង្ស័យត្រូវបានចោទប្រកាន់តាមមាត្រា៤១ "រូបភាពអាសអាភាសកុមារ" នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងមាត្រា ២៣២ "ការគំរាមកំហែង ជំរិតទារប្រាក់" នៃក្រមព្រហ្មទណ្ឌ។
- ជនសង្ស័យត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលបីឆ្នាំ។
- ស្រីលីនបានទទួលបានសេវាគាំទ្រ ពីអង្គការមិនមែនរដ្ឋាភិបាលផ្នែកផ្លូវច្បាប់ ប្រឹក្សាយោបល់ផ្លូវចិត្ត និងការគាំទ្រជាបន្តបន្ទាប់ពីឪពុកម្តាយរបស់នាង។
- ពួកគេបានយល់ព្រមចូលរួមក្នុងការស្រាវជ្រាវ ពីព្រោះពួកគេចង់ឱ្យមនុស្សផ្សេងទៀតស្វែងយល់អំពីបទពិសោធន៍របស់ពួកគេ និងដើម្បីជួយមន្ត្រីនគរបាល និងអ្នកផ្តល់សេវា
- ផ្សេងទៀតថា តើវាមានសារៈសំខាន់យ៉ាងណាក្នុងការគាំទ្រកុមារ។

## សំណួរសម្រាប់ពិភាក្សាជាមួយសិក្ខាកាម

⇒ តើអ្វីជាចំណុចសំខាន់ និងចំណុចដែលអាចរៀនសូត្របានពីករណីសិក្សាខាងលើនេះ ដែលអាចនឹងអនុវត្តក្នុងការងារប្រចាំថ្ងៃរបស់អ្នក?

⇒ សូមចែករំលែកបទពិសោធន៍របស់អ្នកនូវអ្វីដែលអ្នកគិតថា ធ្លាប់ជួប និងអនុវត្តប្រហាក់ប្រហែលករណីសិក្សាខាងលើ ព្រមទាំងចំណុចវិជ្ជមានក្នុងការគាំទ្រកុមារ និងគ្រួសារដែលរងផលប៉ះពាល់ដោយអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ។

## ខ តើកុមារត្រូវការអ្វីខ្លះ?

### ខ.១- អ្វីដែលកុមារត្រូវការមន្ត្រីនគរបាល

កុមារ និងយុវជន (ដែលរងផលប៉ះពាល់ពី CSEA & OCSEA នៅពេលដែលពួកគេ ត្រូវបានគេសាកសួរអំពីអ្វីដែលពួកគេត្រូវការពីមន្ត្រីនគរបាល មន្ត្រីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ អ្នកផ្តល់សេវា និងអ្នកគាំទ្រផ្សេងៗ។

ប្រសិនបើយើងប្តេជ្ញាចិត្តយ៉ាងពិតប្រាកដក្នុងការគាំពារសិទ្ធិរបស់កុមារ ហើយឆ្លើយតបតាមបែបកុមារមេត្រី យើងអាចចាប់ផ្តើមដោយសិក្សាពាក្យសម្តី និងគំនិតរបស់ពួកគេ ហើយគិតអំពីរបៀបដែលយើងអាចអនុវត្តវានៅក្នុងការងារប្រចាំថ្ងៃរបស់យើង។ ប្រសិនបើ យើងអាចបញ្ចូលគំនិតទាំងនេះ និងធ្វើឱ្យវាជាផ្នែកប្រចាំថ្ងៃ និងទូទៅនៃការអនុវត្តរបស់យើង វាមានអត្ថប្រយោជន៍ជាច្រើន៖

⇒ កុមារនឹងមានអារម្មណ៍ថាមានសុវត្ថិភាព និងទុកចិត្តអ្នកកាន់តែច្រើន ហើយមានទំនុកចិត្តកាន់តែច្រើន និងអាចសហការយ៉ាងជិតស្និទ្ធជាមួយអ្នក។

⇒ វានឹងធ្វើឱ្យដំណើរការកាន់តែរលូន និងបង្កើនលទ្ធភាព ដែលជាលទ្ធផលជោគជ័យសម្រាប់អ្នកក្នុងនាមជាមន្ត្រីនគរបាល។

⇒ របៀបដែលអ្នក និងមនុស្សផ្សេងទៀតមានឥរិយាបថ ក៏អាចមានឥទ្ធិពលវិជ្ជមានលើរបៀបដែលព្យាបាលរបស់ពួកគេ។

⇒ សូមធ្វើតាមការណែនាំទាំងនេះ ដែលជាយុទ្ធសាស្ត្រ «ឈ្នះ-ឈ្នះ» សម្រាប់អ្នករាល់គ្នា!

### ខ.២- អ្វីដែលកុមារត្រូវការពីអ្នកផ្តល់សេវា គ្រួសារ និងអ្នកគាំទ្រផ្សេងទៀត

- ស្តាប់ខ្ញុំ
- ជឿខ្ញុំ
- ទទួលយកខ្ញុំ
- មិនវិនិច្ឆ័យ ឬបន្ទោស
- ជម្រើសភេទស្រី-ប្រុស ដើម្បីសម្ភាសន៍ខ្ញុំ
- មានសំឡេងលើអ្វីៗដែលប៉ះពាល់ដល់ខ្ញុំ
- ជួយនៅពេលជួបបញ្ហា
- មនុស្សទន់ភ្លន់ និងអត់ធ្មត់ដែលផ្តល់ជំនួយដល់ខ្ញុំ
- មានសុវត្ថិភាព
- ផ្តល់ក្តីស្រលាញ់
- ព័ត៌មានត្រឹមត្រូវអំពីសេវា និងសុវត្ថិភាពអ៊ីនធឺណិត
- ទទួលបានការការពារ
- មានជម្រើស និងផ្តល់អំណាច
- ទទួលបានការលើកទឹកចិត្ត
- ទំនាក់ទំនងដែលគួរជាទីទុកចិត្ត
- យល់ចិត្ត
- រក្សាការសម្ងាត់
- ទីកន្លែងឯកជន និងស្ងៀមស្ងាត់សម្រាប់កិច្ចសម្ភាសន៍
- គោរពសិទ្ធិរបស់ខ្ញុំ

## គ បទពិសោធន៍នៃការអនុវត្តគំរូល្អ

### គ.១- ករណីគំរូបាណាហាស (Barnahus) (ផ្ទះកុមារ)[16]

#### តើបាណាហាសជាអ្វី (Barnahus)?

បាណាហាស (Barnahus) ដែលមានន័យថា ផ្ទះរបស់កុមារគឺជាមជ្ឈមណ្ឌលពហុភាគីសម្រាប់ កុមាររងគ្រោះ និងកុមារជាសាក្សី ដែលពួកគេអាចត្រូវបានសម្ភាសន៍ និងពិនិត្យកោសលវិច័យផ្នែកវេជ្ជសាស្ត្រ និងទទួលបានសេវាទាំងអស់ពីអ្នកជំនាញដែលសមស្របនៅកន្លែងតែមួយ។

សកម្មភាពនេះត្រូវបានផ្អែកលើភាពជាដៃគូរវាងមន្ត្រីនគរបាល មន្ទីរពេទ្យ និងភ្នាក់ងារការពារកុមារ រួមទាំង ភ្នាក់ងាររដ្ឋាភិបាលសម្រាប់ការពារកុមារ ដែលទទួលខុសត្រូវចំពោះប្រតិបត្តិការរបស់ខ្លួន។ បាណាហាស (Barnahus) មានដើមកំណើតមកពីគំរូតស៊ូមតិ គាំទ្រកុមារ ដែលបានអនុម័តនៅសហរដ្ឋអាមេរិក ក្នុងទសវត្សឆ្នាំ១៩៨០។ វាត្រូវបានគេអនុវត្តដំបូងក្នុងឆ្នាំ១៩៩៨ ដោយប្រទេសអៀកឡង់ និងតាមបណ្តាប្រទេសប៉ែកអឺរ៉ុបខាងជើងផ្សេងទៀតដូចជា ប្រទេសស៊ុយអែតនៅឆ្នាំ២០០៥ ប្រទេសន័រវេសនៅឆ្នាំ២០០៧ ប្រទេសហ្វាំងឡង់ក្នុងឆ្នាំ២០១១ ប្រទេសដាណឺម៉ាកនៅឆ្នាំ២០១៣ ក្រោមឈ្មោះថាបាណាហាស (Barnahus) ឬផ្ទះរបស់កុមារ។

[16] ប្រភព៖ ដកស្រង់ចេញពីសៀវភៅគោលការណ៍ប្រតិបត្តិកុមារមេត្រីរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

គំនិតជាមូលដ្ឋានរបស់បាណាហាស(Barnahus) គឺជៀសវាងការសម្ភាសកុមារម្តងហើយម្តងទៀត ដោយមន្ត្រីនគរបាលជាច្រើននៅទីតាំងផ្សេងៗគ្នា។ ការរងគ្រោះសារជាថ្មីអាចមានផលប៉ះពាល់ខ្លាំងដល់កុមារច្រើន ជាងការរំលោភបំពាននោះទៅទៀត។ លើសពីនេះទៀត ការសម្ភាសម្តងហើយម្តងទៀត ដែលធ្វើឡើងដោយ មន្ត្រីនគរបាលដែលមិនបានទទួលការហ្វឹកហាត់ជាក់លាក់ក្នុងការសម្ភាសកោសលវិច័យ អាចនឹងធ្វើឱ្យខូចព័ត៌មានរបស់កុមារ ដោយមូលហេតុនៃការសាកសួរសំណួរនាំមុខ ដែលអាចប៉ះពាល់ដល់នីតិវិធីស៊ើបអង្កេត។ គោលបំណងមួយទៀតគឺ ដើម្បីផ្តល់បរិយាកាសបែបកុមារមេត្រី សម្រាប់ការសម្ភាសបែបស៊ើបអង្កេត ដែលអាចកាត់បន្ថយកម្រិតនៃការថប់បារម្ភរបស់កុមារ និងជំរុញឱ្យមានការបង្ហាញ ឬនិយាយចេញរឿងហេតុ ដែលបានកើតឡើង។

## ក្រុមគោលដៅ៖

- កុមារដែលមានការសង្ស័យថា មានការរំលោភបំពានផ្លូវភេទ (ប្រទេសអៀកឡង់)
- កុមារដែលត្រូវគេសង្ស័យ ឬធ្លាប់ទទួលរងនូវហិង្សា (ឧក្រិដ្ឋកម្មប្រឆាំងនឹងជីវិត និងសុខភាព)
- ការដកហូតសេរីភាពផ្ទាល់ខ្លួនដោយខុសច្បាប់ ការជួញដូរ ការឃុំឃាំងដោយខុសច្បាប់ ការគំរាមកំហែង ដោយខុសច្បាប់ ការយាយីដោយឧក្រិដ្ឋកម្មផ្សេងៗ (ឧក្រិដ្ឋកម្មប្រឆាំងសេរីភាព និងសន្តិភាព) ប្រទេសស៊ុយអែត។
- កុមារដែលបានឃើញអំពើហិង្សាលើសាច់ញាតិផ្ទាល់(ប្រទេសស៊ុយអែត)
- ស្ត្រីដែលត្រូវបានកាត់ប្រដាប់ភេទបន្តពូជចោល(ប្រទេសស៊ុយអែត)
- មនុស្សពេញវ័យដែលមានពិការភាពក្នុងការអភិវឌ្ឍ(ប្រទេសន័រវេស)

## បរិយាកាស៖

បរិវេណមានទីតាំងស្ថិតនៅក្នុងតំបន់លំនៅដ្ឋាន ដែលផ្នែកខាងក្នុងមានការរៀបចំបែបកុមារមេត្រី។ "ផ្ទះរបស់កុមារ" មិនប្រើសម្រាប់ជនដែលប្រព្រឹត្តបទល្មើសទេ។

## សេវាកម្មដែលផ្តល់ជូន៖

ការសម្ភាសកោសលវិច័យ ការពិនិត្យសុខភាព សេវាព្យាបាល ការផ្តល់ប្រឹក្សា និងការគាំទ្រដល់គ្រួសារ។

## របៀបដំណើរការ៖

- **ការសម្ភាស៖** កុមារត្រូវបានសម្ភាសន៍នៅក្នុងបន្ទប់ពិសេសមួយ ដោយមានមន្ត្រីនគរបាលជំនាញសម្ភាសន៍ កោសលវិច័យ ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ហើយអនុវត្តសមស្របទៅតាមអាយុ និងការលូតលាស់របស់កុមារ។

- **ការស្តាប់៖** កិច្ចសម្ភាសន៍ត្រូវបានគេមើលឃើញនៅក្នុងបន្ទប់ផ្សេងគ្នា ដោយបុគ្គលិកសង្គមកិច្ច មន្ត្រីនគរបាល ព្រះរាជអាជ្ញា ចៅក្រម មេធាវី និងអ្នកតស៊ូមតិសម្រាប់កុមារ។ ដូចដែលបាននិយាយខាងលើកិច្ចសម្ភាសន៍ ត្រូវបានថតជាវីដេអូសម្រាប់គោលបំណងច្រើន។ ការរៀបចំនេះអាចធ្វើទៅបានក្នុងករណីភាគច្រើន ដែលទាក់ទងនឹងការសម្ភាសតែមួយជាមួយកុមារ នៅពេលដែលកុមារមិនចាំបាច់ត្រូវបង្ហាញខ្លួន នៅគ្រប់នីតិវិធីតុលាការ។

- **ការពិនិត្យកោសលវិច័យ៖** បន្ទាប់ពីសម្ភាសន៍កុមារ ត្រូវមានការពិនិត្យសុខភាពនៅបន្ទប់វេជ្ជសាស្ត្រក្នុងផ្ទះកុមារ។ ការងាររបស់បុគ្គលិកថែទាំសុខភាពនៅ Barnahus គឺដើម្បីស៊ើបអង្កេតស្ថានភាពរាងកាយ របស់កុមារ ចំពោះការព្យាបាលលើរាងកាយ។ គោលបំណងនៃការស៊ើបអង្កេតវេជ្ជសាស្ត្រ គឺដើម្បីកត់ត្រា ទុកជាឯកសារនូវការរងរបួស និងចេញលទ្ធផល កោសលវិច័យ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យ។

- **ការគាំទ្រវិបត្តិ និងការព្យាបាល៖** ការគាំទ្រវិបត្តិសម្រាប់កុមារ ឪពុកម្តាយ និងសមាជិកគ្រួសារផ្សេងទៀត អាចត្រូវបានផ្តល់ជូននៅនឹងកន្លែងដោយបុគ្គលិកដែលទទួលខុសត្រូវ ឬសមាជិកក្រុមដែលបណាការស៊ើបអង្កេត និងដំណើរការផ្លូវច្បាប់ នៅកំពុងបន្ត ឬពួកគាត់អាចបញ្ជូនឱ្យទៅទទួលសេវានៅក្នុងសហគមន៍ផ្ទាល់។

- ផ្ទះនេះក៏ផ្តល់នូវសេវាព្យាបាលកុមាររងគ្រោះដោយការរំលោភបំពានផ្លូវភេទ និងគ្រួសាររបស់ពួកគាត់ផងដែរ។ កុមារត្រូវបានគេធ្វើការប៉ាន់ប្រមាណតម្រូវការ និងវាយតម្លៃសម្រាប់គោលបំណងព្យាបាល និង ទទួលបានសេវាគាំទ្រសមស្រប ហើយផែនការព្យាបាលនីមួយៗត្រូវបានរៀបចំ និងធ្វើឡើងនៅកន្លែងព្យាបាលផ្ទាល់ ឬប្រសិនបើ កុមាររស់នៅក្រៅតំបន់រដ្ឋធានី ដូចជានៅជិតលំនៅដ្ឋានរបស់កុមារតាម ដែលអាចធ្វើទៅបាន។

- **សូមមើលលើបទដ្ឋានប្រតិបត្តិការជាស្តង់ដារ៖** ស្តង់ដារ Barnahus អឺរ៉ុប ត្រូវបានបង្កើតឡើងដោយ គម្រោង PROMISE ដែលឧបត្ថម្ភថវិកាដោយសហភាពអឺរ៉ុប ដែលតំណាងឱ្យក្របខណ្ឌប្រតិបត្តិការ និង រៀបចំសម្រាប់អង្គការ។

- គោលដៅសំខាន់ៗដើម្បីលើកកម្ពស់ការអនុវត្ត ដែលទប់ស្កាត់ការប៉ះទង្គិចផ្លូវចិត្តឡើងវិញស្របពេលដែលបានធានាសក្ខីកម្មត្រឹមត្រូវសម្រាប់តុលាការ និងអនុលោមទៅនឹងសិទ្ធិរបស់កុមារក្នុងការការពារ ការផ្តល់ជំនួយ និងយុត្តិធម៌បែបកុមារមេត្រី។

## ឧស្សាហ៍នៃភាពជោគជ័យ

- បន្ទាប់ពី១៥ឆ្នាំ នៃការប្រតិបត្តិការមានកុមារជាង ៣.៥០០នាក់ ត្រូវបានគេបញ្ជូនទៅផ្ទះបាណាហាស (Barnahus) ប្រទេសអៀកឡង់ ដោយមន្ត្រីនគរបាល និងទីភ្នាក់ងារការពារកុមារ ចាប់តាំងពីឆ្នាំ១៩៩៨ កុមារប្រមាណ ២៥០.៣០០នាក់ ជារៀងរាល់ឆ្នាំ។ ចំនួនករណីដែលបានស៊ើបអង្កេតមានការកើនឡើង ទ្វេដង និងការចោទប្រកាន់ជនសង្ស័យ មានការកើនឡើង៣ដង ហើយនិងការផ្តន្ទាទោសមានការកើនឡើងទ្វេដង។ ការវាយតម្លៃបានបង្ហាញថាមានលទ្ធផលល្អប្រសើរជាងមុនសម្រាប់កុមាររងគ្រោះ និងគ្រួសាររបស់ពួកគេ។

### គ.១- សេចក្តីសង្ខេបអត្ថន័យរៀនសូត្រពីការអនុវត្តគំរូល្អ

មន្ត្រីនគរបាលយើងអាចរៀនសូត្រពីគំរូការអនុវត្តល្អពីកន្លែងផ្សេងទៀត។ ជាអាទិ៍ ផ្ទះបាណាហាស (Barnahus) ឬផ្ទះរបស់កុមារ គឺជាគំរូល្អមួយ។ នៅក្នុងទីកន្លែងតែមួយ កុមាររងគ្រោះអាចទទួលបាន៖ (១) - ការពិនិត្យសុខភាព (២) - ការសម្ភាសបែបកុមារមេត្រី (៣) - ការវាយតម្លៃ ការព្យាបាល ការគាំទ្រ និង (៤) - ការការពារកុមារ។ ការអនុវត្តបែបនេះមិនត្រឹមការពារកុមារពីការរងគ្រោះប៉ុណ្ណោះទេ ថែមទាំង ផ្តល់ជូននូវសេវាសម្រាប់ការស្តា និងការធ្វើសមាហរណកម្មរបស់កុមារផងដែរ។

- **បន្ទប់សម្ភាសន៍បែបកុមារមេត្រី គឺជាធាតុផ្សំដ៏សំខាន់មួយនៃកម្មវិធីបទដ្ឋាននីតិវិធីប្រតិបត្តិការ (SOP) បែបកុមារមេត្រី៖** មន្ត្រីនគរបាលត្រូវយល់ដឹងពីជំហាននានា នៃការប្រើប្រាស់បន្ទប់សម្ភាសន៍កុមារមេត្រីនិងផែនការក្នុងការបង្កើត ឬកែលម្អបន្ទប់សម្ភាសន៍បែបកុមារមេត្រីក្នុងអង្គភាពរបស់ខ្លួន។
- **គោលការណ៍ណែនាំក្នុងការធ្វើការជាមួយកុមាររងគ្រោះ ដើម្បីឆ្លើយតបទៅនឹងករណីរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ (CSEA)៖** លើកកម្ពស់សិទ្ធិកុមារ អនុវត្តនីតិវិធីងាយស្រួលសម្រាប់កុមារ វិធីសាស្ត្រពហុជំនាញ វិធីសាស្ត្រផ្តោតលើយេនឌ័រ ការពារភាពឯកជន និងការសម្ងាត់ ការថែទាំ និងការពង្រឹងភាពធន់ (ភាពខ្លាំង) របស់កុមារ។
- **ចរិតលក្ខណៈនៃនីតិវិធីប្រតិបត្តិជាស្តង់ដារបែបកុមារមេត្រី៖** សុខុមាលភាពរបស់កុមារគឺជាអាទិភាព បង្កើត បរិយាកាសល្អសម្រាប់កុមារ អនុញ្ញាតឱ្យមានវត្តមានអ្នកគាំទ្រ អនុញ្ញាតឱ្យមានវត្តមានមន្ត្រីសុខុមាលភាពសង្គម កាត់បន្ថយទំនាក់ទំនងជាមួយជនសង្ស័យ ប្រើប្រាស់ភាសាទៅតាមអាយុ និង

កម្រិតនៃការអភិវឌ្ឍរបស់កុមារ និងមិនត្រូវវិនិច្ឆ័យមុន ការប្រើប្រាស់សម្ភារៈជំនួយក្នុងការសម្ភាស ការយកចិត្តទុកដាក់ចំពោះតម្រូវការខាងរាងកាយ និងផ្នែកអារម្មណ៍របស់កុមារ ការរៀបចំទុកដាក់ឯកសារ និងសុំឱ្យកុមារចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

- **ការសម្ភាសបែបកុមារមេត្រី មានប្រាំដំណាក់កាល ដែលមន្ត្រីនគរបាលត្រូវអនុវត្តតាម៖** ការណែនាំខ្លួន/ ការកំណត់លក្ខខណ្ឌក្នុងការកសាងទំនាក់ទំនង ការបរិយាយ ឬរៀបរាប់រឿងហេតុដោយសេរី ការសាកសួរ និងការបិទបញ្ចប់។ មានសំណួរប្រាំប្រភេទដែលត្រូវប្រើប្រាស់ក្នុងការសម្ភាស៖ សំណួរបើក សំណួរបិទ សំណួរផ្តោត សំណួរដាក់លាក់ និងសំណួរនាំមុខ។ ក្នុងការសម្ភាសទាំងមូល អ្នកសម្ភាសន៍គួរផ្លាស់ប្តូរ ពីសំណួរបើកទៅជាសំណួរផ្តោតវិញ ដើម្បីប្រមូលព័ត៌មានបញ្ជាក់ ហើយបន្ទាប់មកត្រឡប់ទៅរកសំណួរបើកវិញ។ សំណួរដែលនាំមុខ និងបង្ខិតបង្ខំគួរតែត្រូវបានជៀសវាងជាទូទៅ។

- **ក្រៅពីនេះមន្ត្រីនគរបាលអាចប្រើយុទ្ធវិធីផ្សេងទៀត ដូចជា៖** អនុញ្ញាតឱ្យមានអ្នកលើកទឹកចិត្តតិចតួច ការផ្អាកសិន និងការយកចិត្តទុកដាក់ឡើងវិញ ដើម្បីជួយដល់ដំណើរការនឹកឃើញឡើងវិញរបស់កុមាររងគ្រោះ។ មន្ត្រីនគរបាលត្រូវបង្ហាញការគោរព ការគាំទ្រ ភាពបើកចំហ មិនវិនិច្ឆ័យទុកមុន ការនិយាយត្រង់ៗ និងសមភាពស្មើគ្នាក្នុងអំឡុងពេលសម្ភាសន៍។ មន្ត្រីនគរបាល ត្រូវថតសំឡេង ឬវីដេអូពីសក្ខីកម្មរបស់កុមារ ដើម្បីការពារការសម្ភាសច្រើនដងដែលអាចធ្វើឱ្យប៉ះពាល់ដល់កុមារបន្ថែមទៀត។

- **ឧបករណ៍ជំនួយការសម្ភាស អាចជួយដល់មន្ត្រីនគរបាលក្នុងការដំណើរការសម្ភាសន៍/ការស៊ើបអង្កេត៖** ទោះយ៉ាងណាក៏ដោយ មន្ត្រីនគរបាលត្រូវប្រើឧបករណ៍ទាំងនោះដោយប្រុងប្រយ័ត្ន ហើយមានតែមន្ត្រីនគរបាលដែលមានការបណ្តុះបណ្តាលត្រឹមត្រូវតែប៉ុណ្ណោះ ដែលត្រូវបានណែនាំឱ្យប្រើឧបករណ៍ទាំងនោះជាមួយកុមារ។

- **មន្ត្រីនគរបាលត្រូវយល់ដឹងអំពីភាពលំអៀងផ្នែកយេនឌ័រ៖** ការសន្និដ្ឋាន និងការគិតខុសដែលគាត់មានចំពោះជនរងគ្រោះជាកុមារ និង/ឬក្រុមគ្រួសាររបស់ពួកគេ។ កុមាររងគ្រោះទាំងអស់ មិនថាភេទប្រុស ឬស្រី ឬភេទអ្វីផ្សេង ជាជនជាតិភាគតិច ប្រវត្តិគ្រួសារ ជនពិការជាដើម ត្រូវប្រព្រឹត្តដោយស្មើភាពគ្នា និងដោយភាពថ្លៃថ្នូរ និងការគោរព។

- **មានបច្ចេកទេសខ្លះៗ ដើម្បីកាត់បន្ថយលទ្ធភាពដែលកុមារនិយាយកុហកក្នុងអំឡុងពេលសម្ភាសន៍៖** ការកំណត់មូលដ្ឋាន និងភាពខុសគ្នារវាងការកុហក និងការពិត គឺជាឧទាហរណ៍បច្ចេកទេសដែលមន្ត្រីនគរបាល អាចធ្វើនៅពេលចាប់ផ្តើមដំណើរការសម្ភាស។

- **ការឆ្លើយតបទៅនឹងការរំលោភបំពានដ៏ស្មុគស្មាញ** ដែលពាក់ព័ន្ធនឹងជនរងគ្រោះជាកុមារច្រើន តម្រូវឱ្យមន្ត្រីនគរបាលយកចិត្តទុកដាក់លើវិសាលភាពនៃការស៊ើបអង្កេត ពេលវេលា និងធនធានដែលត្រូវការ និងកិច្ចខិតខំប្រឹងប្រែងដែលបានចំណាយ។ តម្រូវឱ្យមានការរៀបចំផែនការដ៏ល្អ ការធ្វើការងារជាមួយអន្តរទីភ្នាក់ងារល្អ យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការ សុខុមាលភាពរបស់ជនរងគ្រោះ និងការបង្ការកុំឱ្យមានការរំលោភបំពានបន្ថែមទៀតដល់កុមាររងគ្រោះដ៏ទៃទៀត។
- **នៅពេលធ្វើការជាមួយឪពុកម្តាយរបស់ជនរងគ្រោះ មន្ត្រីនគរបាលត្រូវចងចាំថា** ឪពុកម្តាយ/អ្នកថែទាំក៏ ត្រូវការការថែទាំផ្នែកចិត្តសាស្ត្រ ឬការថែទាំ ការព្យាបាល ឬការអប់រំពីសំណាក់ទីភ្នាក់ងារនានា ដើម្បីផ្តល់នូវការការពារ និងការថែទាំល្អបំផុតសម្រាប់កូនរបស់ពួកគេ។ សម្រាប់មាតាបិតា/អ្នកថែទាំដែលជាអ្នករំលោភបំពាន គឺអាស្រ័យទៅលើឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ ដែលមន្ត្រីនគរបាលធ្វើការសម្រេចចិត្តក្នុងការបំបែកកុមារពីគ្រួសារ ឬអត់។
- **ការធ្វើការជាមួយភាគីពាក់ព័ន្ធផ្សេងៗ ដូចជា៖** ប្រព័ន្ធផ្សព្វផ្សាយសង្គម អ្នកឯកទេសវេជ្ជសាស្ត្រ និងអង្គការមិនមែនរដ្ឋាភិបាល/អ្នកធ្វើការងារសង្គមកិច្ច ក៏តម្រូវឱ្យមន្ត្រីនគរបាលធ្វើការបង្ហាញនូវជំនាញជាក់លាក់ និងអាកប្បកិរិយាត្រឹមត្រូវផងដែរ។ ការសហការគ្នាក្នុងក្រុមពហុជំនាញ ជួយយ៉ាងច្រើនក្នុងដំណើរការស៊ើបអង្កេត និងសម្ភាសន៍ ព្រមទាំងក្នុងការព្យាបាល និងសមាហរណកម្មសម្រាប់កុមាររងគ្រោះ និងគ្រួសារ របស់ពួកគេ។

មេរៀនទី៩៖

# ដំណោះស្រាយចំពោះបញ្ហាប្រឈម និងផលវិបាកនានា

ជាទូទៅក្នុងការអនុវត្តកិច្ចការស៊ើបអង្កេត ក៏ដូចជាការឆ្លើយតបករណី OCSEA។ ករណីខ្លះកើតឡើងទាំងស្រុងនៅក្នុងប្រព័ន្ធអនឡាញ និងករណីខ្លះទៀតកើតឡើងនៅក្រៅប្រព័ន្ធអនឡាញ ដែលវាធ្វើអន្តរកម្មគ្នាទៅវិញទៅមក។ លើសពីនេះទៀត វាជាប់ទាក់ទងនឹងការលើកកម្ពស់សិទ្ធិកុមារ ឧត្តមប្រយោជន៍កុមារ និងការអនុវត្តបែបកុមារមេត្រី។ ក្នុងន័យនេះ មន្ត្រីនគរបាលមែងជួបនូវបញ្ហាប្រឈមជាច្រើនជាមិនខាន។ នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីបញ្ហាប្រឈមមួយចំនួន ដែលមន្ត្រីនគរបាលធ្លាប់ជួបប្រទះនាពេលកន្លងមក និងដំណោះស្រាយផងដែរ។

## ក បញ្ហាប្រឈមដែលជួបប្រទះ

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក ក៏ដូចជាការសិក្សាប៉ាន់ប្រមាណសេចក្ដីត្រូវការសម្រាប់បណ្ដុះបណ្ដាលមន្ត្រីនៃអង្គភាពជំនាញអនុវត្តច្បាប់នៅប្រទេសកម្ពុជា បានរកឃើញបទពិសោធន៍ជុំវិញបញ្ហាប្រឈម និងដំណោះស្រាយដែលមន្ត្រីនគរបាលធ្លាប់ជួបប្រទះនាពេលកន្លងមក។ ខាងក្រោមនេះ គឺជាការឆ្លុះបញ្ចាំងពីបញ្ហាប្រឈម និងដំណោះស្រាយខ្លះៗ។

### បញ្ហាប្រឈមមួយចំនួនដែលមន្ត្រីនគរបាលបានជួបប្រទះនាពេលកន្លងមក រួមមាន៖

- បញ្ហាប្រឈមក្នុងការជួបដោយផ្ទាល់ជាមួយកុមារ និងអាណាព្យាបាលរបស់ពួកគេ។
- ពួកគេអាចមានអារម្មណ៍ថា កុមារមិនសហការ។
- ពួកគេអាចមានបញ្ហាប្រឈមក្នុងការយល់ដឹងអំពីបច្ចេកវិទ្យា។
- ពួកគេប្រហែលជាចង់ស្វែងរកដំណោះស្រាយរហ័សចំពោះបញ្ហា ( ប៉ុន្តែប្រហែលជាមិនមានដំណោះស្រាយរហ័ស និងងាយស្រួលទេ )។

**ប៉ុន្តែ នៅពេលដែលយើងស្តាប់កុមារ និងក្រុមគ្រួសាររបស់ពួកគេអំពីទស្សនៈរបស់ពួកគេ យើងដឹងថា៖**

- ពួកគេមិនងាយសហការជាមួយមន្ត្រីនគរបាលឡើយ។
- ជារឿយៗ ពួកគេមិនយល់ពីច្បាប់ ដំណើរការច្បាប់ ឬអត្ថប្រយោជន៍នៃច្បាប់ឡើយ។
- ពួកគេអាចមានការភ័យខ្លាច និង/ឬមិនទុកចិត្តមន្ត្រីនគរបាល។
- ពួកគេអាចមានអារម្មណ៍ថប់បារម្ភ និង/ឬមានអារម្មណ៍អៀនខ្មាស និងអាម៉ាស់យ៉ាងខ្លាំង។
- ពួកគេអាចឈឺចាប់ តក់ស្លុត និងច្របូកច្របល់។
- ពួកគេអាចស្គាល់ជនល្មើស ហើយភ័យខ្លាចចំពោះការតបត។
- ពួកគេអាចបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង ឬត្រូវបានស្តីបន្ទោស។
- ពួកគេអាចមានពិការភាព ហើយពិបាកយល់ ឬពិបាកទំនាក់ទំនង។

បញ្ហាទាំងនេះ និងបញ្ហាជាច្រើនទៀត រារាំងដំណើរការមិនមានភាពរលូន និងសុវត្ថិភាព។ នៅពេលដែលយើងពិនិត្យមើលឱ្យបានជិតដល់ចំពោះព័ត៌មានលម្អិតនៃករណីទាំងនេះ ជាញឹកញាប់ យើងអាចមើលឃើញថា កុមារមិនសហការ។ ប៉ុន្តែ ត្រូវប្រឈមមុខនឹងបញ្ហាជាក់ស្តែង ដែលធ្វើឱ្យពិបាកក្នុងដំណើរការ។

មានពេលខ្លះ គម្លាតរវាងទស្សនៈរបស់ជនរងគ្រោះ និងមន្ត្រីនគរបាល និងកង្វះការយល់ដឹងរវាងកុមារដែលទទួលបានយុត្តិធម៌ និងអ្នកដែលមានភារកិច្ចជួយពួកគេ។

ឧទាហរណ៍អំពីបញ្ហាប្រឈមដែលកុមារបានចែករំលែក កុមារនិយាយថា ពួកគេមិនចង់រាយការណ៍ដោយសារខ្លាចជនល្មើស ឬជនល្មើសជាបុគ្គលដែលគេស្គាល់។ ពួកគេព្រួយបារម្ភអំពីអ្វីដែលនឹងកើតឡើង។

តើមានបញ្ហាចម្បងអ្វីខ្លះសម្រាប់មន្ត្រីនគរបាលដើម្បីពិចារណា? តើមន្ត្រីនគរបាលគួរធ្វើអ្វី និងគួរនិយាយដូចម្តេច?

ឧទាហរណ៍ បញ្ហាសំខាន់ៗមួយចំនួនដែលត្រូវពិចារណា គឺកំណត់អត្តសញ្ញាណជនល្មើស ហើយប្រសិនបើគាត់មានសិទ្ធិចូលទៅជួបកុមារទាំងលើប្រព័ន្ធអនឡាញ ឬក្រៅប្រព័ន្ធអនឡាញ ដែលធ្វើឱ្យកុមារផ្សេងទៀត អាចមានហានិភ័យហើយជនល្មើសអាចបង្កគ្រោះថ្នាក់ដល់កុមារ ប្រសិនបើពួកគេរាយការណ៍។ តម្រូវការដើម្បីអនុវត្តការវាយតម្លៃសុវត្ថិភាព និងហានិភ័យអាស្រ័យលើព័ត៌មានលម្អិតនៃករណី។

មន្ត្រីនគរបាលត្រូវបង្ហាញឱ្យច្បាស់ថា យល់ពីបញ្ហារបស់កុមារ និងជានាទីចំពោះកុមារថា នឹងព្យាយាមឱ្យអស់ពីលទ្ធភាព ហើយធ្វើការជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរក្សាសុវត្ថិភាពរបស់កុមារ។ មន្ត្រីនគរបាលអាចពន្យល់ (ជាភាសាដែលកុមារយល់) ពីរបៀបដែលប្រព័ន្ធច្បាប់អាចដំណើរការ ដើម្បីរក្សាសុវត្ថិភាពរបស់កុមារ និងលើកទឹកចិត្តកុមារឱ្យសួរសំណួរ។ ប្រសិនបើ កុមារត្រូវការកន្លែងមានសុវត្ថិភាព សូមចូលរួមជាមួយពួកគេក្នុងការស្វែងរកដំណោះស្រាយ (ឧទាហរណ៍៖ សមាជិកគ្រួសារដែលមានសុវត្ថិភាព)។

## ខ បញ្ហាប្រឈមដែលជួបប្រទះញឹកញាប់[17]

### ខ.១- ភាពខុសគ្នារវាងការពិត និងការកុហក

កុមារទាំងអស់គួរតែត្រូវបានប្រាប់ថា ត្រូវនិយាយតែការពិត។ បើទោះបីជាមន្ត្រីនគរបាលមិនបាន ឬបានកំណត់វិធាននៃការសម្ភាសក៏ដោយ ក៏មន្ត្រីនគរបាលចាំបាច់ត្រូវបញ្ជាក់ពីសារៈសំខាន់នៃការនិយាយ ការពិតដោយសួរកុមារថា៖

- តើការប្រាប់ការពិតមានន័យយ៉ាងដូចម្ដេច?
- តើការនិយាយកុហកមានន័យយ៉ាងដូចម្ដេច?
- តើមានអ្វីកើតឡើងពេលមនុស្សនិយាយកុហក?

ប្រសិនបើ កុមារមិនអាចញែកដាច់ពីភាពខុសគ្នារវាងការពិត និងការកុហកនោះទេ សូមផ្ដល់ជាឧទាហរណ៍ ដល់កុមារពីពាក្យដែលនិយាយពិតប្រាកដ និងពាក្យកុហក ដោយសុំឱ្យកុមារប្រាប់មន្ត្រីនគរបាលថា តើពាក្យនិយាយបែបនេះ គឺជាការពិត ឬកុហក?

សូមផ្ដល់ជាឧទាហរណ៍ដល់កុមាររវាងការពិត និងការកុហក៖ "ប្រសិនបើខ្ញុំនិយាយថាអាវរបស់អ្នកពណ៌ក្រហម តើវាជាការពិតទេ ឬជាការកុហក?"។

ប្រសិនបើកុមារ ពាក់អាវពណ៌ខៀវ ពិតណាស់វាជាការកុហក។ ប្រសិនបើ កុមារពាក់អាវពណ៌ខ្មៅ សូមសួរថា "បើខ្ញុំនិយាយថា អាវរបស់អ្នកខ្មៅ តើវាជាការពិត ឬជាការកុហក"?

ការធ្វើរបៀបនេះនឹងជួយឱ្យមន្ត្រីនគរបាលដឹងថា តើកុមារអាចបែងចែករវាងចំណុចទាំងពីរនេះបានដែរឬទេ។ ប្រសិនបើកុមារមិនយល់ពីគំនិតនៃពាក្យពិត និងពាក្យកុហកនោះទេ ការសម្ភាសអាចបន្តទៅមុខបានដែរប៉ុន្តែ ត្រូវមានការប្រុងប្រយ័ត្ន និងការទទួលស្គាល់ថា កុមារអាចងាយនឹងទទួលរងឥទ្ធិពលខ្លាំង។

---

[17] ប្រភព៖ ដកស្រង់ចេញពីសៀវភៅគោលការណ៍ប្រតិបត្តិកុមារមេត្រីរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE)

## ៦.២- អនុវត្តបច្ចេកវិទ្យាក្នុងការសម្ភាសបែបកោសលវិច័យ

### ការប្រើភស្តុតាងជាខ្សែអាត់សំឡេង និងវីដេអូ (VARE)

ភស្តុតាងជាខ្សែអាត់សំឡេង និងវីដេអូ (VARE) គឺជាការថតបែបឌីជីថលនៃភស្តុតាងរបស់បុគ្គលណាម្នាក់ នៅក្នុងកាលៈទេសៈទាំងអស់នេះ ស្របតាមនីតិវិធីច្បាប់។ មន្ត្រីនគរបាល គួរតែពិចារណាស្នើសុំការប្រើប្រាស់ភស្តុតាងជាខ្សែអាត់សំឡេង និងវីដេអូ (VARE) ជាមួយព្រះរាជអាជ្ញា ដើម្បីធានាថាកុមាររងគ្រោះត្រូវបានគាំទ្រយ៉ាងពេញលេញ ហើយភាពស្មោះត្រង់នៃការសម្ភាស ដែលមិនមានហានិភ័យ និងប៉ះពាល់ដល់ ការ បែកករណី។

### ខ្សែអាត់សំឡេង និងវីដេអូសម្ភាសន៍ដែលថតបាន ត្រូវបានប្រើប្រាស់សម្រាប់៖

១ ការត្រួតពិនិត្យជាចម្បងលើកុមាររងគ្រោះ និង

២ ការប្រមូលភស្តុតាងសម្រាប់ប្រើក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។

កុមារមានសិទ្ធិក្នុងការបដិសេធមិនថតសំឡេង ឬវីដេអូក្នុងអំឡុងពេលសម្ភាសន៍ ដែលបានថតទុកជា ភស្តុងតាងជាចម្បង និងដោយមធ្យោបាយនៃការផ្សាយផ្ទាល់ ឬទាំងពីរ។

ប្រសិនបើកុមារយល់ថា មិនមានសុវត្ថិភាព និងមិនចង់ឱ្យថតនោះទេ ដូច្នេះ គួរតែពិចារណាលើជម្រើស វិធានការពិសេសផ្សេងទៀត ដូចជាការធ្វើការសាកសួរ និងកត់ត្រាកំណត់ហេតុរបស់កុមារឱ្យបានពេញលេញ។

កត្តាសំខាន់មួយក្នុងការឆ្លើយតបទៅនឹងស្ថានភាពនៃការកេងប្រវ័ញ្ច និងរំលោភបំពានដ៏ស្មុគស្មាញ ដែលមានការរៀបចំទុកជាមុន ឬក្រុមចាត់តាំង មានមនុស្សពាក់ព័ន្ធច្រើន វាគឺជាវិសាលភាព ឬសក្តានុពលនៃការស៊ើបអង្កេត។ ការស៊ើបអង្កេតអាចមានការលំបាក ចំណាយពេលវេលាច្រើន និងទាមទារឱ្យមានធនធានច្រើន។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់ទំហំ និងភាពស្មុគស្មាញនៃការសាកសួរ ឱ្យបានឆាប់តាមដែល អាចធ្វើទៅបាន ដើម្បីពិចារណាលើជម្រើសដែលអាចរកបាន។ តម្រូវការក្នុងការវាយតម្លៃផ្តល់ផលប៉ះពាល់រយៈពេលខ្លី និងយូរអង្វែងព្រមទាំងឥទ្ធិពលនៃការកើនឡើងខ្លាំង វាពិតជាមានសារៈសំខាន់ណាស់។ តម្រូវឱ្យមានការរៀបចំផែនការម៉ត់ចត់ ក្នុងការធ្វើការងារអន្តរទីភ្នាក់ងារ (ក្រុមពហុជំនាញ) និងការយកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការខាងផ្នែកសុខុមាលភាពរបស់កុមាររងគ្រោះ។

ការស៊ើបអង្កេតលើករណីរំលោភបំពានដ៏ស្មុគស្មាញដែលមានការរៀបចំទុកជាមុន ឬមានមនុស្សពាក់ព័ន្ធច្រើន គឺជាការចាំបាច់នូវជាតុផ្សំ ដ៏មានប្រយោជន៍ក្នុងការកំណត់ ចរិតលក្ខណៈនៃការសាកសួរលើករណីដែលមានជនរងគ្រោះច្រើន ជនល្មើសច្រើន ចំនួននៃបទល្មើសច្រើន ការរំលោភបំពានក្នុងស្ថាប័ន រយៈពេល នៃការរំលោភបំពាន កត្តាភូមិសាស្ត្រ បទល្មើសឆ្លងកាត់ព្រំដែន និងបញ្ហាដើម្បីផលប្រយោជន៍ សាធារណៈ។

## គោលការណ៍សម្រាប់ការស៊ើបអង្កេតលើករណីរំលោភបំពានដែលមានភាពស្មុគស្មាញ៖

- មន្ត្រីនគរបាល និងមន្ត្រីផ្តល់សេវាកម្មសង្គមកិច្ច ត្រូវមានផែនការឆ្លើយតប និងសម្របសម្រួលធនធានឆ្លើយតបដោយត្រឹមត្រូវ ព្រមទាំងការប្តេជ្ញាចិត្តឆ្លើយតបឱ្យបានល្អប្រសើរ។
- សុវត្ថិភាព និងសុខុមាលភាពរបស់កុមារត្រូវគិតពិចារណាឱ្យបានខ្ពស់បំផុតនៅពេលអត្តសញ្ញាណរបស់ពួកគេ ត្រូវបានគេស្គាល់ ឬអាចត្រូវបានកំណត់។
- ភាគីទាំងអស់ត្រូវប្រុងប្រយ័ត្នចំពោះមនុស្សពេញវ័យពាក់ព័ន្ធ ដែលអាចជាបណ្តាញនៃអំពើកេងប្រវ័ញ្ច និងរំលោភបំពាន ដើម្បីឆ្លើយតបទៅនឹងករណីនេះ។
- គ្រប់ភាគីទាំងអស់ត្រូវជានាលើការការពារកុមាររងគ្រោះ និងកុមារពាក់ព័ន្ធដទៃទៀត និងត្រូវធានា លើការប្រមូលភស្តុតាង និងផលប៉ះពាល់នៃការស៊ើបអង្កេតទៅលើបុគ្គល និងសហគមន៍ផ្សេងដែរ។
- តម្រូវការនៃការរក្សាការសម្ងាត់យ៉ាងតឹងរឹង និងត្រូវបានវាយតម្លៃនៅដើមដំបូងនៃការសាកសួរ និងពិនិត្យឡើងវិញ ដើម្បីបង្ការកុំឱ្យមានការបែកធ្លាយព័ត៌មានដល់ជនល្មើស។
- ភាគីនានាយល់ស្របដើម្បីពិគ្រោះ ចែករំលែកនូវព័ត៌មាន និងការរក្សាការសម្ងាត់។

## ការត្រួតពិនិត្យ និងតាមដាន

ប្រសិនបើខ្សែអាត់សំឡេង ឬវីដេអូ ត្រូវបានប្រើប្រាស់ នោះគោលការណ៍ណែនាំគួរតែ ត្រូវបានបង្កើតឡើង ដែលគោលការណ៍នេះគួរតែរួមបញ្ចូល ទាំងការរៀបចំ ការសរសេរកំណត់ហេតុ ការរក្សាទុក ការទទួលខុសត្រូវ និងការប្រើប្រាស់ខ្សែអាត់សំឡេង ឬវីដេអូផងដែរ។ ក្រុមការងារ ត្រូវប្រាកដថា វាមានលក្ខណៈគ្រប់គ្រាន់ក្នុងការថតចម្លង បានត្រឹមត្រូវ ដើម្បីឱ្យលទ្ធផលមានគុណភាព ដែលអាចមើលឃើញ និងស្តាប់ឮនូវអ្វីដែលកំពុងកើតឡើងនៅក្នុងការសម្ភាស។

អ្នកសង្កេតការណ៍នៃការសម្ភាស គួរសរសេរកំណត់ហេតុឱ្យបានពេញលេញ ទៅតាមពាក្យសម្តីទាំងអស់ដែលមាននៅក្នុងខ្សែអាត់សំឡេងនិងវីដេអូ(VARE)។ មធ្យោបាយដែលកាន់តែមានប្រយោជន៍មួយទៀត គឺថាប្រសិនបើអ្នកសង្កេតការណ៍នៃការសម្ភាស អាចជួយគាំទ្រអ្នកសម្ភាសន៍ដោយគូសបញ្ជាក់ចំណុចណាដែលមានសក្តានុពលនៃការស៊ើបអង្កេតបន្ថែមសម្រាប់អ្នកសម្ភាសន៍ ដើម្បីបន្តការសម្ភាស (ពួកគេ អាចនិយាយគ្នាបាននៅពេលសម្រាក)។

## ខ.៣- ដំណោះស្រាយនៃការរំលោភបំពានដែលស្មុគស្មាញពាក់ព័ន្ធនឹងកុមាររងគ្រោះច្រើននាក់

ការរំលោភបំពានដ៏ស្មុគស្មាញ មានការរៀបចំក្រុមចាត់តាំងដែលមានមនុស្សច្រើន មិនថាជាការរំលោភផ្លូវភេទ ផ្លូវកាយ ផ្លូវចិត្ត ឬការធ្វេសប្រហែសកើតឡើង ជាផ្នែកមួយនៃបណ្តាញ ការរំលោភបំពានតាមគ្រួសារ ឬសហគមន៍ នៅក្នុងលំនៅដ្ឋាន ឬសាលារៀន និងនៅក្នុងក្រុមពិរុទ្ធជនផ្លូវភេទ ដែលមានក្នុងបណ្តាញ ឬក្រៅបណ្តាញ។ ជួនកាលការរំលោភបំពានបែបនេះ ត្រូវបានរាយការណ៍ជាយូរមកហើយ បន្ទាប់ពីបទល្មើស បានកើតឡើង។

ខាងក្រោមនេះ គឺជាការផ្តល់យោបល់មួយចំនួនសម្រាប់មន្ត្រីនគរបាល ដើម្បីដោះស្រាយការរំលោភបំពាន ដែលស្មុគស្មាញពាក់ព័ន្ធនឹងកុមាររងគ្រោះច្រើននាក់ ឱ្យមានប្រសិទ្ធភាព៖

- សហការល្អជាមួយក្រុមពហុជំនាញ។
- ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការស៊ើបអង្កេតឱ្យបានពេញលេញ។
- ចាត់ថ្នាក់របាយការណ៍នៃការរំលោភបំពានផ្លូវភេទឱ្យបានត្រឹមត្រូវ។
- ជនរងគ្រោះទទួលបានសេវាកម្មសមស្របទៅតាមតម្រូវការរបស់ពួកគាត់។

## ខ.៤- ការដោះស្រាយ បញ្ហាលម្អៀងផ្នែកយេនឌ័រក្នុងការឆ្លើយតបរបស់មន្ត្រីនគរបាល

ភាពលម្អៀងមិនគួររារាំងមន្ត្រីមិនឱ្យយករបាយការណ៍មន្ត្រីនគរបាលស៊ើបអង្កេត ពីការស៊ើបអង្កេតពេញលេញនោះទេ។

### កត្តាខាងក្រោមនេះ អាចធ្វើឱ្យប៉ះពាល់ដល់ភាពជឿទុកចិត្តរបស់ជនរងគ្រោះ ដែលមានដូចជា៖

ការរាយការណ៍យឺតយ៉ាវ ប្រវត្តិរបស់ជនរងគ្រោះក្នុងការធ្វើរបាយការណ៍ស្រដៀងគ្នា ប្រវត្តិនៃការរងគ្រោះផ្លូវភេទ ស្ថានភាពផ្លូវចិត្ត ការខ្វះភាពធន់ មានប្រវត្តិបទល្មើស ឬប្រវត្តិសាវតានៃការធ្វើជាពេស្យាចារ ជំងឺផ្លូវចិត្ត ប្រវត្តិនៃការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន អ្វីដែលជនរងគ្រោះ បាននឹង

កំពុងស្លៀកពាក់ នៅពេលមាន រឿងហេតុកើតឡើង ការខ្វះខាតនូវអត្តសញ្ញាណជាក់ស្តែងណាមួយ នៃផលប៉ះពាល់រាងកាយ ឬអត្តសញ្ញាណ ផ្លូវភេទរបស់ជនរងគ្រោះ ឬអត្តសញ្ញាណយេនឌ័រ។ ការធ្វើសកម្មភាពលើភាពលម្អៀងនានា អាចបង្កើតបាន នូវការរើសអើងខុសច្បាប់ និងធ្វើឱ្យប៉ះពាល់ដល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះ ឧក្រិដ្ឋកម្ម ទាំងនេះ។

ឧទាហរណ៍៖ ប្រសិនបើមន្ត្រីនគរបាលម្នាក់ជឿថា ការរំលោភបំពានផ្លូវភេទមិនសូវជាធ្ងន់ធ្ងរទេ ដោយសារជនរងគ្រោះដែលជាក្មេងប្រុស ឬក្មេងស្រីដែលស្រលាញ់ភេទដូចគ្នា ត្រូវបានរំលោភសេពសន្ថវៈ ដោយមនុស្សពេញវ័យ នោះគឺជាការលម្អៀងផ្អែកយេនឌ័រ ហើយអាចជាការរើសអើងដែលផ្ទុយនឹងច្បាប់។ ករណីមួយទៀត គឺក្មេងស្រីម្នាក់ដែលម្តាយរបស់នាងជាស្រីពេស្យា បានមកដល់ប៉ុស្តិ៍នគរបាល ដើម្បីរាយការណ៍ថា កូនរបស់គាត់ ត្រូវបានរំលោភបំពានផ្លូវភេទដោយភ្ញៀវម្នាក់។ មន្ត្រីនគរបាល ក៏សរសេរចម្លើយ អះអាងរបស់នាង។ ប៉ុន្តែមិនបានចាត់វិធានការបន្ថែមទៀតទេ ដោយសារតែមានប្រវត្តិផ្លូវភេទ និងឧក្រិដ្ឋកម្ម របស់គ្រួសារ នោះ។

បុរស និងស្ត្រីដែលស្រលាញ់ភេទដូចគ្នា (LGBT) បានកំណត់អត្តសញ្ញាណថា ជាអ្នករស់រានមានជីវិត ពីការរំលោភបំពាន អាចមានការស្ទាក់ស្ទើរក្នុងការលាតត្រដាងពីការរំលោភបំពានផ្លូវភេទ ដោយមូលហេតុ បារម្ភខ្លាចការអនុវត្តច្បាប់ចាត់ទុកពួកគាត់មិនសូវសំខាន់ គ្មានតម្លៃ ភ័យខ្លាចថាពួកគាត់ត្រូវបានទទួលរងការចំអកឡកឡឺយ និងធ្វើឱ្យអាម៉ាស់បន្ថែមទៀត។ ភ័យខ្លាចថាការលាតត្រដាងរបស់ពួកគេនឹងទៅជា ការបញ្ចេញអារម្មណ៍ជ្រុល និងព្រួយបារម្ភពីធនធានកណ្តាលនៃវិបត្តិ ដែលបណ្តាលមកពីការរំលោភ សេពសន្ថវៈ ដោយការសង្កត់ធ្ងន់ជាប្រវត្តិសាស្ត្រលើការជួយស្ត្រីដែលរស់រានមានជីវិត និងនិន្នាការនយោបាយ ដែលអាចកើតមានមិនត្រូវបានគេរៀបចំឡើង ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់។

**ខាងក្រោមនេះ គឺជាការផ្តល់យោបល់មួយចំនួនសម្រាប់មន្ត្រីនគរបាល ដើម្បីដោះស្រាយភាពលម្អៀង ទាំងនេះយ៉ាងមានប្រសិទ្ធភាពចំពោះករណីរំលោភបំពានផ្លូវភេទកុមារ៖**

- ទទួលស្គាល់ និងដោះស្រាយភាពលម្អៀង ការសន្មត និងការយល់ខុសអំពីជនរងគ្រោះ។
- ប្រព្រឹត្តចំពោះជនរងគ្រោះទាំងអស់ដោយការគោរព និងសេចក្តីថ្លៃថ្នូរ។
- ជនរងគ្រោះទទួលបានសេវាកម្មសមស្របទៅតាមតម្រូវការរបស់ពួកគាត់។
- ថែរក្សាព័ត៌មានជាឯកជនភាព និងមានការគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទឱ្យមានសុវត្ថិភាព។

នៅក្នុងមេរៀនអ្នកបានយល់ដឹងអំពីការប្រឈមដែលមន្ត្រីនគរបាលធ្លាប់ជួបប្រទះនាពេលកន្លងមក និងបានសិក្សាវិភាគឆ្លុះបញ្ចាំងលើបញ្ហាទាំងនោះ ព្រមទាំងបានកំណត់នូវដំណោះស្រាយឆ្លើយតប។ បញ្ហាប្រឈមមួយចំនួន គឺជាគម្លាតរវាងទស្សនៈរបស់ជនរងគ្រោះ និងមន្ត្រីនគរបាលទៅវិញនោះទេ។ មន្ត្រីនគរបាលយើងត្រូវយកចិត្តទុកដាក់លើចំណុចនេះ ដើម្បីធានាបានថាការយល់ដឹងអំពីកុមារបានច្បាស់ ដើម្បីធ្វើយ៉ាងណាឱ្យពួកគេទទួលបាននូវយុត្តិធម៌ពេញលេញ ក៏ដូចជាបានបំពេញភារកិច្ចរបស់ខ្លួនមានប្រសិទ្ធភាពខ្ពស់ផងដែរ។ លើសពីនេះ អំពីបញ្ហាប្រឈមទូទៅជាច្រើនដែលមន្ត្រីនគរបាល យើងឧស្សាហ៍ជួបប្រទះ មានដូចជា ភាពខុសគ្នារវាងការពិត និងការកុហករបស់កុមារ ការប្រើភស្តុតាងជាខ្សែអាត់សំឡេង និងវីដេអូ ការត្រួតពិនិត្យ និងតាមដាន ការដោះស្រាយការរំលោភបំពានដែលស្មុគស្មាញខ្លាំងពាក់ព័ន្ធនឹងកុមាររងគ្រោះច្រើននាក់ ព្រមទាំងយល់ដឹងពីការដោះស្រាយបញ្ហាដែលជៀសផុតពីការលម្អៀងលើផ្នែកយេនឌ័រជាដើម។

មេរៀនទី១០៖

# វិធានសុវត្ថិភាពនៅលើអនឡាញ ការរាយការណ៍ និងការស្វែងរកជំនួយ

ក្នុងនាមជាមន្ត្រីនគរបាល អ្នកផ្តល់សេវាពាក់ព័ន្ធឆ្លើយតបនឹង OCSEA ត្រូវមានចំណេះដឹង និងជំនាញមូលដ្ឋាន ជាពិសេសធានាសុវត្ថិភាពនៅលើប្រព័ន្ធអនឡាញ និងការលើកកម្ពស់ការរាយការណ៍ និងស្វែងរកជំនួយផ្សេងៗ។ អ្នកមិនត្រឹមតែជួយផ្តល់បទអន្តរាគមន៍ឆ្លើយតបចំពោះបទល្មើសនោះទេ ថែមទាំងជួយចូលរួមផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ការទប់ស្កាត់ការប្រឈមមុខ និងហានិភ័យរបស់កុមារ និងយុវជនផងដែរ។ នៅក្នុងមេរៀននេះអ្នកនឹងស្វែងយល់បន្ថែមពីការដោះស្រាយបញ្ហាប្រឈម និងភាពសាំញ៉ាំនៅក្នុងករណី (OCSEA) ភាពលំបាកទាក់ទងនឹងកុមារ ឬគ្រួសារ និងស្វែងយល់ដឹងពីសារៈសំខាន់វិធានការសុវត្ថិភាព និងការរាយការណ៍របស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត អ្នករៀនអំពីរបៀបចូលប្រើ APLE Chatbot និងចូលប្រើ APLE Chatbot តាមទូរស័ព្ទស្មាតហ្វូន (Smartphone) ដែលស្វែងរកចម្លើយនៃបញ្ហាចម្ងល់របស់អ្នកជាច្រើនផងដែរ។

## ក ស្វែងយល់ពីការដោះស្រាយបញ្ហាប្រឈម ការលំបាក និងភាពលំបាក

**តើបញ្ហាសំខាន់អ្វីខ្លះដែលមន្ត្រីនគរបាលត្រូវពិចារណា?**

**តើមន្ត្រីនគរបាលគួរធ្វើអ្វីខ្លះ ក្នុងការឆ្លើយតបករណីនេះ?**

| | |
|---|---|
| ១- កុមារនិយាយថាពួកគេមិនមានបំណងចង់ផ្តល់ចម្លើយដល់មន្ត្រីនគរបាលដោយសារតែការភ័យខ្លាចជនល្មើស និង/ឬជនល្មើសគឺជាមនុស្សដែលពួកគេស្គាល់ច្បាស់។ ពួកគេព្រួយបារម្ភអំពីអ្វីដែលនឹងកើតឡើង។ | ២- កុមារមិនយល់ថាអ្វីដែលបានកើតឡើងចំពោះពួកគេគឺវាខុសនោះទេ។ |

| | |
|---|---|
| ៣- កុមាររងគ្រោះគិតថាត្រូវបានស្តីបន្ទោសឱ្យពួកគេចំពោះអ្វីដែលបានកើតឡើង។ | ៤- កុមារមើលទៅភ័យខ្លាចខ្លាំងណាស់ នៅពេលដែលអ្នកជួបពួកគេ។ អាណាព្យាបាល និង/ឬបុគ្គលិកសុខុមាលភាពកុមារពន្យល់ថា កុមារភ័យខ្លាចមន្ត្រីនគរបាលខ្លាំងណាស់។ |
| ៥- កុមារដែលជាជនរងគ្រោះនៃ OCSEA ប៉ុន្តែពួកគេគិតថាពួកគេបានចូលរួមប្រព្រឹត្តបទឧក្រិដ្ឋ ហើយមានការភ័យខ្លាចយ៉ាងខ្លាំងថាពួកគេនឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយអាចជាប់ពន្ធនាគារ។ ដូច្នេះគេមិនព្រមនិយាយជាមួយអ្នកទេ។ | ៦- កុមារមានអារម្មណ៍អាម៉ាស់ខ្លាំង ហើយយំសោក។ ពួកគេមិនចង់និយាយជាមួយនរណាម្នាក់អំពីអ្វីដែលបានកើតឡើងចំពោះពួកគេទេ។ |
| ៧- កុមារអាយុ១៦ឆ្នាំម្នាក់ គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម ហើយមានការខូចចិត្ត និងខឹងសម្បារយ៉ាងខ្លាំងចំពោះអ្វីដែលបានកើតឡើង ប៉ុន្តែពួកគេមិនចង់ឱ្យឪពុកម្តាយរបស់ខ្លួនដឹងអំពីរឿងនេះទេ។ ដូច្នេះពួកគេមិនចង់ធ្វើការរាយការណ៍ផ្លូវការទៅអង្គភាពណាទេ។ | ៨- កុមារពិបាកនិយាយរឿងផ្លូវភេទជាមួយមន្ត្រីនគរបាលប្រុស ព្រោះជនល្មើសក៏ជាបុរសដែរ។ |
| ៩-កុមារពិបាកនិយាយរឿងពាក់ព័ន្ធផ្លូវភេទណាស់ | ១០- កុមារមានការភ័យខ្លាចយ៉ាងខ្លាំង - ពួកគេនិយាយត្រដិត ហើយរកពាក្យនិយាយមិនចេញ។ (នេះក៏អាចបង្ហាញពីពិការភាពដែលអាចកើតមានដែរទេ ? ) |
| ១១- ឪពុកម្តាយ និង/ឬកុមារមិនយល់ពីច្បាប់ ឬដំណើរការច្បាប់ទេ។ ពួកគេទំនងជាមិនសហការទេ លុះត្រាតែពួកគេអាចយល់កាន់តែច្បាស់។ | ១២- អ្នកសង្កេតឃើញសហសេវិកម្នាក់រើសអើងដល់យុវជន ហើយបន្ទោសពួកគេចំពោះអ្វីដែលបានកើតឡើងដោយសារតែពួកគេជា LGBTQI ។ ពួកគេប្រាប់យុវជនថា ប្រសិនបើពួកគេ «ធម្មតា» ដូចគេឯង នោះពួកគេមិនជួបរឿងបែបនេះទេ។ |

| | |
|---|---|
| ១៣- អ្នកសង្កេតឃើញសហការីរបស់អ្នក ម្នាក់ រើសអើងលើជនរងគ្រោះជាកុមារ ហើយបន្ទោស ពួកគេចំពោះអ្វីដែលបានកើតឡើង។ ពួកគេ ប្រាប់កុមារថា ប្រសិនបើពួកគេមិនបាន ចំណាយពេលច្រើននៅលើទូរស័ព្ទទេ រឿងនេះនឹងមិនកើតឡើងនោះទេ។ | ១៤- អ្នកសង្កេតឃើញឪពុកម្តាយរបស់កុមារ ហើយពួកគេខឹងខ្លាំងណាស់ ពួកគេធ្វើបាបកុមារ ហើយបន្ទោសកុមារសម្រាប់អ្វីដែលបាន កើតឡើង។ |
| ១៥- កុមារឃ្លាន និង/ឬមានតម្រូវការមូលដ្ឋាន និង/ឬតម្រូវការផ្នែកវេជ្ជសាស្ត្រដែលត្រូវការ ការយកចិត្តទុកដាក់។ អ្នកចង់ធ្វើការសម្ភាស ដើម្បីអ្នកអាចទៅផ្ទះបាន។ | ១៦- កុមារនឿយហត់ ប៉ះទង្គិច និងប៉ះពាល់ ផ្លូវចិត្តរបស់ពួកគេ ពួកគេគេងមិនលក់យូរហើយ ហើយពួកគេមិនអាចផ្ចង់អារម្មណ៍និយាយបាន។ |
| ១៧- កុមារមានពិការភាពខាងសតិបញ្ញា/ការ អភិវឌ្ឍ ហើយពិបាកទំនាក់ទំនងបានច្បាស់។ តើអ្នកគួរឆ្លើយតបបែបណា? | ១៨-កុមារមានបញ្ហាការស្តាប់ ហើយមិនអាច យល់ពីអ្វីដែលអ្នកកំពុងនិយាយ ឬទំនាក់ទំនង។ |
| ១៩- អ្នកផ្សេងទៀត (ឪពុកម្តាយ មិត្តភក្តិ) បាន ប្រាប់កុមារថា អ្វីដែលបានកើតឡើងមិនធ្ងន់ធ្ងរទេ ហើយពួកគេមិនគួរខ្ជះខ្ជាយពេលរាយការណ៍ទេ ដោយសារប៉ូលិសពុករលួយ ហើយមន្ត្រី នគរបាលមិនចាប់អារម្មណ៍ជួយអ្នកទេ។ | ២០- កុមាររស់នៅតាមដងផ្លូវ ហើយហិតការ និង កំពុងបែកថ្នាំនៅពេលអ្នកជួបគាត់។ |
| ២១- កុមារហាក់ដូចជាមានបញ្ហាសុខភាពផ្លូវចិត្ត ហើយមានការភ័ន្តច្រឡំខ្លាំង ហើយមើលទៅ ហាក់ដូចជាខ្លាចអ្នកខ្លាំងណាស់។ | ២២-កុមារមានអាយុ ១៥ឆ្នាំ ហើយប្រាប់អ្នកថា ពួកគេបានយល់ព្រមចំពោះការកេងប្រវ័ញ្ចនេះ ដែលត្រូវបានរៀបចំជាភាគីទីបីតាមរយៈកម្មវិធី បណ្តាញទំនាក់ទំនងសង្គមមួយ |

| | |
|---|---|
| ២៣-បុគ្គលិកសង្គមកិច្ចដែលនៅជាមួយយុវជនប្រាប់អ្នកថា យុវជននោះកំណត់អត្តសញ្ញាណថាជា LGBTQI ហើយពួកគេបានជួបប្រទះការរើសអើងជាច្រើនពីមនុស្សក្នុងសហគមន៍ពីមុនមក រួមទាំងមន្ត្រីប៉ូលិសផងដែរ។ ពួកគេរំពឹងថាដូចគ្នានឹងកើតឡើងសាជាថ្មី ដូច្នេះពួកគេមិនមានអារម្មណ៍ជឿជាក់ក្នុងការធ្វើសេចក្តីបំភ្លឺទេ។ | ២៤-អ្នកផ្សេងទៀត (ឪពុកម្តាយ មិត្តភក្តិ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬនគរបាល) បានប្រាប់កុមារថា អ្វីដែលបានកើតឡើងគឺមិនធ្ងន់ធ្ងរទេ ព្រោះវាគ្រាន់តែនៅក្នុងប្រព័ន្ធអនឡាញ ហើយដូចជាមិនមានការប៉ះពាល់អ្វីឡើយ។ ពួកគេប្រាប់បុគ្គលនោះថា ពួកគេមិនគួរខ្ជះខ្ជាយពេលវេលារាយការណ៍អំពីឧក្រិដ្ឋកម្មនោះទេ។ |

## ខ ភាពលំបាកទាក់ទងនឹងដំណើរការរបស់មន្ត្រីនគរបាល ឬបរិស្ថាននៅប៉ុស្តិ៍រដ្ឋបាល

### តើបញ្ហាសំខាន់អ្វីខ្លះ ដែលមន្ត្រីនគរបាលត្រូវពិចារណារ?

### តើមន្ត្រីនគរបាលគួរធ្វើអ្វី ពេលជួបនូវការកត្តាប្រឈមខាងក្រោមនេះ ?

| | |
|---|---|
| ២៥- អ្នកចង់ធ្វើការសម្ភាស ប៉ុន្តែមិនអាចរកបានបុគ្គលិកសង្គមកិច្ច ឬអាណាព្យាបាលណាបានលុះត្រាតែចាំរហូតដល់ពេលក្រោយ។ | ២៦-សហការីរបស់អ្នកដែលគ្រោងនឹងធ្វើបទសម្ភាស ហើយមិនសូវមានជំនាញ «កុមារមេត្រី»។ អ្នកព្រួយបារម្ភថាពួកគេនឹងមិនធ្វើការបានល្អ។ |
| ២៧- សហសេវិករបស់អ្នកដែលនឹងធ្វើបទសម្ភាស អស់កម្លាំង និងតានតឹងខ្លាំង។ អ្នកមានការព្រួយបារម្ភថាពួកគេមិនមែនជាមនុស្សដែលល្អ ក្នុងការធ្វើបទសម្ភាសបឋមជាមួយកុមារនោះទេ។ | ២៨-សហសេវិករបស់អ្នកបានទាញយករូបភាពមួយចំនួននៃ OCSEA ដាក់លើទូរស័ព្ទផ្ទាល់ខ្លួនរបស់គាត់ ហើយចែករំលែកវានៅក្នុងក្រុម Telegram។ |
| ២៩- ឯកសណ្ឋានរបស់មន្ត្រីនគរបាលធ្វើឱ្យកុមារមានអារម្មណ៍មិនស្រួល និងភ័យខ្លាច។ | ៣០- កុមារពិបាកនិយាយជាមួយមន្ត្រីជាបុរស |
| ៣១- បន្ទប់ដែលអ្នកចង់ធ្វើការសម្ភាសគឺមិនមានភាពឯកជនទេ ហើយកុមារអាចត្រូវបានគេមើលឃើញ និង អ្នកដទៃទៀតអាចស្តាប់ឮ។ | ៣២- សហការីរបស់អ្នកដែលនឹងធ្វើបទសម្ភាសគឺអស់កម្លាំង និងតានតឹងខ្លាំង។ |

| | |
|---|---|
| ៣៣- មន្ត្រីផ្សេងទៀតដើរកាត់បន្ទប់ដែលអ្នកកំពុងសម្ភាសន៍កុមារ ហើយពេលខ្លះពួកគេចូលមកស្តាប់។ អ្នកសង្កេតឃើញថា កុមារមិនមានផាសុកភាព ហើយខ្មាសអៀន។ | ៣៤- អ្នកកំពុងពិភាក្សាករណីមួយជាមួយក្មេងប្រុសដែលត្រូវបានគេរំលោភបំពាន។ សហសេវិកពីនាក់បានស្តាប់ឮពីការសន្ទនា ហើយសើចចំអកដាក់កុមារនោះ ហើយនិយាយចំអន់ផ្សេងៗ។ |
| ៣៥- អ្នកឮមិត្តសហសេវិកនិយាយអំពីករណី OCSEA និងកុមារដែលគាត់នឹងសម្ភាសន៍។ គាត់និយាយថាវាមិនធ្ងន់ធ្ងរទេព្រោះជាក្មេងប្រុសម្នាក់ដែលស្រលាញ់ភេទដូចគ្នា ហើយគាត់ប្រហែលជាចង់ឱ្យវាកើតឡើងបែបនោះដែរ។ | ៣៦- អ្នកឮសហសេវិកនិយាយអំពីករណី OCSEA និងកុមារដែលគាត់នឹងសម្ភាសន៍។ គាត់និយាយថា វាមិនធ្ងន់ធ្ងរទេ ព្រោះជនរងគ្រោះជាក្មេងប្រុស ហើយជនល្មើសជាស្ត្រី។ ពួកគេនិយាយថាក្មេងប្រុសនេះ «សំណាង» ដែលគាត់អាចទទួលបានបទពិសោធន៍នេះ ហើយពួកគេបានសើច។ |
| ៣៧- អ្នកឮសហសេវិកនិយាយជាមួយឪពុកម្តាយរបស់កុមារទាក់ទងនឹងករណី OCSEA ហើយពួកគេប្រាប់ឪពុកម្តាយថា «ហេតុផលតែមួយគត់ដែលអ្នកនៅទីនេះគឺដោយសារតែអង្គការឱ្យមក ហើយចាប់អារម្មណ៍តែលុយប៉ុណ្ណោះ!" | ៣៨- កុមារ និងអាណាព្យាបាលរបស់គាត់កំពុងរង់ចាំទទួលការសម្ភាស។ សហការីរបស់អ្នកបានសុំឱ្យអ្នកធ្វើអ្វីមួយសម្រាប់ពួកគេ។ ការធ្វើកិច្ចការនោះមានន័យថា កុមារអាចត្រូវរង់ចាំពីរម៉ោងទៀត។ |
| ៣៩- កុមារដែលអ្នកត្រូវសម្ភាសន៍មានពិការភាពផ្នែកបញ្ញា និងការលំបាកក្នុងការទំនាក់ទំនង។ | ៤០- កុមារដែលត្រូវបានរំលោភបំពានលើប្រព័ន្ធអនឡាញ ថ្លង់ ហើយត្រូវការអ្នកបកប្រែភាសាសញ្ញាដើម្បីទំនាក់ទំនងបានច្បាស់។ |
| ៤១- ការសម្ងាត់នៃសម្ភារៈ និងភស្តុតាងទាំងអស់ (ជាក់ស្តែង និងឌីជីថល) គឺមានសារៈសំខាន់ខ្លាំងណាស់។ | ៤២-ជាក់ស្តែងនៅក្នុងករណី OCSE មន្ត្រីនគរបាលត្រូវរាយការណ៍ទៅថ្នាក់គ្រប់គ្រងពីមួយទៅមួយទៀត។ វាក៏អាចផ្ញើរូបអាសអាភាសកុមារ ឬតំណភ្ជាប់នៃរូបភាពអាសអាភាសកុមារផងដែរ។ **តើអ្នកជៀសវាងការចែករំលែករូបភាពអាសអាភាសកុមារដោយរបៀបណា?** **តើអ្នកគ្រប់គ្រងភស្តុតាងឌីជីថលដោយរបៀបណា?** |

## គ ភាពលំបាកដែលទាក់ទងនឹងឧក្រិដ្ឋកម្មជាក់លាក់ ច្បាប់ និង/ឬបញ្ហាបច្ចេកវិទ្យាឌីជីថល

តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?

តើមន្ត្រីនគរបាលគួរធ្វើអ្វី ហើយនិយាយទៅកុមារបែបណា?

តើមន្ត្រីនគរបាលគួរចាត់វិធានការអ្វីទៀត?

តើព័ត៌មានបន្ថែមអ្វីខ្លះដែលមន្ត្រីនគរបាលអាចផ្តល់ឱ្យពួកគេ ដែលអាចមានប្រយោជន៍?

| | |
|---|---|
| ៨៣-កុមារជាជនរងគ្រោះមិនស្គាល់អត្តសញ្ញាណជនសង្ស័យទេ ព្រោះប្រើអត្តសញ្ញាណប័ណ្ណ និងគណនីហ្វេសប៊ុកក្លែងក្លាយ។ កុមារពិបាកចិត្តខ្លាំងណាស់។ | ៨៤- ជនល្មើសបានប្រព្រឹត្តបទល្មើសយ៉ាងធ្ងន់ធ្ងរលើកុមារ ហើយភស្តុតាងទាំងអស់បានបង្ហាញថា ពួកគេអាចនឹងរស់នៅក្រៅប្រទេសកម្ពុជា។ |
| ៨៥- កុមារ និងឪពុកម្តាយរបស់ពួកគេ ប្តឹងអំពីអាកប្បកិរិយាលើប្រព័ន្ធអនឡាញ ដែលតាមលក្ខណៈបច្ចេកទេសគឺមិនទាន់ជាឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា។ កុមារពិបាកចិត្តណាស់។ ដោយគ្រាន់តែប្រាប់គេថាគ្មានអ្វីដែលអ្នកអាចធ្វើបានទេ ព្រោះវាមិនខុសច្បាប់ហើយក៏គ្មានប្រយោជន៍ដែរ។ | ៨៦- អ្នកជួបករណីដែលឪពុកម្តាយចង់ប្តឹងប៉ុន្តែកូន ឬយុវជនមិនព្រម។ *(ឧ. កុមារបានចែករំលែករូបភាពជាមួយមិត្តប្រុស/មិត្តស្រីរបស់ពួកគេដោយការយល់ព្រម។ តាមបច្ចេកទេសមិនមានឧក្រិដ្ឋកម្មណាមួយត្រូវបានប្រព្រឹត្តទេ)*។ ឪពុកម្តាយខឹងខ្លាំងណាស់។ |
| ៨៧- អ្នកកំពុងធ្វើការលើករណីដែលអ្នកសង្ស័យថាឧបករណ៍មួយមានរូបភាព CSAM ប៉ុន្តែអ្នកមិនមានជំនាញបច្ចេកទេសឌីជីថលដើម្បីដំណើរការទេ។ | ៨៨-ក្រឡេកមើលអង្គហេតុនៃករណីនេះ បទល្មើសហាក់ដូចជាបានប្រព្រឹត្ត ប៉ុន្តែយុវជននោះមានអាយុលើសពី១៨ឆ្នាំ។ |

## ឃ ស្វែងយល់ដឹងពីសារៈសំខាន់វិធានការសុវត្ថិភាព និងការរាយការណ៍របស់ប្រជាពលរដ្ឋ

ក្នុងនាមជាមន្ត្រីនគរបាលចាំបាច់យល់ដឹងពីវិធានសុវត្ថិភាពនៃការប្រើបច្ចេកវិទ្យាផងដែរ។ មន្ត្រីនគរបាលអាចជួយពន្យល់ដល់ក្រុមគ្រួសារកុមារ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យមានការយល់ដឹងពីការប្រើឧបករណ៍ និងប្រព័ន្ធបច្ចេកវិទ្យា អ៊ីនធឺណិត និងអនឡាញមានសុវត្ថិភាពជាពិសេសបណ្តាញព័ត៌មានសង្គម។

### ឃ.១- វិធានសុវត្ថិភាពលើអ៊ីនធឺណិត[18]

មន្ត្រីនគរបាលប្រើបច្ចេកវិទ្យាឌីជីថល ចាំបាច់ត្រូវយល់ដឹងពីវិធានសុវត្ថិភាព នៅពេលតភ្ជាប់បណ្ដាញ អ៊ីនធឺណិត ក្នុងការសិក្សាស្រាវជ្រាវ ការអប់រំ ការធ្វើទំនាក់ទំនង ការកម្សាន្ត ការធ្វើពាណិជ្ជកម្ម។ល។ វិធានសុវត្ថិភាពមួយចំនួនអ្នកប្រើត្រូវដឹងរួមមាន៖ ការកំណត់ឯកជនភាពសុវត្ថិភាពនៃការស្វែងរកព័ត៌មាន ការរាំងខ្ទប់បុគ្គលណាម្នាក់ វិធីសាស្ត្រការពារខ្លួនពីការលួងលោម និងរបៀបប្រាស្រ័យទាក់ទង ប្រកបដោយសុវត្ថិភាពលើប្រព័ន្ធអនឡាញ។

### ឃ.២-ការកំណត់ឯកជនភាព

ឯកជនភាព និងសុវត្ថិភាពតាមអនឡាញមានសារៈសំខាន់ដូចគ្នា។ កម្មវិធីអនឡាញភាគច្រើនផ្ដល់មធ្យោបាយឱ្យយើងអាចកំណត់ឯកជនភាពដើម្បីគ្រប់គ្រងព័ត៌មានដែលយើងកំពុងប្រើ និងចែករំលែក។




មន្ត្រីនគរបាលអាចណែនាំអំពីកំណត់ឯកជនភាព នៅលើកម្មវិធីអនឡាញ ឬគេហទំព័រ ដោយរកមើល និងជ្រើសរើសយក ពាក្យដូចជា "គណនីរបស់ខ្ញុំ (My Account)" ឬ "ការកំណត់ (Settings)"។ ពាក្យទាំងពីរនេះ ជាកន្លែង ដែលអ្នកប្រើប្រាស់នឹងធ្វើការកំណត់ឯកជនភាពតាមការសម្រេចចិត្ត ដូចជា៖

- ព័ត៌មានដែលអ្នកប្រើប្រាស់ចង់ឱ្យគេមើលឃើញនៅលើទំព័រ (Page) ឬប្រវត្តិរូប (Profile) របស់ខ្លួន
- អ្នកប្រើអាចចែករំលែកឱ្យអ្នកផ្សេងទៀត មើលឃើញការបង្ហោះ រូបថត វីដេអូ ឬមាតិកាផ្សេងៗក្រោយពីបានធ្វើការកំណត់ឯកជនភាពលើគណនីរួចរាល់ហើយអ្នកត្រូវធ្វើបច្ចុប្បន្នភាពលើការកំណត់ទាំងនេះឱ្យបានទៀងទាត់។
- ក្រៅពីការកំណត់ខាងលើ អ្នកក៏ត្រូវគិតថា នរណាគួរទទួលយក ធ្វើជាមិត្ត (Friend) ឬអ្នកតាមដាន (Follower) នៅលើអនឡាញ។ ជម្រើសដែលមានសុវត្ថិភាពបំផុតគឺមានតែមិត្តភក្តិ និងក្រុមគ្រួសារ ដែលអ្នកបានស្គាល់ដោយផ្ទាល់។ ប្រសិនបើអ្នកប្រើអនុញ្ញាតឱ្យអ្នកដទៃ មើលឃើញព័ត៌មានដែលអ្នកប្រើបង្ហោះចែករំលែកនោះ អាចនឹងត្រូវបានមើលឃើញដោយអ្នកមិនធ្លាប់ជួប ឬស្គាល់។

[18] ដកស្រង់ចេញពីសៀវភៅណែនាំបង្រៀនអំពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញកម្រិតបឋមសិក្សាបឋមភូមិ

## ឃ.៣- កំណត់សុវត្ថិភាពនៃការស្វែងរកលើប្រព័ន្ធអនឡាញ

- អ៊ីនធឺណិតគឺជាកន្លែងមួយដែលផ្ទុកព័ត៌មានល្អៗយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលអ្នកប្រើអាចស្វែងរកបាន។ កម្មវិធីស្វែងរកតាមអ៊ីនធឺណិត ឬគេហៅថា ម៉ាស៊ីនស្វែងរក (Search Engine) ជួយយើងប្រមូល និងបង្រួមចំនួនព័ត៌មានដែលមកពីប្រភពផ្សេងៗគ្នា ជុំវិញពិភពលោក។ វាជាឧបករណ៍ដែលមនុស្សប្រើ ដើម្បីស្វែងរកព័ត៌មានលើប្រធានបទគ្រប់ប្រភេទ។
- ដើម្បីប្រើឧបករណ៍នេះ អ្នកប្រើប្រាស់ត្រូវវាយសំណួរ ឬពាក្យគន្លឹះទៅក្នុងរបារ ឬប្រអប់ទទេនៅលើម៉ាស៊ីនស្វែងរក ឬនៅក្នុងកម្មវិធីរុករក (Browser) របស់អ្នក (កន្លែងដែលអ្នកប្រើប្រាស់វាយអាសយដ្ឋានគេហទំព័រ) ដើម្បីទទួលបានព័ត៌មានអំពីប្រធានបទដែលអ្នកចង់ដឹងបន្ថែម។ បន្ទាប់មកសូមចុច Return ឬ Search key ហើយម៉ាស៊ីនស្វែងរកនឹងធ្វើដំណើរការរបស់វា។ ប៉ុន្តែអ្វីដែលសំខាន់ អ្នកប្រើត្រូវដឹងថាម៉ាស៊ីនស្វែងរកណាមួយដែលជួយអ្នកប្រើស្វែងរកព័ត៌មានប្រកបដោយសុវត្ថិភាព និងអាចទុកចិត្តបាន។
- **ប្រមាញ់អ្នករុករកតាមអ៊ីនធឺណិត៖** ចូរស្វែងរកព័ត៌មានជាក់លាក់តាមរយៈវេទិកាអនឡាញផ្សេងៗគ្នា ដោយប្រើប្រាស់តារាង ភារកិច្ច ឬសំណួរដែលចែកជូន។ បន្ទាប់មក ចូរពន្យល់ប្រាប់អំពីសារៈសំខាន់នៃការផ្ទៀងផ្ទាត់ព័ត៌មាន ការកំណត់ប្រភពដែលអាចទុកចិត្តបាន និងការប្រុងប្រយ័ត្នក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួន។
- **កម្មវិធីស្វែងរកមួយចំនួនបានបំពាក់មុខងារបន្ថែម៖** ដើម្បីជួយដល់ការស្វែងរកប្រកបដោយសុវត្ថិភាព។ ជម្រើសនៃការស្វែងរកមួយដែលមានសុវត្ថិភាព គឺការប្រើមុខងារ Safe Search ដែលម៉ាស៊ីនស្វែងរក មួយចំនួនបានបំពាក់មកជាមួយ ដូចជា Google Chrome Firefox Safari ជាដើម។ Safe Search អាចជួយដកមាតិកាមិនសមរម្យចេញ ជាពិសេសមាតិកាដែលមានលក្ខណៈហិង្សា អាសអាភាស អាក្រាត ។ល។ ហើយវាបង្ហាញតែមាតិកាដែលល្អ សមស្របនឹងអាយុ និងមានប្រយោជន៍។

ដើម្បីធ្វើការកំណត់លើសុវត្ថិភាព និងសន្តិសុខនៅលើម៉ាស៊ីនស្វែងរក ឬកម្មវិធីរុករកតាមអ៊ីនធឺណិត អ្នកប្រើប្រាស់ត្រូវអនុវត្តវិធីដូចខាងក្រោម៖

- **នៅលើកម្មវិធីហ្គូហ្គលក្រូម (Google Chrome)៖** នៅរបារខាងលើ សូមចុចលើសញ្ញា (...) ចុច លើ "ការកំណត់" (Settings) បន្ទាប់មកទៀតចុចលើពាក្យឯកជនភាព និងសន្តិសុខ (Privacy and Security)។ បន្ទាប់មកចុចលើពាក្យ សន្តិសុខ (Security) និងចុចយកពាក្យ ការពារប្រកបដោយស្តង់ដារ (Standard Protection)។

- **នៅលើកម្មវិធីហ្វៃអឺហ្វក** (Firefox)៖ នៅរបារខាងលើសូមចុចលើសញ្ញា (...) បន្ទាប់មកទៀតចុចលើសញ្ញាផ្ទាំងឯកជនថ្មី (NewPrivateWindow) បន្ទាប់មកចុចលើពាក្យជម្រើស (Options) និង បន្ទាប់មកទៀត ចុចលើពាក្យ ឯកជនភាព (Privacy)។

- **នៅលើកម្មវិធីសាហ្វារី** (Safari)៖

  ១- ចុចលើ ពាក្យ ហ្វាល់ (File) បន្ទាប់មកចុចលើពាក្យ ផ្ទាំង ឯកជនថ្មី (New Private Window)

  ២- ចុចលើពាក្យកុំតាមដាន (Do Not Track) បន្ទាប់មក ចុចលើពាក្យចំណូលចិត្ត (Preferences) និងជ្រើសរើសពាក្យ ឯកជនភាព (Privacy Tab)។

ការរុករកប្រកបដោយសុវត្ថិភាពមានន័យថាការប្រើប្រាស់អ៊ីនធឺណិតតាមរបៀបដែលអាចការពារអ្នកប្រើប្រាស់ពីគ្រោះថ្នាក់ដែលអាចកើតមាន។ អ្នកប្រើប្រាស់គួរតែអនុវត្តវិធីដូចខាងក្រោម ដើម្បីធ្វើការរុករកប្រកបដោយ សុវត្ថិភាពនៅលើអ៊ីនធឺណិត៖

- **ប្រើតែគេហទំព័រណាដែលអាចទុកចិត្តបាន៖** វាដូចជាការដែលអ្នកទៅកន្លែងដែលអ្នកប្រើប្រាស់ដឹងថាមានសុវត្ថិភាពដូច្នេះដែរ។ បើមន្ត្រីនគរបាលពន្យល់កុមារ គួរឱ្យកុមារចូលទៅប្រើគេហទំព័រដែលបង្កើតឡើងសម្រាប់កុមារ ឬដែលត្រូវបានណែនាំដោយមនុស្សពេញវ័យដែលអ្នកជឿ ទុកចិត្ត ដូចជា ឪពុកម្តាយ គ្រូបង្រៀន ឬបណ្ណារក្សជាដើម។

- **រក្សាព័ត៌មានផ្ទាល់ខ្លួនជាឯកជនភាព៖** វាដូចជាការមិនប្រាប់មនុស្សប្លែកមុខអំពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងជីវិតពិតដែរ។ អ្នកប្រើប្រាស់មិនត្រូវចែករំលែកព័ត៌មានផ្ទាល់ខ្លួន ដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ ឬឈ្មោះសាលារៀនតាមអ៊ីនធឺណិតទេ ព្រោះវាជួយការពារឯកជនភាពរបស់អ្នកប្រើប្រាស់ និងរក្សាសុវត្ថិភាពផ្ទាល់ខ្លួន។

- **ប្រុងប្រយ័ត្នលើតំណភ្ជាប់ (URL) និងការផ្សាយពាណិជ្ជកម្មតំណភ្ជាប់** គឺដូចជាច្រកទ្វារទៅកាន់កន្លែងផ្សេងទៀតនៅលើអ៊ីនធឺណិត។ សូមប្រយ័ត្នចំពោះការចុចលើតំណភ្ជាប់ឬការផ្សាយពាណិជ្ជកម្ម។

### ឃ.៤- ការរាំងខ្ទប់នរណាម្នាក់លើអនឡាញ (block)

- **ណែនាំកុមារត្រូវយល់ដឹងពីរបៀបរាំងខ្ទប់** (Block) នរណាម្នាក់ ឬគណនីណាមួយដែលប៉ុនប៉ងលួងលោម ឬធ្វើការគំរាមកំហែងខ្លួន។ កម្មវិធីអនឡាញភាគច្រើនមានមុខងារទប់ស្កាត់ការពារទំនាក់ទំនងជាមួយនរណាម្នាក់ ឬគណនីណាមួយ ដែលយើងមិនចង់មានទំនាក់ទំនងជាមួយ។ អ្នកប្រើប្រាស់ត្រូវរាយការណ៍ពីការគំរាមកំហែងជូនសមត្ថកិច្ច ដើម្បីមានចំណាត់ការសមស្របទៅនឹងជនល្មើស។



- **ការរាំងខ្ទប់នរណាម្នាក់នៅលើអ៊ីនធឺណិតគឺជាមធ្យោបាយ**ដ៏មានប្រយោជន៍មួយ ដើម្បីការពារពួកគេពីការទាក់ទង ឬមើលឃើញមាតិការបស់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់គួរអនុវត្តជំហានងាយៗដូចខាងក្រោម ដើម្បីរាំងខ្ទប់ នរណាម្នាក់នៅលើអ៊ីនធឺណិត។

- **កំណត់អត្តសញ្ញាណបុគ្គល៖** ជាដំបូង អ្នកប្រើប្រាស់ត្រូវប្រាកដថាខ្លួនយល់ដឹងថា ចង់រាំងខ្ទប់អ្នកណាខ្លះ។ នេះអាចជាបុគ្គលណាដែលផ្ញើសារដែលមិនសមរម្យមកអ្នកប្រើប្រាស់ បុគ្គលគំរាមកំហែងតាមអនឡាញ ឬជនដែលរុកកួនឆាឆៅដល់អ្នកប្រើប្រាស់ ឬនរណាម្នាក់ដែលអ្នកប្រើប្រាស់មិនចង់ទាក់ទងជាមួយទៀតទេ។

- **ស្វែងរកជម្រើសរាំងខ្ទប់៖** វេទិកាផ្សេងគ្នាមានវិធីផ្សេងគ្នា ដើម្បីរាំងខ្ទប់នរណាម្នាក់ ដូច្នេះអ្នកត្រូវកំណត់កន្លែងនៃជម្រើសរាំងខ្ទប់នៅក្នុងវេទិកានោះ។ ជាធម្មតា អ្នកប្រើប្រាស់អាចរកឃើញវានៅក្នុងប្រវត្តិរូប (Profile) នៅក្នុងមីនុយនៃការកំណត់ឯកជនភាព (Privacy Settings) ឬនៅក្នុងការកំណត់របស់អ្នក (My Settings) ឬដោយចុចខាងស្តាំលើឈ្មោះឬសាររបស់ពួកគេ។ បន្ទាប់មកចុចលើពាក្យ "Block" ឬ "Block User"។

- **ពិនិត្យមើលការកំណត់ការរាំងខ្ទប់៖** វេទិកាមួយចំនួនផ្តល់នូវជម្រើសរាំងខ្ទប់បន្ថែម ដូចជាការរាំងខ្ទប់នរណាម្នាក់ពីការមើលឃើញ Profile របស់អ្នកប្រើប្រាស់ ឬដាក់កម្រិតលទ្ធភាពរបស់ពួកគេក្នុងការទាក់ទង។ សូមណែនាំឱ្យអ្នកប្រើប្រាស់ចំណាយធ្វើការកំណត់ការរាំងខ្ទប់ ដើម្បីពិនិត្យមើលការកំណត់ទាំងនេះហើយកែតម្រូវវាទៅតាមចំណូលចិត្តរបស់ខ្លួន។

### ឃ.៥- ការរាយការណ៍

- **ការរាយការណ៍ពីអាកប្បកិរិយាមិនសមរម្យ ឬគួរឱ្យសង្ស័យណាមួយនៅលើអនឡាញ** អាចធ្វើឱ្យអ្នកប្រើប្រាស់មានសុវត្ថិភាព និងជួយទប់ស្កាត់គ្រោះថ្នាក់ណាមួយចំពោះអ្នកដទៃ។ វេទិកាភាគច្រើនមានមុខងាររាយការណ៍ ដើម្បីដោះស្រាយបញ្ហាបែបនេះ ហើយអ្នកគួរប្រើមុខងារទាំងនោះដើម្បីរាយការណ៍ករណីណាមួយនៃការកេងប្រវ័ញ្ចផ្លូវភេទ ឬការរុកកួនឆាឆៅតាមអនឡាញ។

- **ហេតុអ្វីបានជាអ្នកគួររាយការណ៍?** ការរាយការណ៍គឺជាវិធីមួយបានបង្កើនលទ្ធភាពនៃការលុបបំបាត់មាតិការំលោភបំពានពីគេហទំព័រ នឹងជួយបញ្ឈប់ការរំលោភបំពានដោយផ្ទាល់ និងការរំលោភបំពានលើប្រព័ន្ធអនឡាញ។ វេទិកា និងកម្មវិធីបណ្តាញទំនាក់ទំនងសង្គមភាគច្រើនមានឧបករណ៍ឬមុខងាររាយការណ៍ នៅក្នុងនោះប្រសិនបើអ្នកប្រើប្រាស់ឃើញមាតិកាផ្លូវភេទ ឬមិនសមរម្យនៅលើអនឡាញ ឬមានអារម្មណ៍ថាកុមារអាចស្ថិតនៅក្នុងស្ថានភាពមួយដែលធ្វើឱ្យពួកគេជួបគ្រោះថ្នាក់នៅលើអនឡាញ អ្នកត្រូវដឹងអំពីទីកន្លែងដើម្បីរាយការណ៍អំពីបញ្ហាទាំងនោះ។

- **បើសិនអ្នកប្រើប្រាស់គិតថា មានបទល្មើសផ្លូវភេទមួយបានកើតឡើង** ហើយចង់ដាក់ពាក្យបណ្ដឹង សូមណែនាំពួកគេស្វែងរកជំនួយបន្ថែមទៀតបាន តាមរយៈការទាក់ទងទៅអាជ្ញាធរនៅទីកន្លែងដែលអ្នករស់នៅ ទាក់ទងទៅមន្ត្រីនគរបាលជំនាញ គ្រូបង្រៀន ឬបុគ្គលិកសង្គមកិច្ច។ ពួកគេអាចផ្ដល់ព័ត៌មានអំពីសិទ្ធិ សេវា និងជម្រើសនានា ដើម្បីនាំជនល្មើសទៅផ្ដន្ទាទោស។ នៅពេលមនុស្សកាន់តែច្រើនរាយការណ៍ ជនល្មើសកាន់តែភ័យខ្លាច និងមិនហ៊ានប្រព្រឹត្តខុស។

**អង្គការ APLE** **១២៨៨**



- **ប្រព័ន្ធរាយការណ៍របស់មន្ត្រីនគរបាល ឬអាជ្ញាធរមូលដ្ឋាន៖** បើសិនអ្នកប្រើប្រាស់បានទទួលរងនូវការរំលោភបំពាននៅលើអនឡាញ សូមណែនាំឱ្យពួកគេអាចរាយការណ៍ផ្ទាល់ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត ឬទាក់ទងទៅលេខទូរស័ព្ទទាន់ហេតុការណ៍របស់នគរបាលជាតិ១២៨៨ (២៤ម៉ោង/៧ថ្ងៃក្នុងមួយសប្ដាហ៍) ដោយមិនអស់កម្រៃ។

- **ប្រព័ន្ធរាយការណ៍តាមអនឡាញ៖** អង្គការសកម្មភាពដើម្បីកុមារ (APLE) បានដាក់ឱ្យដំណើរការប្រព័ន្ធរាយការណ៍តាមរយៈគេហទំព័រ និងលេខទូរស័ព្ទរាយការណ៍បន្ទាន់ (Hotline) របស់ខ្លួនសម្រាប់ទទួលការរាយការណ៍អំពីរាល់ទម្រង់ នៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ដែលសង្ស័យថាបានកើតឡើង។ រាល់ការរាយការណ៍ ទៅកាន់ប្រព័ន្ធរាយការណ៍នេះនឹងត្រូវបានរក្សាការសម្ងាត់ ឬអាចធ្វើបានដោយអនាមិក (មិនតម្រូវឱ្យ បង្ហាញអត្តសញ្ញាណ) អង្គការសកម្មភាពដើម្បីកុមារ (APLE) សហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីនគរបាលជាតិ និងអ្នកផ្ដល់សេវាគាំទ្រដល់កុមាររងគ្រោះផ្សេងៗ ដើម្បីឆ្លើយតបនឹងការរាយការណ៍របស់អ្នក។

- **ប្រសិនបើអ្នកប្រើប្រាស់ជាជនរងគ្រោះ ឬសង្ស័យ**ថា នរណាម្នាក់ជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ អ្នកប្រើប្រាស់អាចទាក់ទងមកអង្គការសកម្មភាពដើម្បីកុមារ (APLE) តាមរយៈលេខទូរស័ព្ទ រាយការណ៍បន្ទាន់ ០៩២ ៣១១ ៥១១ ឬតាមរយៈគេហទំព័រ www.aplecambodia.org ដោយអនុវត្តតាមជំហានងាយៗដូចខាងក្រោម៖

| ជំហានទី ១ | ជំហានទី ២ | ជំហានទី ៣ | ជំហានទី ៤ |
|---|---|---|---|
| ចូលទៅកាន់គេហទំព័រ www.aplecambodia.org | ស្វែងរក និងចុចប៊ូតុង រាយការណ៍ ការរំលោភបំពាន ឬ Report Abuse | ជ្រើសរើសយកប្រភេទករណីនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទណាមួយដែលអ្នកចង់រាយការណ៍ រួចបំពេញទម្រង់ ឬឆ្លើយសំណួរដែលមាន ឱ្យបានត្រឹមត្រូវ។ | ចុចប៊ូតុងបញ្ជូនទម្រង់របាយការណ៍ ជាការស្រេច។ |

- ត្រូវចងចាំថា ក្នុងករណីដែលអ្នក ឬនរណាម្នាក់កំពុងស្ថិតនៅក្នុងគ្រោះថ្នាក់បន្ទាន់ ហើយទាមទារការអន្តរាគមន៍ជួយសង្គ្រោះបន្ទាន់ អ្នកប្រើប្រាស់ត្រូវទាក់ទងទៅអាជ្ញាធរនៅទីកន្លែងដែលនៅជិតអ្នកបំផុត។
- ការសង្គ្រោះ និងផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះពីការរំលោភបំពានផ្លូវភេទទាន់ពេលវេលាជារឿងសំខាន់ បំផុតនៅពេលវាកើតឡើង។

## ង អំពីរបៀបចូលប្រើ APLE Chatbot និងចូលប្រើ APLE Chatbot តាមទូរស័ព្ទដៃស្មាតហ្វូន

នៅក្នុងប្រទេសកម្ពុជា អង្គការ APLE បានធ្វើការដើម្បីប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់ នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទអស់រយៈពេល ២០ឆ្នាំមកហើយ ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូជាតិ ក្នុងតំបន់ និងអន្តរជាតិ រួមទាំងរាជរដ្ឋាភិបាល ការអនុវត្តច្បាប់ អង្គការ INGO អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឧស្សាហកម្ម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ APLE បាន និងកំពុងចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការឆ្លើយតបករណី OCSEA នៅក្នុងប្រទេសកម្ពុជា។

អង្គការ APLE បង្កើតជំនួយការឌីជីថល ឆាតបត Chatbot ដើម្បីជួយដោះស្រាយបញ្ហាជាច្រើនដែលទាក់ទងនឹង OCSEA។ សូម Scan QR code ខាងក្រោមនេះ ដើម្បីចូទៅប្រើ Chatbot របស់អង្គការ APLE នៅលើ Facebook Messager


APLE Cambodia
សួស្តី! ខ្ញុំគឺពិសី
Hi
0:11
សូមស្វាគមន៍មកកាន់ អង្គការសកម្មភាពដើម្បី កុមារ (APLE)! សូមចុច ជ្រើសយកភាសា
ណាមួយដែល
ង់ប្រើ
Aa


APLE Cambodia
តើអ្នកចង់ធ្វើអ្វីដែរ?
0:02
សួស្តី! ខ្ញុំឈ្មោះ ពិសី ជា ជំនួយការឌីជីថលរបស់ អង្គការសកម្មភាពដើម្បី កុមារ។ ខ្ញុំមិន
មនុស្សទេ
Aa


APLE Cambodia
0:14
តើអ្នកមានអ្វីឲ្យ ខ្ញុំជួយដែរ?
សូមជ្រើសរើសជម្រើស ណាមួយខាងក្រោម
ចង់ស្វែងយល់បន្ថែម
0:02
Aa


APLE Cambodia
0:02
តើអ្នកស្ថិតក្នុងក្រុមអាយុ មួយណា?
១៨-២៤ឆ្នាំ
0:02
Aa

ឥឡូវនេះ អ្នកមានការយល់ដឹងយ៉ាងស៊ីជម្រៅពីរបៀបដោះស្រាយបញ្ហាប្រឈម និងភាពលំបាកនៅក្នុងករណី OCSEA ភាពលំបាកទាក់ទងនឹងកុមារ ឬគ្រួសាររបស់ពួកគេនៅក្នុងអំឡុងពេលអនុវត្តភារកិច្ចរបស់អ្នក តាមរយៈសំណួរ-ចម្លើយទាំង៤៨ចំណុច។ អ្នកអាចត្រឡប់មើលឡើងវិញនៅពេលណាអ្នកជួបឧបសគ្គក្នុងអំឡុងពេលអនុវត្តបទអន្តរាគមន៍ឆ្លើយតប និងជួយសង្គ្រោះកុមារ។ អ្នកអាចជួយផ្សព្វផ្សាយ ឬពន្យល់ដល់កុមារ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេអំពីវិធានសុវត្ថិភាពនៅក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធអនឡាញទាំងនៅលើម៉ាស៊ីនកុំព្យូទ័រ និងទូរស័ព្ទដៃផងដែរ។ ស្រដៀងគ្នាចំណុចខាងលើដែរ អ្នកអាចត្រឡប់មើលឡើងវិញអំពីរបៀបកំណត់ឯកជនភាព បិទខ្ទប់ជនណាម្នាក់ របៀបរាយការណ៍ នៅលើវេទិកាបណ្តាញសង្គម និងគេហទំព័ររុករកព័ត៌មានផ្សេងៗ។ អ្នកអាចបង្រៀនកុមារ និងសហគមន៍របស់អ្នកនូវចំណេះ ជំនាញមូលដ្ឋានគ្រឹះទាំងនេះ ដែលជួយឱ្យពួកគេមានការយល់ដឹង ចេះការពារ និងបង្ការខ្លួនពួកគេពីហានិភ័យ និងគ្រោះថ្នាក់ទាំងឡាយដែលអាចកើតមាននៅលើប្រព័ន្ធអនឡាញ។ ជាចុងក្រោយអ្នកមានបទពិសោធន៍ក្នុងការចូលប្រើ APLE Chatbot តាមទូរស័ព្ទស្មាតហ្វូនរបស់អ្នក។ វាជាមជ្ឈមណ្ឌលចំណេះដឹង ផ្តល់នូវចម្លើយទាន់ចិត្ត ដែលជួយអ្នកការសិក្សាស្វែងយល់បន្ថែម។

# មេរៀនទី១១៖

## ការប្រតិបត្តិផ្អែកលើចំណេះដឹង និងជំនាញ

ការរៀនសូត្រ និងចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលមកដល់ពេលនេះបានធ្វើឱ្យអ្នកចូលរួមត្រៀមខ្លួនរួចជាស្រេចសម្រាប់ការស៊ើបអង្កេតករណី OCSEA ដោយពិចារណា និងរៀបចំផែនការច្បាស់លាស់ ហើយផ្អែកលើមូលដ្ឋានគ្រឹះនៃសិទ្ធិកុមារ និងការអនុវត្តកិច្ចការការពារកុមារបែបកុមារមេត្រី។ អ្នកនឹងអាចកត់សម្គាល់បានថា សិទ្ធិកុមារ និងការអនុវត្តកិច្ចការពារកុមារបែបកុមារមេត្រី ត្រូវបានលើកឡើង ស្របតាមកម្មវិធីវគ្គបណ្តុះបណ្តាល ក្នុងន័យនេះ អ្នកចូលរួមគួរតែជ្រួតជ្រាបនឹងលក្ខខណ្ឌតម្រូវនេះ។ ក្នុងវេលានេះដល់ពេលសម្រាប់អ្នកចូលរួម ដើម្បីអនុវត្តចំណេះដឹងរបស់ពួកគេចំពោះករណីសិក្សាដែលមានភ្ជាប់ក្នុងឯកសារឧបសម្ព័ន្ធ ដែលផ្អែកលើករណីជាក់ស្តែងពីការស្រាវជ្រាវ និងការអនុវត្ត។ ករណីសិក្សាមានភាពប្រាកដនិយមតាមដែលអាចធ្វើបាន ព្រោះវាផ្អែកលើព្រឹត្តិការណ៍ និងបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង។ ករណីសិក្សាទាំងនេះឆ្លុះបញ្ចាំងពីតថភាពនៃ OCSEA នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ។

### ការឆ្លុះបញ្ចាំងពីរបៀបដែលល្អបំផុតក្នុងការទាក់ទង និងរៀបចំផែនការស៊ើបអង្កេតករណី (OCSEA)

### គោលការណ៍ណែនាំ និងសំណួរសម្រាប់ករណីសិក្សា៖

ដោយផ្អែកលើព័ត៌មានដែលបានរួមបញ្ចូលនៅក្នុងករណីសិក្សា មន្ត្រីនគរបាលត្រូវបានស្នើឱ្យពិចារណា និងឆ្លើយតបទៅនឹងសំណួរនីមួយៗខាងក្រោមក្នុងក្រុមរបស់ខ្លួន។ សូមប្រើសន្លឹកកិច្ចការនេះ ដើម្បីជួយណែនាំការពិភាក្សារបស់អ្នក ហើយរៀបចំចម្លើយ និងបទបង្ហាញរបស់អ្នកទៅកាន់ក្រុមធំ។

សូមចាំថា មានជំហានជាច្រើនក្នុងការស៊ើបអង្កេត និងកិច្ចការផ្សេងៗជាច្រើនដែលត្រូវធ្វើ ដើម្បីទទួលបានការកាត់ក្តីជោគជ័យនៅក្នុងករណីមួយ។

**កំណត់ថា តើមានសមាសធាតុលើប្រព័ន្ធអនឡាញតែប៉ុណ្ណោះ ឬចំពោះខ្ញុំក្រិដ្ឋកម្មនោះ ឬមានទាំងលើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។**

*(សូមសរសេរការឆ្លើយតបរបស់អ្នកនៅក្នុងប្រអប់ខាងក្រោម)*

| សមាសធាតុតាមប្រព័ន្ធអនឡាញ៖ | សមាសធាតុក្រៅប្រព័ន្ធអនឡាញ (ប្រសិនបើមាន)៖ |
|---|---|
| | |

**១- បើយោងតាមច្បាប់កម្ពុជាបច្ចុប្បន្ន តើមានច្បាប់ណាខ្លះ ដែលពាក់ព័ន្ធក្នុងករណីនេះ?**

*(សូមសរសេរការឆ្លើយតបរបស់អ្នកនៅក្នុងប្រអប់ខាងក្រោម)*

| សមាសធាតុតាមប្រព័ន្ធអនឡាញ៖ | សមាសធាតុក្រៅប្រព័ន្ធអនឡាញ (ប្រសិនបើមាន)៖ |
|---|---|
| | |

**តើអ្នកមានកង្វល់អ្វីខ្លះ ទាក់ទងនឹងករណីនេះ?**

*(កង្វល់នានាអាចទាក់ទងនឹងសុវត្ថិភាព ឬសុខភាពរបស់កុមារ ហានិភ័យទាក់ទងនឹងជនល្មើសដែលត្រូវបានចោទប្រកាន់ ការរើសអើងដែលពួកគេអាចជួបប្រទះ តម្រូវការពិសេស ឬតម្រូវការជាក់លាក់ដែលកុមារអាចមាន ឬបញ្ហាផ្សេងទៀត)។*

ដោយផ្អែកលើគំនិតរបស់អ្នក តើអ្នកគួរធ្វើអ្វីខ្លះ ដើម្បីឆ្លើយតបឱ្យបានត្រឹមត្រូវ ទៅនឹងដំណោះស្រាយនៃកង្វល់របស់អ្នក?

*(សូមកត់ត្រាការឆ្លើយតបរបស់អ្នកដោយប្រើប្រអប់ខាងក្រោម)*

## *ឧទាហរណ៍មួយចំនួនដូចខាងក្រោម៖*

| កង្វល់ | ការឆ្លើយតបដែលសមរម្យ |
|---|---|
| *កុមារបង្កគ្រោះថ្នាក់ដល់ខ្លួនឯង គំរាមធ្វើអត្តឃាត*<br>*កុមារមានអារម្មណ៍ថាមិនអាចនិយាយអំពីបញ្ហាទៅកាន់មនុស្ស ឬបុគ្គលណាម្នាក់បានដោយសារតែភាពអាម៉ាស់។* | *សូមយកចិត្តទុកដាក់ចំពោះការគំរាមនេះ សូមគោរពចំពោះកុមារ និងពិនិត្យមើលចំណុចរសើប។ ស្វែងរកការគាំទ្រពីអ្នកប្រឹក្សាដែលសមស្រប និង/ឬបញ្ជូនទៅអង្គការមិនមែនរដ្ឋាភិបាល។*<br>*សូមប្រព្រឹត្តទៅដោយការគោរព និងប្រាស្រ័យទាក់ទងឱ្យបានច្បាស់លាស់ថា អ្នកយល់ និងគោរពតាមបំណងប្រាថ្នារបស់ពួកគេ ដែលអនុញ្ញាតឱ្យមន្រ្តីនគរបាលជាស្ត្រីធ្វើការសម្ភាស។ ប្រសិនបើមិនអាចទេ ចូរពន្យល់កុមារថា ពេលនេះមិនបានទេ ហើយសុំឱ្យបុគ្គលិកអង្គការស្រីម្នាក់ចូលរួម និងគាំទ្រ។* |

**២- នីតិវិធីកុមារមេត្រី និងបញ្ហាសិទ្ធិកុមារ៖** ផ្អែកលើព័ត៌មាននៅក្នុងករណីសិក្សា តើអ្នកត្រូវធ្វើ ឬដាក់អ្វីខ្លះ ដើម្បីធានាថាសិទ្ធិរបស់កុមារត្រូវបានគោរព និងការពារ ហើយនីតិវិធីបែបកុមារមេត្រីអ្វីខ្លះដែលត្រូវបានអនុវត្ត?

| សិទ្ធិកុមារ | នីតិវិធីបែបកុមារមេត្រី |
|---|---|
| | |

៣- **ការទទួលពាក្យបណ្តឹង ការស៊ើបអង្កេតបឋម៖** ដោយផ្អែកលើព័ត៌មាននៅក្នុងករណីសិក្សា សូមពណ៌នាអំពីផែនការរបស់អ្នកក្នុងការជួបជាមួយកុមារ និងអាណាព្យាបាលរបស់ពួកគេ ដើម្បីធ្វើសេចក្តីថ្លែងការណ៍ ដោយធានាថាកុមារ ត្រូវបានប្រព្រឹត្តដោយគិតគូរពីអារម្មណ៍របស់ពួកគេ និងដោយការគោរព យោងតាមគោលការណ៍ណែនាំបែបកុមារមេត្រី។ *(ការទទួលពាក្យបណ្តឹង ការស៊ើបអង្កេតបឋម ការប្រមូលភស្តុតាងដំបូង)*។ សូមផ្តល់ព័ត៌មានលម្អិតអំពីរបៀបដែលអ្នកនឹងអនុវត្ត តើនរណាខ្លះ និងអង្គភាពណាខ្លះ ដែលអ្នកនឹងបញ្ចូលក្នុងផែនការរបស់អ្នក។

| ចំណុចសកម្មភាព | តើអ្នកណាខ្លះ ត្រូវចូលរួម? |
|---|---|
| | |

## ការប្រមូល និងរក្សាទុកភស្តុតាង៖

យោងតាមករណីសិក្សា ច្បាប់ និងលក្ខណៈនៃឧក្រិដ្ឋកម្ម ឧបករណ៍អេឡិចត្រូនិក និងកម្មវិធីដែលប្រើ សូមពណ៌នាអំពីប្រភេទភស្តុតាងដែលអាចមាន។ *(សូមចំណាំថា តម្រូវឱ្យមានការបណ្តុះបណ្តាលបន្ថែមទាក់ទងនឹងការប្រមូលផ្តុំ និងការរក្សាទុកភស្តុតាងឌីជីថល ដែលបច្ចុប្បន្ននេះកំពុងរៀបចំ)*។

*ឧទាហរណ៍*

| ប្រភេទភស្តុតាងឌីជីថល និងអនឡាញ | ប្រភេទភស្តុតាងក្រៅប្រព័ន្ធអនឡាញ |
|---|---|
| *ទូរស័ព្ទរបស់ជនរងគ្រោះ រូបថត និងរូបភាពឌីជីថល សារ និងការសន្ទនាតាមកម្មវិធី Messenger ឬតាមថ្នាលកម្មវិធីផ្សេងៗ។* | *សេចក្តីបំភ្លឺរបស់ជនរងគ្រោះ សេចក្តីបំភ្លឺរបស់អ្នករាយការណ៍ដំបូង (គ្រូ) សេចក្តីបំភ្លឺរបស់សាក្សីផ្សេងទៀត ប្រសិនបើប្រឈមមុខដោយផ្ទាល់ជាមួយនឹងទំនាក់ទំនងផ្លូវភេទ/បទល្មើស* |

## ការស្តាប់ចម្លើយ/ការសម្ភាសជនសង្ស័យ និងការប្រមូលភស្តុតាងបន្ថែម៖

(ដោយសន្មតថា មានភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្ហាញថាឧក្រិដ្ឋកម្មបានកើតឡើង អ្នកត្រូវបានតម្រូវឱ្យសម្ភាសន៍ជនសង្ស័យដែលត្រូវបានចោទប្រកាន់ និងដើម្បីទទួលបាននូវភស្តុតាងឌីជីថល និងរូបវន្តណាមួយនៅកន្លែងនោះ។

សូមពណ៌នាអំពីផែនការរបស់អ្នក ដើម្បីសម្រេចកិច្ចការនេះនៅក្នុងប្រអប់ខាងក្រោម។)

| ចំណុចសកម្មភាព | តើអ្នកណាខ្លះ ត្រូវចូលរួម? |
|---|---|
| | |

## សកម្មភាពបន្ថែម៖

(ដោយសន្មតថា អ្វីៗដំណើរការទៅតាមផែនការ ហើយអ្នកប្រមូលសេចក្តីថ្លែងការណ៍ និងភស្តុតាងដែលត្រូវការ សូមរៀបចំជំហានបន្ទាប់ដោយសង្ខេប យោងទៅតាមជំហាននៃការស៊ើបអង្កេត)។

| ចំណុចសកម្មភាព | តើអ្នកណាខ្លះ ត្រូវចូលរួម? |
|---|---|
| | |

# សេចក្ដីសន្និដ្ឋាន

សៀវភៅគោលស្ដីពី «ការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)»នេះ ត្រូវបានរៀបចំឡើង ដើម្បីជាការឆ្លើយតបចំពោះតម្រូវការសំខាន់ៗ ក្នុងការបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាល ចំពោះការស៊ើបអង្កេត និងការឆ្លើយតបនឹងបទល្មើសទាក់ទងនឹង OCSEA។ ខ្លឹមសារ និងប្រធានបទទាំងអស់ ដែលស្នើឡើងនៅក្នុងសៀវភៅនេះ គឺផ្អែកលើរបាយការណ៍ប៉ាន់ប្រមាណតម្រូវការវគ្គបណ្ដុះបណ្ដាលសម្រាប់មន្ត្រីនគរបាលនៅកម្ពុជា (ខែមីនា ឆ្នាំ២០២៣) ព្រមទាំងលទ្ធផលនៃការវាយតម្លៃតម្រូវការជាក់លាក់ជាច់ដោយឡែក ដែលធ្វើឡើងតែនៅក្នុងចំណោមគ្រូបង្គោល និងមន្ត្រីជំនាញនៃបណ្ឌិត្យសភានគរបាលកម្ពុជា (ខែសីហា ឆ្នាំ២០២៤) ព្រមទាំងផ្អែកលើរបកគំហើញនៃរបាយការណ៍ស្រាវជ្រាវសកលស្ដីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disrupting Harm Global Study in Cambodia) ។

ថ្នាក់ដឹកនាំនៃបណ្ឌិត្យសភានគរបាលកម្ពុជា បានប្ដេជ្ញាខ្ពស់ក្នុងដាក់បញ្ចូលប្រធានបទទាក់ទងនឹង OCSEA ទៅក្នុងកម្មវិធីសិក្សារបស់បណ្ឌិត្យសភានគរបាលកម្ពុជា ព្រមទាំងបានបង្កើតនូវគណៈកម្មាធិការដើម្បីត្រួតពិនិត្យ និងកែសម្រួលខ្លឹមសារនៃសេចក្ដីព្រាងសៀវភៅដ៏មានសារៈសំខាន់នេះ និងគាំទ្រដល់ដំណើរការរៀបចំរបស់បណ្ឌិត្យសភានគរបាលកម្ពុជា។ ខ្លឹមសារសំខាន់នៅក្នុងមេរៀនទាំង១១ អាចសង្ខេបដូចក្រោមនេះ

- **ការស្គាល់ និងកំណត់លក្ខណៈនៃ OCSEA** មេរៀននេះនឹងណែនាំមន្ត្រីនគរបាលអំពីវិធីសាស្ត្រដើម្បីស្គាល់ និងកំណត់ករណី OCSEA តាមការវិភាគលក្ខណៈសំខាន់ៗរបស់វា។ វាក៏ផ្ដោតលើការស្គាល់ប្រព័ន្ធឧក្រិដ្ឋតាមអនឡាញ និងការអភិវឌ្ឍសមត្ថភាព ។
- **បច្ចេកទេសស៊ើបអង្កេត និងប្រមូលភស្តុតាងឌីជីថល** មេរៀននេះនឹងលើកឡើងអំពីវិធីសាស្ត្រក្នុងការស្វែងរក និងស៊ើបអង្កេតលើព័ត៌មានឌីជីថលដែលទាក់ទងនឹងករណី OCSEA។ វាពន្យល់អំពីកិច្ចការរួមបញ្ចូលការរកឃើញភស្តុតាងឌីជីថល និងការប្រើប្រាស់ឧបករណ៍បច្ចេកទេសឌីជីថលក្នុងការស៊ើបអង្កេត។
- **ការកំណត់ពីបទល្មើសទាក់ទងនឹង OCSEA** មេរៀននេះបង្ហាញពីវិធានការកាត់សេចក្ដីទាក់ទងនឹងករណី OCSEA ដោយផ្ដោតលើការចាត់ការសំណុំរឿង និងវិធានការច្បាប់ដែលត្រូវអនុវត្តចំពោះអំពើឧក្រិដ្ឋនេះ។ មន្ត្រីនគរបាលនឹងយល់ដឹងពីបែបបទ និងដំណាក់កាលនៃសំណុំរឿង។

- **កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នផ្សេងៗក្នុងការស៊ើបអង្កេត** មេរៀននេះផ្ដោតលើសារៈសំខាន់នៃការរួមគ្នាជាមួយស្ថាប័នផ្សេងៗ ដូចជាអង្គការមូលដ្ឋាន និងអន្តរជាតិក្នុងការស៊ើបអង្កេត និងការចាត់ការករណី OCSEA។ វាបង្ហាញពីវិធីសាស្ត្រក្នុងការធ្វើការជាមួយក្រុមការងារពហុវិស័យ ដើម្បីធានាបាននូវផលវិជ្ជមាន។
- **វិធីសាស្ត្រការពារនិងជួយសង្គ្រោះជនរងគ្រោះ** មេរៀននេះបង្ហាញអំពីវិធានការពារ និងការជួយសង្គ្រោះជនរងគ្រោះ (Victim) នៃករណី OCSEA ដោយផ្ដោតសំខាន់ទៅលើការទប់ស្កាត់ ការការពារ និងការអភិវឌ្ឍវិធានការការពារសុវត្ថិភាពរបស់ជនរងគ្រោះ។
- **ការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតបទល្មើសទាក់ទងនឹង OCSEA** មេរៀននេះសំដៅទៅលើការប្រើប្រាស់ឧបករណ៍បច្ចេកទេសឌីជីថលសម្រាប់ការស៊ើបអង្កេត OCSEA ដោយមានការបង្ហាញពីកិច្ចការក្នុងការប្រើប្រាស់វិធីសាស្ត្របច្ចេកទេសដើម្បីរកឃើញភស្តុតាង និងការស៊ើបអង្កេតលម្អិត។
- **ការប្រមូលភស្តុតាងអេឡិចត្រូនិក** មេរៀននេះផ្ដោតលើវិធីសាស្ត្រនៃការចងក្រង និងការការពារភស្តុតាងអេឡិចត្រូនិកដែលទាក់ទងនឹង OCSEA ដើម្បីធានាបាននូវការស៊ើបអង្កេតដែលមានប្រសិទ្ធភាព និងស្របតាមច្បាប់។
- **តួនាទីរបស់មន្ត្រីនគរបាលក្នុងការការពារកុមារ** មេរៀននេះអប់រំមន្ត្រីនគរបាលអំពីតួនាទីក្នុងការការពារកុមារពីអំពើ OCSEA ហើយផ្ដោតលើការផ្ដល់សេវាជំនួយសង្គ្រោះ ជនរងគ្រោះដែលត្រូវរំលោភបំពាន។
- **ការពង្រឹងសមត្ថភាពមន្ត្រីនគរបាល** មេរៀននេះជួយបង្កើនសមត្ថភាពមន្ត្រីនគរបាលក្នុងការទទួលបានចំណេះដឹងលើប្រព័ន្ធអនឡាញ ដោយផ្ដោតសំខាន់ទៅលើវិធីសាស្ត្របច្ចេកទេសស៊ើបអង្កេត។
- **ការរៀបចំបង្ហាញភស្តុតាង និងការត្រៀមខ្លួនសម្រាប់សវនាការ** មេរៀនចុងក្រោយនេះផ្ដោតលើការរៀបចំ និងការរៀបចំសាក្សី និងភស្តុតាងក្នុងការកាត់សំណុំរឿង OCSEA។

សៀវភៅនេះក៏បានបង្ហាញសារៈសំខាន់នៃការបណ្ដុះបណ្ដាលផ្នែកស៊ើបអង្កេតករណី OCSEA ដែលផ្ដោតសំខាន់លើវិធីសាស្ត្រក្នុងការឆ្លើយតបនឹង OCSEA។ ការងារជាក់លាក់នៃមន្ត្រីនគរបាលត្រូវការ ការអភិវឌ្ឍន៍គុណភាពនៃជំនាញបច្ចេកទេស ដើម្បីស៊ើបអង្កេតករណី OCSEA ឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ សៀវភៅនេះក៏បានរចនាឡើងក្នុងគោលបំណងបង្ហាញអំពីវិធីសាស្ត្រសម្របសម្រួល និងការពង្រឹងសមត្ថភាពក្នុងការរៀនសូត្របែបជាប្រព័ន្ធ ដើម្បីឱ្យមន្ត្រីនគរបាលអាចឆ្លើយតបតាមកម្រិតជំនាញស្តង់ដារ។ នៅក្នុងន័យនេះ សៀវភៅនេះគឺជាមធ្យោបាយសំខាន់សម្រាប់ការបណ្ដុះបណ្ដាលមន្ត្រីនគរបាលឱ្យមានចំណេះដឹង ក្នុងការស្វែងយល់អំពី OCSEA និងវិធីសាស្ត្រស៊ើបអង្កេតឱ្យបានទូលំទូលាយ។

# សន្ទានុក្រម

| | |
|---|---|
| **CNP** | នគរបាលជាតិកម្ពុជា |
| **ACCD** | នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា |
| **AHTJD** | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| **APLE** | អង្គការសកម្មភាពដើម្បីកុមារ |
| **UNICEF** | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| **CSEA** | ការកេងប្រវញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ |
| **OCSEA** | ការកេងប្រវញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ |
| **DH** | របាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅប្រទេសកម្ពុជា |
| **INGO** | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| **KI** | អ្នកផ្តល់ព័ត៌មានសំខាន់ៗ |
| **LGBTQI** | អ្នកស្រលាញ់ភេទដូចគ្នា អ្នកមាននិន្នាការភេទដូចគ្នា |
| **SOGIE** | ការតម្រង់ទិសផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងការបញ្ចេញមតិ |
| **MOSVY** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **TNA** | ការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល |
| **SOP** | នីតិវិធីប្រតិបត្តិជាស្តង់ដារ |
| អ៊ីនធឺណិត (Internet) | គឺជាបណ្តាញសកលដ៏ធំទូលាយមួយដែលតភ្ជាប់កុំព្យូទ័រ ឬឧបករណ៍ឌីជីថលរាប់ពាន់លានជាមួយគ្នា ដោយអនុញ្ញាតឱ្យមនុស្សទូទាំងពិភពលោកចូលដំណើរការ និងចែករំលែកព័ត៌មានតាមរយៈគេហទំព័រ និងកម្មវិធី (Apps)។ |
| អនឡាន (Online) | សំដៅទៅដល់ការតភ្ជាប់ឧបករណ៍ឌីជីថលទៅនឹងបណ្តាញអ៊ីនធឺណិតដែលអនុញ្ញាតឱ្យឧបករណ៍ទាំងនោះចូលប្រើប្រាស់កម្មវិធី ឬធនធាននៅលើអនឡាញបាន។ |
| បច្ចេកវិទ្យាឌីជីថល (Digital Technology) | សំដៅទៅដល់បច្ចេកវិទ្យាអេឡិចត្រូនិកដែលត្រូវគេបង្កើត និងប្រើប្រាស់ដើម្បីរក្សាទុក ធ្វើដំណើរការ (បំប្លែង និងវិភាគ) បញ្ជូន និងបង្ហាញព័ត៌មាន។ |

| | |
|---|---|
| Link | តំណភ្ជាប់នៅក្នុងបរិបទនៃប្រភពព័ត៌មានវិទ្យាសំដៅលើមធ្យោបាយ ឬបណ្តាញតភ្ជាប់រវាងឯកសារនៅលើបណ្តាញអ៊ីនធឺណិត។ |
| គេហទំព័រ ( website ) | បណ្តុំនៃគេហទំព័រមានផ្ទុកព័ត៌មាន មាតិកាផ្សេងៗ |
| ថ្នាលបច្ចេកវិទ្យា ឬវេទិកា ( Platform ) | សំដៅដល់ទីកន្លែងដែលអ្នកតភ្ជាប់អ៊ីនធឺណិត អាចស្វែងរក និងចែកចាយព័ត៌មាន មាតិកា និងបញ្ជូន ឬភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃពីចម្ងាយ។ |
| មាតិកា ( Content ) | សំដៅដល់អ្វីៗទាំងអស់ដែលអ្នកអាចមើលឃើញ អាន ទស្សនា ស្តាប់នៅលើអ៊ីនធឺណិត ឬអនឡាញ។ |
| វេទិកាបណ្តាញទំនាក់ទំនងសង្គម ( Social Media Platforms ) | វេទិកា ឬកម្មវិធី ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ ចែករំលែកព័ត៌មាន និងកំសាន្ត ដែលជាមាតិកា បែបអត្ថបទ រូបភាព វីដេអូ និងសំឡេងជាដើម។ |
| ដានឌីជីថល | សកម្មភាពអនឡាញតែងបន្សល់ទុកជាដានឌីជីថលដូចជាអ្វីដែលអ្នកប្រើប្រាស់បង្ហោះ ចែករំលែក និងបញ្ចេញមតិយោបល់នៅលើបណ្តាញអ៊ីនធឺណិត។ |
| ព័ត៌មានផ្ទាល់ខ្លួន ( Privacy ) | ព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានឯកជនភាពដែលអ្នកប្រើប្រាស់ត្រូវរក្សាទុកជាលក្ខណៈឯកជននៅពេលប្រើប្រាស់អ៊ីនធឺណិត មានដូចជា អត្តសញ្ញាណ អាយុ ឈ្មោះ អាសយដ្ឋាន ទីតាំងកំពុងស្ថិតនៅ។ |
| កម្មវិធីផ្ញើសារតាមអនឡាញ ( Social Message App ) | កម្មវិធីអ្នកប្រើប្រាស់អាចប្រាស្រ័យទាក់ទងគ្នា ឬចែកចាយមាតិកាដែលមានលក្ខណៈឯកជនតាមរយៈការផ្ញើសារជាអត្ថបទ សំឡេង រូបថត វីដេអូ រូបភាព និងផ្សាយផ្ទាល់បានភ្លាមៗ។ |
| កម្មវិធីហ្គេមអនឡាញ ( Online Game ) | កម្មវិធីដែលត្រូវបានគេបង្កើតឡើងជាល្បែងសម្រាប់លេងកម្សាន្ត ប្រកបដោយភាពច្នៃប្រឌិត ហើយមានសមត្ថភាពឱ្យអ្នកប្រើប្រាស់លេងជាមួយគ្នាក្នុងពេលតែមួយ។ |
| គណនី ( Account ) | គឺជាឈ្មោះគណនីសម្រាប់អ្នកប្រើប្រាស់ឧបករណ៍ឌីជីថល ឬកម្មវិធីណាមួយ |
| រូបថតប្រវត្តិរូប ( Profile Picture ) | រូបភាពដាក់នៅលើ រូបថត ឬរូបថ្លុកតំណាងឱ្យបុគ្គលម្នាក់។ |
| ប្រវត្តិរូបក្លែងក្លាយ ( Fake Profile ) | គឺជាការដាក់រូបថតមិនពិត រូបក្លែងបន្លំ បំភាន់ ក្នុងគោលបំណងបោកប្រាស់គេ។ |

| | |
|---|---|
| ការដាក់លេខសម្ងាត់ (Password) | គឺជាការដាក់លេខកូដសម្ងាត់លើឧបករណ៍ប្រើប្រាស់ កម្មវិធីនៅអ៊ីនធឺណិត ប្រៀបដូចជាការចាក់សោរអីចឹង។ |
| ជនល្មើស | គឺជាបុគ្គលដែលត្រូវបានរកឃើញថាបានប្រព្រឹត្តឧក្រិដ្ឋ ឬអំពើបំពានច្បាប់។ |
| ជនរងគ្រោះ | គឺជាបុគ្គលដែលបានជួបប្រទះនូវគ្រោះថ្នាក់ របួស រងការបាត់បង់ ឬរងនូវការរំលោភបំពាន ឬកេងប្រវ័ញ្ច។ |
| ការរុកកួនធាផៅតាមអនឡាញ (Cyberbullying) | គឺជាការរុកកួនធាផៅ ឬការសម្លុតគំរាមកំហែងតាមអនឡាញ ដែលបង្កផលប៉ះពាល់ដល់ផ្លូវចិត្ត (ការថប់អារម្មណ៍ ការធ្លាក់ទឹកចិត្ត ការប៉ុនប៉ងធ្វើអត្តឃាត)។ |
| ការបោកប្រាស់តាមអនឡាញ (Online Scams) | ការបោកប្រាស់តាមអនឡាញ ជាទម្រង់បោកបញ្ឆោត ឬល្បិចដែលអ្នកប្រើប្រាស់ប្រើដើម្បីបានព័ត៌មានផ្ទាល់ខ្លួន ប្រាស់កាស ឬទ្រព្យសម្បត្តិដ៏មានតម្លៃពីបុគ្គលណាម្នាក់។ |
| ការបោកប្រាស់តាមរយៈការបោកបញ្ឆោត (Phising Scams) | ការបោកប្រាស់ក្លែងបន្លំ ធ្វើជានណាម្នាក់ តំណាងជាអង្គភាពមួយ ដូចជាធនាគារ ស្នើសុំព័ត៌មានផ្ទាល់ខ្លួន ដូចជា អ៊ីម៉ែល លេខទូរស័ព្ទ ឬលេខកូដសម្ងាត់ជាដើម។ |
| ការបោកប្រាស់តាមការលេងឆ្នោត ឬត្រូវរង្វាន់ (Lottery or Prize Scams) | ជនបោកប្រាស់ប្រាប់ជនរងគ្រោះថា ពួកគេបានឈ្នះរង្វាន់ធំ ត្រូវឆ្នោត ឬរង្វាន់ពិសេស ហើយដើម្បីបើករង្វាន់បាន ពួកគេទាមទាមថ្លៃសេវា ឬសួរព័ត៌មានផ្ទាល់ខ្លួន។ |
| ការបោកប្រាស់បែបស្នេហា (Romance Scams) | អ្នកបោកប្រាស់បង្កើតការណាត់ជួបក្លែងក្លាយ និងបង្កើតទំនាក់ទំនងផ្លូវចិត្តជាមួយជនរងគ្រោះ។ |
| សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (Child Sexual Abuse Materials) | សំដៅលើរូបភាព ដូចជា រូបថត វីដេអូ ឬមាតិកាឌីជីថលផ្សេង រួមទាំងរូបភាពអាសអាភាសកុមារ។ |
| ការលួងលោមតាមអនឡាញក្នុងគោលបំណងផ្លូវភេទ (Online Grooming) | គឺជាការលួងលោមដោយប្រើវិធីសាស្ត្រទាក់ទងកុមារតាមអនឡាញ កសាងទំនុកចិត្ត និងបង្កការភ័ន្តច្រឡំក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទលើពួកគេ។ |
| ការផ្ញើសារបែបផ្លូវភេទ (Sexting) | គឺជាសកម្មភាពផ្ញើ ឬទទួលសារជារូបភាព រូបថត ឬជាវីដេអូដែលបង្ហាញពីផ្នែករាងកាយឯកជន រូបភាពអាក្រាត ឬសំណេរដែលមានលក្ខណៈផ្លូវភេទរវាងមនុស្សពីរនាក់ ឬច្រើននាក់។ |

| | |
|---|---|
| ការគំរាមកំហែងទាក់ទងនឹងផ្លូវភេទ( Sextortion) | គឺជាការគំរាមកំហែងទាក់ទងនឹងផ្លូវភេទតាមអនឡាញជាទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទពាក់ព័ន្ធនឹងការគំរាមនរណាម្នាក់ឱ្យផ្ញើរូបថត ឬវីដេអូអាក្រាតរបស់ខ្លួន ឬគំរាមឱ្យនរណាម្នាក់ចូលរួមសកម្មភាពផ្លូវភេទតាមអនឡាញ។ |
| ការផ្សាយផ្ទាល់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ( Live Streaming ) | គឺសំដៅលើការផ្សាយផ្ទាល់ ឬបង្ហាញវីដេអូផ្ទាល់ដែលជាសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ អនុញ្ញាតឱ្យអ្នកដទៃមើលឃើញពីចម្ងាយតាមរយៈកម្មវិធីផ្សាយផ្ទាល់។ |
| ការរាំងខ្ទប់ (Block) | គឺជាវិធីសាស្រ្តរារាំង ឬរាំងខ្ទប់នរណាម្នាក់ ឬគណនីណាមួយដែលប៉ុនប៉ងលួងលោម ឬគំរាមកំហែងនៅលើកម្មវិធី ឬវេទិកាបណ្តាញសង្គម។ |
| អក្ខរកម្មឌីជីថល | ការយល់ដឹងអំពីឌីជីថលនៅមានកម្រិត ឬចំណេះដឹងទាបទាក់ទងនឹងឌីជីថល។ |
| ពលរដ្ឋឌីជីថល | ពលរដ្ឋសកម្មដែលយល់ដឹងខ្ពស់អំពីការប្រើប្រាស់ប្រព័ន្ធឌីជីថលបានត្រឹមត្រូវ និងមានសុវត្ថិភាពខ្ពស់។ |
| ប្រព័ន្ធរាយការណ៍នៅលើវេទិកា | នៅតាមកម្មវិធី ឬឧបករណ៍ឌីជីថល កន្លែងដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់រាយការណ៍ ឬផ្តល់ព័ត៌មានត្រឡប់ទៅកម្មវិធីវិញនូវអ្វីដែលគេឃើញ ឬយល់ថាមិនត្រឹមត្រូវ។ |
| ប្រព័ន្ធរាយការណ៍តាមអនឡាញ | គឺជាប្រព័ន្ធរាយការណ៍តាមគេហទំព័រ (Online Report) និងតាមលេខទូរស័ព្ទភ្លាម (Hotline) ដែលដំណើរការដោយអង្គការ សកម្មភាពដើម្បីកុមារ (APLE)។ |

# ឧបសម្ព័ន្ធ៖ ដំណើរការ និងជំហានសម្របសម្រួលវគ្គ

## ឧបសម្ព័ន្ធមេរៀនទី១៖

## ការយល់ដឹងអំពីបច្ចេកវិទ្យា និងពិភពនិម្មិត របស់កុមារនិងយុវជនក្នុងបរិបទកម្ពុជា

### ដំណើរការ និងជំហានសម្របសម្រួល

១ រៀបចំបរិយាកាសនៃវគ្គបណ្តុះបណ្តាលនេះ ហើយធ្វើការណែនាំអំពីវគ្គនេះដោយប្រើកំណត់ចំណាំខាងលើ និងចែករំលែកពីលទ្ធផលដែលរំពឹងទុកពីវគ្គបណ្តុះបណ្តាល។

២ សូមពន្យល់ដល់ក្រុមអ្នកចូលរួមថា យើងនឹងឆ្លុះបញ្ចាំងអំពីការប្រើប្រាស់ ICT របស់ពួកគេផ្ទាល់។ យើងនឹងធ្វើដូច្នេះដោយការពិភាក្សាជាដៃគូ ឬការពិភាក្សាប្រមូលគំនិតក្នុងក្រុមធំជាងនេះ (មួយណាក៏បានឱ្យតែសមរម្យ)។

៣ ក្នុងនាមជាអ្នកសម្របសម្រួល អ្នកគួរផ្តល់យោបល់អំពីភាពស្រដៀងគ្នា និងភាពខុសគ្នាដែលអ្នកសង្កេតឃើញ ហើយអញ្ជើញក្រុមបញ្ចេញមតិយោបល់របស់ពួកគេទាក់ទងអ្វីដែលពួកគេមើលឃើញ។

៤ ធ្វើការសង្ខេបផ្នែកនៃមេរៀននេះ ដោយចង្អុលបង្ហាញថា អំពីមាតិកា និងខ្លឹមសាររួមនៅក្នុងមេរៀនទី១នេះ ដែលមានដូចជា៖

#### ក ការយល់ដឹងអំពី ពាក្យគន្លឹះ និងនិយមន័យនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន

- ឧបករណ៍អេឡិចត្រូនិក ( Electronic Device )
- ឧបករណ៍ឌីជីថល ( Digital Device )
- បច្ចេកវិទ្យាឌីជីថល ( Digital Technology )
- ឧបករណ៍បណ្តាញ ( Network Devices )
- បច្ចេកវិទ្យាព័ត៌មាន ( Information Technology "IT" )
- បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ( ICT )
- ពិភពនិម្មិត ( Virtual World )
- អ៊ីនធឺណិត ( Internet )
- ប្រព័ន្ធអនឡាញ ( Online )

## ខ យល់ដឹងអំពីដំណើរការ ការប្រើប្រាស់ បង្កើត និងចែកចាយព័ត៌មាននៅលើពិភពអ៊ីនធឺណិត

- អំពីបណ្តាញគេហទំព័រជុំវិញពិភពលោក ( World Wide Web )
- អំពីអ្នកផ្តល់សេវាអ៊ីនធឺណិត (Internet Service Providers"ISP" )
- អំពីអាសយដ្ឋានអ៊ីនធឺណិត (Internet Protocol )
- អំពីហ្វ្រីណិត (Freenet )
- អពីកម្មវិធីប្រព័ន្ធប្រតិបត្តិការ (Operation System "OS" )
- កម្មវិធី (Application )
- អំពីកម្មវិធី (Apps )
- អំពីគេហទំព័ររុករកនៅលើអ៊ីនធឺណិត (Internet Browser )
- ម៉ាស៊ីនស្វែងរក ឬ អ្នករុករក (Search Engine )
- អំពីភាពខុសគ្នារវាងម៉ាស៊ីនរុករក (Apps ) និងគេហទំព័ររុករកតាមអ៊ីនធឺណិត
- ទំព័រដើម (Homepage )
- គេហទំព័រងងឹត (Dark Web )
- ប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Media )
- កម្មវិធីផ្ញើសារ (Messager App )
- គោលបំណង និងមុខងារនៃកម្មវិធី និង វេទិកានីមួយៗដែលបានប្រើ
- កម្មវិធីហ្គេមអនឡាញ
- ស្វែងយល់អំពីបញ្ញាសិប្បនិម្មិត (AI )

## គ របកគំហើញនៃការសិក្សាស្រាវជ្រាវអំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ

៥ សូមពន្យល់ប្រាប់ពួកគេថា ឥឡូវនេះយើងនឹងចំណាយពេលពិចារណា និងសិក្សាអំពីរបៀបដែលកុមារ និងយុវជនកម្ពុជាប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យា ហើយថា តើពិភពនិម្មិតមានលក្ខណៈបែបណាសម្រាប់ពួកគេ។

គំនិតរបស់ពួកគេ អាចរួមមាន៖ កុមារប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណិតសម្រាប់ការកម្សាន្ត (មើលភាពយន្ត និងវីដេអូជាដើម) ដើម្បីបង្កើតមិត្តភក្តិ និងរក្សាទំនាក់ទំនងជាមួយមិត្តភក្តិពួកគេ

ដើម្បីការរៀនសូត្រ ការអប់រំ និងការស្រាវជ្រាវ ដើម្បីណាត់ជួប និងស្វែងរកដៃគូ ដើម្បីចែករំលែករូបភាព និងវីដេអូ និងលេង «ហ្គេម» ដែលកំពុងតែពេញនិយមកាន់តែខ្លាំងឡើងនាពេលបច្ចុប្បន្ននេះ។

៦ បន្ទាប់មកចែករំលែកព័ត៌មានពីស្លាយដែលពាក់ព័ន្ធនឹងស្លាយមេរៀននេះ។ *(កម្មវិធី គេហទំព័រ សកម្មភាព សហគមន៍ហ្គេម និងធនធានអប់រំដែលប្រើប្រាស់ដោយកុមារ និងយុវជនកម្ពុជា។)* សូមពន្យល់ថា ព័ត៌មាននេះគឺផ្អែកលើព័ត៌មានដែលផ្តល់ដោយអ្នកស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាល APLE យោងតាមអ្វីដែលកុមារប្រាប់ពួកគេ (២០២៣) ។

បញ្ជាក់ប្រាប់ពួកគេផងដែរថា និន្នាការ(ទំនោរ) កម្មវិធី បច្ចេកវិទ្យា និងសកម្មភាពទាំងនេះអាចហើយជាញឹកញាប់ផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

បញ្ជាក់ប្រាប់ពួកគេផងដែរថា និន្នាការ(ទំនោរ) កម្មវិធី បច្ចេកវិទ្យា និងសកម្មភាពទាំងនេះអាចហើយជាញឹកញាប់ផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

៧ បន្តការពិភាក្សាដោយសួរពួកគេអំពីគំនិតរបស់ពួកគេទាក់ទងនឹងអ្វី ដែលពួកគេគិតថាជា «**អត្ថប្រយោជន៍ និងគុណសម្បត្តិ**» ហើយអ្វីជា «**គុណវិបត្តិ និងហានិភ័យ**» សម្រាប់កុមារកម្ពុជា។

នៅដំណាក់កាលនេះ អ្នកគ្រាន់តែសុំគំនិត និងយោបល់របស់ពួកគេ ដែលអាចផ្អែកលើបទពិសោធន៍ជីវិតរបស់ពួកគេផ្ទាល់ (ប្រហែលជាកូនៗរបស់ពួកគេ) ឬអ្វីដែលពួកគេបានឮពីការងាររបស់ពួកគេ និង/ឬការសន្ទនារបស់ពួកគេ។

៨ ចែករំលែកព័ត៌មានទាក់ទងនឹងការស្រាវជ្រាវអំពីកុមារ និងយុវជនកម្ពុជា និងរបៀបដែលពួកគេប្រើប្រាស់ប្រព័ន្ធអនឡាញ៖

បន្ទាប់ពីក្រុមបានចែករំលែកគំនិតរបស់ពួកគេរួចហើយ ពន្យល់ប្រាប់ពួកគេថា យើងនឹងចែករំលែកព័ត៌មានសង្ខេបអំពីការស្រាវជ្រាវទាក់ទងនឹងរបៀប ដែលកុមារកម្ពុជាប្រើប្រាស់ប្រព័ន្ធអនឡាញ។ ព័ត៌មាននេះគឺផ្អែកលើការស្រាវជ្រាវជាមួយកុមារនៅប្រទេសកម្ពុជា (ការបញ្ឈប់គ្រោះថ្នាក់) និងព័ត៌មានបន្ថែមដែលផ្តល់ដោយ APLE ក្នុងឆ្នាំ២០២៣។ *(កំណត់ចំណាំចំពោះអ្នកបណ្តុះបណ្តាល៖ ព័ត៌មាននេះអាចនឹងគួរត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ)*។

៩ ចែករំលែកព័ត៌មានបន្ថែមនៅលើ (**អត្ថប្រយោជន៍ និងគុណសម្បត្តិ** និង **គុណវិបត្តិ និងហានិភ័យ** សម្រាប់កុមារកម្ពុជា)៖ ក៏រួមបញ្ចូលព័ត៌មានសំខាន់ៗដែលត្រូវចែករំលែកផងដែរ (មានតំណភ្ជាប់បន្ថែមដែលផ្តល់ជូនក្នុងកំណត់ចំណាំនៅខាងក្រោមស្លាយ)។

១០ បន្ទាប់ពីអ្នកបានចែករំលែកព័ត៌មាននេះរួចហើយ អ្នកអាចសួរសំណួរខាងក្រោមទៅកាន់ក្រុម៖

- តើព័ត៌មានអ្វីខ្លះដែលធ្វើឱ្យពួកគេភ្ញាក់ផ្អើល?
- តើព័ត៌មានអ្វីខ្លះដែលធ្វើឱ្យពួកគេចាប់អារម្មណ៍?
- តើពួកគេមានមតិយោបល់អ្វី ឬសំណួរអ្វីបន្ថែមទាក់ទងនឹងអ្វីដែលពួកគេបានរៀនដែ

## សកម្មភាព

១ ដោយប្រើក្តារខៀន ឬក្រដាសផ្ទាំងធំ សូមគូសរង្វង់មួយនៅកណ្តាលក្រដាស ហើយសរសេរពាក្យ «អ៊ីនធឺណិត» «បច្ចេកវិទ្យា» និង «ពិភពនិម្មិត» នៅក្នុងរង្វង់នេះ ហើយផ្នែកខាងឆ្វេងនៃរង្វង់ សូមគូសគំនូសឈរមួយដែលមានចំណងជើងថា «អត្ថប្រយោជន៍ និងគុណសម្បត្តិសម្រាប់ខ្ញុំ» និងនៅខាងស្តាំដៃ «ហានិភ័យ និងគុណវិបត្តិសម្រាប់ខ្ញុំ»។

២ សុំឱ្យក្រុមពិភាក្សាគ្នាជាដៃគូ រយៈពេលដប់នាទី អំពីការប្រើប្រាស់បច្ចេកវិទ្យា វេទិកា កម្មវិធី និងឧបករណ៍ផ្សេងៗរបស់ពួកគេ៖ ពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិ នៃការប្រើប្រាស់របស់ទាំងនេះ។ពួកគេអាចសរសេរគំនិតរបស់ពួកគេនៅលើក្រដាសកំណត់ចំណាំ (ប្រសិនបើអ្នកមាន) ឬក្រដាសពណ៌។ (ឧ.ពណ៌បៃតងសម្រាប់គុណសម្បត្តិ ហើយពណ៌ខៀវសម្រាប់គុណវិបត្តិ)។

៣ នាំក្រុមតូចនីមួយៗ ត្រឡប់មកក្រុមធំវិញ ហើយសុំពួកគេឱ្យចែករំលែកគំនិតរបស់ពួកគេ-ជាដំបូង ដោយសួរពួកគេអំពីឧបករណ៍ និងកម្មវិធីផ្សេងៗ ដែលពួកគេធ្លាប់បានប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃពួកគេ។ វាគួរតែងាយស្រួលសម្រាប់ពួកគេក្នុងការចែករំលែក ដោយសារពួកគេប្រើប្រាស់វាជារៀងរាល់ថ្ងៃ។

៤ សួរក្រុមដោយផ្អែកលើបទពិសោធន៍របស់ពួកគេផ្ទាល់-តើពួកគេដឹងអ្វីខ្លះ៖ អំពីរបៀបដែលកុមារកម្ពុជាប្រើប្រាស់អ៊ីនធឺណិត (ឧ. ឧបករណ៍ កម្មវិធី និងវេទិកា ដែលពួកគេប្រើប្រាស់) ហើយពួកគេប្រើអ៊ីនធឺណិតដើម្បីអ្វី (ឧ.គោលបំណង និងហេតុផល ដែលពួកគេប្រើប្រាស់វា)។ អនុញ្ញាតឱ្យពួកគេឆ្លើយតបសិន មុនពេលបន្តទៅមុខទៀត។

## សកម្មភាពគាំទ្រ ឬសារគន្លឹះមេរៀន

- វាច្បាស់ណាស់ថា ទាំងមនុស្សពេញវ័យ និងកុមារ ពឹងផ្អែកកាន់តែខ្លាំងជាងមុនលើប្រព័ន្ធអនឡាញ និងបច្ចេកវិទ្យា នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតពួកគេ។ ការរីកចម្រើននៃ បច្ចេកវិទ្យា និងការប្រើប្រាស់ទាំងនេះ មានល្បឿនលឿនណាស់រយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះ។

- បច្ចេកវិទ្យាផ្តល់ឱកាសគ្មានទីបញ្ចប់សម្រាប់ការរៀន ការធ្វើការ ការភ្ជាប់ទំនាក់ទំនង សង្គម ការរៀបចំ និងការរៀបចំផែនការ ផ្តល់ភាពសប្បាយរីករាយ និងការសម្រាកលំហែ ការទិញទំនិញ ការចូលមើលការកម្សាន្តផ្សេងៗគឺគ្មានទីបញ្ចប់ទេ!
- មានគុណសម្បត្តិជាច្រើននៃបច្ចេកវិទ្យា និងអ៊ីនធឺណិត ប៉ុន្តែវាក៏មានគុណវិបត្តិផងដែរ។
- កុមារប្រើប្រាស់ប្រព័ន្ធអនឡាញកាន់តែច្រើនឡើងនៅប្រទេសកម្ពុជា ហើយពួកគេក៏ទទួលបានអត្ថប្រយោជន៍ ព្រមទាំងប្រឈមនឹងបញ្ហា និងការលំបាកជាច្រើនផងដែរ។
- ប្រសិនបើយើងជួយកុមារ និងយុវជន ដែលរងផលប៉ះពាល់ដោយបទឧក្រិដ្ឋលើប្រព័ន្ធអនឡាញ OCSEA វាមានប្រយោជន៍សម្រាប់យើងក្នុងការស្វែងយល់អំពីបរិបទដែលកុមារកម្ពុជាប្រើប្រាស់អ៊ីនធឺណិត និង «ពិភពឌីជីថល» ដែលពួកគេកំពុងរស់នៅ។
- យើងដឹងហើយថា ពេលដែលមានរឿងខុសប្រក្រតីកើតឡើង កុមារតែងតែមានអារម្មណ៍ភ័យខ្លាច ច្របូកច្របល់ ហើយពួកគេមិនដឹងថាត្រូវធ្វើអ្វីទេ។ ពួកគេក៏ប្រហែលជា មានអារម្មណ៍ថា ពួកគេមិនអាចទុកចិត្តនគរបាលដើម្បីដោះស្រាយបញ្ហារបស់ពួកគេដែរ។ មន្ត្រីនគរបាលខ្លះមើលឃើញថា កុមារ «មិនសហការ» ជាមួយពួកគេទេ ប៉ុន្តែជារឿយៗ ពួកគេគ្រាន់តែមានអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់តែប៉ុណ្ណោះ។
- ព័ត៌មាននៅក្នុងមេរៀននេះ អាចមានប្រយោជន៍សម្រាប់យើង ពេលយើងជួបកុមារ និងអាណាព្យាបាលរបស់ពួកគេ។ ដូច្នេះយើងមានព័ត៌មាន និងចំណេះដឹងមូលដ្ឋាន អំពីប្រធានបទនេះ។ ការណ៍នេះអាចជួយកុមារ និងយុវជន ឱ្យមានអារម្មណ៍ជឿជាក់លើមន្ត្រីនគរបាល ថាពួកគេមានចំណេះដឹង និងការយល់ដឹងសមស្រប... ការនេះអាចជួយឱ្យកុមារមានភាពជឿជាក់លើយើងក្នុងឋានៈជាមន្ត្រីនគរបាល ហើយបន្ទាប់មកមានអារម្មណ៍ជឿជាក់ក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយយើង។

# ឧបសម្ព័ន្ធមេរៀនទី២៖

## ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

### ជំហាន និងដំណើរការសម្របសម្រួល

- អ្នកសម្របសម្រួលសង្ខេបមាតិកា និងខ្លឹមនៅក្នុងមេរៀនទី២នេះ៖

ក តើយើងដឹងអ្វីខ្លះអំពី OCSEA ?

- ស្វែងអំពីពាក្យគន្លឹះ៖
  - ហានិភ័យ
  - ការកេងប្រវ័ញ្ចផ្លូវភេទ
  - ការរំលោភបំពានផ្លូវភេទ
  - ជនល្មើស
  - ជនរងគ្រោះ
- ការស្វែងយល់ ពីឥរិយាបថកុមារនៅលើអ៊ីនធឺណិត ឬប្រព័ន្ធអនឡាញ
  - ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម
  - ការលេងហ្គេមអនឡាញ
  - ការចែករំលែកព័ត៌មានផ្ទាល់ខ្លួន
  - ការចែករំលែកមាតិកាមិនសមរម្យ
  - អ្នកប្រមាញ់តាមអ៊ីនធឺណិត
  - ការប្រាស្រ័យទាក់ទង និងការអប់រំ
- ការស្វែងយល់ ពីហានិភ័យដែលកុមារអាចជួបប្រទះនៅលើអ៊ីនធឺណិត ឬប្រព័ន្ធអនឡាញ
  - ហានិភ័យនៃមាតិកា
  - ហានិភ័យទំនាក់ទំនង
  - ហានិភ័យនៃការប្រព្រឹត្ត
  - ហានិភ័យនៃកិច្ចសន្យា

- ការស្វែងយល់ពីហានិភ័យនៃការកេងប្រវ័ញ្ចលើអ៊ីនធឺណិត ឬប្រព័ន្ធអនឡាញ
  - ការរុកកួនឆាឆៅតាមអនឡាញ (Cyberbullying)
  - ជនរងគ្រោះ

## ខ ការយល់ដឹងអំពីមូលដ្ឋានគ្រឹះនៃឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតលើកុមារ

- ទិដ្ឋភាពទូទៅនៃឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងសារៈសំខាន់របស់វា
- ផលប៉ះពាល់នៃការកេងប្រវ័ញ្ចកុមារតាមបច្ចេកវិទ្យា
- តម្រូវការសម្រាប់វិធីសាស្ត្រទូលំទូលាយ

## គ របកគំហើញនៃការសិក្សាស្រាវជ្រាវអំពី OCSEA

## ឃ ទស្សនៈ ឬជំនឿមួយចំនួនពាក់ព័ន្ធនឹងអំពើ OCSEA

- ធ្វើឱ្យប្រាកដថាអ្នកសម្របសម្រួលបានអាន **សន្លឹកកិច្ចការភ្ជាប់ជាមួយចម្លើយ** និងការពន្យល់បន្ថែម មុនពេលសម្របសម្រួលមេរៀននេះ ហើយពន្យល់ចម្លើយពិតប្រាកដដែលមានក្នុង ស្លាយមេរៀន។
- ស្វាគមន៍ក្រុម ចែករំលែកលទ្ធផលនៃការរំពឹងទុករបស់វគ្គបណ្តុះបណ្តាល ដោយប្រើកំណត់ចំណាំនៅខាងលើ និងស្លាយ។ សូមពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនេះ។
- ចាប់ផ្តើមដោយសុំឱ្យក្រុមពិភាក្សា និងចែករំលែកគំនិតរបស់ពួកគេអំពីអ្វី ដែលពួកគេបានដឹង ឬឮអំពី OCSEA។

អ្នកអាចធ្វើដូច្នេះបាន ដោយសុំពួកគេឱ្យពិភាក្សាគ្នាជាគូរយៈពេលពីរបីនាទី ហើយបន្ទាប់មកសុំពួកគេឱ្យចែករំលែកក្នុងក្រុម។ ការស្នើសុំពួកគេឱ្យពិភាក្សាគ្នាជាគូ អនុញ្ញាតឱ្យគ្រប់គ្នាមានឱកាសក្នុងការចូលរួមចែករំលែកគំនិតយោបល់របស់ពួកគេ។

គោលគំនិតនៃលំហាត់នេះ គឺដើម្បីប្រមូល (ឬទាញយក) គំនិតរបស់ពួកគេ។ នៅដំណាក់កាលនេះ វាមិនសំខាន់ក្នុងការផ្តល់មតិយោបល់ត្បោះក្បាយច្រើនពេក អំពីគំនិតដែលពួកគេចែករំលែក ឬនិយាយថាគំនិតរបស់ពួកគេ «ត្រូវ» ឬ «ខុស»ទេ ព្រោះថានេះមិនមែនជាគោលបំណងនៃលំហាត់នេះទេ។

## ចំណុចពិភាក្សាសំខាន់ៗ ដើម្បីក្រុមធ្វើការឆ្លុះបញ្ចាំង មានដូចជា៖

- តើ OCSEA មានន័យយ៉ាងដូចម្តេច?
- តើវាពាក់ព័ន្ធនឹងឥរិយាបថ ឬទង្វើអ្វីខ្លះ?
- តើវាកើតឡើងដោយរបៀបណា?
- តើអ្នកណាជាជនរងគ្រោះ ហើយអ្នកណាជាជនល្មើស?
- បន្ទាប់ពីពួកគេបានចំណាយពេល ដើម្បីពិភាក្សា ហើយសុំពួកគេឱ្យចែករំលែកនៅក្នុងក្រុម។ អ្នកអាចសរសេរគំនិតរបស់ពួកគេនៅលើក្រដាស ផ្ទាំងធំ ឬក្តារខៀន ដូច្នេះមនុស្សទាំងអស់នៅក្នុងក្រុមអាចមើលឃើញបាន។ វាអាស្រ័យលើចំណេះដឹង និងបទពិសោធន៍ ដែលមានស្រាប់របស់ក្រុមអ្នកអាចទទួលបានការឆ្លើយតបមួយចំនួនដែលមានប្រយោជន៍ និង/ឬត្រឹមត្រូវ ហើយការឆ្លើយតបផ្សេងទៀតមិនសូវត្រឹមត្រូវប៉ុន្មានទេ។ នៅដំណាក់កាលនេះវាមិនសូវសំខាន់ក្នុងការកែតម្រូវការឆ្លើយតបដែលមិនត្រឹមត្រូវទេ ព្រោះថាព័ត៌មានដែលត្រឹមត្រូវ នឹងត្រូវផ្តល់ជូននៅក្នុងវគ្គបន្ទាប់។ *(ការចែករំលែកនៅក្នុងក្រុមធំ)*
- អនុញ្ញាតឱ្យក្រុមពិភាក្សាដោយសង្ខេបអំពីព័ត៌មាន ដែលពួកចែករំលែក ប្រសិនបើពួកគេចង់ធ្វើដូច្នេះ។
- ពន្យល់ប្រាប់ពួកគេថា អ្នកនឹងមិនបញ្ចេញមតិលម្អិតនៅដំណាក់កាលនេះទេ ប្រសិនបើព័ត៌មានដែលពួកគេចែករំលែកវាត្រឹមត្រូវ និងជាការពិតហើយ ព្រោះយើងនឹងបន្តតាមដានព័ត៌មានទាំងនេះនៅវគ្គបន្ទាប់ទៀត។ គោលបំណងនៃវគ្គនេះ គឺដើម្បីស្វែងយល់ និងកសាងអ្វីដែលក្រុមបានដឹងរួចហើយ។ ទុកក្រដាសផ្ទាំងធំនេះនៅលើជញ្ជាំងដូច្នេះអ្នកអាចត្រលប់ទៅមើលវាវិញនៅពេលក្រោយប្រសិនបើអ្នកត្រូវការ។
- ពន្យល់ប្រាប់ក្រុមថាឥឡូវនេះ អ្នកនឹងចែកសន្លឹកកម្រងសំណួរការធ្វើតេស្តទៅកាន់មនុស្សម្នាក់ៗនៅក្នុងក្រុម។ វាគឺជាកម្រងសំណួរដែលពួកគេត្រូវឆ្លើយ «ត្រូវ» ឬ «ខុស» អំពីប្រធានបទដែលពាក់ព័ន្ធនឹង OCSEA ដែលមាន ១៤សំណួរ។
- អ្នកចូលរួមម្នាក់ៗ ត្រូវឆ្លើយសំណួរទាំងនេះដោយខ្លួនឯង ដោយសម្ងាត់ ដោយមិនពិភាក្សា ឬមើលចម្លើយរបស់អ្នកដទៃឡើយ។
- ទុកពេលប្រហែល ៧-១០នាទី ដើម្បីឱ្យមនុស្សគ្រប់គ្នានៅក្នុងក្រុមបំពេញសន្លឹកកម្រងសំណួរនេះ ដោយមិនដាក់ឈ្មោះ ហើយបន្ទាប់មកបត់វាជាពីរ ហើយដាក់វានៅក្នុងប្រអប់មួយដែល

ផ្តល់ឱ្យពួកគេ។ ពេលពួកគេបានបំពេញវារួចរាល់ហើយ ក្នុងនាមជាអ្នកសម្របសម្រួល សូមសាប់សន្លឹកកម្រងសំណួរទាំងនេះ ហើយចែកវាទៅឱ្យមនុស្សនៅក្នុងក្រុមវិញ ដោយឱ្យមនុស្សម្នាក់ៗមានសន្លឹកកម្រងសំណួរណាដែលមិនមែនជារបស់ពួកគេ។

- នៅលើផ្ទាំងក្រដាសធំ ឬក្តារខៀន សូមបង្កើតតារាងយ៉ាងសាមញ្ញមួយ ស្រដៀងគ្នានឹងតារាងខាងក្រោម។ សម្រាប់សំណួរនីមួយៗ សុំក្រុមឱ្យលើកដៃឡើង (ឧ. រាប់ចំនួនអ្នកដែលឆ្លើយថា «ត្រូវ» និងចំនួនអ្នកដែលឆ្លើយថា «ខុស») ហើយសរសេរចំនួនសរុបទៅតាមជួរដែលពាក់ព័ន្ធ។

## នេះជាឧទាហរណ៍នៃតារាងដែលអ្នកអាចគូរបាន៖

| លេខសំណួរ | ចំនួនអ្នកឆ្លើយថា «ត្រូវ» | ចំនួនអ្នកឆ្លើយថា «ខុស» |
|---|---|---|
| ១ | ១១ | ១២ |
| ២ | ៥ | ១៨ |
| ៣ | ២២ | ១ |
| ៤ | ១៤ | ១៣ |

តាមរយៈការបំពេញតារាងសម្រាប់សំណួរទាំងអស់នេះ អ្នកអាចបង្ហាញពីភាពខុសគ្នា នៃការឆ្លើយតបរបស់មនុស្សម្នាក់ៗនៅក្នុងក្រុម ហើយដោយសារការបំពេញសន្លឹកកម្រងសំណួរនេះធ្វើឡើងដោយមិនបានដាក់ឈ្មោះ ដូច្នេះគ្មានអ្នកចូលរួមណាម្នាក់នឹងមានអារម្មណ៍ខ្មាសអៀន ដោយសារចម្លើយមិនត្រឹមត្រូវរបស់ពួកគេទេ។ ការពិនិត្យមើលចម្លើយរួមគ្នានេះ គួរតែចំណាយពេលតែប៉ុន្មាននាទីតែប៉ុណ្ណោះ។ អ្នកអាចផ្តល់មតិយោបល់លើចម្លើយនីមួយៗ ដែលបង្ហាញពីភាពខុសគ្នានៃចម្លើយ របស់ពួកគេចំពោះសំណួរតែមួយដូចគ្នា។

- ពេលអ្នកបានបំពេញតារាងរួចរាល់ហើយ អ្នកអាចពិនិត្យមើលចម្លើយដែលត្រឹមត្រូវទាំងអស់ដោយអានតាមចម្លើយនីមួយៗនៅលើសន្លឹកកិច្ចការដែលបានផ្តល់ឱ្យ និង/ឬប្រើស្លាយដែលមានព័ត៌មានត្រឹមត្រូវ។ ស្លាយដែលបានរៀបចំរួចហើយ គ្រាន់តែប្រាប់ពីការពិតនៃចំណងជើង មិនប្រាប់ព័ត៌មានលម្អិតទេ (អ្នកអាចប្រើឯកសារចែកជូនដើម្បីពន្យល់ព័ត៌មានលម្អិត ប្រសិនបើអ្នក ចង់ធ្វើដូច្នេះ)។

អនុញ្ញាតឱ្យក្រុមផ្តល់មតិយោបល់លើការឆ្លើយតបត្រឹមត្រូវនីមួយៗ ប្រសិនបើពួកគេចង់ធ្វើដូច្នេះ។ ពួកគេអាចនឹងភ្ញាក់ផ្អើលចំពោះព័ត៌មានមួយចំនួន?

ពន្យល់ប្រាប់ពួកគេថា ព័ត៌មាននេះនឹងត្រូវផ្តល់ជូននៅក្នុងឯកសារចែកជូន ហើយអាចនឹងមានប្រយោជន៍ ក្នុងការចែករំលែកឯកសារនេះ ជាមួយសហសេវិក នៅក្នុងការិយាល័យរបស់ពួកគេ និង/ឬនៅក្នុងការសន្ទនាជាមួយកុមារ និងយុវជន និងអាណាព្យាបាល ពេលពួកគេស្វែងរកការគាំទ្រដើម្បីដាក់ពាក្យបណ្តឹងទៅកាន់នគរបាល។

អ្នកក៏អាចសុំឱ្យក្រុមផ្តល់យោបល់ អំពីអត្ថប្រយោជន៍បន្ថែម នៃការមានព័ត៌មានត្រឹមត្រូវអំពី OCSEA នៅប្រទេសកម្ពុជាផងដែរ។

- ចែកសន្លឹកសំណួរចម្លើយទៅកាន់ក្រុម ហើយសុំពួកគេឱ្យរក្សាវាទុកដោយសុវត្ថិភាពសម្រាប់ជាឯកសារយោងរបស់ពួកគេ។
- ពន្យល់ពួកគេថា វគ្គនេះនឹងបញ្ចប់ក្នុងពេលឆាប់ៗនេះ ប៉ុន្តែសូមសួរក្រុមសិនថាតើពួកគេមានសំណួរអ្វីបន្ថែមទៀតទាក់ទងនឹង OCSEA ដែរឬទេ? បើមានសរសេរវានៅលើផ្ទាំងក្រដាសធំ។ អ្នកក៏អាចផ្តល់យោបល់អំពីភាពស្រដៀងគ្នា និងភាពខុសគ្នារវាងគំនិតរបស់ពួកគេ ដែលប្រមូលបានពីពេលមុន និងព័ត៌មានពិតផងដែរ។

ការសម្របសម្រួលសំណួរក៏អាចផ្តល់ឱ្យអ្នកនូវគំនិតបន្ថែមអំពីតម្រូវការសិក្សារបស់ក្រុម សូមប្រាកដថាអ្នកឆ្លើយតបទៅកាន់ពួកគេ ហើយបញ្ចូលវាទៅក្នុងវគ្គបណ្តុះបណ្តាលនៅពេលក្រោយ។

- បិទវគ្គ និងសម្រាករយៈពេលខ្លី។ ពេលអ្នករៀបចំសម្រាប់វគ្គបន្ទាប់ ដែលនឹងផ្តោតលើការចែករំលែកព័ត៌មានត្រឹមត្រូវ និងករណីសិក្សាអំពី OCSEA នៅប្រទេសកម្ពុជា។

# ឧបសម្ព័ន្ធមេរៀនទី៣៖

## ចរិតលក្ខណៈ និងផលប៉ះពាល់នៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

### ដំណើរការ និងជំហានសម្រាប់សម្របសម្រួល

១ កំណត់ចំណាំពិសេសសម្រាប់អ្នកសម្របសម្រួល៖ ត្រូវប្រាកដថាអ្នកបានអានផែនការមេរៀន ឯកសារចែកជូន និងករណីសិក្សាទាំងអស់ឱ្យបានលម្អិត ជាផ្នែកនៃការរៀបចំរបស់អ្នកសម្រាប់មេរៀននេះ។ វានឹងផ្តល់ឱ្យអ្នកនូវព័ត៌មានដែលពាក់ព័ន្ធ ដើម្បីជួយអ្នកចូលរួមក្នុងការសិក្សាប្រកបដោយប្រសិទ្ធភាព និងសម្រាប់អ្នកក្នុងការឆ្លើយតបទៅនឹងសំណួរដែលពួកគេអាចសួរបាន។

២ ស្វាគមន៍ក្រុម និងចែករំលែកអំពីលទ្ធផលនៃការរំពឹងទុកចេញពីវគ្គនេះ ដោយប្រើកំណត់ចំណាំនៅខាងលើ និងស្លាយ។ សូមពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីទទួលបានលទ្ធផលនៃការរំពឹងទុកនេះ។

៣ រំលឹកក្រុមថា កាលពីវគ្គមុនពួកគេត្រូវបានស្នើសុំឱ្យធ្វើការឆ្លុះបញ្ចាំង អំពីគំនិតរបស់ពួកគេទាក់ទងនឹង OCSEA និងពិពណ៌នាអំពីអត្ថន័យរបស់ OCSEA មានឥរិយាបថ ឬសកម្មភាពអ្វីខ្លះដែលជាប់ពាក់ព័ន្ធ របៀបដែលវាកើតឡើង ហើយអ្នកណាជាជនរងគ្រោះ និងជនល្មើស។

សូមពន្យល់ប្រាប់ពួកគេថា គំនិតជាច្រើនរបស់ពួកគេមានប្រយោជន៍ខ្លាំងណាស់ ហើយឥឡូវនេះ យើងនឹងស្វែងយល់បន្ថែមអំពី OCSEA ដោយផ្អែកលើការស្រាវជ្រាវក្នុងប្រទេសកម្ពុជា។

៤ សង្ខេបមាតិកា និងខ្លឹមសារមេរៀនទី៣នេះ

ក និយមន័យនៃការរំលោភបំពានផ្លូវភេទលើកុមារ (CSA) ៖

- អង្គការសុខភាពពិភពលោក (WHO) កំណត់ការរំលោភផ្លូវភេទលើកុមារ
- ការរំលោភបំពានផ្លូវភេទលើកុមារដោយផ្ទាល់ និងមិនផ្ទាល់។ ការរំលោភបំពានលើរាងកាយ ឬការប៉ះពាល់ដោយផ្ទាល់
- សកម្មភាពនៃការរំលោភបំពានផ្លូវភេទដែលមិនពាក់ព័ន្ធនឹងការប៉ះពាល់ផ្ទាល់

**ខ និយមន័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (CSE)**

**គ ការស្វែងយល់ និងនិយមន័យ OCSEA**

**ឃ តើ OCSEA មានលក្ខណៈបែបណា?**

- ការផលិត ការកាន់កាប់ ឬការចែកចាយ CSAM
- ការល្បួងលោមកុមារតាមអនឡាញក្នុងគោលបំណងផ្លូវភេទ (Grooming of Children for Sexual Purposes)
- ការគំរាមទាក់ទងនឹងផ្លូវភេទ (Sextortion )
- ការផ្សាយផ្ទាល់អំពីការរំលោភបំពានផ្លូវភេទលើកុមារ (Live Streaming)

**ង ផលប៉ះពាល់នៃ OCSEA**

៥ ពន្យល់ប្រាប់ពួកគេថា ជាដំបូងអ្នកនឹងរំលឹកក្រុមអំពីនិយមន័យនៃពាក្យ «**ការរំលោភបំពានផ្លូវភេទលើកុមារ** CSA » និង «**ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ** CSE »។

៦ ឥឡូវនេះ សូមពន្យល់ប្រាប់ក្រុមថា អ្នកនឹងចែករំលែកការពិពណ៌នាអំពីអ្វី ដែលត្រូវបានគេចាត់ទុកថាជា OCSEA ដោយប្រើស្លាយដែលបានផ្ដល់ឱ្យ ដែលជាព័ត៌មានដូចគ្នាដែលមាននៅលើសន្លឹកធនធានឧទាហរណ៍របស់ OCSEA ផងដែរ។

ដោយប្រើស្លាយ សូមនិយាយអំពីសកម្មភាព និងឥរិយាបថរបស់ OCSEA នីមួយៗ ដោយពន្យល់យ៉ាងច្បាស់ពីអត្ថន័យរបស់វា ដោយប្រើកំណត់ចំណាំដែលមាននៅលើសន្លឹកធនធាន។ អ្នកក៏អាចប្រើឧទាហរណ៍ពីការងាររបស់អ្នក ដើម្បីជួយពន្យល់ពីសាច់រឿងជាក់លាក់ណាមួយផងដែរ។ ទុកពេលច្រើនសម្រាប់ការចែករំលែក និងការពន្យល់ ដោយអនុញ្ញាតឱ្យក្រុមសួរសំណួរ និងបញ្ជាក់អត្ថន័យនៃទង្វើ និងឥរិយាបថនីមួយៗ។

៧ ស្វាគមន៍ក្រុមត្រឡប់មកវិញ ហើយពន្យល់ប្រាប់ពួកគេថា ដើម្បីស្វែងយល់បន្ថែមអំពី OCSEA និងប្រភេទនៃសកម្មភាព និងឥរិយាបថដែលពាក់ព័ន្ធនឹងវា អ្នកនឹងចែករំលែកករណីសិក្សាជាបន្តបន្ទាប់ដែលផ្អែកលើករណីពិត និងព្រឹត្តិការណ៍ពិតក្នុងប្រទេសកម្ពុជា។ អាស្រ័យលើទំហំក្រុម សូមបំបែកក្រុមធំទៅជាក្រុមតូចៗដែលមានអ្នកចូលរួមចំនួន ៣, ៤ ឬ ៥នាក់។

៨ ពន្យល់ប្រាប់ក្រុមថា ភារកិច្ចរបស់ពួកគេ គឺត្រូវអង្គុយជាមួយគ្នា ហើយពិភាក្សាករណីសិក្សានីមួយៗ ហើយរៀបចំបទបង្ហាញដល់ក្រុមដទៃទៀត ដូច្នេះពួកគេអាចចែករំលែកការពិតសំខាន់ៗនៃករណីនីមួយៗ។

ទុកពេលច្រើនដើម្បីឱ្យពួកគេអានសង្ខេប និងរៀបចំបទបង្ហាញរបស់ពួកគេ។ ការធ្វើបែបនេះអាចត្រូវការពេលពី ៣០-៤៥ នាទី។

ពន្យល់ប្រាប់ពួកគេថា ពួកគេអាចប្រើផ្ទាំងក្រដាសធំ ហើយអាចបង្កើតផ្ទាំងរូបភាពផងដែរ ប្រសិនបើពួកគេចង់ធ្វើដូច្នេះ ហើយវាជួយដល់ការពន្យល់ករណីសិក្សានេះដល់ក្រុមដទៃទៀត។

នៅក្នុងបទបង្ហាញខ្លីរបស់ពួកគេ សូមពន្យល់ប្រាប់ពួកគេថា ពួកគេត្រូវបានស្នើសុំឱ្យធ្វើដូចខាងក្រោម៖

៩ ពណ៌នាអំពីតួអង្គសំខាន់ៗ និងសាច់រឿងចម្បងក្នុងករណីសិក្សានីមួយៗ

១០ គូសបញ្ជាក់ថាករណីនេះកើតឡើងលើប្រព័ន្ធអនឡាញ ឬក្រៅប្រព័ន្ធអនឡាញ ប្រសិនបើមាន

១១ ចែករំលែកព័ត៌មានបន្ថែមអំពីរបៀបដែលព្រឹត្តិការណ៍នេះបានប៉ះពាល់ដល់កុមារ និងគ្រួសារ (ប្រសិនបើព័ត៌មាននេះមាននៅក្នុងករណីសិក្សា)

១២ បញ្ចេញមតិយោបល់អំពីបញ្ហាណាមួយដែលគួរឱ្យចាប់អារម្មណ៍ ឬថ្មីសម្រាប់ពួកគេ

១៣ បញ្ចេញមតិយោបល់អំពីបញ្ហាណាមួយដែលធ្វើឱ្យមានការភ័ន្តច្រឡំ ឬពិបាកសម្រាប់ពួកគេក្នុងនាមពួកគេជាមន្ត្រីនគរបាល

១៤ អនុញ្ញាតឱ្យក្រុមដទៃទៀតសួរសំណួរបន្ថែម (ពន្យល់ប្រាប់អ្នកចូលរួមទាំងអស់ថា ពេលក្រុមផ្សេងទៀតកំពុងធ្វើបទបង្ហាញ ពួកគេក៏នឹងត្រូវបានស្នើសុំឱ្យយកចិត្តទុកដាក់ និងសួរសំណួរដែលពាក់ព័ន្ធផងដែរ)។

១៥ ពេលដែលក្រុមទាំងអស់មានឱកាសចែករំលែកបទបង្ហាញរបស់ពួកគេហើយ ពួកគេនឹងបានដឹងពីករណី និងសាច់រឿងជាច្រើនដែលទាក់ទងនឹង OCSEA ហើយទទួលបានគំនិតកាន់តែច្រើនថែមទៀតអំពីបញ្ហា និងការលំបាកដែលជនរងគ្រោះកំពុងប្រឈម។

ក្រុមអាចមានសំណួរបន្ថែមទៀតអំពី OCSEA ដែលអ្នកអាចកត់ត្រាវាទុកក្នុងផ្ទាំងក្រដាសធំ ឬក្តារខៀន ដើម្បីដោះស្រាយវានៅពេលក្រោយ។

១៦ ចែកសៀវភៅជាមួយករណីសិក្សាទាំងអស់ដល់ក្រុម ហើយពន្យល់ប្រាប់ពួកគេថា សៀវភៅ និងករណីសិក្សាទាំងនេះ គឺដើម្បីឱ្យពួកគេប្រើប្រាស់ជាឯកសារយោងបន្ថែម ព្រោះយើងនឹងប្រើប្រាស់វានៅក្នុងវគ្គបន្ទាប់ ដើម្បីពិចារណាបញ្ហាផ្លូវច្បាប់ ការឆ្លើយតបរបស់មន្ត្រីនគរបាល និងការអនុវត្តបែបកុមារមេត្រី។

ស្នើទៅកាន់ក្រុមថា វានឹងមានប្រយោជន៍សម្រាប់ពួកគេក្នុងការដែលពួកគេអានករណីសិក្សាទាំងអស់ជាមុនសម្រាប់វគ្គបន្ទាប់ទៀត ប្រសិនបើពួកគេអាចធ្វើទៅបាន។

## សកម្មភាព

១ សួរក្រុមថាតើពួកគេអាចចងចាំពីការបណ្តុះបណ្តាលជាមូលដ្ឋានរបស់ពួកគេ តើនិយមន័យនៃការរំលោភបំពានផ្លូវភេទលើកុមារ CSA គឺជាអ្វី និងសកម្មភាពអ្វីខ្លះដែលត្រូវបានគេចាត់ទុកថាជា CSA។ ទទួលយកការឆ្លើយតបមួយចំនួនពីក្រុម។ នៅពេលដែលអ្នកពេញចិត្តនឹងការឆ្លើយតបរបស់ពួកគេ សូមសួរក្រុមថាតើសកម្មភាព ឬអាកប្បកិរិយាបែបណាខ្លះ ដែលត្រូវបានចាត់ទុកថាជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ CSEA។ នេះប្រហែលជាពិបាកបន្តិចសម្រាប់ពួកគេក្នុងការពន្យល់ ឬបញ្ចេញមតិ ប៉ុន្តែសូមទទួលយកការឆ្លើយតបមួយចំនួនពីក្រុម។

២ បង្ហាញស្លាយដែលមាននិយមន័យនៃពាក្យ CSA និង CSE ទៅកាន់ក្រុម ជាការរំលឹកឡើងវិញ សូមប្រាកដថាក្រុមទទួលបានការយល់ដឹងច្បាស់លាស់។ អ្នកក៏អាចចែករំលែកច្បាប់ចម្លងនៃសន្លឹកកិច្ចការស្តីពីនិយមន័យ CSA និង CSE ដើម្បីឱ្យពួកគេរក្សាទុកសម្រាប់ជាឯកសារយោងបន្ថែម។ បញ្ជាក់ប្រាប់ក្រុមថា និយមន័យដែលបានចែករំលែកនៅទីនេះ ពិពណ៌នាអំពីសកម្មភាព និងឥរិយាបថជាច្រើន ប៉ុន្តែប្រហែលជាមិនដូចគ្នាទាំងស្រុងទៅនឹងការពិពណ៌នានៅក្នុងច្បាប់ប្រទេសកម្ពុជាទេ។ សកម្មភាពផ្លូវច្បាប់នឹងត្រូវចែករំលែក និងបញ្ជាក់នៅក្នុងវគ្គបន្ទាប់ទៀត។

៣ **ចែកករណីសិក្សាផ្សេងៗដល់ក្រុមនីមួយៗ៖** ត្រូវប្រាកដថាគំរូផ្សេងគ្នានៃឥរិយាបថ និងទង្វើគ្រប់ប្រភេទត្រូវបានចែកដល់ពួកគេ។ ឧទាហរណ៍៖

**ក្រុម ក៖** ករណីសិក្សាចំនួនពីរ (ក)- ជាប់ទាក់ទងនឹង CSAM (ខ)- ការលួងលោមលើប្រព័ន្ធអនឡាញក្នុងគោលបំណងទាក់ទងនឹងផ្លូវភេទ

**ក្រុម ខ៖** ករណីសិក្សាចំនួនពីរ (ក)- ការចែករំលែក CSAM (ខ)-ការផ្សាយបន្តផ្ទាល់

**ក្រុម គ៖** ករណីសិក្សាចំនួនពីរ (ក)- ការបៀតបៀនផ្លូវភេទ (ខ)- ការចែករំលែកខ្លឹមសារផ្លូវភេទដែលបង្កើតដោយខ្លួនឯង

៤ អញ្ជើញតំណាងក្រុមនីមួយៗ ដើម្បីផ្ដល់បទបង្ហាញដល់ក្រុមដទៃ បន្ទាប់ពីការងារក្រុមរបស់ពួកគេបានបញ្ចប់

៥ ស្នើទៅក្រុមថា វានឹងមានប្រយោជន៍សម្រាប់ពួកគេក្នុងការអានករណីសិក្សាទាំងអស់ជាមុននៃវគ្គបន្ទាប់ ប្រសិនបើអាចធ្វើទៅបាន

ក្រុមអាចមានសំណួរបន្ថែមទៀតអំពី OCSEA ដែលអ្នកអាចកត់ត្រាវាទុកក្នុងផ្ទាំងក្រដាសធំ ឬក្ដារខៀន ដើម្បីដោះស្រាយវានៅពេលក្រោយ។

៦ ចែកសៀវភៅជាមួយករណីសិក្សាទាំងអស់ដល់ក្រុម ហើយពន្យល់ប្រាប់ពួកគេថា សៀវភៅ និងករណីសិក្សាទាំងនេះ គឺដើម្បីឱ្យពួកគេប្រើប្រាស់ជាឯកសារយោងបន្ថែម ព្រោះយើងនឹងប្រើប្រាស់វានៅក្នុងវគ្គបន្ទាប់ ដើម្បីពិចារណាបញ្ហាផ្លូវច្បាប់ ការឆ្លើយតបរបស់មន្ត្រីនគរបាល និងការអនុវត្តបែបកុមារមេត្រី។

ស្នើទៅកាន់ក្រុមថា វានឹងមានប្រយោជន៍សម្រាប់ពួកគេក្នុងការដែលពួកគេអានករណីសិក្សាទាំងអស់ជាមុនសម្រាប់វគ្គបន្ទាប់ទៀត ប្រសិនបើពួកគេអាចធ្វើទៅបាន។

# ឧបសម្ព័ន្ធមេរៀនទី៤៖

## មាត្រាច្បាប់ និងសូចនាករពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

### ដំណើរការ និងជំហានសម្របសម្រួល

១ ស្វាគមន៍ក្រុម និងចែករំលែកអំពីលទ្ធផល នៃការរំពឹងទុកចេញពីវគ្គនេះ ដោយប្រើកំណត់ចំណាំនៅខាងលើ និងស្លាយ។ សូមពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីទទួលបានលទ្ធផលនៃការរំពឹងទុកនេះ។

២ រំលឹកក្រុមអំពីឥរិយាបថ និងសកម្មភាពចម្បងៗ ដែលត្រូវបានចាត់ទុកថាជា OCSEA (កាលពីវគ្គមុន) ហើយពន្យល់ប្រាប់ពួកគេថា ភារកិច្ចនៅក្នុងផ្នែកទីមួយនៃវគ្គនេះ គឺត្រូវកំណត់ឱ្យច្បាស់ថា តើច្បាប់ប្រទេសកម្ពុជាមួយណាដែលពាក់ព័ន្ធនឹងសកម្មភាព ឬបទឧក្រិដ្ឋនីមួយៗ ហើយធ្វើការកត់សម្គាល់អំពីគម្លាតផ្លូវច្បាប់មួយចំនួនដែលអាចកើតមាន។

៣ វាមិនទំនងទេ ដែលអ្នកចូលរួមនឹងដឹងរួចហើយថាទង្វើ ឬឥរិយាបថបែបណាខ្លះត្រូវបានចែងដោយច្បាប់ជាក់លាក់ណាមួយ ដូច្នេះសូមពន្យល់ប្រាប់ពួកគេថា ផ្នែកនៃវគ្គនេះនឹងចែករំលែកអំពីច្បាប់ដែលពាក់ព័ន្ធ ដោយប្រើស្លាយ និង/ឬសន្លឹកធនធានច្បាប់ដែលពាក់ព័ន្ធ។

ពួកគេនឹងអាចរក្សាឯកសារធនធានទុក ដើម្បីប្រើជាឯកសារយោង ព្រោះវាពណ៌នាអំពីច្បាប់ពាក់ព័ន្ធទាំងអស់យ៉ាងលម្អិត។ ពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើសន្លឹកធនធាននៅក្នុងវគ្គក្រោយៗទៀត ពេលដែលយើងអនុវត្តច្បាប់នៅក្នុងករណីសិក្សា។

### សង្ខេបមាតិកា និងខ្លឹមសារមេរៀននេះ៖

ក ការគាំទ្រផ្លូវច្បាប់

ខ មាត្រាច្បាប់ពាក់ព័ន្ធកម្ពុជាពាក់ព័ន្ធនឹ OCSEA)

- ការលួងលោមកុមារលើប្រព័ន្ធអនឡាញ
- ការផលិត ការកាន់កាប់ ឬការចែកចាយរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM)
- ការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ
- ការចែករំលែកខ្លឹមសារពាក់ព័ន្ធនឹងភេទ ឬរូបភាពអាសអាភាសរបស់ពួកគេ ដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ

- ការគំរាមកំហែងខាងផ្លូវភេទលើកុមារ
- ការបៀតបៀនផ្លូវភេទលើកុមារ
- ការប៉ះពាល់ ឬការបៀតបៀនផ្លូវភេទលើកុមារ

## គ កំណត់សម្គាល់ពិសេស

៤ ការប្រើប្រាស់ផ្ទាំងស្លាយ និងស្លាយដែលពាក់ព័ន្ធ៖ (ក)ទង្វើ ឬឥរិយាបថនីមួយៗ (ខ)ច្បាប់ពាក់ព័ន្ធបានចែងអ្វីខ្លះ និង(គ)គម្លាតដែនកំណត់ ឬវិធានការពិសេសណាមួយដែលទាក់ទងនឹងច្បាប់។

អ្នកក៏អាចផ្តល់យោបល់ (ក្នុងករណីដែលពាក់ព័ន្ធ) លើបញ្ហាជាក់លាក់ណាមួយដែលទាក់ទងនឹងតួនាទីរបស់មន្ត្រីនគរបាលផងដែរ។ ស្លាយនឹងរួមបញ្ចូលតារាង ដែលមើលទៅស្រដៀងនឹងសន្លឹកធនធាន (សូមមើលខាងក្រោម)។

៥ បន្ទាប់មកពន្យល់ប្រាប់ក្រុមថា ច្បាប់ជាតិដែលអ្នកទើបបានចែករំលែកជាមួយពួកគេ ចែងអំពីតួនាទីរបស់មន្ត្រីនគរបាលក្នុងការការពារកុមារប្រឆាំងនឹងបទឧក្រិដ្ឋ OCSEA ហើយចែងអំពីប្រភេទ បទឧក្រិដ្ឋណាខ្លះដែលមន្ត្រីនគរបាលអាចធ្វើការស៊ើបអង្កេត និងកាត់ទោសជនល្មើសបាន។

**កំណត់សម្គាល់ពិសេស៖** លើសពីនេះក៏មានផែនការ និងក្របខ័ណ្ឌថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដែលពាក់ព័ន្ធនឹង OCSEA ផងដែរ ដែលមានទាក់ទងនឹងភាគីដែលពាក់ព័ន្ធជាច្រើនទៀត។ ប្រអប់ខាងក្រោមនេះសង្ខេបក្របខ័ណ្ឌទាំងនេះ ហើយអ្នកក៏អាចមើលវានៅលើផ្ទាំងស្លាយផងដែរ ប្រសិនបើចាំបាច់។

៦ នៅថ្នាក់តំបន់ ផែនការសកម្មភាពក្នុងតំបន់អាស៊ាន ដើម្បីការពារកុមារទាំងអស់ពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ រៀបរាប់លម្អិតយ៉ាងច្បាស់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់រួមទាំងមន្ត្រីនគរបាល និងក្របខ័ណ្ឌការពារកុមារលើប្រព័ន្ធអនឡាញរបស់ ITU/ASEAN ផងដែរ។

៧ នៅកម្រិតថ្នាក់ជាតិ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ និងផែនការអនុវត្តយុទ្ធសាស្រ្តការការពារ កុមារកម្ពុជាឆ្នាំ២០២២-២០២៦ (កំពុងព្រាង) មានឯកសារយោងលើតួនាទីនៃការអនុវត្តច្បាប់។

៨ លើសពីនេះ សេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងសេចក្តីព្រាងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន រួមជាមួយនឹងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវឧបករណ៍នីតិប្បញ្ញត្តិជាតិសំខាន់ៗជាច្រើន។

ពេលដែលសេចក្តីព្រាងច្បាប់ទទួលបានសច្ចាប័ន និងដាក់ឱ្យមានដំណើរការ ឯកសារបេណ្តុះបណ្តាលនឹងត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍទាំងនេះ។

៩ មុនពេលបិទវគ្គនេះ ផ្តល់ឱកាសឱ្យអ្នកចូលរួមសួរសំណួរ និងស្វែងរកភាពច្បាស់លាស់អំពីច្បាប់ដែលពាក់ព័ន្ធ ហើយពន្យល់ប្រាប់ពួកគេថា ពួកគេនឹងមានឱកាសពង្រឹងការសិក្សារបស់ពួកគេទាក់ទងនឹងច្បាប់ ពេលយើងអនុវត្តន៍ការសិក្សារបស់ពួកគេនៅក្នុងករណីសិក្សានៅវគ្គក្រោយៗទៀត។

១០ ពន្យល់ប្រាប់ពួកគេថា មុនពេលយើងរៀនអំពីការអនុវត្តអ្វីដែលយើងបានរៀននៅក្នុងវគ្គបន្ទាប់ យើងនឹងផ្តោតលើការសិក្សាអំពី**សិទ្ធិកុមារក្នុងពិភពឌីជីថល** និងការរំលឹកអំពីគោលការណ៍សំខាន់ៗនៃ**គោលការណ៍ណែនាំការអនុវត្តដោយផ្តោតលើកុមារ** សម្រាប់ការគាំទ្រកុមារដែលរងផលប៉ះពាល់ដោយបទឧក្រិដ្ឋផ្លូវភេទ។

## សកម្មភាព

### បែងចែកជាក្រុមពិភាក្សាលើមាត្រាច្បាប់ពាក់ព័ន្ធទៅនឹងអំពើខាងក្រោម៖

- ការលួងលោមកុមារលើប្រព័ន្ធអនឡាញ
- ការផលិតការកាន់កាប់ ឬការចែកចាយរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM)
- ការផ្សាយបន្តផ្ទាល់ នៃការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ
- ការចែករំលែកខ្លឹមសារពាក់ព័ន្ធនឹងផ្លូវភេទ ឬរូបភាពអាសអាភាសរបស់ពួកគេ ដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ។
- ការគំរាមកំហែងខាងផ្លូវភេទលើកុមារ
- ការបៀតបៀនផ្លូវភេទលើកុមារ

### ការប៉ះពាល់ ឬការបៀតបៀនផ្លូវភេទលើកុមារមាត្រាច្បាប់ពាក់ព័ន្ធ OCSEA

| មាត្រាច្បាបពាក់ព័ន្ធ (ច្បាប់នៅកម្ពុជា) | ការពន្យល់បន្ថែម (ចន្លោះខ្វះខាត, ដែនកំណត់..... ) |
|---|---|
| | |

- បទបង្ហាញតាមក្រុមបន្ទាប់ពីកិច្ចពិភាក្សា

# ឧបសម្ព័ន្ធមេរៀនទី៥៖

## សិទ្ធិកុមារនៅក្នុងពិភពឌីជីថល

### ដំណើរការ និងជំហានសសម្របសម្រួល

**១** សូមស្វាគមន៍ក្រុម ហើយពន្យល់ប្រាប់ពួកគេថា យើងនឹងសិក្សាអំពីសិទ្ធិរបស់កុមារ និងរបៀបដែលអនុវត្តវានៅក្នុងពិភពឌីជីថល។

**សង្ខេបអំពីមាតិកា និងខ្លឹមសារសំខាន់ៗនៅក្នុងមេរៀនទី៥នេះ៖**

- **ក** ស្វែងយល់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ គឺជាកិច្ចព្រមព្រៀងដ៏សំខាន់របស់ ប្រទេសជាហត្ថលេខីដែលបានសន្យាការពារសិទ្ធិរបស់កុមារ
- **ខ** ស្វែងយល់អំពីសិទ្ធិកុមារក្នុងពិភពឌីជីថល
- **គ** សេចក្តីសំយោគអំពីសិទ្ធិកុមារសំខាន់ៗក្នុងពិភពឌីជីថល
- **ឃ** សេចក្តីសង្ខេបពីអនុសាសន៍ទូទៅរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ លេខ២៥ ស្តីពីសិទ្ធិកុមារក្នុងពិភពឌីជីថល (UNCRC General Comment No.25)

**២** ពន្យល់ប្រាប់ក្រុមថា អ្នកនឹងណែនាំពួកគេអំពីសិទ្ធិសំខាន់ៗមួយចំនួនរបស់កុមារ យោងទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ CRC ជាអនុសញ្ញាអង្គការសហប្រជាជាតិ ដែលត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដោយរាជរដ្ឋាភិបាលកម្ពុជា (UNCRC)។

**ការណ៍នេះមានន័យថា ភាគីពាក់ព័ន្ធទាំងអស់ក្នុងប្រទេស ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ត្រូវមានកាតព្វកិច្ចចាត់វិធានការអ្វីក៏ដោយ ដែលពួកគេអាចធ្វើបាន ដើម្បីការពារ លើកកម្ពស់ និងគាំទ្រសិទ្ធិរបស់កុមារ។ ភាគីទាំងនេះរាប់បញ្ចូលទាំងមន្ត្រីនគរបាល និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។**

**៣** ប្រើស្លាយដែលបានផ្តល់ជូន ដើម្បីចែករំលែកព័ត៌មានសំខាន់ៗទាក់ទងនឹង UNCRC (ព័ត៌មាននេះក៏ត្រូវបានរួមបញ្ចូលផងដែរ នៅក្នុងសន្លឹកធនធាន ដែលអ្នកនឹងចែករំលែកជាមួយអ្នកចូលរួម បន្ទាប់ពីវគ្គនេះ)។ ធ្វើបទបង្ហាញអំពីផ្នែកនីមួយៗនៃសន្លឹកកិច្ចការ/ស្លាយ ដោយពន្យល់ប្រាប់អំពីចំណុចនីមួយៗយ៉ាងច្បាស់ដល់អ្នកចូលរួម។ *(អ្នកអាចសុំឱ្យអ្នកចូលរួមជួយ ដោយការអានផ្នែកខ្លះនៃសន្លឹកកិច្ចការនេះ)*។

៤ ពេលដែលក្រុម/ដៃគូ បានធ្វើកំណត់ចំណាំលើមាត្រានីមួយៗរួចរាល់ហើយ អ្នកអាចអញ្ជើញពួកគេឱ្យចែករំលែកគំនិតរបស់ពួកគេនៅក្នុងក្រុមធំ ដោយបង្ហាញពីចំណុចសំខាន់ៗ និងឥរិយាបថដែលមន្ត្រីនគរបាលដែលមានទំនួលខុសត្រូវ និងសីលធម៌ ត្រូវអនុវត្តតាម។អ្នកចូលរួមផ្សេងទៀតក៏អាចបន្ថែមគំនិតមានប្រយោជន៍ផ្សេងទៀត និង/ឬសុំការបំភ្លឺបន្ថែមប្រសិនបើចាំបាច់។

៥ ក្នុងនាមជាអ្នកសម្របសម្រួលអ្នកប្រហែលជាត្រូវរៀបចំការណែនាំដ៏មានប្រយោជន៍មួយចំនួនដោយផ្អែកលើចំណេះដឹងរបស់អ្នក អំពីរបៀបដែលមន្ត្រីនគរបាលធ្វើប្រតិបត្តិការ និងការយល់ដឹងរបស់អ្នកអំពីសិទ្ធិ និងគោលការណ៍នៃការអនុវត្តតាមបែបកុមារមេត្រី(សូមមើលវគ្គបន្ទាប់)។ ដើម្បីជួយអ្នក យើងបានរៀបចំកំណត់ចំណាំបន្ថែមទៀតសម្រាប់អ្នកសម្របសម្រួល ដើម្បីជួយអ្នកណែនាំអ្នកអំពីដំណើរការ និងផ្តល់ជូនគំនិតមានប្រយោជន៍មួយចំនួន ប្រសិនបើអ្នកចូលរួមពិបាករកចម្លើយ។

៦ ទុកពេលវេលាឱ្យអ្នកចូលរួមសួរសំណួរ អំពីទិដ្ឋភាពណាមួយ នៃសិទ្ធិកុមារនៅក្នុងពិភពឌីជីថល។

៧ ពន្យល់ប្រាប់ក្រុមថា មន្ត្រីនគរបាលត្រូវគិតគូរអំពីផលប៉ះពាល់នៃសិទ្ធិកុមារទាំងអស់ លើគ្រប់ទិដ្ឋភាពនៃការងាររបស់ពួកគេ និងរបៀបដែលពួកគេអាចរួមបញ្ចូលការការពារសិទ្ធិកុមារទៅក្នុងសកម្មភាពការងារប្រចាំថ្ងៃរបស់ពួកគេ។

## សកម្មភាព

១ សួរទៅកាន់ក្រុមថា តើពួកគេធ្លាប់បានឮអំពី «សិទ្ធិកុមារ» ពីមុនមកទេ? ហើយថា តើពួកគេមានចំណេះដឹងអំពីច្បាប់ពាក់ព័ន្ធ ដែលបង្ហាញអំពីសិទ្ធិរបស់កុមារដែរឬទេ? ឬថា តើសិទ្ធិកុមារជាមូលដ្ឋានមានអ្វីខ្លះ? ទុកពេលវេលាពីរទៅបីនាទី ដើម្បីឱ្យក្រុមចែករំលែកគំនិតរបស់ពួកគេ។ អ្នកអាចសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ ឬក្តារខៀនក៏បាន ប្រសិនបើអ្នកចង់។

២ បន្ទាប់មក អ្នកក៏អាចចែក**សន្លឹកកិច្ចការសិទ្ធិកុមារនៅក្នុងពិភពឌីជីថល** ហើយសុំឱ្យអ្នកចូលរួមធ្វើការជាក្រុមតូចៗ ឬជាដៃគូ។

សុំឱ្យពួកគេអានតាមសន្លឹកកិច្ចការនោះ ហើយបន្ថែមកំណត់ចំណាំទៅក្នុងប្រអប់ដែលពាក់ព័ន្ធដែលមាននៅក្នុងអត្ថបទនោះ។ (ឧទាហរណ៍៖ **ក្រុមទី១** ធ្វើលើមាត្រា ២ និង ៣, **ក្រុមទី២** ធ្វើលើមាត្រា១២ និង១៣, **ក្រុមទី៣** ធ្វើការលើមាត្រា១៦ និង១៩ ហើយក្រុមបន្តបន្ទាប់ ទៀតធ្វើការលើមាត្រាដទៃទៀត រហូតទាល់តែអស់មាត្រាសំខាន់ៗដែលមានទាំងប៉ុន្មាន។

**ឧទាហរណ៍៖** យោងតាមមាត្រា១២ (សិទ្ធិឯកជនភាព) ក្រុមអាចធ្វើកំណត់ចំណាំបន្ថែមអំពីផលប៉ះពាល់នៃមាត្រានេះសម្រាប់មន្ត្រីនគរបាល នៅក្នុងប្រអប់អត្ថបទនៅលើសន្លឹកកិច្ចការនេះ។

ឧទាហរណ៍៖ យោងតាមមាត្រា១២ (សិទ្ធិឯកជនភាព)

ដើម្បីរក្សាសិទ្ធិរបស់កុមារ ការនេះមានន័យថា ក្នុងនាមយើងជាមន្ត្រីនគរបាល៖

- ក្នុងនាមជាមន្ត្រីនគរបាល យើងត្រូវតែប្រាកដថា ការសម្ភាសធ្វើឡើងជាលក្ខណៈឯកជន និងរក្សាការសម្ងាត់ មិនមែនធ្វើឡើងនៅក្នុងការិយាល័យដែលបើកចំហនោះទេ។
- កុមារដែលត្រូវបានរាប់បញ្ចូលនៅក្នុងការស៊ើបអង្កេត តាមរបៀបមួយដែលការពារអត្តសញ្ញាណរបស់ពួកគេពីសាធារណៈជន។ (ឧ. នៅពេលដែលហៅពួកគេឱ្យធ្វើសេចក្តីថ្លែង សូមធ្វើដូច្នេះតាមរបៀបមួយដែលនឹងមិនជូនដំណឹងដល់អ្នកជិតខាងទាំងមូល ដែលអាចធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំងនោះទេ)។
- ព័ត៌មាន និងភស្តុតាងមិនគួរណាត្រូវបានចែករំលែកដោយមន្ត្រីនគរបាលទៅកាន់មនុស្សផ្សេងទៀត ដែលមិនចាំបាច់ត្រូវដឹងទេ។
- ភស្តុតាងទាំងអស់គួរតែរក្សាសុវត្ថិភាព និងរក្សាការសម្ងាត់ជានិច្ច។ សេចក្តីថ្លែង និងភស្តុតាងរូបវន្ត គួរតែត្រូវបានរក្សាទុកដោយសុវត្ថិភាពនៅក្នុងទូដែលចាក់សោរជាប់ជានិច្ច។
- ភស្តុតាងឌីជីថល៖ មន្ត្រីនគរបាលមិនគួរទាញយកភស្តុតាងឌីជីថលចូលទៅក្នុងទូរស័ព្ទ និងឧបករណ៍ផ្ទាល់ខ្លួនរបស់ពួកគេឡើយ ហើយមិនគួរចែករំលែកភស្តុតាងឌីជីថល (រូបថត រូបភាព ឬវីដេអូ) ជាមួយមិត្តភក្តិ ឬក្រុមសង្គម ដោយប្រើវេទិកាឯកជន ដូចជា៖

Messenger, Telegram ឬ WhatsApp ទេ។

# ឧបសម្ព័ន្ធមេរៀនទី៦៖

## គោលការណ៍អនុវត្តបែបកុមារមេត្រី

### ដំណើរការ និងជំហានសម្របសម្រួល

**១ សង្ខេបអំពីមាតិកា និងខ្លឹមសារមេរៀននេះ៖**

- ក ការអនុវត្តបែបកុមារមេត្រី
- ខ តើពួកគេគិតថា ការអនុវត្តបែបកុមារមេត្រីអាចមានអត្ថប្រយោជន៍អ្វីខ្លះដល់កុមារ?
- គ បង្កើតបរិយាកាសបែបកុមារមេត្រី
- គ នីតិវិធីប្រតិបត្តិបែបកុមារមេត្រី

ណែនាំវគ្គនេះដោយប្រើកំណត់ចំណាំខាងលើ។ ពន្យល់ប្រាប់ក្រុមថា យើងនឹងរៀនអំពី ការអនុវត្តបែបកុមារមេត្រីដោយប្រើធនធានជាច្រើន។

អ្នកអាចចែករំលែកនិយមន័យដ៏សាមញ្ញមួយនៃ «ការអនុវត្តបែបកុមារមេត្រី»

*គោលគំនិតនៃ «ការអនុវត្តបែបកុមារមេត្រី» សម្រាប់មន្ត្រីនគរបាល មានន័យថាជាការអនុវត្តដែលធានាថា ពេលដែលកុមារមកទាក់ទងជាមួយមន្ត្រីនគរបាល និងប្រព័ន្ធយុត្តិធម៌ ពួកគេនឹងទទួលបានការប្រព្រឹត្តតាមរបៀបមួយដែលត្រឹមត្រូវ សមរម្យ និងមិនបង្កគ្រោះថ្នាក់ដល់ពួកគេទេ។*

ពន្យល់ប្រាប់ពួកគេថា ការណ៍នេះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងមានកាតព្វកិច្ចធ្វើសកម្មភាពតាមរបៀបមួយដែលលើកកម្ពស់ផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ ក្នុងគ្រប់ជំហាន ទាំងអស់នៃទំនាក់ទំនងរបស់យើង និងការធ្វើការជាមួយពួកគេ។ ការធ្វើបែបនេះមិនមែនជាជម្រើសទេ តែវាជាតម្រូវការ។

អ្នកក៏អាចសួរក្រុមផងដែរថា តើពួកគេគិតថា ការអនុវត្តបែបកុមារមេត្រីអាចមានអត្ថប្រយោជន៍អ្វីខ្លះដល់កុមារ?

ពួកគេប្រហែលជាមិនទាន់ប្រាកដក្នុងចិត្តក្នុងដំណាក់កាលនេះនៅឡើយទេ ប៉ុន្តែយើងនឹងពិនិត្យមើលសំណួរនេះឡើងវិញនៅចុងបញ្ចប់នៃវគ្គនេះ។

**២** **អ្នកចូលរួមមួយចំនួនបានចូលរួមវគ្គបណ្តុះបណ្តាល** អំពីការអនុវត្តបែបកុមារមេត្រីកាលពីពេលមុនរួចហើយ ប៉ុន្តែសម្រាប់អ្នកខ្លះ វាអាចជាប្រធានបទថ្មីស្រឡាងសម្រាប់ពួកគេ។ (អ្នកអាចសួរពួកគេថា តើមាននរណាម្នាក់នៅក្នុងក្រុមធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលអំពីប្រធានបទនេះកាលពីមុនទេ?)។

ពន្យល់ប្រាប់ក្រុមថា វគ្គនេះគឺជាការរំលឹកឡើងវិញសម្រាប់អ្នកខ្លះ ហើយអាចជាប្រធានបទថ្មីសម្រាប់អ្នកផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ វាតែងតែមានសារៈសំខាន់សម្រាប់យើងក្នុងការរំលឹកឡើងវិញអំពីការអនុវត្តបែបកុមារមេត្រី ពេលធ្វើការជាមួយកុមារដែលរងផលប៉ះពាល់ដោយសារការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។

**៣** **សូមពន្យល់ប្រាប់ពួកគេថា** ការអនុវត្តបែបកុមារមេត្រីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសិទ្ធិកុមារដែលយើងបានរៀននៅក្នុងវគ្គមុន។ ការអនុវត្តបែបកុមារមេត្រី បានលេចជារូបរាងឡើងក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ដើម្បីជួយមន្ត្រីនគរបាលជុំវិញពិភពលោក ប្រព្រឹត្តចំពោះកុមារប្រកបដោយភាពស្មើគ្នា និងភាពសមរម្យ ពេលធ្វើការជាមួយកុមារ ហើយមានសារៈសំខាន់ជាពិសេសពេលធ្វើការជាមួយកុមារទាក់ទងនឹងបទឧក្រិដ្ឋផ្លូវភេទ។

**៤** **ដោយប្រើស្លាយ** សូមពន្យល់ប្រាប់ពួកគេថា អ្នកនឹងណែនាំក្រុមអំពីគោលការណ៍សំខាន់ៗ ឬតម្រូវការមួយចំនួននៃការអនុវត្តបែបកុមារមេត្រី។ គោលការណ៍ៈ តម្រូវការសំខាន់ៗទាំងនេះរួមមានៈ

## គោលការណ៍ទូទៅៈ

- ការប្រើនីតិវិធីការអនុវត្តបែបកុមារមេត្រី-វិធីសាស្ត្រដោយផ្តោតលើកុមារជាសំខាន់
- ធ្វើការក្នុងភាពជាដៃគូដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាព
- មានវិធីសាស្ត្រដោយគិតអំពីយេនឌ័រ
- ការសម្ភាសៈ ផ្តល់អាទិភាពដល់សុខុមាលភាព និងឧត្តមប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ

## តម្រូវការចាំបាច់ៈ

- ការបង្កើតបរិយាកាសបែបកុមារមេត្រី
- មានវត្តមានរបស់អ្នកគាំទ្រ

- មានវត្តមានមន្ត្រីសង្គមកិច្ច
- កុមារដែលមានពិការភាព
- យេនឌ័ររបស់មន្ត្រីនគរបាលដែលធ្វើបទសម្ភាសន៍
- មិនឱ្យកុមារទំនាក់ទំនងជាមួយនឹងជនសង្ស័យ
- កែសម្រួលការប្រើប្រាស់ភាសាស្របទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារ

**៥** **មានវិធីសាស្ត្រពីរយ៉ាង**ដែលអ្នកសម្របសម្រួលអាចបង្រៀនប្រធានបទនេះ វាអាស្រ័យលើទំហំនៃក្រុម ពេលវេលាដែលមាន និងចំណាប់ចំណូលចិត្តរបស់អ្នកសម្របសម្រួល។

វិធីសាស្ត្រមួយគឺមានការចូលរួម (ពីអ្នកចូលរួមដោយការធ្វើការជាក្រុមតូចៗ)៖ សូមមើលចំណុច (ក) ខាងក្រោម។ វិធីសាស្ត្រមួយទៀតគឺជាវិធីសាស្ត្រ «រចនាបទនៃការបង្រៀន» ជាការបង្រៀនតាមប្រពៃណីដោយប្រើស្លាយ៖ សូមមើលចំណុច (ខ) ខាងក្រោម។ មានការពណ៌នាអំពីវិធីសាស្ត្រទាំងពីរនេះ។

អ្នកអាចសម្រេចចិត្តថា តើវិធីសាស្ត្រមួយណាដែលអ្នកនឹងប្រើ មុនពេលអ្នកសម្របសម្រួលវគ្គនេះ។

**៦** **មានឧទាហរណ៍ខាងក្រោម** ដែលបង្ហាញថាកិច្ចការដែលបានបញ្ចប់រួចរាល់ហើយ មើលទៅអាចមានលក្ខណៈយ៉ាងដូចម្ដេច?

## បង្កើតបរិយាកាសបែបកុមារមេត្រី៖

- ការសម្ភាសជាមួយកុមារគួរតែធ្វើឡើងក្នុងកន្លែងឯកជន ប្រកបដោយផាសុកភាព ដែលមិនមានការរំខាន (ឧទាហរណ៍៖ សំឡេងទូរស័ព្ទរោទ៍ មនុស្សដើរចេញចូល) និងមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តសម្រាប់កុមារ និងសមាជិកគ្រួសារ។
- ការសម្ភាសជាមួយកុមាររងគ្រោះ និងកុមារជាសាក្សី មិនគួរណាធ្វើឡើងនៅក្នុងការិយាល័យដ៏មមាញឹក ដែលមានមនុស្សអាចមើលឃើញកុមារ និងស្ដាប់ឮអ្វីដែលពួកគេនិយាយនោះទេ។
- ប្រដាប់ប្រដាក្មេងលេង និងហ្គេមអាចមានប្រយោជន៍ពេលកុមារកំពុងរង់ចាំមុនពេលសម្ភាសន៍ ប៉ុន្តែគួរតែត្រូវបានយកទុកវិញក្នុងអំឡុងពេលសម្ភាសន៍ ដើម្បីកុំឱ្យមានការរំខានដល់កុមារ។
- ប្រសិនបើមិនមានកន្លែងបែបកុមារមេត្រីនៅក្នុងប៉ុស្តិ៍នគរបាលសម្រាប់កុមារទេ សូមស្នើសុំប្រើប្រាស់កន្លែងដែលមានសុវត្ថិភាពសម្រាប់កុមាររបស់ភាគីដែលពាក់ព័ន្ធផ្សេងទៀត (ដូចជាកន្លែងរបស់បុគ្គលិកសង្គមកិច្ច ឬអង្គការមិនមែនរដ្ឋាភិបាល)។

- មន្ត្រីនគរបាលគួរជៀសវាងពាក់ឯកសណ្ឋានពេញលេញជានគរបាល ព្រោះជារឿយៗវាអាចធ្វើឱ្យកុមារមានអារម្មណ៍ភ័យខ្លាច (គួរស្លៀកសំលៀកបំពាក់ស៊ីវិល)។
- មន្ត្រីនគរបាលគួរតែអង្គុយក្បែរកុមារ ជាជាងអង្គុយនៅចំមុខកុមារ ដើម្បីជៀសវាងការប្រឈមមុខដាក់គាត់។

## អ្វីដែលគួរឱ្យចាប់អារម្មណ៍ និង/ឬថ្មី

- *យើងពិបាកស្វែងរកកន្លែងឯកជន ប៉ុន្តែឥឡូវនេះយើងយល់ថា វាអាចធ្វើឱ្យមនុស្សមានអារម្មណ៍សុវត្ថិភាព*
- *ការយល់ដឹងថាកន្លែងបែបកុមារមេត្រីអាចជួយឱ្យកុមារមានអារម្មណ៍ធូរស្រាលជាងមុន*
- *មិនបានដឹងថា ឯកសណ្ឋានអាចជាការរារាំងដល់កុមារទេ*
- *ប្រើកន្លែងនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាល ប្រសិនបើយើងមិនមានកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារ។ វាអាចមិនសូវស្រួលសម្រាប់យើង ប៉ុន្តែមានប្រយោជន៍សម្រាប់កុមារ។*

## អត្ថប្រយោជន៍សម្រាប់កុមារ៖

- *ប្រសិនបើពួកគេមានអារម្មណ៍ថាមានសុវត្ថិភាពជាងនេះ តើពួកគេអាចចែករំលែកបានច្រើនជាងនេះដែរឬទេ?*

## ដើម្បីធានាថាមានការអនុវត្តតាមគោលការណ៍ នៃការមានសុវត្ថិភាពសម្រាប់កុមារ ក្នុងនាមយើងជាមន្ត្រីនគរបាលយើងគួរ៖

- *យើងអាចស្នើសុំធនធានសម្រាប់បន្ទប់កុមារមេត្រី នៅការិយាល័យរបស់យើង ប្រសិនបើមិនមានទេ យើងអាចធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រើប្រាស់កន្លែងឯកជន ប្រសិនបើពួកគេមាន ដូចជានៅ A21 ក្នុងខេត្តសៀមរាបជាដើម។*

១ អនុញ្ញាតឱ្យក្រុមមានពេលវេលាគ្រប់គ្រាន់ដើម្បីពិភាក្សា និងបង្កើតគំនិត ហើយសរសេរវានៅលើផ្ទាំងក្រដាសធំ។ តាមក្បួនខ្នាតទូទៅ អនុញ្ញាតយ៉ាងហោចណាស់រយៈពេល **២០នាទី** ក្នុងមួយប្រធានបទសម្រាប់ក្រុមនីមួយៗ។

២ ពេលបានបញ្ចប់រួចរាល់ហើយ សូមអនុញ្ញាតឱ្យក្រុមបង្ហាញគំនិតរបស់ពួកគេទៅកាន់ក្រុមដទៃទៀត។ ក្នុងនាមជាអ្នកសម្របសម្រួល អ្នកអាចផ្ដល់យោបល់លើគំនិតដែលមានប្រយោជន៍ និងធ្វើកំណត់

ចំណាំអំពីអ្វីដែលអាចទាមទារឱ្យមានសកម្មភាពបន្ថែមទៀត ដែលចាំបាច់ត្រូវបញ្ចូលទៅក្នុងកិច្ចពិភាក្សា សកម្មភាព ឬរបាយការណ៍។

៣ នៅចុងបញ្ចប់នៃវគ្គ សុំឱ្យក្រុមផ្តល់មតិយោបល់ជាទូទៅអំពី «អត្ថប្រយោជន៍នៃការការអនុវត្តបែបកុមារមេត្រី»។

## សកម្មភាព

១ សួរក្រុមថាតើពួកគេធ្លាប់បានឮអំពី «ការអនុវត្តបែបកុមារមេត្រី» កាលពីមុនទេ (ជួនកាលគេហៅវាថា «ការអនុវត្តដោយផ្តោតលើកុមារ» «ការផ្តោតលើកុមារជាសំខាន់» ឬពាក្យស្រដៀងគ្នាផ្សេងទៀត)។

សួរពួកគេថាតើ «ការអនុវត្តបែបកុមារមេត្រី» មានន័យយ៉ាងដូចម្តេច?។ ស្តាប់ការឆ្លើយតបរបស់ពួកគេ ហើយសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ ឬក្តារខៀន ប្រសិនបើអ្នកចង់ធ្វើដូច្នេះ ដើម្បីឱ្យមនុស្សដទៃទៀតក្នុងក្រុមអាចមើលឃើញ។

២ **ការធ្វើការជាក្រុមតូចៗ - វិធីសាស្ត្រចូលរួម៖**

បែងចែកក្រុមធំជាក្រុមតូចៗ (ប្រហែលមានគ្នាពី ៤-៦នាក់) ហើយចែកប្រធានបទកុមារមេត្រី (ខុសៗគ្នា) ដែលអ្នកបានរៀបចំរួចហើយ ហើយក៏ចែកទំព័រ ឬផ្នែកនៃសន្លឹកកិច្ចការដែលទាក់ទងនឹងប្រធានបទមានសុវត្ថិភាពសម្រាប់កុមារទៅកាន់ក្រុមនីមួយៗផងដែរ។

បន្ទាប់មក អ្នកអាចសុំឱ្យក្រុមតូចៗទាំងនោះ ធ្វើការលើប្រធានបទផ្សេងៗគ្នា ដែលអ្នកបានផ្តល់ជូនពួកគេ ដោយឱ្យពួកគេធ្វើកំណត់ចំណាំអំពីអ្វីដែលមន្ត្រីនគរបាលគួរតែធ្វើនៅក្នុងការបំពេញការងាររបស់ពួកគេ។

បន្ទាប់ពីបានធ្វើចប់រួចរាល់ហើយ ពួកគេអាចចែករំលែកគំនិតរបស់ពួកគេនៅក្នុងបទបង្ហាញនៅក្នុងក្រុមធំ។

ក្រុមនីមួយៗអាចធ្វើបទបង្ហាញដោយសង្ខេបអំពីប្រធានបទមានសុវត្ថិភាពសម្រាប់កុមារ និងចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុមដទៃទៀត។

យើងសូមធ្វើការណែនាំឱ្យក្រុមទាំងអស់ធ្វើការលើប្រធានបទ «វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រ» ព្រមទាំងប្រធានបទយ៉ាងហោចណាស់ពីរផ្សេងទៀត។

**ឧទាហរណ៍៖ ក្រុម (ក) ធ្វើលើ៖** ការប្រើប្រាស់នីតិវិធីការអនុវត្តបែបកុមារមេត្រី - វិធីសាស្ត្រដោយផ្តោតលើកុមារជាសំខាន់

ការសម្ភាសៈ ផ្តល់អាទិភាពដល់សុខុមាលភាព និងឧត្តមប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារៈ

វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រៈ

ក្រុម (ខ) ធ្វើលើៈ

ធ្វើការក្នុងភាពជាដៃគូដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាពបង្កើតបរិយាកាសដែលមានសុវត្ថិភាពសម្រាប់កុមារៈ
វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រៈ

ក្រុម (គ) ធ្វើលើៈ

កែសម្រួលការប្រើភាសាស្របទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារៈ
វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រៈ
កុមារដែលមានពិការភាពៈ

ក្រុមអាចមានប្រធានបទបី ឬច្រើនដើម្បីពិភាក្សា អាស្រ័យលើពេលវេលាដែលមាន។ ល្អបំផុតប្រធានបទទាំងអស់ត្រូវបានចែករំលែកស្មើគ្នាក្នុងចំណោមក្រុមអ្នកចូលរួមទាំងអស់។

១ ក្រុមនីមួយៗគួរតែទទួលបានផ្ទាំងក្រដាសធំ និងប៊ិចពណ៌គូសចំណាំ ហើយត្រូវការការណែនាំយ៉ាងច្បាស់លាស់។ ពួកគេនឹងត្រូវបានរំពឹងថា ត្រូវធ្វើការជាក្រុមជាមួយគ្នាយ៉ាងសកម្ម ដោយបំពេញកិច្ចការមួយចំនួនដូចខាងក្រោមៈ

ក- អានកំណត់ចំណាំសម្រាប់ប្រធានបទនីមួយៗដែលមាននៅលើសន្លឹកកិច្ចការ

ខ- ធ្វើការឆ្លុះបញ្ចាំង និងពិភាក្សាអំពីកំណត់ចំណាំៈ កត់សម្គាល់អ្វីដែល**គួរឱ្យចាប់អារម្មណ៍ និង/ឬថ្មីសម្រាប់ពួកគេ**។ (ពួកគេក៏អាចកត់សម្គាល់សំណួរជាក់លាក់ណាមួយ ដែលពួកគេមានទាក់ទងនឹងប្រធានបទនេះផងដែរ ប្រសិនបើពួកគេត្រូវការបញ្ជាក់បន្ថែម)

គ- គូសចំណាំអ្វីៗដែលពួកគេគិតថា មាន**អត្ថប្រយោជន៍**ទាក់ទងនឹងគោលការណ៍ និងការណែនាំអំពីប្រធានបទនេះ

ឃ- កត់សម្គាល់**អ្វីខ្លះដែលអ្នកត្រូវធ្វើដើម្បីអនុវត្តតាមតម្រូវការទាំងនេះ?**

# ឧបសម្ព័ន្ធមេរៀនទី៧៖

## ការស៊ើបអង្កេតបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

### ដំណើរការ និងជំហានសម្របសម្រួល

**១** ស្វាគមន៍ការចូលមកដល់មេរៀនថ្មីនេះ ធ្វើសេចក្តីសង្ខេប មាតិកា និងខ្លឹមសារ៖

**ក** ជំហាននៃការស៊ើបអង្កេតករណីនៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ(CSEA) និងអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

- ការទទួលពាក្យបណ្តឹង
- ដំណាក់កាលស៊ើបអង្កេតបឋម
- ដំណាក់កាលស្តាប់ចម្លើយ/ប្រមូលភស្តុតាង
- ការរៀបចំរបាយការណ៍
- ដំណាក់កាលព្រះរាជអាជ្ញា
- ដំណាក់កាលចៅក្រមស៊ើបសួរ

**ខ** បច្ចេកទេសស៊ើបអង្កេតបទល្មើសផ្លូវភេទតាមអ៊ីនធឺណិត

- ការប្រមូលភស្តុតាងឌីជីថល
- ធ្វើការស៊ើបអង្កេតតាមអនឡាញ
- បច្ចេកទេសស៊ើបអង្កេតតាមអនឡាញកម្រិតខ្ពស់

**គ** គោលការណ៍រួមក្នុងការស៊ើបអង្កេតតាមបែបកុមារមេត្រី

- កុមាររងគ្រោះគួរត្រូវបានកំណត់អត្តសញ្ញាណ
- ព័ត៌មានត្រូវត្រួតពិនិត្យឡើងវិញ និងត្រូវរក្សាជាការសម្ងាត់
- បង្ការកុំឱ្យមានទំនាក់ទំនងគ្នារវាងកុមាររងគ្រោះ និងជនសង្ស័យ

### ឃ គោលការណ៍នៃការសម្ភាសតាមបែបកុមារមេត្រី

- បង្កើតបរិយាកាសបែបកុមារមេត្រី
- ការរៀបចំរបស់អ្នកសម្ភាសន៍
- ការរៀបចំអ្នកចូលរួមផ្សេងទៀត

សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផល ដែលបានគ្រោងទុកនៃវគ្គបណ្តុះបណ្តាល ដោយប្រើកំណត់សម្គាល់ និងតាមស្លាយខាងលើ។ សូមពន្យល់ថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

### ២ ប្រើស្លាយដើម្បីបង្ហាញដោយសង្ខេបអំពីដំណាក់កាលនៃការស៊ើបអង្កេត

សូមពន្យល់ថា ដំណាក់កាលនៃការស៊ើបអង្កេតទាំងនេះ អាចមានភាពខុសប្លែកគ្នាបន្តិចបន្តួចទៅនឹងគំនិតដែលពួកគេបានលើកឡើង ប៉ុន្តែទាំងនេះគឺជាដំណាក់កាលដែលយើងនឹងប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាលផ្សេងទៀត ដើម្បីជួយយើងឱ្យកាន់តែយល់ច្បាស់ពីតួនាទីរបស់មន្ត្រីនគរបាល និងសកម្មភាពដែលយើងគួរធ្វើតាមដំណាក់កាលនីមួយៗ ក្នុងនាមជាមន្ត្រីនគរបាល។ ដំណាក់កាលនីមួយៗត្រូវបានសង្ខេបនៅក្នុងប្រអប់ខាងក្រោម៖

១- ទទួលពាក្យបណ្តឹង

២- ដំណាក់កាលស៊ើបអង្កេតបឋម

៣- ដំណាក់កាលស្តាប់ចម្លើយ/ប្រមូលភស្តុតាង

៤- សរសេររបាយការណ៍សំយោគ និងដាក់របាយការណ៍ទៅតុលាការ

៥- ដំណាក់កាលព្រះរាជអាជ្ញា

៦- ដំណាក់កាលចៅក្រមស៊ើបសួរ

៧- ការជំនុំជម្រះក្តី

៣ ពន្យល់អ្នកចូលរួមថា យើងនឹងធ្វើការជាក្រុមតូចដើម្បីពិភាក្សា និងកំណត់កិច្ចការជាក់លាក់នៅក្នុងការស៊ើបអង្កេតដែលមន្ត្រីនគរបាលទទួលខុសត្រូវ ទាក់ទងនឹង OCSEA ។ ពន្យល់ថា មានភាពខុសប្លែកគ្នាបន្តិចបន្តួចនៅក្នុងវគ្គនេះ យើងនឹងផ្តោតលើ OCSEA ទាក់ទងនឹង ការកេងប្រវញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។

រំលឹកអ្នកចូលរួមថា នៅក្នុងបទឧក្រិដ្ឋ OCSEA ជាច្រើន (មិនមែនទាំងអស់) អាចត្រូវបានប្រព្រឹត្ត ទាំង**លើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ**។ ដូច្នេះ នៅពេលគិតអំពីកិច្ចការនេះ ពួកគេត្រូវចងចាំអំពីចំណុចនេះ ហើយពិចារណាពីរបៀបដែលករណីនេះអាចមានឥទ្ធិពលលើតួនាទី និងកិច្ចការដែលពួកគេធ្វើ។

៤ បំបែកអ្នកចូលរួមទៅជា ក្រុមតូចៗ (អាស្រ័យលើចំនួនអ្នកចូលរួម ដោយក្នុងមួយក្រុមអាចមានចំនួន ៥, ៦ ឬ ៧នាក់)។ ដាក់ក្រុមនីមួយៗនៅតាមក្រដាសផ្ទាំងធំ និងពន្យល់ទៅកាន់ក្រុមថា ពួកគេត្រូវធ្វើការជាក្រុមយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

នៅពេលសកម្មភាពចាប់ផ្តើម ពួកគេនឹងមានពេលខ្លី ដើម្បីពិភាក្សាយ៉ាងឆាប់រហ័សអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលចំពោះកិច្ចការនីមួយៗ ហើយសរសេរគំនិតរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ (សូមមើលឧទាហរណ៍ខាងក្រោម)។ ពន្យល់អ្នកចូលរួមថា នៅពេលចាប់ផ្តើមសកម្មភាព ពួកគេគួរតែសរសេរអំពីគំនិតរបស់ខ្លួនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន នៅលើក្រដាសផ្ទាំងធំតាមពេលវេលាដែលពួកគេមាន ។

នៅពេលអ្នកផ្លុំកញ្ចែ ឬចុចកណ្តឹង ក្រុមត្រូវប្តូរទីតាំងភ្លាមៗ ទៅកាន់ក្រដាសផ្ទាំងធំបន្ទាប់ មកបន្តរហូតដល់ក្រុមទាំងអស់បានបញ្ចប់កិច្ចការនៅលើក្រដាសផ្ទាំងធំនីមួយៗ។

ពន្យល់អ្នកចូលរួមថា ពួកគេមិនត្រូវចម្លងមតិយោបល់ពីក្រុមផ្សេងទៀតឡើយ ប៉ុន្តែត្រូវបន្ថែមកិច្ចការថ្មី ដោយផ្អែកលើគំនិតរបស់ពួកគេ។

៥ បន្ទាប់មក ឆ្លៀតពេលដើរជុំវិញក្រដាសផ្ទាំងធំនីមួយៗជាមួយក្រុមធំ ដើម្បីមើលគំនិតរបស់ពួកគេ។

ប្រហែលជាមិនចាំបាច់ផ្តល់មតិយោបល់ច្រើនលើខ្លឹមសារនៅពេលនេះទេ លុះត្រាតែមានតម្រូវការក្នុងការបញ្ជាក់ខ្លឹមសារជាក់លាក់ សួរសំណួរ និង/ឬធ្វើការកត់សម្គាល់ដែលចាំបាច់ដើម្បីពង្រឹងការរៀនសូត្រ។

រំលឹកក្រុមថា បទឧក្រិដ្ឋ OCSEA អាចត្រូវបានប្រព្រឹត្ត**លើប្រព័ន្ធអនឡាញទាំងស្រុង** ហើយកិច្ចការសម្រាប់មន្ត្រីនគរបាលអាចប្រែប្រួល យោងទៅតាមករណីនីមួយៗ។ ក្នុងករណីដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត**ក្រៅប្រព័ន្ធអនឡាញ និងលើប្រព័ន្ធអនឡាញ** អាចមានកិច្ចការស្រដៀងគ្នា (ចំណាយពេលប្រហែល ៣០នាទីសម្រាប់ការពន្យល់ពីចំណុចនេះ)។

នៅពេលដែលអ្នកបានបញ្ចប់កិច្ចការនេះ សូមថ្លែងអំណរគុណដល់អ្នកចូលរួមសម្រាប់គំនិតរបស់ពួកគេ ហើយសម្រាករយៈពេលខ្លី។

៦ នៅពេលអ្នកត្រលប់ចូលវិញ សូមប្រើស្លាយដែលអ្នកបានរៀបចំ ដើម្បីចែករំលែកគំនិតទាក់ទងនឹងកិច្ចកាសម្រាប់ដំណាក់កាលនីមួយៗ។ ស្លាយផ្សេងទៀតក៏នឹងត្រូវធ្វើដូចគ្នា ប៉ុន្តែអាចមានកិច្ចការបន្ថែមដែលត្រូវបញ្ជាក់។

៧ នៅពេលអ្នកបង្ហាញស្លាយនីមួយៗ សូមរំលឹកក្រុមអំពីមេរៀន ដែលយើងបានរៀនរួចហើយទាក់ទងនឹងការលើកកម្ពស់**សិទ្ធិកុមារ** និងធានា**ការអនុវត្តនីតិវិធីបែបកុមារមេត្រី**។ អ្នកក៏អាចឱ្យអ្នកចូលរួមបញ្ចេញមតិអំពីរបៀបធ្វើកិច្ចការទាំងនោះនៅលើស្លាយនីមួយៗ។ (ការណ៍នេះនឹងពង្រឹងការរៀនសូត្ររបស់ពួកគេ ហើយរំលឹកពួកគេថា សិទ្ធិកុមារ និងការអនុវត្តបែបកុមារមេត្រី គឺជាលក្ខខណ្ឌតម្រូវចាំបាច់ក្នុងតួនាទីជាមន្ត្រីនគរបាល)។

៨ នៅពេលដែលអ្នកបានបញ្ចប់ការបង្ហាញស្លាយ សូមចែកឯកសារសង្ខេបអំពីជំហាននៃការស៊ើបអង្កេតទៅឱ្យអ្នកចូលរួម និងប្រាប់ឱ្យពួកគេរក្សាទុកសម្រាប់ជាឯកសារយោងបន្ថែម។

## សកម្មភាព

១ សួរអ្នកចូលរួមថា តើពួកគេអាចបញ្ចេញមតិអំពី**ជំហាន** (ឬ**ដំណាក់កាល**) **ផ្សេងៗ** នៃការស៊ើបអង្កេត តាំងពីពេលចាប់ផ្តើមរហូតដល់ចប់បានដែរឬទេ?

ទុកពេលវេលាខ្លះសម្រាប់ការចែករំលែក ហើយប្រសិនបើចាំបាច់ សរសេរគំនិតមួយចំនួនរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ/ក្តារខៀន ដោយសង្ឃឹមថា ពួកគេនឹងចងចាំព័ត៌មានសំខាន់ៗនេះពីការបណ្តុះបណ្តាលមូលដ្ឋានរបស់ពួកគេ។

២ អាស្រ័យលើចំនួនអ្នកចូលរួម សូមបំបែកពួកគេទៅជាក្រុមតូចៗ ហើយផ្តល់ឱ្យពួកគេនូវច្បាប់ចម្លងនៃសន្លឹកកិច្ច ការអំពីជំហាននៃការស៊ើបអង្កេត។

សូមពន្យល់ថា ពួកគេអាចប្រើសន្លឹកកិច្ចការនេះជាការរំលឹកអំពីជំហានសំខាន់ៗ និងបញ្ចូលប្រអប់ទទេ (Text box) សម្រាប់ពួកគេដើម្បីសរសេរពីគំនិតរបស់ពួកគេ ប្រសិនបើពួកគេចង់ធ្វើដូច្នេះ។

សូមដាក់ក្រដាសផ្ទាំងធំទទេចំនួននៅជុំវិញបន្ទប់ (នៅលើជញ្ជាំង ឬនៅលើតុ) ដោយសរសេរដំណាក់កាលស៊ើបអង្កេតនីមួយៗនៅផ្នែកខាងលើ។ ដូច្នេះ អ្នកគួរមានក្រដាសផ្ទាំងធំ (ទទេ) សម្រាប់ដំណាក់កាលនីមួយៗ។ (សូមមើលខាងក្រោម)

| ទទួលពាក្យបណ្តឹង | ដំណាក់កាលស៊ើបអង្កេតបឋម | ដំណាក់កាលស្តាប់ចម្លើយ/ប្រមូលភស្តុតាង | សរសេរនិងធ្វើរបាយការណ៍សំយោគ | ដំណាក់កាលព្រះរាជអាជ្ញា | ដំណាក់កាលចៅក្រមស៊ើបសួរ | ការជំនុំជម្រះក្តី |
|---|---|---|---|---|---|---|

៣ បំបែកអ្នកចូលរួមទៅជាក្រុមតូចៗ (អាស្រ័យលើចំនួនអ្នកចូលរួម ដោយក្នុងមួយក្រុមអាចមានចំនួន ៥, ៦ ឬ ៧នាក់)។ ដាក់ក្រុមនីមួយៗនៅតាមក្រដាសផ្ទាំងធំ និងពន្យល់ទៅកាន់ក្រុមថាពួកគេត្រូវធ្វើការជាក្រុមយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

៤ ចាប់ផ្តើមធ្វើកិច្ចការ ហើយត្រូវប្រាកដថា អ្នកឱ្យក្រុមនីមួយៗផ្លាស់ប្តូរទីតាំងបន្ទាប់ពីរយៈពេលប្រហែល ៣ **នាទី**រហូតដល់ក្រុមទាំងអស់បានបញ្ចប់កិច្ចការ។ លំហាត់នេះនឹងសាកល្បងសមត្ថភាពរបស់ពួកគេក្នុងការធ្វើការងារជាក្រុមយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពចំណេះដឹងអំពីកិច្ចការរបស់ពួកគេក្នុងដំណាក់កាលនីមួយៗនៃការស៊ើបអង្កេត ហើយក៏នឹងមានភាពរីករាយផងដែរ។ ការធ្វើការយ៉ាងឆាប់រហ័សនឹងបង្កើនសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហា។

# ឧបសម្ព័ន្ធមេរៀនទី៨៖

## វិធីសាស្ត្រឆ្លើយតបការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

### ដំណើរការ និងជំហានសម្របសម្រួល

❶ ណែនាំដោយសង្ខេបមេរៀនអំពីខ្លឹមសារមេរៀន និងមាតិកា៖

- របកគំហើញសំខាន់ៗនៃការសិក្សាស្រាវជ្រាវនៅកម្ពុជាទាក់ទងនឹងបទពិសោធន៍របស់កុមារ ក្នុងការស្វែងរកជំនួយ និងការសហការជាមួយមន្ត្រីនគរបាលទាក់ទងនឹង OCSEA
- សេចក្តីថ្លែងការណ៍បទពិសោធន៍របស់កុមារ និងគ្រួសារក្នុងការស្វែករក និងទទួលបានជំនួយពីមន្ត្រីនគរបាល
- ការឆ្លើយតបបែបវិជ្ជមាន និងមានប្រយោជន៍
- តើកុមារត្រូវការអ្វីខ្លះ ពីមន្ត្រីនគរបាល?
- អ្វីដែលកុមារត្រូវការពីមន្ត្រីនគរបាល

សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផលដែលបានគ្រោងទុកពីវគ្គនេះ ដោយប្រើកំណត់សម្គាល់ និងស្លាយខាងលើ។ ពន្យល់ថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

❷ ពន្យល់ថា មន្ត្រីនគរបាលកំពុងបង្កើនការរំពឹងទុកក្នុងការឆ្លើយតបទៅនឹងតម្រូវការ របស់កុមារប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈ។ នេះមានន័យថា មន្ត្រីនគរបាលត្រូវបានរំពឹងថានឹងឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ស្របតាមការណែនាំបែបកុមារមេត្រី និងដោយការគោរពសិទ្ធិកុមារគ្រប់ពេលវេលា។

❸ បញ្ជាក់ដល់ក្រុមថា ការធ្វើកិច្ចការទាំងនេះមិនមែនជាជម្រើសទេ វាជាការរំពឹងទុកអំពីតួនាទីរបស់ពួកគេក្នុងនាមជាមន្ត្រីនគរបាល។

### សង្ឃឹមថាអ្នកចូលរួមនឹងចងចាំ ប្រសិនបើអ្នកចូលរួមមិនចងចាំទេ សូមរំលឹកពួកគេថា៖

កុមារ និងយុវជនដែលមានអាយុ និងដំណាក់កាលលូតលាស់ខុសគ្នា ដែលត្រូវបានកេងប្រវ័ញ្ច និងរំលោភបំពាន ពិបាកនឹងជឿទុកចិត្តលើនរណាម្នាក់ រួមទាំងមន្ត្រីនគរបាលផងដែរ។ ប្រសិនបើយើងអនុវត្តវិធីសាស្ត្របែបកុមារមេត្រី ហើយគោរព និងលើកកម្ពស់សិទ្ធិរបស់ពួកគេផងដែរ៖

- នេះអាចជួយយើងកសាងទំនុកចិត្តជាមួយកុមាររងគ្រោះ សាក្សី និងក្រុមគ្រួសាររបស់ពួកគេ។ ប្រសិនបើ យើងទទួលបានការជឿជាក់កាន់តែខ្លាំង កុមាររងគ្រោះនឹងមានអារម្មណ៍ថា កាន់តែមានសុវត្ថិភាព។ នេះនឹងនាំឱ្យមានកិច្ចសហការកាន់តែល្អប្រសើរឡើង ហើយការផ្ដល់របាយការណ៍ និងភស្តុតាងក៏កាន់តែប្រសើរផងដែរ។ ភស្តុតាងកាន់តែប្រសើរនាំឱ្យមានការស៊ើបអង្កេតកាន់តែមានប្រសិទ្ធភាពខ្ពស់ មានភាពរលូន និងទទួលបានជោគជ័យ។

៤ ពន្យល់ថា យើងមានសំណាងដែលនៅឆ្នាំ២០២២ ការស្រាវជ្រាវត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជាដែលផ្ដោតលើ OCSEA ហើយផ្នែកខ្លះនៃការស្រាវជ្រាវរួមមានការសម្ភាសជាមួយមន្ត្រីនគរបាលច្បាប់ កុមារ និងគ្រួសារដែលរងគ្រោះដោយ OCSEA។

ការស្រាវជ្រាវនេះបង្ហាញយ៉ាងច្បាស់ អំពីបទពិសោធន៍របស់កុមារក្នុងអំឡុងពេល និងបន្ទាប់ពី OCSEA និងបទពិសោធន៍របស់ពួកគេជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ចាប់ ពីការរាយការណ៍ ឬការលាតត្រដាងព័ត៌មាន រហូតដល់លទ្ធផលចុងក្រោយនៃករណី។

ការណ៍នេះមានប្រយោជន៍ណាស់ ដោយសារវាជួយយើងឱ្យដឹងពីអ្វីដែលជា**ការអនុវត្តល្អ និងមានប្រយោជន៍**ទាក់ទងនឹងការធ្វើការជាមួយកុមារ ដូច្នេះ យើងអាចកសាងសមត្ថភាពរបស់យើង ធ្វើអ្វីដែលមានប្រយោជន៍កាន់តែច្រើន និងកែលម្អអ្វីដែលយើងធ្វើ។

យើងក៏អាចដឹងថា អ្វីជា**ការអនុវត្តមិនល្អ និងមិនមានប្រយោជន៍**នៅពេលធ្វើការជាមួយកុមារដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ហើយរៀនចៀសវាងការធ្វើរឿងទាំងនោះ។

៥ ពន្យល់ថា អ្នកនឹងបំបែកក្រុមធំទៅជាក្រុមតូចៗ (ឬជាគូអាស្រ័យលើចំនួនអ្នកចូលរួម)។ បន្ទាប់មក ចែកកាតមួយចំនួន ដែលមានរបាយការណ៍ពីកុមារ អំពីបទពិសោធន៍របស់ពួកគេក្នុងការជួបជាមួយមន្ត្រីនគរបាល។ ប្រើ**កាតឆ្លើយតបដែលមានប្រយោជន៍**ជាមុនសិន។ មានកាតចំនួន ១២ (អ្នកអាចបង្កើតកាតបន្ថែមប្រសិន បើអ្នកមានបំណងបង្កើត)។ ដូច្នេះ អ្នកអាចបង្កើតក្រុម និងផ្ដល់ឱ្យក្រុមនីមួយៗ នូវកាតចំនួន ២, ៣ ឬ ៤ សន្លឹក។

៦ ពេលដែលអ្នកបានបញ្ចប់កិច្ចការនេះ សូមអរគុណដល់ក្រុម ហើយសង្ខេបចំណុចសិក្សាដែលមានប្រយោជន៍បំផុតមួយចំនួន។

៧ បន្ទាប់មក ពន្យល់ថា យើងក៏មានកាតមួយចំនួនទៀត ដើម្បីចែកដល់ក្រុម ប៉ុន្តែពេលនេះ របាយការណ៍ និងសារ គឺមកពីកុមារ និងឪពុកម្ដាយ ដោយគូសបញ្ជាក់ពីបទពិសោធន៍ដែលមិនសូវមានប្រយោជន៍ដែលពួកគេមាន។

អ្នកចូលរួមមួយចំនួនប្រហែលជាមិនចូលចិត្តគំនិតនេះទេ ឬប្រហែលជាមានការជំទាស់បន្តិចបន្តួច? នេះគឺជាការរំពឹងទុក។

សូមពន្យល់ថា យើងអាចរៀនបានច្រើនពីអ្វីដែលដំណើរការ។ ប៉ុន្តែយើងក៏អាចរៀនបានច្រើន អំពីអ្វីដែលយើងអាចធ្វើបានកាន់តែប្រសើរ ឬផ្លាស់ប្តូរ និងកែលម្អពីអ្វីដែល មានដំណើរការមិនល្អ ផងដែរ។

ក្នុងនាមជាអ្នកសម្របសម្រួល កិច្ចការរបស់អ្នកគឺដើម្បីជួយពួកគេកុំឱ្យដោះសារចំពោះស្ថានភាព ដែលមិនមានប្រយោជន៍ទាំងនោះ ហើយគូសបញ្ជាក់ពីដំណោះស្រាយវិជ្ជមាន ការឆ្លើយតប ដោយសមស្របបែបកុមារមេត្រី និងអត្ថប្រយោជន៍ពីការអនុវត្តតាមដំណោះស្រាយ និងការ ឆ្លើយតបទាំងនោះសម្រាប់កុមារ និងការស៊ើបអង្កេត។

៨ នៅពេលដែលអ្នកបានបញ្ចប់កិច្ចការនេះ សូមអរគុណដល់ក្រុម ហើយសង្ខេបចំណុចសិក្សាដែល មានប្រយោជន៍បំផុតមួយចំនួនពីការពិភាក្សា។

### សូមរំលឹកក្រុមថា៖

- ជារឿយៗ កុមារក្រៀមក្រំ និងតក់ស្លុតយ៉ាងខ្លាំង ដោយសារបទពិសោធន៍នៃការទទួលរងការ កេងប្រវ័ញ្ច និងរំលោភបំពាន។
- ជារឿយៗ ពួកគេមានការភ័យខ្លាចយ៉ាងខ្លាំង ក្នុងការប្រាប់ពីរឿងរ៉ាវរបស់ពួកគេ ហើយកុមារ ជាច្រើនរាយការណ៍ថា មានអារម្មណ៍ភ័យខ្លាច និងការគំរាមកំហែងពីមន្ត្រីនគរបាល និង ការរំពឹងទុកដែលពួកគេត្រូវប្រាប់ពីបទពិសោធន៍ដែលគួរឱ្យខ្មាសអៀនរបស់ពួកគេ។ ដូចនេះ រាល់សកម្មភាព ឬឥរិយាបថរបស់មន្ត្រីនគរបាលចំពោះកុមារ អាចធ្វើឱ្យមានភាពខុសគ្នាយ៉ាង សំខាន់ចំពោះលទ្ធផលនៃករណី។ ប៉ុន្តែវាមានសារៈសំខាន់ខ្លាំងណាស់ចំពោះសុខភាព និង សុខុមាលភាពរបស់កុមារគ្រប់រូប។
- វាជាកាតព្វកិច្ចរបស់អ្នកក្នុងនាមជាមន្ត្រីនគរបាល ដែលត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីលើកកម្ពស់សិទ្ធិរបស់ពួកគេ និងអនុវត្តន៍តាមបែបកុមារមេត្រីគ្រប់ពេលវេលា។ វាមិនមែន ជាជម្រើសទេ គឺចាំបាច់ត្រូវធ្វើបែបនេះ។

៩ សម្រាករយៈពេលខ្លី ដើម្បីឱ្យក្រុមត្រៀមខ្លួនសម្រាប់ផ្នែកចុងក្រោយនៃវគ្គ។

១០ បន្ទាប់ពីសម្រាក សូមពន្យល់ថា អ្នកនឹងចែករំលែកករណីសិក្សាពីជីវិតពិត ដែលមាននៅក្នុង របាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅប្រទេសកម្ពុជា។ ករណីសិក្សានេះផ្អែកលើបទពិសោធន៍របស់

កុមារី ជាជនជាតិខ្មែរម្នាក់ ដែលជាជនរងគ្រោះពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។

កុមារី និងឪពុករបស់នាងជាទូទៅមានបទពិសោធន៍ល្អជាមួយនគរបាល និងមនុស្សផ្សេងទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ពួកគេចង់ចែករំលែកបទពិសោធន៍របស់ពួកគេ ដើម្បីឱ្យយើងទាំងអស់គ្នាបានរៀនពីបទពិសោធន៍ទាំងនោះ...។

ករណីនេះនឹងជួយអ្នកចូលរួមក្នុងការកំណត់**ការឆ្លើយតបជាវិជ្ជមាន និងមានប្រយោជន៍របស់**មន្ត្រីនគរបាល និង**បង្ហាញពីអ្វីដែលជា "ការអនុវត្តល្អ" នៅក្នុងជីវិតជាក់ស្តែង**។

វាបង្ហាញពីរបៀបដែលការលើកកម្ពស់សិទ្ធិកុមារ និងការអនុវត្តតាមបែបកុមារមេត្រីអាចផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នាដែលពាក់ព័ន្ធ និងនាំឱ្យទទួលបានលទ្ធផលជោគជ័យ។

១១ ក្នុងនាមជាអ្នកសម្របសម្រួល អ្នកមានជម្រើសចំនួន ៣ អំពីរបៀបដែលអ្នកចែករំលែកករណីសិក្សានេះ។

ក អ្នកអាចចែកច្បាប់ចម្លងនៃករណីសិក្សានីមួយៗ ឱ្យអ្នកចូលរួមអានដោយស្ងៀមស្ងាត់ដោយខ្លួនឯង ហើយបន្ទាប់មកប្រមូលពួកគេឱ្យមកជុំគ្នាដើម្បីពិភាក្សា និងឆ្លើយសំណួរ៖

*"តើអ្វីជាចំណុចសំខាន់ក្នុងករណីសិក្សានេះ<br>ដែលអ្នកអាច និងគួរអនុវត្តក្នុងការងាររបស់អ្នក?"*

*"តើអ្នកអាចលើកឧទាហរណ៍ពីការងារផ្ទាល់ខ្លួនរបស់អ្នក<br>ដែលអ្នកបានធ្វើរឿងដែលមានប្រយោជន៍ និងវិជ្ជមានស្រដៀងគ្នានេះ<br>ដើម្បីជួយដល់កុមារដែលរងផលប៉ះពាល់ដោយការរំលោភបំពាន ឬការកេងប្រវ័ញ្ចដែរឬទេ?"*

ខ អ្នកអាចបំបែកក្រុមធំទៅជាក្រុមតូចៗ ចែកករណីសិក្សា ហើយឱ្យពួកគេអានជាមួយគ្នាក្នុងក្រុមតូច និងឆ្លើយសំណួរខាងលើ បន្ទាប់មកឱ្យអ្នកចូលរួមចូលទៅក្រុមធំវិញសម្រាប់ការចែករំលែក និងការពិភាក្សាកាន់តែទូលំទូលាយ។

គ អ្នកអាចចែករំលែកករណីសិក្សាដោយប្រើស្លាយ ដោយចែករំលែកចំណុចនីមួយៗនៅលើស្លាយនីមួយៗម្តងមួយៗ។ នៅពេលបញ្ចប់សូមលើកទឹកចិត្តឱ្យមានការពិភាក្សាលើសកម្មភាពវិជ្ជមានរបស់មន្ត្រីនគរបាល ហើយថែមទាំងឆ្លើយសំណួរខាងលើ ។

ប្រសិនបើអ្នកត្រូវត្រឡប់ទៅមើលស្លាយនីមួយៗ ដើម្បីឆ្លើយសំណួរ *"តើអ្វីជាចំណុចសំខាន់ក្នុងករណីសិក្សានេះ ដែលអ្នកអាច និងគួរអនុវត្តក្នុងការងារ របស់អ្នក?"* សូមធ្វើដូច្នេះចុះ។

នៅពេលអ្នកពេញចិត្តថា អ្នកចូលរួមយល់ពីចំណុចសិក្សាសំខាន់ៗ ហើយអាចចែករំលែកឧទាហរណ៍ផ្ទាល់របស់ពួកគេអំពីការអនុវត្តល្អ ក្នុងនាមជាអ្នកសម្របសម្រួល ។

១២ ពន្យល់ថា ផ្នែកចុងក្រោយនៃវគ្គនេះគឺដើម្បីចែករំលែកស្លាយសង្ខេប និងឯកសារចែកជូនដែលទាក់ទងនឹងអ្វីដែលកុមារនៅក្នុងប្រទេសកម្ពុជា (ដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ) ត្រូវការពីមន្ត្រីនគរបាល អ្នកជំនាញផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ អ្នកផ្តល់សេវា គ្រួសារ និងអ្នកគាំទ្រផ្សេងទៀត។

គំនិតនេះត្រូវបានប្រមូលដោយការស្តាប់សំឡេង និងយោបល់របស់កុមារនៅក្នុងរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅប្រទេសកម្ពុជា និងការស្រាវជ្រាវ វាយតម្លៃផ្សេងទៀតដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល រួមទាំងអង្គការ APLE ផងដែរ។

១៣ អ្នកអាចសុំយោបល់ពីពួកគេអំពីរបៀប ដែលគំនិតទាំងនេះអាចយកទៅអនុវត្តបាននៅក្នុងការងារប្រចាំថ្ងៃរបស់មន្ត្រីនគរបាលជាមួយកុមារ និងយុវជន ដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច ឬការរំលោភបំពានផ្លូវភេទ។

**ឧទាហរណ៍៖** ប្រសិនបើកុមារនិយាយថា ពួកគេត្រូវការឱ្យមានអ្នកយល់ចិត្តពួកគេ - សួរក្រុមពីអ្វីដែលពួកគេអាចធ្វើ និង/ឬនិយាយ ដើម្បីបង្ហាញការយល់ចិត្តចំពោះកុមារ។

**ឧទាហរណ៍ផ្សេងទៀត៖** ប្រសិនបើកុមារនិយាយថា ពួកគេត្រូវការមនុស្សដើម្បីលើកទឹកចិត្តពួកគេ សួរក្រុមនូវអ្វីដែលពួកគេអាចនិយាយ ឬធ្វើដើម្បីលើកទឹកចិត្តកុមារតាមរបៀបដែលមានប្រយោជន៍។

បន្តពិភាក្សាអំពីគំនិតផ្សេងទៀតដែលកុមារបានលើកឡើង ហើយស្វែងរកឧទាហរណ៍អំពីរបៀបដែលមន្ត្រីនគរបាលអាចបំពេញតម្រូវការទាំងនេះ។

*សង្ខេប និងចែករំលែកដោយប្រើចំណុចខាងក្រោម ដែលត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងឯកសារចែក៖ អ្នកអាចនិយាយថា៖ "ប្រសិនបើយើងប្តេជ្ញាចិត្តយ៉ាងពិតប្រាកដក្នុងការលើកកម្ពស់សិទ្ធិកុមារ ហើយឆ្លើយតបតាមបែបកុមារមេត្រី យើងអាចចាប់ផ្តើមដោយសិក្សាពាក្យ និងគំនិតរបស់ពួកគេ ហើយគិតអំពីរបៀបដែលយើងអាចអនុវត្តវានៅក្នុងការងារប្រចាំថ្ងៃរបស់យើង។ ប្រសិនបើ យើងអាចបញ្ចូលគំនិតទាំងនេះ និងធ្វើឱ្យទៅជាការអនុវត្តប្រចាំថ្ងៃ នោះនឹងមានអត្ថប្រយោជន៍ជាច្រើន៖*

- កុមារនឹងមានអារម្មណ៍ថាមានសុវត្ថិភាព និងជឿជាក់លើអ្នកកាន់តែច្រើន ហើយមានទំនុកចិត្តកាន់តែច្រើន និងអាចសហការកាន់តែជិតស្និទ្ធជាមួយអ្នក។
- វានឹងធ្វើឱ្យដំណើរការកាន់តែរលូន និងបង្កើនលទ្ធភាពនៃលទ្ធផលជោគជ័យសម្រាប់អ្នកក្នុងនាមជាមន្ត្រីនគរបាល និងសម្រាប់កុមារដែលជាជនរងគ្រោះ។
- របៀបដែលអ្នក និងមនុស្សផ្សេងទៀតប្រព្រឹត្តចំពោះពួកគេ ក៏អាចជះឥទ្ធិពលវិជ្ជមានផងដែរលើរបៀបដែលពួកគេបានធូរស្បើយពីអ្វីដែលពួកគេជួបប្រទះ។
- ការធ្វើតាមការណែនាំទាំងនេះគឺ "ឈ្នះ-ឈ្នះ" សម្រាប់គ្រប់គ្នា!។

១៤ ចែកឯកសារដល់អ្នកចូលរួមឱ្យទុកប្រើប្រាស់ និងបិទវគ្គ ហើយអរគុណអ្នកចូលរួមសម្រាប់ការងារ និងការប្ដេជ្ញាចិត្តរបស់ពួកគេចំពោះបញ្ហាទាំងនេះ។

ពន្យល់ថា នៅក្នុងវគ្គបន្ទាប់ យើងនឹងចែករំលែកចំណេះដឹងរួមគ្នា ដើម្បីពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅចំពោះករណីសិក្សា ហើយពិចារណាពីរបៀបដែលយើងអាចអនុវត្តវាទៅនឹងសេណារីយ៉ូករណីជាក់ស្ដែង។

## សកម្មភាព

១ សួរក្រុមថាតើពួកគេអាចចងចាំពីវគ្គដែលទាក់ទងនឹងការលើកកម្ពស់សិទ្ធិកុមារ និងការអនុវត្តបែបកុមារមេត្រីដែរឬទេ? តើកុមារនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីសកម្មភាពទាំងនោះ?

២ *តើអ្វីជាទង្វើ ឬឥរិយាបថសំខាន់ៗនៅក្នុងរបាយការណ៍នីមួយៗ?*

៣ *តើអ្វីជាលទ្ធផលនៃឥរិយាបថ ឬទង្វើនោះ ហើយតើវានឹងផ្ដល់អត្ថប្រយោជន៍ដល់កុមារយ៉ាងដូចម្ដេច?*

៤ *តើឥរិយាបថ ឬទង្វើនោះនឹង (ឬអាច) ផ្ដល់អត្ថប្រយោជន៍ដល់កុមារ និងធ្វើឱ្យដំណើរការនៃករណីនេះប្រសើរឡើងយ៉ាងដូចម្ដេច?*

៥ *តើវាទាក់ទងនឹងការអនុវត្តបែបកុមារមេត្រី និងការលើកកម្ពស់សិទ្ធិកុមារយ៉ាងដូចម្ដេច?*

- ឱ្យគ្រប់គ្នាចូលមកកាន់ក្រុមវិញ ហើយសុំឱ្យពួកគេអានរបាយការណ៍មួយចំនួន និងសង្ខេបចម្លើយរបស់ពួកគេ។ គួរចងចាំផងដែរក្នុងការគូសបញ្ជាក់ពីការអនុវត្តបែបកុមារមេត្រី និងរបៀបដែលសិទ្ធិកុមារត្រូវបានលើកកម្ពស់។

- ចែកកាតមួយចំនួនដូចដែលអ្នកបានធ្វើពីមុនមក ប៉ុន្តែ លើកនេះ គឺចែកកាតឆ្លើយតបដែលមិនមានប្រយោជន៍។
- ពន្យល់ថា កិច្ចការរបស់ពួកគេ គឺត្រូវអានរបាយការណ៍នៅលើកាតក្នុងក្រុមម្តងមួយៗ ហើយបន្ទាប់មកពិភាក្សា និងពិចារណាសំណួរខាងក្រោម៖
- តើអ្វីជាបញ្ហាចម្បង ការលំបាក ឬឥរិយាបថ ឬស្ថានភាពដែលមិនមានប្រយោជន៍នៅក្នុងរបាយការណ៍នីមួយៗ?
- តើចំណុចទាំងនោះប៉ះពាល់ដល់កុមារយ៉ាងដូចម្តេច? (ឬតើវាទំនងជាប៉ះពាល់ដល់កុមារយ៉ាងដូចម្តេច?)
- តើអ្នកគិត ឬមានអារម្មណ៍យ៉ាងណាចំពោះអ្វីដែលកុមារពណ៌នា?
- តើអ្វីដែលកុមារពិពណ៌នាអាចប៉ះពាល់ដល់លទ្ធផលនៃដំណើរការនេះដោយរបៀបណា?
- នៅពេលគិតអំពីការអនុវត្តបែបកុមារមេត្រី និងការលើកកម្ពស់សិទ្ធិកុមារ តើអ្នកមានដំណោះស្រាយបែបណា ដើម្បីធ្វើឱ្យស្ថានភាពកាន់តែប្រសើរឡើង? តើមានដំណោះស្រាយផ្សេងពីនេះដែរឬទេ?
- ផ្តល់ពេលវេលាឱ្យក្រុមប្រហែល១៥ទៅ២០នាទី ដើម្បីពិភាក្សាអំពីរបាយការណ៍។

### ៥ ជាសកម្មភាពជួយមន្ត្រីនគរបាលក្នុងការចែករំលែក និងផ្សព្វផ្សាយចំណេះដឹងរបស់ពួកគេ៖

- សុំមន្ត្រីនគរបាលដែលមានវត្តមានឱ្យយករូបភាពនោះត្រឡប់ទៅកន្លែងធ្វើការវិញ ហើយចំណាយពេល១៥នាទី នៅការិយាល័យរបស់ពួកគេដើម្បីចែករំលែកគំនិតសំខាន់ៗ ទាំងនេះជាមួយសហការីរបស់ពួកគេ។
- បន្ទាប់មកសុំឱ្យពួកគេបិទក្រដាសផ្ទាំងធំនៅកន្លែងដែលងាយមើលឃើញនៅលើជញ្ជាំងក្នុងការិយាល័យរបស់ពួកគេ ដើម្បីឱ្យពួកគេ និងសហការីរបស់ពួកគេអាចចងចាំពីអ្វីដែលកុមារត្រូវការគ្រប់ពេលវេលា។
- នេះក៏នឹងរំលឹកពួកគេអំពីសារៈសំខាន់នៃការលើកកម្ពស់សិទ្ធិកុមារ និងអនុវត្តតាមបែបកុមារមេត្រី។

# ឧបសម្ព័ន្ធមេរៀនទី៩៖

## ដំណោះស្រាយចំពោះបញ្ហាប្រឈម និងផលវិបាកទូទៅ

### ដំណើរការ និងជំហានសម្របសម្រួល

① សូមស្វាគមន៍ការចូលមកកាន់មេរៀនថ្មីនេះ សង្ខេបមាតិកា និងខ្លឹមសារមេរៀន៖

ក បញ្ហាប្រឈមដែលជួបប្រទះពេលធ្វើការឆ្លើយតបករណីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA)

ខ បញ្ហាប្រឈមទូទៅ ដែលជួបប្រទះញឹកញាប់

- ភាពខុសគ្នារវាងការពិត និងការកុហក
- អនុវត្តបច្ចេកវិទ្យាក្នុងការសម្ភាសបែបកោសលវិច័យ
- ដំណោះស្រាយការរំលោភបំពានដែលស្មុគស្មាញពាក់ព័ន្ធនឹងកុមាររងគ្រោះ ច្រើននាក់

ការដោះស្រាយ បញ្ហាលម្អៀងផ្នែកយេនឌ័រក្នុងការឆ្លើយតបរបស់មន្ត្រីនគរបាល សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផលដែលបានគ្រោងទុកនៃវគ្គសិក្សានេះ ដោយប្រើកំណត់សម្គាល់ និងស្លាយខាងលើ។ ពន្យល់ថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

② ពន្យល់ថា នៅក្នុងដំណើការ TNA ដែលជះឥទ្ធិពលលើការបង្កើតវគ្គបណ្តុះបណ្តាលនេះ មន្ត្រីនគរបាល បានកំណត់ពីការលំបាក និងបញ្ហាប្រឈមមួយចំនួនក្នុងការងាររបស់ពួកគេជាមួយកុមារដែលរងផលប៉ះពាល់ដោយការការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ។ ត្រូវប្រាកដថា អ្នកពន្យល់ពីចំណុចនៅក្នុងកំណត់សម្គាល់(ខាងលើ)អំពីភាពខុសគ្នានៃទស្សនៈ និង "ភាពខ្វះចន្លោះ" ក្នុងការឈ្វេងយល់ពីកុមារដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច និងរំលោភំពានផ្លូវភេទដែលបានកើតឡើង។

③ បញ្ហាប្រឈមមួយចំនួនដែលមន្ត្រីនគរបាលបានចែករំលែក រួមមាន៖

- បញ្ហាប្រឈមក្នុងការជួបដោយផ្ទាល់ជាមួយកុមារ និងអាណាព្យាបាលរបស់ពួកគេ។
- ពួកគេអាចមានអារម្មណ៍ថា កុមារមិនសហការ។
- ពួកគេអាចមានបញ្ហាប្រឈមក្នុងការយល់ដឹងអំពីបច្ចេកវិទ្យា។
- ពួកគេប្រហែលជាចង់ស្វែងរកដំណោះស្រាយរហ័សចំពោះបញ្ហា (ប៉ុន្តែប្រហែលជាមិនមានដំណោះស្រាយរហ័ស និងងាយស្រួលទេ)។

**ប៉ុន្តែ នៅពេលដែលយើងស្តាប់កុមារ និងក្រុមគ្រួសាររបស់ពួកគេអំពីទស្សនៈរបស់ពួកគេ យើងដឹងថា៖**

- ពួកគេមិនងាយសហការជាមួយមន្ត្រីនគរបាលឡើយ។
- ជារឿយៗ ពួកគេមិនយល់ពីច្បាប់ ដំណើរការច្បាប់ ឬយល់ពីអត្ថប្រយោជន៍នៃច្បាប់ឡើយ។
- ពួកគេអាចមានការភ័យខ្លាច និង/ឬមិនទុកចិត្តមន្ត្រីនគរបាល។
- ពួកគេអាចមានអារម្មណ៍ថប់បារម្ភ និង/ឬមានអារម្មណ៍អៀនខ្មាស និងអាម៉ាស់យ៉ាងខ្លាំង។
- ពួកគេអាចឈឺចាប់ តក់ស្លុត និងច្របូកច្របល់។
- ពួកគេអាចស្គាល់ជនល្មើស ហើយភ័យខ្លាចចំពោះការតបត។
- ពួកគេអាចបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង ឬត្រូវបានស្តីបន្ទោស។
- ពួកគេអាចមានពិការភាព ហើយពិបាកយល់ ឬពិបាកទំនាក់ទំនង។

៤ ពន្យល់ទៅកាន់ក្រុមថា បញ្ហាទាំងនេះ និងបញ្ហាជាច្រើនទៀត រារាំងដំណើរការមិនមានភាពរលូន និងសុវត្ថិភាព។ នៅពេលដែលយើងពិនិត្យមើលឱ្យបានជិតដល់ចំពោះព័ត៌មានលម្អិតនៃករណីទាំងនេះ ជាញឹកញាប់ យើងអាចមើលឃើញថា កុមារមិនសហការ ប៉ុន្តែត្រូវប្រឈមមុខនឹងបញ្ហាជាក់ស្តែង ដែលធ្វើឱ្យពិបាកក្នុងការដំណើរការ។ មានពេលខ្លះ គម្លាតរវាងទស្សនៈរបស់ជនរងគ្រោះ និងមន្ត្រីនគរបាល និងការខ្វះការយល់ដឹងរវាងកុមារដែលទទួលបានយុត្តិធម៌ និងអ្នកដែលមានភារកិច្ចជួយពួកគេ។

៥ លំហាត់នេះត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាប្រឈម និងបញ្ហាទូទៅដែលកុមារ និងមន្ត្រីនគរបាលជួបប្រទះ និងស្វែងរកដំណោះស្រាយ។ លំហាត់នេះក៏ត្រូវបានរៀបចំឡើងដើម្បីស្វែងរកវិធីដើម្បីបំពេញ "ភាពខ្វះចន្លោះ" រវាងអ្វីដែលមន្ត្រីនគរបាលមើលឃើញ និងរបៀបដែលកុមាររងគ្រោះមានអារម្មណ៍ និងបទពិសោធន៍នៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ពន្យល់ឧទាហរណ៍ទាំងអស់នៃបញ្ហា ដែលអ្នកនឹងចែករំលែក គឺផ្អែកលើស្ថានភាព និងករណីជាក់ស្តែង។

៧ លំហាត់នេះអាចធ្វើជាក្រុមធំ ក្រុមតូច ឬជាគូ។ កំណត់សម្គាល់ខាងក្រោមនឹងពន្យល់សង្ខេបអំពីវិធីសាស្ត្រផ្សេងៗ។ ប៉ុន្តែ អ្នកក៏អាចបង្កើតវិធីសាស្ត្រសម្របសម្រួលផ្ទាល់ខ្លួនផងដែរ។ មុននឹងចាប់ផ្តើម សូមរំលឹកក្រុមទាំងមូលឱ្យចងចាំពីនីតិវិធីបែបកុមារមេត្រី និងការលើកកម្ពស់សិទ្ធិកុមារ គឺជាផ្នែកសំខាន់នៃការងាររបស់ពួកគេ ហើយចំណុចទាំងអស់នេះ គួរត្រូវបានដាក់បញ្ចូលនៅក្នុងការឆ្លើយតបទាំងអស់។

៨ ឧទាហរណ៍អំពីករណីដោយប្រើស្លាយ៖ មុនពេលអ្នកសម្របសម្រួលឱ្យធ្វើលំហាត់ ប្រសិនបើអ្នកត្រូវការបង្ហាញកិច្ចការ អ្នកអាចធ្វើដូច្នេះបានដោយប្រើឧទាហរណ៍ខាងក្រោម៖

ឧទាហរណ៍អំពីបញ្ហាប្រឈមដែលកុមារបានចែករំលែក

កុមារនិយាយថា ពួកគេមិនចង់រាយការណ៍ដោយសារខ្លាចជនល្មើស និង/ឬជនល្មើសជាបុគ្គលដែលគេស្គាល់។ ពួកគេព្រួយបារម្ភអំពីអ្វីដែលនឹងកើតឡើង។

តើមានបញ្ហាចម្បងអ្វីខ្លះសម្រាប់អ្នកដើម្បីពិចារណា?

តើអ្នកគួរធ្វើអ្វី និងគួរនិយាយដូចម្តេច?

អ្នកចូលរួមគួរតែអាចកំណត់ពីបញ្ហាសំខាន់ៗមួយចំនួន និងអាចស្វែងរកដំណោះស្រាយមានប្រយោជន៍មួយចំនួនដើម្បីយកឈ្នះបញ្ហាទាំងនោះ។

ឧទាហរណ៍ បញ្ហាសំខាន់ៗមួយចំនួនដែលត្រូវពិចារណា គឺកំណត់អត្តសញ្ញាណជនល្មើស ហើយប្រសិនបើគាត់មានសិទ្ធិចូលជួបកុមារទាំងលើប្រព័ន្ធអនឡាញ ឬក្រៅប្រព័ន្ធអនឡាញ ដែលធ្វើឱ្យកុមារផ្សេងទៀត អាចមានហានិភ័យហើយជនល្មើសអាចបង្កគ្រោះថ្នាក់ដល់កុមារ ប្រសិនបើពួកគេរាយការណ៍។ តម្រូវការដើម្បីអនុវត្តការវាយតម្លៃសុវត្ថិភាព និងហានិភ័យអាស្រ័យលើព័ត៌មានលម្អិតនៃករណី។

មន្ត្រីនគរបាលត្រូវបង្ហាញឱ្យច្បាស់ថា ពួកគេយល់ពីបញ្ហា និងធានាចំពោះកុមារថា ពួកគេនឹងព្យាយាមឱ្យអស់ពីលទ្ធភាព ហើយធ្វើការជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរក្សាសុវត្ថិភាពរបស់កុមារ។ ពួកគេអាចពន្យល់ (ជាភាសាដែលកុមារយល់) ពីរបៀបដែលប្រព័ន្ធច្បាប់អាចដំណើរការដើម្បីរក្សាសុវត្ថិភាពរបស់កុមារ។ លើកទឹកចិត្តកុមារឱ្យសួរសំណួរ។ ប្រសិនបើកុមារត្រូវការកន្លែងមានសុវត្ថិភាព សូមចូលរួមជាមួយពួកគេក្នុងការស្វែងរកដំណោះស្រាយ (ឧទាហរណ៍៖ សមាជិកគ្រួសារដែលមានសុវត្ថិភាព)។

៩ នៅពេលអ្នកធ្វើកិច្ចការរួចរាល់ ឱ្យអ្នកចូលរួមចូលមកក្នុងក្រុមដើម្បីសង្ខេបមេរៀនសំខាន់ៗ ដែលបានរៀន។ អរគុណអ្នកចូលរួមសម្រាប់ការចូលរួមរបស់ពួកគេ និងបិទបញ្ចប់វគ្គបណ្តុះបណ្តាល។

## សកម្មភាព

១ ដើម្បីសម្របសម្រួលដល់ការធ្វើលំហាត់ប្រាណជាក្រុមធំ៖

ស្នើសុំអ្នកស្ម័គ្រចិត្តក្នុងការជ្រើសរើសកាតពីកញ្ចប់ កាតបញ្ហាប្រឈម និងការលំបាកទូទៅ។

ពួកគេអាចអានកាតនោះឱ្យក្រុមទាំងមូលស្តាប់ ដោយស្វែងរកចម្លើយពីក្រុមអំពីវិធីឆ្លើយតបទៅនឹងស្ថានភាព និងដោះស្រាយបញ្ហា ដោយយោងតាមការណែនាំអំពីកុមារ និងត្រូវប្រាកដថាពួកគេលើកកម្ពស់សិទ្ធិកុមារ។

ប្រសិនបើអ្នកកត់សម្គាល់ពីភាពខ្វះចន្លោះសំខាន់ៗនៅក្នុងចម្លើយ និងការឆ្លើយតប អ្នកអាចពន្យល់ពីអ្វីដែលត្រូវធ្វើបន្ថែមទៀតនៅក្នុងសេណារីយ៉ូនីមួយៗ។

ត្រូវប្រាកដថា អ្នកចូលរួមមិនដោះសារចំពោះសេណារីយ៉ូទាំងនោះ *(ឧទាហរណ៍៖ ដោយសារតែពួកគេផ្តោតលើតម្រូវការរបស់មន្រ្តីនគរបាល មិនមែនកុមារ)*។

ក៏ត្រូវប្រាកដផងដែរថា មនុស្សមិននិយាយលេងសើច និងបញ្ចេញមតិមិនសមរម្យអំពីទិដ្ឋភាពណាមួយនៃសេណារីយ៉ូ *(ឧទាហរណ៍ ក្រុមមនុស្ស* LGBTQI *ការរំលោភបំពានលើកុមារា ឬបញ្ហាយេនឌ័រផ្សេងទៀត ឬកុមារមានពិការភាពជាដើម)*។ ត្រូវប្រាកដថា អ្នកប្រើកាតដែលទាក់ទងនឹងប្រភេទផ្សេងៗគ្នាទាំងអស់ *(ឧទាហរណ៍៖ ទាក់ទងនឹងកុមារ បរិស្ថាន/ដំណើរការ ច្បាប់ ការគ្រប់គ្រងករណី។ល។)* (ក្នុងករណីមួយចំនួន អ្នកក៏អាចសុំឱ្យអ្នកស្ម័គ្រចិត្តដំបូងជ្រើសរើសអ្នកចូលរួមម្នាក់ទៀត ដើម្បីសម្តែងក្នុងឈុតឆាកខ្លីមួយដោយ បង្ហាញពីអ្វីដែលត្រូវធ្វើ និងនិយាយ)។

## ២ ដើម្បីសម្របសម្រួលការធ្វើលំហាត់ជាក្រុមតូចៗ ឬជាគូ៖

បំបែកក្រុមធំទៅជាក្រុមតូច ឬជាគូ។

ចែកកាតពីរបីសន្លឹកទៅឱ្យក្រុម ឬដៃគូនីមួយៗពីកញ្ចប់ កាតបញ្ហាប្រឈម និងការលំបាកទូទៅ។ ត្រូវប្រាកដថា អ្នកប្រើកាតដែលទាក់ទងនឹងប្រភេទផ្សេងៗទាំងអស់ ឧទាហរណ៍៖ *ទាក់ទងនឹងកុមារ បរិស្ថាន/ដំណើរការ ច្បាប់ ការគ្រប់គ្រងករណី។*

សុំឱ្យពួកគេធ្វើការរួមគ្នាដើម្បីពិភាក្សាអំពីកាតនីមួយៗ ស្វែងរកដំណោះស្រាយ។ ទុកពេល ១៥ ឬ ២០នាទី ដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយ។

បន្ទាប់មកឱ្យអ្នកចូលរួមចូលមកក្នុងក្រុមវិញ ដើម្បីចែករំលែក និងពិភាក្សាអំពីដំណោះស្រាយមួយចំនួនរបស់ពួកគេចំពោះបញ្ហាដែលពួកគេបានពិភាក្សា។

អ្នកក៏អាចសុំឱ្យក្រុមតូចជ្រើសរើសកាតមួយចំនួន ហើយសម្តែងក្នុងឈុតឆាកខ្លីមួយ ដូច្នេះ ពួកគេអាចអនុវត្តអ្វីដែលត្រូវនិយាយ និងរបៀបឆ្លើយតបយ៉ាងសមស្រប។

# ឧបសម្ព័ន្ធមេរៀនទី១០៖

## វិធានសុវត្ថិភាពនៅលើអនឡាញ ការរាយការណ៍ និងការស្វែងរកជំនួយ

### ដំណើរការ និងជំហានសម្របសម្រួល

សូមស្វាគមន៍ការចូលមកកាន់មេរៀនថ្មីនេះ សង្ខេបមាតិកា និងខ្លឹមសារមេរៀន៖

ក ស្វែងយល់ពីការដោះស្រាយបញ្ហាប្រឈម ការលំបាក និងភាពលំបាកនៅក្នុងករណី ( OCSEA ) ភាពលំបាកទាក់ទងនឹងកុមារ ឬគ្រួសារ

ខ ស្វែងយល់ដឹងពីសារៈសំខាន់វិធានការសុវត្ថិភាព និងការរាយការណ៍របស់ប្រជាពលរដ្ឋ

- វិធានសុវត្ថិភាពលើអ៊ីនធឺណិត
- ការកំណត់ឯកជនភាព
- ការរាំងខ្ទប់នរណាម្នាក់លើអនឡាញ ( block )
- កំណត់សុវត្ថិភាពនៃការស្វែងរកតាមអនឡាញ

### ប្រព័ន្ធរាយការណ៍តាមអនឡាញ ជំហាននៃការរាយការណ៍

សូមចំណាំថា តាមឧត្តមគតិបុគ្គលិកអង្គការ APLE ត្រូវតែធ្វើបទបង្ហាញវគ្គនេះ ដោយផ្អែកលើបទពិសោធន៍ និងបទបង្ហាញដែលមានស្រាប់របស់ពួកគេ៖

- សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផលដែលបានគ្រោងទុកនៃវគ្គនេះ ដោយប្រើកំណត់ចំណាំខាងលើ និងផ្ទាំងស្លាយ។ ពន្យល់ថាយើងនឹងប្រើស្លាយ និងស្នាតហ្វូនផ្ទាល់ខ្លួនរបស់អ្នកចូលរួម ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។ អ្នកក៏អាចប្រើឯកសារនេះឧបសម្ព័ន្ធ ( APLE Best Practice Case Study ) ដើម្បីពន្យល់ព័ត៌មានលម្អិត និងជាតុផ្សំមួយចំនួននៃការអនុវត្តល្អៗ។
- ប្រើកំណត់ចំណាំខាងលើ និងផ្ទាំងស្លាយ ដើម្បីពន្យល់ពីដំណើររឿង អំពីរបៀប និងមូលហេតុដែលអង្គការ APLE បង្កើត Chatbot ដើម្បីជួយដោះស្រាយបញ្ហាជាច្រើនដែលទាក់ទងនឹង OCSEA។
- ប្រើស្លាយដើម្បីបង្ហាញ «ផ្ទាល់» របៀបដែល Chatbot អាចប្រើបាន។
- ផ្តល់ QR កូដ ដើម្បីឱ្យអ្នកចូលរួមក៏អាចចូលប្រើ Chatbot «អនុវត្តផ្ទាល់» ផងដែរ។ ទុកពេលប្រហែល ១៥ ឬ ២០នាទី សម្រាប់អ្នកចូលរួមរុករកកម្មវិធី ហើយព្យាយាមចូលប្រើមុខងារនេះ។

- សួរក្រុមអំពីអ្វីដែលពួកគេចាត់ទុកថា ជាគុណប្រយោជន៍មួយចំនួនរបស់ chatbot អាចយកចម្លើយមួយចំនួន ហើយសង្ខេបផងដែរ ប្រសិនបើពួកគេខកខានចំណុចខាងក្រោម៖
  - វាងាយស្រួលប្រើ និងអាចចូលប្រើបានក្នុង «ពិភពឌីជីថល» របស់ពួកគេ
  - រចនាដោយកុមារ និងយុវវ័យសម្រាប់ពួកគេ (ដូច្នេះពួកគេទំនងជាប្រើវា)
  - វាជាឯកជន និងអនាមិក
  - វាលើកកម្ពស់សុវត្ថិភាព និងផ្តល់ជម្រើស សម្រាប់កុមារឱ្យមានសំឡេង (ការលើកកម្ពស់សិទ្ធិកុមារនៅក្នុងពិភពឌីជីថល)
  - មុខងារច្រើន-សម្រាប់សិក្សាអំពី OCSEA និងការចូលប្រើធនធានមានប្រយោជន៍។ រាយការណ៍ពីកង្វល់ ឬបញ្ហាជាក់ស្តែងរបស់ OCSEA ដោយសុវត្ថិភាព និងសម្ងាត់។ សម្រាប់ការចូលប្រើព័ត៌មានអំពីសេវាកម្មមានប្រយោជន៍។
  - អាចមានប្រយោជន៍សម្រាប់កុមារ យុវជន និងមនុស្សពេញវ័យ
- សួរក្រុមពីរបៀប ដែលពួកគេគិតថាកម្មវិធីអាចមានប្រយោជន៍ដល់មន្ត្រីនគរបាល ក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ។ មានលទ្ធភាពមួយចំនួនខាងក្រោម៖
  - យើងអាចស្វែងយល់អំពីបញ្ហាចុងក្រោយរបស់ OCSEA និងអាចចូលប្រើប្រាស់ឯកសារសិក្សាផងដែរ។
  - យើងអាចចែករំលែកព័ត៌មានកម្មវិធី និង OCSEA ជាមួយសហការីរបស់យើងផ្ទាល់ ដូច្នេះយើងទាំងអស់គ្នាដឹងពីបញ្ហាសំខាន់ៗរបស់ OCSEA។
  - យើងអាចចែករំលែកព័ត៌មានជាមួយក្រុមគ្រួសារ មិត្តភក្តិ និងសហគមន៍របស់យើងផ្ទាល់ ដូច្នេះពួកគេអាចបង្កើនការយល់ដឹងក្រុមកុមារដែលប្រើប្រាស់អ៊ីនធឺណិតឱ្យចេះបង្ការ ហើយពួកគេអាចរៀនពីរបៀបការពារខ្លួន។
  - យើងអាចចែករំលែកកម្មវិធី និងព័ត៌មានជាមួយកុមារ យុវជន ឪពុក ម្តាយ និងអាណាព្យាបាល ដូច្នេះពួកគាត់ក៏អាចស្វែងយល់អំពីបញ្ហាសំខាន់ៗ ដែលទាក់ទងនឹង OCSEA និងរៀនពីរបៀបការពារខ្លួនឱ្យបានប្រសើរជាងមុន។
- សង្ខេបវគ្គដោយគូសបញ្ជាក់ថា មានអត្ថប្រយោជន៍ជាច្រើន នៃធនធានដូចជា chatbot/app ជាដើម។ ព័ត៌មានកំពុងត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដូច្នេះជាធនធានដែលមានប្រយោជន៍។ ពន្យល់ថាអ្នកចង់ឱ្យអ្នកចូលរួមចែករំលែកព័ត៌មានល្អអំពី «ពិសី» ជជែកជាមួយអ្នកដទៃនាពេលអនាគត ដោយធ្វើតាមកិច្ចការសាមញ្ញ «តស៊ូមតិក្នុងសកម្មភាព» ខាងក្រោម។

## ការតស៊ូមតិក្នុងសកម្មភាព

កិច្ចការនេះមានភាពងាយស្រួលក្នុងការសម្រេចបាន ហើយនឹងចំណាយពេលត្រឹមតែពីរបីនាទីនៃពេលវេលារបស់អ្នកចូលរួមប៉ុណ្ណោះ។ នេះក៏ជាមធ្យោបាយដ៏សាមញ្ញ និងមានប្រសិទ្ធភាពផងដែរ ដែលពួកគេអាចតស៊ូមតិដើម្បីសុវត្ថិភាព និងការការពារកុមារ និងលើកកម្ពស់សិទ្ធិរបស់ពួកគេនៅក្នុងពិភពក្រៅបណ្ដាញ និងក្នុងអ៊ីនធឺណិត។

## ពន្យល់ថាអ្វីដែលអ្នកចង់ឱ្យពួកគេធ្វើចាប់ពីពេលនេះតទៅគឺ៖

- ចែករំលែក និងពន្យល់កម្មវិធីទៅមិត្តរួមការងារផ្សេងទៀត ដែលពួកគេធ្វើការជាមួយនៅពេលពួកគេត្រឡប់ទៅការិយាល័យវិញ (ហើយក៏ប្ដេជ្ញាចែករំលែកជាមួយសហការីថ្មីនាពេលអនាគតផងដែរ)។
- ចែករំលែក និងពន្យល់កម្មវិធីជាមួយមិត្តភក្ដិ ក្រុមគ្រួសារ កូនៗ និងចៅៗរបស់ពួកគេ។
- ចែករំលែក និងពន្យល់កម្មវិធីដល់កុមារ មិត្តភក្តិ និងអាណាព្យាបាល ដែលពួកគេមានទំនាក់ទំនងជាមួយក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ។

# ឧបសម្ព័ន្ធមេរៀនទី១១៖

## ការប្រតិបត្តិផ្អែកលើចំណេះដឹង និងជំនាញ

វគ្គនេះត្រូវបានបង្កើតឡើងសម្រាប់អ្នកចូលរួមក្នុងការធ្វើការជាក្រុម ទោះបីជាវាអាចត្រូវបានកែសម្រួលសម្រាប់ពួកគេឱ្យធ្វើការជាគូ ឬក្នុងករណីខ្លះ ជាបុគ្គល ប្រសិនបើចាំបាច់។

ជាមួយគ្នានេះដែរ ក៏មានជម្រើសផងដែរក្នុងការឱ្យអ្នកចូលរួមដើរតួ ( Role play ) ដើម្បីបង្ហាញចំណេះដឹង និងជំនាញរបស់ពួកគេ ដែលពួកគេបានសម្ភាសន៍កុមាររងគ្រោះ និងដែលបានពិពណ៌នានៅក្នុងករណីសិក្សា។

### ដំណើរការ និងជំហានសម្របសម្រួល

១ ស្វាគមន៍ការចូលមកកាន់មេរៀនថ្មី និងធ្វើសេចក្តីសង្ខេបមាតិកា និងខ្លឹមសារ៖

- បញ្ជាំងពីរបៀបដែលល្អបំផុតក្នុងការទាក់ទង និងរៀបចំផែនការស៊ើបអង្កេតករណី OCSEA
- កំណត់ថាតើមានសមាសធាតុលើប្រព័ន្ធអនឡាញតែប៉ុណ្ណោះ ឬចំពោះឧក្រិដ្ឋកម្មនោះ ឬមានទាំងលើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។
- នីតិវិធីកុមារមេត្រី និងបញ្ហាសិទ្ធិកុមារ
- ការប្រមូល និងរក្សាភស្តុតាង
- ការស្តាប់ចម្លើយ/ការសម្ភាសជនសង្ស័យ និងការប្រមូលភស្តុតាងបន្ថែម

ស្វាគមន៍ក្រុម និងចែករំលែកលទ្ធផលដែលបានគ្រោងទុកនៃវគ្គនេះ ដោយប្រើកំណត់សម្គាល់ និងស្លាយខាងលើ។ ពន្យល់ថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

២ ពន្យល់ថា យើងនឹងប្រើប្រាស់បទពិសោធន៍ និងចំណេះដឹងដែលមានស្រាប់របស់ក្រុមទាំងអស់ជាមួយនឹងចំណេះដឹងថ្មីរបស់ពួកគេអំពី OCSEA និងអនុវត្តចំណេះដឹងទាំងនោះចំពោះករណីសិក្សា។

រំលឹកក្រុមថា ករណីសិក្សាគឺផ្អែកលើករណីជាក់ស្តែងពីការស្រាវជ្រាវ និងការអនុវត្ត។ ករណីសិក្សាមានភាពប្រាកដនិយមតាមដែលអាចធ្វើបាន ព្រោះវាផ្អែកលើព្រឹត្តិការណ៍ និងបទឧក្រិដ្ឋជាក់ស្តែង។ ករណីសិក្សាទាំងនោះឆ្លុះបញ្ជាំងពីតថភាពនៃ OCSEA នៅកម្ពុជាសព្វថ្ងៃ។

៣ ពន្យល់ថា អ្នកនឹងផ្តល់ឱ្យក្រុមនីមួយៗនូវករណីសិក្សាមួយ (ពួកគេគួរតែដឹងពីករណីសិក្សានៅពេលឥឡូវនេះ ប្រសិនបើពួកគេបានអានករណីសិក្សានោះ)។ អ្នកក៏នឹងផ្តល់ឱ្យក្រុមនីមួយៗនូវច្បាប់ចម្លងនៃសំណួរ ដើម្បីណែនាំពួកគេឱ្យធ្វើកិច្ចការ។

៤ ពន្យល់ថា សមាជិកក្រុមម្នាក់ៗនឹងចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើបទបង្ហាញ (ឧទាហរណ៍៖ កុំចាំមនុស្សតែម្នាក់ ឬពីរនាក់ឱ្យធ្វើការងារនេះ។ នេះជាការងារជាក្រុម។

៥ កិច្ចការគឺងាយស្រួលយល់ ហើយក្រុមត្រូវអនុវត្តតាមជំហាន ដែលបានបង្ហាញនៅក្នុងសន្លឹកកិច្ចការ។ ទោះយ៉ាងណា សូមប្រើស្លាយដែលពាក់ព័ន្ធ ដើម្បីបង្ហាញដល់ក្រុមនូវជំហាននីមួយៗ និងសំណួរអំពីកិច្ចការ ប្រសិនបើអ្នកគិតថា ការធ្វើដូចនេះអាចជួយពួកគេ។

៦ បែងចែកក្រុមទៅជាក្រុមតូចៗដោយក្នុងមួយក្រុមមាន ៥នាក់ ហើយសុំឱ្យពួកគេចាប់ផ្តើមធ្វើការជាមួយគ្នា។ ក្នុងនាមជាអ្នកសម្របសម្រួលគឺធានាថា ក្រុមបន្តធ្វើកិច្ចការទៅតាមពេលវេលាកំណត់។ លើសពីនេះ អ្នកអាចផ្តល់ការលើកទឹកចិត្ត និងឆ្លើយសំណួរដើម្បីបញ្ជាក់ពីកិច្ចការ។ អ្នកក៏អាចរំលឹកពួកគេអំពីបញ្ហាសំខាន់ៗ ដើម្បីបញ្ចូលក្នុងបទបង្ហាញរបស់ពួកគេ ប្រសិនបើពួកគេមានភាពស្រពេចស្រពិល។

សូមរំលឹកពួកគេថា ការលើកកម្ពស់សិទ្ធិកុមារ និងការអនុវត្តបែបកុមារមេត្រី គឺជាលក្ខខណ្ឌតម្រូវចាំបាច់នៃការងាររបស់ពួកគេ ប្រសិនបើចាំបាច់។ កុំភ្លេចប្រើកំណត់សម្គាល់បន្ថែមសម្រាប់អ្នកសម្របសម្រួល ប្រសិនបើអ្នកត្រូវការធ្វើដូច្នេះ។

៧ បន្ទាប់ពីក្រុមបានបញ្ចប់កិច្ចការរបស់ពួកគេ សូមសម្រាករយៈពេលខ្លី។

៨ បន្ទាប់មកសុំឱ្យក្រុមនីមួយៗធ្វើបទបង្ហាញនៃចម្លើយរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ។ ពួកគេគួរពណ៌នាសង្ខេបអំពីករណី និងឆ្លើយសំណួរទាំងអស់ដែលមាននៅក្នុងសន្លឹកកិច្ចការ។ អ្នកចូលរួមផ្សេងទៀតអាចត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរ ឬផ្តល់មតិត្រឡប់ជាវិជ្ជមាន បន្ទាប់ពីការធ្វើបទបង្ហាញបានបញ្ចប់។

៩ ក្នុងនាមជាអ្នកសម្របសម្រួល ប្រសិនបើអ្នកសម្គាល់ឃើញអ្វីមួយនៅក្នុងបទបង្ហាញដែលមិនត្រឹមត្រូវ ឬចម្លើយដែលមានលក្ខណៈវិជ្ជមាន និងការប្រើប្រាស់ចំណេះដឹងដែលបានរៀនបានយ៉ាងល្អ សូមកត់ចំណាំទុក។ ដូចគ្នានេះដែរ ប្រសិនបើចំណុចសិក្សាសំខាន់ៗដែលមិនត្រូវបានលើកឡើងនៅក្នុងបទបង្ហាញ សូមប្រើចំណេះដឹងផ្ទាល់ខ្លួនរបស់អ្នក និងកំណត់សម្គាល់បន្ថែមសម្រាប់អ្នកសម្របសម្រួល ដើម្បីបញ្ជាក់ពីចំណុចទាំងនោះ។

១១ នៅពេលដែលក្រុមទាំងអស់បានបញ្ចប់ការធ្វើបទបង្ហាញរបស់ពួកគេ សូមសង្ខេបចំណុចសិក្សាសំខាន់ៗ។

១២ ប្រសិនបើអ្នកចង់ធ្វើដូច្នេះ ហើយអ្នកមានពេល អ្នកក៏អាចសួរក្រុម ឬស្វែងរកអ្នកស្ម័គ្រចិត្តដើម្បីដើរតួក្នុងការសម្តែង ដើម្បីបង្ហាញពីការអនុវត្តវិជ្ជមាន និងការប្រើប្រាស់ការអនុវត្តបែបកុមារមេត្រី។

## សកម្មភាព

ពន្យល់ថា លំហាត់នេះគឺជាការងារជាក្រុម ដោយមានការចូលរួមពីសមាជិកម្នាក់ៗក្នុងក្រុម។

- ពួកគេនឹងមានពេល ២០នាទី ដើម្បីអានករណីសិក្សារួមគ្នា និងសំណួរណែនាំ។
- បន្ទាប់មកពួកគេនឹងមានពេល ៤៥នាទី បន្ថែមទៀត ដើម្បីឆ្លើយសំណួរនីមួយៗ និងកត់ត្រាចំណុចសំខាន់ៗនៅលើក្រដាសផ្ទាំងធំសម្រាប់សំណួរនីមួយៗ។
- បន្ទាប់មក ពេលក្រុមមកជុំគ្នា ក្រុមនីមួយៗនឹងមានពេលបន្ថែម១៥ ទៅ២០នាទី ដើម្បីសង្ខេបចម្លើយរបស់ពួកគេ និងធ្វើបទបង្ហាញដល់ក្រុមធំ។ *(ដូច្នេះ ៥ ក្រុមនឹងមានពេលបន្ថែម ៥៧-១០០នាទី)*

# ករណីសិក្សា

## ១- ការផលិត កាន់កាប់ ឬការចែកចាយ CSAM៖

### ករណីសិក្សា ក៖

អ្នកទទួលបានការហៅទូរស័ព្ទពីអ្នកគ្រប់គ្រងហាងកុំព្យូទ័រមួយ។ ពួកគេបានទទួលកុំព្យូទ័រយួរដៃមួយដែលត្រូវការជួសជុលពីអតិថិជនជនជាតិខ្មែរម្នាក់។ ពេលបើកកុំព្យូទ័រនោះ ជាងជួសជុលកុំព្យូទ័របានរកឃើញតំណភ្ជាប់ទៅនឹងរូបភាពជាង១០០០រូបភាពនៃកុមារ ដែលត្រូវបានរំលោភបំពានផ្លូវភេទ រួមទាំងរូបភាពដែលមើលទៅដូចកុមារកម្ពុជា។ រូបភាព និងវីដេអូមួយចំនួនហាក់ដូចជាទើបត្រូវបានគេផលិតឡើងក្នុងប៉ុន្មានសប្តាហ៍កន្លងមកនេះ។

ជាងជួសជុលកុំព្យូទ័រក៏បានរកឃើញឯកសារដែលគាត់ជឿថាជាកំណត់ត្រារបស់អតិថិជន - ទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជាដែលបានទិញរូបភាពទាំងនេះ។ កំណត់ត្រានេះបង្ហាញពីឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អតិថិជន អ្វីដែលពួកគេបានទិញ និងចំនួនប្រាក់ដែលពួកគេបានបង់រួចរាល់ហើយ។ អ្នកដែលកំពុងនិយាយតាមទូរស័ព្ទនោះក៏បានពន្យល់ទៀតថា អតិថិជននឹងត្រឡប់មកហាងគាត់វិញដើម្បីយកកុំព្យូទ័រយួរដៃរបស់គាត់វិញរយៈពេលពីរថ្ងៃទៀត។

### ករណីសិក្សា ខ៖

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយ ទាក់ទងមកកាន់ការិយាល័យរបស់អ្នក (ដែលមន្ត្រីនគរបាល) ពួកគេកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយកងកម្លាំងប៉ូលិសក្រៅប្រទេសទាក់ទងនឹងរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (CSAM) ដែលបានរកឃើញនៅលើកុំព្យូទ័រយួរដៃរបស់ជនបរទេសម្នាក់ដែលរស់ក្នុងប្រទេសនោះ។ នៅក្នុងការស៊ើបអង្កេតនាពេលថ្មីៗនេះ រូបភាពរាប់ពាន់សន្លឹកត្រូវបានរកឃើញនៅលើកុំព្យូទ័រនៅផ្ទះរបស់គាត់ ហើយគាត់ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទឧក្រិដ្ឋមួយចំនួន។ រូបភាពខ្លះបានមកពីពេលដែលជនល្មើសនោះបានមកលេងប្រទេសកម្ពុជាកាលពីប៉ុន្មានឆ្នាំមុននេះ អំឡុងឆ្នាំ២០១៥។ ក្មេងៗដែលមានវត្តមាននៅក្នុងរូបថតទាំងនោះឥឡូវនេះទំនងបានក្លាយជាមនុស្សពេញវ័យហើយ។ រូបភាពជាច្រើនរបស់ពួកគេត្រូវបានបង្ហោះចូលទៅក្នុងគេហទំព័រងងឹត (Dark Web)។ ឥឡូវនេះ គេបានយករូបភាពទាំងនេះចេញពីគេហទំព័រនោះហើយ ប៉ុន្តែអាចនៅមានគេបង្ហោះវានៅកន្លែងផ្សេងទៀត។

ជនល្មើសចូលចិត្តរក្សាកំណត់ត្រាលម្អិតអំពីកុមារទាំងអស់ដែលគាត់បានធ្វើបាប ហើយបានផ្តល់បញ្ជីឈ្មោះកុមារកម្ពុជាមួយចំនួនដល់កងកម្លាំងនគរបាលក្រៅប្រទេស និងអង្គការក្រៅរដ្ឋាភិបាលកម្ពុជា (បច្ចុប្បន្នពួកគេក្លាយជាមនុស្សពេញវ័យហើយ) ដែលត្រូវបានគេរំលោភបំពាន/កេងប្រវ័ញ្ច និងទីតាំងដែលការរំលោភបំពាននេះបានកើតឡើង។ ប្រហែលជាគ្មាននរណាម្នាក់ក្នុងចំណោមជនរងគ្រោះទាំងនេះ ដឹងថាការរំលោភបំពានរបស់ពួកគេត្រូវបានគេបង្ហោះលើប្រព័ន្ធអនឡាញ ហើយពួកគេប្រហែលជាមិនដែលរាយការណ៍អំពីការរំលោភបំពានរបស់ពួកគេ ឬទទួលបានការគាំទ្រសម្រាប់បទពិសោធន៍ដែលពួកគេបានឆ្លងកាត់ទេ។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជានោះបានប្រាប់ដំណឹងថា ពួកគេបានរកឃើញទីតាំងរបស់ស្ត្រីម្នាក់ (បច្ចុប្បន្ននេះមានអាយុ២៣ឆ្នាំ) ដែលកំពុងរស់នៅក្នុងតំបន់អ្នក ជាមួយប្តី និងកូនតូចៗពីរនាក់ទៀត។

### ករណីសិក្សា គ៖

មន្ត្រីជាន់ខ្ពស់ម្នាក់បានប្រាប់អ្នក (មន្ត្រីនគរបាល) យ៉ាងសង្ខេបពីស្ថានភាពមួយទាក់ទងនឹងការលក់ CSAM ហើយគាត់ចង់ឱ្យអ្នករៀបចំផែនការអន្តរាគមន៍ក្នុងករណីនេះ។ ព័ត៌មានលម្អិតពីករណីនេះមានដូចខាងក្រោម៖

ប៉ូលិសបានទទួលព័ត៌មានសម្ងាត់ ហើយបានកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនល្មើសម្នាក់ដែលរស់នៅក្នុងប្រទេសកម្ពុជា ដែលបានបង្កើតក្រុមតេលេក្រាមជាច្រើនលក់រូបភាព និងវីដេអូ CSAM។ រូបភាព និងវីដេអូទាំងនេះ បង្ហាញពីកុមារមកពីទូទាំងពិភពលោក ហើយអាយុរបស់កុមារទាំងនោះហាក់ដូចជាចាប់ពីទារករហូតដល់ក្មេងជំទង់។

ភស្តុតាងបានបង្ហាញថា ជនល្មើសមានសហគមន៍អ្នកទិញពីប្រទេសកម្ពុជា និងនៅទូទាំងអាស៊ីអាគ្នេយ៍ និងប្រទេសដទៃទៀត។ មានបញ្ជីតម្លៃលម្អិត គណនីធនាគារក្នុងប្រទេសកម្ពុជាមានរាប់ពាន់ដុល្លារ និងបញ្ជីទំនាក់ទំនងមួយចំនួន (អ៊ីម៉ែល) ដែលគេជឿថាជារបស់អតិថិជន។

ក្នុងបទសម្ភាសន៍បឋម ជនសង្ស័យបានសារភាពថា គាត់បានចែករំលែក CSAM ប៉ុន្តែបាននិយាយដោយការពារខ្លួនថា មានមនុស្សជាច្រើនទៀតដែលគាត់ស្គាល់ដែលកំពុងធ្វើដូចគាត់ដែរ ហើយរូបភាពទាំងនេះត្រូវបានថត «យូរមកហើយ» ហើយគាត់មិនបានប្រព្រឹត្តបទឧក្រិដ្ឋទេ។ គាត់បាននិយាយថា គាត់មិនបានធ្វើបាបអ្នកណាទេ គ្រាន់តែឆ្លើយតបទៅនឹងអ្វីដែលមនុស្សចង់បានតែប៉ុណ្ណោះ។

## ២- ការផ្សាយបន្តផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារ ( Live streaming )៖

### ករណីសិក្សា

អ្នក (មន្ត្រីនគរបាល) ទទួលបានព័ត៌មានទាក់ទងនឹងក្រុមតេលេក្រាមមួយ ដែលវីដេអូរបស់កុមារត្រូវបានគេរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ និងត្រូវបានបង្ហោះផ្សាយយ៉ាងទៀងទាត់ និងចែករំលែកលើប្រព័ន្ធអនឡាញ។ ការរុករកដំបូងនៃការផ្សាយបន្តផ្ទាល់នេះ ហាក់ដូចជាបង្ហាញកុមារមកពីជុំវិញពិភពលោក រួមទាំងកុមារមួយចំនួនដែលជាជនជាតិអាស៊ី និងអាចជាជនជាតិខ្មែរផងដែរ។ ក្រុមនេះមានសមាជិកជាង ៤០០០នាក់ (មានសមាជិកខ្មែរមួយចំនួន និងបរទេសជាច្រើននាក់)។ វាមិនតែងតែច្បាស់លាស់ទេ ប៉ុន្តែ «ការផ្សាយផ្ទាល់» មួយចំនួនហាក់ដូចជាវីដេអូដែលត្រូវបានគេថតកាលពីពេលមុន ហើយត្រូវបានគេចាក់ផ្សាយ។

## ៣- ការល្បួងលោមកុមារលើប្រព័ន្ធអនឡាញក្នុងគោលបំណងផ្លូវភេទ ( Online Grooming)៖

### ករណីសិក្សា

អ្នក (មន្ត្រីនគរបាល) ទទួលបានព័ត៌មានថា គ្រូបង្រៀនអាយុ៣៥ឆ្នាំម្នាក់នៅសាលារៀនអន្តរជាតិមួយ បានទាក់ទងជាមួយអតីតសិស្សរបស់គាត់មួយចំនួន ហើយផ្ញើសារមិនសមរម្យ និងរូបភាពទាក់ទងផ្លូវភេទរបស់គាត់ទៅដល់ពួកគេ។

ព័ត៌មាននេះបានមកពីមិត្តរួមការងារ និងមិត្តរួមផ្ទះរបស់គ្រូម្នាក់នោះ ដែលទទួលបានការត្អូញត្អែរពីអតីតសិស្សម្នាក់របស់គាត់។ អតីតសិស្សម្នាក់នោះបានប្រាប់នាងថា មានមិត្តភក្តិផ្សេងទៀតបានរៀបរាប់រឿងរ៉ាវស្រដៀងគ្នាទាក់ទងនឹងគ្រូប្រុសម្នាក់នេះ ហើយពួកគេខ្លះបានចែករំលែករូបថតស្និទ្ធស្នាលជាមួយគ្រូប្រុសម្នាក់នោះ។ (មិត្តរួមការងាររបស់គ្រូប្រុសនោះ (ដែលជាគ្រូស្រី) ក៏បានឃើញសារ និងរូបភាពខ្លះដែរ)។

គ្រូស្រីបាននិយាយជាលក្ខណៈឯកជនជាមួយក្មេងស្រីមួយចំនួន។ ក្មេងស្រីដែលពាក់ព័ន្ធទាំងអស់មានអាយុ ១២-១៤ ឆ្នាំ។ ជនល្មើសបានផ្ញើសារប្រាប់ពួកគេថាគាត់ស្រឡាញ់ពួកគេ ហើយនិយាយថាគាត់កំពុងរង់ចាំពួកគេពេញវ័យ ដើម្បីគាត់អាចរួមភេទជាមួយពួកគេ ហើយថែមទាំងផ្ញើរូបថតអាក្រាតកាយ និងប្រដាប់ភេទរបស់គាត់ផងដែរ។ រហូតមកដល់ពេលនេះ គ្មានក្មេងស្រីណាម្នាក់សុខចិត្តដាក់ពាក្យបណ្ដឹងជាផ្លូវការទៅសាលា ឬអាជ្ញាធរឡើយ។ ពួកគេមានអារម្មណ៍ខ្មាសអៀន និងទទួលខុសត្រូវមួយផ្នែកចំពោះអ្វីដែលបានកើតឡើង ហើយក្មេងស្រីមួយចំនួនជឿថាគ្រូប្រុសនោះពិតជាស្រឡាញ់ពួកគេពិតមែន។ គ្រូនោះកំពុងបន្តបម្រើការងារបង្រៀននៅសាលានោះនៅឡើយទេ ហើយបង្រៀនក្មេងៗ ថ្នាក់ទី៦-៧។

មិត្តភក្តិគ្រូប្រុសនេះ/សហសេវិកម្នាក់នេះបាននិយាយជាមួយប្រធានគ្រូនៅសាលា ហើយបង្ហាញពីកង្វល់របស់នាង ប៉ុន្តែសាលាមិនទាន់មានចំណាត់ការអ្វីនៅឡើយទេ។ ប្រធានគ្រូបានណែនាំថាវាជារឿងសំខាន់ក្នុងការការពារកេរ្តិ៍ឈ្មោះរបស់សាលា ហើយជឿថាក្មេងស្រីទាំងនោះប្រហែលជាកំពុងប្រឌិតរឿងទាំងនេះឡើងទេ ប៉ុន្តែគាត់នឹង «តាមដានស្ថានភាព» នេះ។ រហូតដល់ពេលនេះ សហសេវិកម្នាក់នេះមិនទាន់ដាក់ពាក្យដណ្ដឹងជាផ្លូវការនៅឡើយទេ ព្រោះនាងមានការព្រួយបារម្ភអំពីការងារ និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់នាង ប្រសិនបើជនល្មើសបានដឹង។

មិនទាន់មានរបាយការណ៍ ឬពាក្យបណ្ដឹងជាផ្លូវការនៅឡើយទេ ប៉ុន្តែនេះជាឧទាហរណ៍ជាក់ស្ដែងថា កុមារកំពុងស្ថិតក្នុងហានិភ័យ។

## ៨- ការចែករំលែកខ្លឹមសារផ្លូវភេទដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ៖

### ករណីសិក្សា

ឪពុកម្ដាយរបស់ក្មេងស្រីអាយុ១៧ឆ្នាំម្នាក់ បានមកជួបអ្នក (មន្ត្រីនគរបាល) ។ ពួកគេបានរកឃើញថាកូនស្រីរបស់ពួកគេមានមិត្តប្រុសម្នាក់ (អាយុ១៧ឆ្នាំដូចគ្នា) ហើយពួកគេបានផ្លាស់ប្ដូររូបថត និងសារបែបផ្លូវភេទរយៈពេលជាច្រើនខែមកហើយ។ មិនមានភស្តុតាងណាដែលបង្ហាញថាមានការប្រើកម្លាំង ការលួងលោម ឬការបង្ខិតបង្ខំណាមួយពីយុវជនណាម្នាក់ដែលពាក់ព័ន្ធក្នុងរឿងនេះទេ។ មើលទៅហាក់ដូចជាយុវជនទាំងពីរនាក់នេះបានយល់ព្រមចែករំលែករូបភាពទាំងនេះ។ ប៉ុន្តែឪពុកម្ដាយរបស់ក្មេងស្រីមិនសប្បាយចិត្តទាល់តែសោះ។ ពួកគាត់ខឹងកូនស្រីដែលបានប្រព្រឹត្តទង្វើបែបនេះ ហើយបារម្ភអំពីកេរ្តិ៍ឈ្មោះគ្រួសារ។ ពួកគាត់ចង់ឱ្យអ្នកចាប់ខ្លួន និងអនុវត្តច្បាប់ចាប់ក្មេងប្រុសនោះផ្ដន្ទាទោស។

## ៩- ការគំរាមទាក់ទងនឹងផ្លូវភេទ (Sextortion)៖

### ករណីសិក្សា ក៖

គ្រីស្នា ជាក្មេងស្រីអាយុ១៦ឆ្នាំម្នាក់ ដែលរស់នៅជាមួយឪពុកម្តាយនាង។ ឪពុកម្តាយរបស់នាងមិនសូវយកចិត្តទុកដាក់នឹងនាងប៉ុន្មានទេ ព្រោះពួកគេរវល់ធ្វើការច្រើនម៉ោង ដូច្នេះតាំងពីអាយុ១២ឆ្នាំមក នាងបានចំណាយពេលច្រើននៅផ្ទះតែម្នាក់ឯងនៅពេលល្ងាច។ នាងបានចំណាយពេលច្រើនលើប្រព័ន្ធអនឡាញតាមរយៈការផ្ញើសារទៅមិត្តភក្តិ ការជជែកលេងក្នុងគ្រុបឆាត និងជួបមនុស្សដទៃទៀត។

នាងបានជួបនឹងយុវជនម្នាក់ដែលនិយាយថាគាត់រស់នៅប្រទេសបារាំង ហើយមានអាយុ២៣ឆ្នាំ។ ពួកគេបានប្រាស្រ័យទាក់ទងគ្នាជាភាសាអង់គ្លេសតាមរយៈសារ និងតាមរយៈវីដេអូខលផងដែរ។ គាត់បង្ហាញចិត្តល្អចំពោះនាង ហើយធ្វើឱ្យនាងមានអារម្មណ៍ល្អចំពោះខ្លួនឯង ហើយបាននិយាយថានាងជាស្រីស្អាតម្នាក់។ ពួកគេបានយល់ព្រមធ្វើជាមិត្តស្រីមិត្តប្រុសលើប្រព័ន្ធអនឡាញ ហើយគាត់បានសន្យាថាថ្ងៃណាមួយគាត់នឹងមកប្រទេសកម្ពុជាដើម្បីជួបនាង។ យូរៗទៅ ពួកគេនិយាយអំពីរឿងស្និទ្ធស្នាល រួមទាំងរឿងផ្លូវភេទផងដែរ ហើយពួកគេចូលអនឡាញ និងបង្ហាញរាងកាយ និងសម្រេចកាមដោយខ្លួនឯងជាមួយគ្នា។ ពួកគេយល់ស្របថាពួកគេមិនគួរថតវីដេអូទុកពេលពួកគេជួបគ្នាតាមអនឡាញទេ។ គ្រីស្នា មានអារម្មណ៍មិនសូវស្រួលក្នុងការធ្វើបែបនេះទេ ប៉ុន្តែបានយល់ព្រមព្រោះគាត់ធ្វើឱ្យនាងមានអារម្មណ៍ពិសេស ហើយគាត់ប្រាប់នាងថាគាត់ស្រឡាញ់នាង ហើយថាគាត់ចង់រស់នៅជាមួយនាង។ យ៉ាងណាមិញ ថ្ងៃមួយ គាត់បានសុំនាងឱ្យដោះសម្លៀកបំពាក់ចេញ ហើយនាងមិនសប្បាយចិត្តនឹងរឿងនេះទេ នាងបានបដិសេធ។ គាត់ខឹងនឹងនាងខ្លាំង ហើយគំរាមផ្ញើរូបថតស្និទ្ធស្នាលរបស់នាងទៅមិត្តភក្តិ និងសមាជិកគ្រួសាររបស់នាងតាមហ្វេសប៊ុក ហើយថែមទាំងបង្ហោះវីដេអូរបស់នាងនៅលើគេហទំព័រអាសអាភាសទៀតដែរ។ នាងបានបដិសេធគាត់ ហើយមានអារម្មណ៍ខឹងខ្លាំង ក៏បានបិទការហៅតាមទូរស័ព្ទ ហើយបានប្លុកគាត់ចោល។ នាងខឹងខ្លាំងណាស់ ហើយមានអារម្មណ៍ភ័យខ្លាច តែមិនជឿថាគាត់នឹងធ្វើបែបនេះទេ ។

នៅថ្ងៃបន្ទាប់ នាងបានទទួលបានសារពីមិត្តភក្តិនៅសាលារបស់នាង ដោយនិយាយថាពួកគេទទួលបានរូបថតអាក្រាតរបស់នាង ហើយបន្ទាប់មកបងប្រុសរបស់នាងបានទូរស័ព្ទរកនាង។ គាត់ខឹងនាងយ៉ាងខ្លាំង ហើយស្រែកដាក់នាង ដោយសារគាត់ក៏បានទទួលរូបភាពអាក្រាតរបស់នាង ហើយចង់ដឹងថាមានរឿងអ្វីកើតឡើង គាត់បានស្តីបន្ទោសឱ្យនាងថា នាងជា«ស្រីអាក្រក់»។

## ករណីសិក្សា ខ៖

ធីតាមានអាយុ១៥ឆ្នាំ ក្រោយពីរៀននៅសាលាហើយ នាងត្រលប់ទៅផ្ទះវិញ ហើយចំណាយពេលច្រើនតែម្នាក់ឯងលើប្រព័ន្ធអនឡាញ។ នាងបានជួបក្មេងស្រីម្នាក់ឈ្មោះ សុជាតិ អាយុ១៦ឆ្នាំ តាមរយៈហ្វេសប៊ុក។ ពួកគេបានមានទំនាក់ទំនងស្និទ្ធស្នាលជាមួយគ្នា ជួបគ្នារាល់ថ្ងៃតាមអនឡាញ។ ពួកគេនិយាយគ្នាអំពីជីវិត ក្តីសុបិន និងបញ្ហារបស់ពួកគេ ហើយបានបង្កើនការមានទំនុកចិត្តលើគ្នាទៅវិញទៅមក។

ថ្ងៃមួយ ពេលកំពុងផ្ញើសារដោះដូរគ្នា សុជាតិបានសុំឱ្យធីតាចែករំលែករូបថតប្លែកៗ។ សុជាតិសុំឱ្យធីតាផ្ញើរូបថតអត់ពាក់អាវ ហើយធីតាបានផ្ញើរូបថតអត់ពាក់អាវឱ្យទៅសុជាតិ។ ពេលនោះ ធីតា បានសម្រេចចិត្តថានឹងមិនផ្ញើរូបថតបែបនេះទៀតទេ ហើយពួកគេនៅតែជាមិត្តភក្តិនឹងគ្នាដដែល។ ថ្ងៃមួយ ពួកគេបានជួបគ្នាជាលើកដំបូង ដើម្បីញ៉ាំកាហ្វេនៅហាងកាហ្វេមួយក្នុងតំបន់ ហើយពួកគេមានទំនាក់ទំនងល្អជាមួយគ្នា។ ធីតាពិតជារីករាយជាមួយពេលវេលាដែលនាងមានជាមួយសុជាតិខ្លាំងណាស់ ហើយពួកគេបានដោះដូរគ្រឿងអលង្ការឱ្យគ្នាទៅវិញទៅមក ជាសញ្ញានៃចំណងមិត្តភាព។ ធីតាគិតថា សុជាតិ ជាមនុស្សបើកចំហ និងស្មោះត្រង់ខ្លាំងណាស់ ហើយក្នុងន័យខ្លះទៀត ធីតាបានចាប់ផ្តើមមានអារម្មណ៍ «ចាប់ចិត្តស្រឡាញ់» សុជាតិ។ នាងមិនសូវយល់ពីអារម្មណ៍របស់នាងប៉ុន្មានទេ ប៉ុន្តែនាងមានអារម្មណ៍ទាក់ទាញចំពោះសុជាតិ។ យូរៗទៅ ពួកគេកាន់តែស្និទ្ធស្នាលជាងមុន ហើយធីតាក៏យល់ព្រមផ្ញើរូបថត និងវីដេអូខ្លីៗអំពីរាងកាយអាក្រាតរបស់នាង។ ថ្ងៃមួយ ធីតាបានទទួលសំណើអ៊ីនស្តាក្រាម ពីជនមិនស្គាល់មុខម្នាក់ ហើយនាងបានទទួលយកសំណើនោះ។ ម្នាក់នោះបានផ្ញើរូបថតដែលនាងធ្លាប់ចែករំលែកជាមួយសុជាតិ ហើយបានទាមទាររូបថតបន្ថែមទៀត។ ប្រសិនបើនាងមិនយល់ព្រមទេ បុគ្គលនោះបាននិយាយថា ពួកគេនឹងចែករំលែករូបថត និងវីដេអូរបស់នាងយ៉ាងទូលំទូលាយនៅលើ Facebook, Instagram និងបណ្តាញសង្គមផ្សេងទៀត។

នាងភ័យខ្លាចជាខ្លាំង ដូច្នេះនាងបានផ្ញើរូបភាពបន្ថែមទៀត ហើយបន្ទាប់មកបានប្លុកគណនីអ៊ីនស្តាក្រាមនោះចោល។ នាងបានទាក់ទងទៅសុជាតិ ហើយសុជាតិបានប្រាប់នាងថា គណនីរបស់នាងត្រូវបានគេលួចចូល ហើយពួកគេបានលួចរូបថតទាំងនោះ។ ធីតាមិនប្រាកដថា នាងអាចទុកចិត្តសុជាតិបានឬមិនបានទេ ហើយក៏មិនដឹងប្រាកដថាសុជាតិនិយាយការពិតឬមិនពិតដែរ ទើបនាងសម្រេចចិត្តបញ្ចប់មិត្តភាព ហើយបានប្លុកគណនីរបស់សុជាតិចោល។ ចាប់តាំងពីពេលនោះមក ធីតាតែងតែទទួលសារពីគណនីមិនស្គាល់ និងគំរាមចែករំលែករូបថតរបស់នាងលុះត្រាតែនាងចែករំលែករូបថតបន្ថែមទៀត។

នាងបានទាក់ទងទៅអង្គការមិនមែនរដ្ឋាភិបាលមួយដើម្បីសុំជំនួយ បន្ទាប់ពីបានឃើញខ្សែភាពយន្តព័ត៌មានលើប្រព័ន្ធអនឡាញនិយាយអំពីសុវត្ថិភាពលើប្រព័ន្ធអនឡាញ។ នាងចង់ឱ្យបញ្ហានេះទៅឆ្ងាយ ប៉ុន្តែមិនដឹងថាត្រូវធ្វើយ៉ាងណាទេ។

## ៦- ការបៀតបៀនផ្លូវភេទកុមារ៖

### ករណីសិក្សា ក៖

ក្មេងស្រីអាយុ១៤ឆ្នាំម្នាក់ ទទួលបានសំណោរបង្ហោះមួយនៅលើទំព័រហ្វេសប៊ុករបស់នាង ពីមិត្តភក្តិ Facebook ម្នាក់ ដែលនិយាយពាក្យអាក្រក់ៗពីរូបរាងកាយរបស់នាង។ មិត្តភក្តិ និងក្រុមគ្រួសាររបស់នាងទាំងអស់គ្នា សុទ្ធតែអាចមើលឃើញសារទាំងនេះ។ សារទាំងនេះបានបញ្ចេញមតិអំពីការអភិវឌ្ឍផ្លូវភេទ និងទំហំសុដន់របស់នាង ហើយប្រាប់នាងថា នាងមើលទៅដូចជាស្រីពេស្យាដែលមើលទៅទំនងជា មានក្លិនដូចធ្លាប់បានរួមភេទច្រើនដងជាមួយបុរសវ័យចំណាស់ៗ។

ក្មេងស្រីម្នាក់នេះមានអារម្មណ៍អាក់អន់ចិត្ត និងពិបាកចិត្តជាខ្លាំងដោយសារពាក្យសំដីដ៏អាក្រក់បែបនេះ ហើយជាពិសេស ពេលដែលមនុស្សជាច្រើនទៀតក៏បង្ហោះរូបសញ្ញាអារម្មណ៍សើចក្អាកក្អាយ និងមតិសើចចំអកផ្សេងទៀតផងដែរ។

### ករណីសិក្សា ខ៖

ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ បានទាក់ទងទៅការិយាល័យរបស់អ្នក (មន្ត្រីនគរបាល) បន្ទាប់ពីទទួលបានសារ និងសារនៅលើបណ្តាញសង្គម ដែលចោទប្រកាន់ថាគាត់ជាមនុស្សស្រឡាញ់ភេទដូចគ្នា។ បុគ្គល ឬអ្នកដែលបានផ្ញើសារនោះ បានយករូបថតគាត់ចេញពីគណនីហ្វេកប៊ុកគាត់ ហើយបានកាត់តក្បាលរបស់គាត់ដាក់លើរូបភាពបុរសវ័យក្មេងកំពុងរួមភេទ។ គាត់មានមិត្តភក្តិ Facebook ជាច្រើន ហើយមិនដឹងពីរបៀបកំណត់ឯកជនភាពរបស់គាត់ទេ ដូច្នេះរូបភាពនេះត្រូវបានគេចែករំលែក ហើយចែករំលែកបន្តទៀតជាច្រើនដង។

គាត់ពិតជាអាក់អន់ចិត្ត និងពិបាកចិត្តណាស់ ដោយសារការបង្ហោះរូបនេះ និងពាក្យសម្តីអាក្រក់ៗ ហើយជាពិសេស ក៏មានមហាជនជាច្រើនទៀតបានបង្ហោះរូបសញ្ញាអារម្មណ៍សើចក្អាកក្អាយ និងបញ្ចេញមតិយោបល់លេងសើចផ្សេងទៀតផងដែរ។

# ៧- ការជួបប្រទះដែលកុមារមិនចង់ជួប ចំពោះមាតិកាផ្លូវភេទលើប្រព័ន្ធអនឡាញ

## ករណីសិក្សា ក៖

ក្មេងស្រីអាយុ១៤ឆ្នាំម្នាក់ បានទទួលរូបភាពបែបផ្លូវភេទ និងការផលិតរូបភាពអាសអាភាសលក្ខណៈពាណិជ្ជកម្ម ពីសិស្សប្រុសអាយុច្រើនជាងគាត់នៅសាលារៀនរបស់គាត់។ ពួកគេជាមិត្តភក្តិតាម Facebook ហើយបើទោះបីជានាងបានប្លុកគាត់ជាច្រើនដងហើយក៏ដោយ ក៏គាត់នៅតែរករបៀបផ្សេងៗដោយបង្កើតអត្តសញ្ញាណថ្មី និងបន្តផ្ញើសម្ភារៈផ្លូវភេទមកឱ្យនាង។ កាលណានាងកាន់តែប្លុកគាត់ កាលនោះនាងកាន់តែទទួលបានសារកាន់តែច្រើនជាងមុនពីគាត់។ នៅសារចុងក្រោយ អ្នកដែលបានផ្ញើសារមកឱ្យនាង បានប្រាប់នាងថា គាត់ចង់ធ្វើចំពោះនាងដូចអ្វីដែលមនុស្សនៅក្នុងខ្សែភាពយន្តនោះកំពុងធ្វើ។

## ករណីសិក្សា ខ៖

យុវជនអាយុ១៧ឆ្នាំម្នាក់ មកជួបអ្នកនៅការិយាល័យរបស់អ្នក (មន្ត្រីនគរបាល) ជាមួយមិត្តភក្តិម្នាក់របស់គាត់។ គាត់ខ្មាសអៀនយ៉ាងខ្លាំង ហើយក៏មានអារម្មណ៍តានតឹង និងតូចចិត្តផងដែរ ប៉ុន្តែដោយសារមានជំនួយពីមិត្តភក្តិរបស់គាត់ គាត់បានយល់ព្រមមកជួបអ្នក។ គាត់បានពន្យល់ថាគាត់បានក្លាយជាមិត្តតាមអនឡាញជាមួយបុរសជនជាតិខ្មែរអាយុច្រើនជាងគាត់ (យ៉ាងហោចណាស់បុរសនោះមានអាយុប្រហែល៣០ឆ្នាំ ទោះបីគាត់មិនច្បាស់ក៏ដោយ)។ បុរសម្នាក់នោះឈ្មោះសុជាវត្ត បានផ្ញើសម្ភារៈអាសអាភាសរបស់បុរសរួមភេទជាមួយបុរស និងខ្សែភាពយន្តបុរសសម្រេចកាមដោយខ្លួនឯងដល់គាត់។ សម្ភារៈខ្លះត្រូវបានផលិតឡើងជាលក្ខណៈពាណិជ្ជកម្ម ហើយខ្លះទៀតហាក់ដូចជាផលិតឡើងដោយខ្លួនឯង ទោះបីគាត់មិនច្បាស់ពីការនេះក៏ដោយ។

បន្ទាប់ពីការពិភាក្សាបន្ថែមមក មិត្តរបស់ក្មេងប្រុសនោះបានពន្យល់ថាគាត់ (ក្មេងប្រុសនោះ) ចាប់អារម្មណ៍នឹងបុរស ហើយគិតថាគាត់ប្រហែលជាស្រឡាញ់ភេទដូចគ្នាហើយមើលទៅ ដូច្នេះគាត់កាន់តែមានអារម្មណ៍ខ្មាសអៀនក្នុងការរាយការណ៍ពីអ្វីដែលបានកើតឡើង។ គាត់មានអារម្មណ៍ថាគាត់ជាអ្នកត្រូវទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើង ប៉ុន្តែមានអារម្មណ៍តានតឹងចិត្ត និងតូចចិត្តកាន់តែខ្លាំងឡើង។ បុរសដែលផ្ញើខ្សែភាពយន្តនោះប្រាប់គាត់ថាភាពយន្តនោះគឺដើម្បីជួយគាត់ឱ្យដឹងថាតើបុរសស្រឡាញ់ភេទដូចគ្នាមានលក្ខណៈបែបណា។ បុរសរូបនោះក៏បានសុំឱ្យក្មេងប្រុសនោះ ផ្ញើរូបភាព និងថតវីដេអូអាក្រាតរបស់គាត់ផងដែរ ប៉ុន្តែរហូតមកដល់ពេលនេះគាត់បានបដិសេធមិនធ្វើដូច្នេះទេ។

## ៨- កុមារដែលមាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទដូចគ្នា (LGBTQI)៖

### ករណីសិក្សា

អង្គការមិនមែនរដ្ឋាភិបាលមួយបានទាក់ទងមកអ្នក(មន្ត្រីនគរបាល) បន្ទាប់ពីក្មេងប្រុសអាយុ ១៦ឆ្នាំម្នាក់បានទាក់ទងមកពួកគេបន្ទាប់ពីឧប្បត្តិហេតុមួយកាលពីសប្តាហ៍មុន។ ក្មេងប្រុសម្នាក់នេះមិនចង់បញ្ចេញឈ្មោះគាត់ឱ្យគេស្គាល់ទេនៅពេលនេះ។ គាត់បានពន្យល់ថា គាត់បានចូលរួមពិធីជប់លៀងមួយជាមួយមិត្តភក្តិនៅមហាវិទ្យាល័យ។ គាត់ស្រវឹងខ្លាំងណាស់ ហើយក៏សន្លប់បាត់ទៅ។ ពេលដឹងខ្លួនឡើងវិញនៅថ្ងៃបន្ទាប់ គាត់បានត្រឡប់ទៅផ្ទះវិញ ហើយបានដេកច្រើនម៉ោងព្រោះគាត់ឈឺក្បាលខ្លាំង។

ក្រោយមកនៅថ្ងៃដដែលនោះ គាត់បានទទួលសារពីមិត្តម្នាក់របស់គាត់ ដែលបង្ហាញការព្រួយបារម្ភអំពី វីដេអូរួមភេទរបស់គាត់ជាមួយបុរសពេញវ័យពីរនាក់ទៀត ដែលត្រូវបានគេបង្ហោះលើប្រព័ន្ធអនឡាញ។ មិត្តភក្តិម្នាក់នោះបានសន្មតថាក្មេងប្រុសនោះបានបង្ហោះវីដេអូនោះដោយខ្លួនឯង ប៉ុន្តែគាត់មិនបានធ្វើដូច្នេះទេ ហើយគាត់មានអារម្មណ៍តក់ស្លុត និងរំខានយ៉ាងខ្លាំងដោយសារអ្វីដែលគាត់បានឃើញ។ វីដេអូនេះបានធ្វើឡើងក្នុងពិធីជប់លៀង ប៉ុន្តែក្មេងប្រុសម្នាក់នោះមិនបាននឹកចាំពីអ្វីទាំងអស់ដែលបានកើតឡើងទេ។

ចាប់តាំងពីពេលនោះមក ក្មេងប្រុសម្នាក់នោះបានទទួលសារជាច្រើនបង្ហាញពីការស្អប់ខ្ពើមនៅលើគណនី Facebook និង Instagram របស់គាត់ ដូច្នេះហើយគាត់ក៏បិទគណនីទាំងពីរនោះទៅ។ វាហាក់ដូចជាវីដេអូនោះត្រូវបានគេចែករំលែកយ៉ាងទូលំទូលាយនៅលើបណ្តាញសង្គម។

តាំងពីពេលនោះមក គាត់មិនបានចាកចេញពីផ្ទះទេ ហើយឈប់ចូលរៀននៅមហាវិទ្យាល័យទៀត គាត់ក៏ព្យាយាមធ្វើអត្តឃាត(ចងក)ដែរ។ ឪពុកម្តាយគាត់បានដឹងពីរឿងនេះ ហើយពួកគាត់មានទុក្ខព្រួយយ៉ាងខ្លាំង។ ពេលនេះក្មេងប្រុសនេះបានលាតត្រដាងប្រាប់ឪពុកម្តាយរបស់គាត់ ថាគាត់ជាអ្នកស្រឡាញ់ភេទដូចគ្នា ហើយពួកគេក៏ខកចិត្តចំពោះរឿងនេះដែរ ប៉ុន្តែពួកគេនៅតែគាំទ្រគាត់អំឡុងពេលនេះ។

អង្គការមិនមែនរដ្ឋាភិបាលបានពន្យល់ប្រាប់ក្មេងប្រុសនោះថា អ្វីដែលបានកើតឡើងគឺជាការរំលោភបំពាន ដោយគ្មានការយល់ព្រមពីគាត់ ហើយអ្វីដែលបានកើតឡើងក្រោយពីពេលនោះ (ការចែករំលែកខ្សែភាពយន្ត) គឺជាបទល្មើសឧក្រិដ្ឋផងដែរ។ ពួកគេបានសំណូមពរឱ្យក្មេងប្រុសនោះ គួររាយការណ៍ពីរឿងរ៉ាវដែលបានកើតឡើងទៅអាជ្ញាធរ ប៉ុន្តែនៅពេលនេះ គាត់មិនទាន់ព្រមធ្វើដូច្នេះនៅឡើយទេ។ គាត់បាននិយាយប្រាប់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលថា គាត់ធ្លាប់ប្រាប់គេថាគាត់ជាមនុស្សស្រឡាញ់ភេទដូចគ្នា ហើយទទួលបានបទពិសោធន៍នៃការរើសអើងជាច្រើន។ គាត់ជឿថា ប្រសិនបើគាត់រាយការណ៍ គាត់ក៏នឹងទទួលបានការរើសអើងពីប៉ូលិស ហើយត្រូវបានគេស្តីបន្ទោសដោយសារអ្វីដែលបានកើតឡើង។

## ៩- កុមារដែលមានពិការភាព

### ករណីសិក្សា

ប្រធានគ្រូនៅមជ្ឈមណ្ឌលលំនៅឋានសម្រាប់កុមារពិការមួយ បានទាក់ទងមកអ្នក ដោយសារក្មេងប្រុសម្នាក់អាយុប្រហែល១៥ឆ្នាំ ឈ្មោះធៃ ដែលស្ថិតក្រោមការមើលថែរបស់ពួកគេ។ ក្មេងប្រុសនេះមានបញ្ហាមួយដែលគេហៅថា «Autism Spectrum Disorder (ASD ឬមានអូទីស្សឹម)» ។

រោគសញ្ញាមួយចំនួននៃ ASD អាចរួមបញ្ចូលៈ ការប្រាស្រ័យទាក់ទង និងអន្តរកម្មសង្គម (ការយល់ដឹងពីមនុស្សដទៃ និង/ឬធ្វើឱ្យមនុស្សដទៃទៀតយល់ពីពួកគេ) មានឥរិយាបថដែលអាចមើលទៅខុសប្លែកពីអ្នកដទៃ (ឧៈ ការនិយាយតាមពាក្យសំដី ឬកាយវិការរបស់មនុស្សដែលនៅជុំវិញពួកគេ) និងការយល់ដឹងទាក់ទងនឹងញ្ញាណ (ឧៈ ការមើលឃើញ ការស្តាប់ ការប៉ះ រសជាតិ ក្លិន តុល្យភាព និងការយល់ដឹងពីរាងកាយ)។ ដោយមានជំនួយ និងការគាំទ្រត្រឹមត្រូវ ហើយនៅក្នុងបរិយាកាសមួយប្រកបដោយសុវត្ថិភាព កុមារទាំងនេះទទួលបានជំនួយដើម្បីអាចរស់នៅក្នុងជីវិតប្រកបដោយភាពវិជ្ជមានបាន។

ធៃ ជាក្មេងប្រុសស្ងប់ស្ងាត់ម្នាក់ គាត់ចូលចិត្តចំណាយពេលតែម្នាក់ឯង គាត់យល់ថាការប្រាស្រ័យទាក់ទងក្នុងស្ថានភាពសង្គមពិបាកខ្លាំងសម្រាប់គាត់ ដូច្នេះហើយគាត់ចំណាយពេលច្រើនលើប្រព័ន្ធអនឡាញ ដោយប្រើទូរស័ព្ទ ឬថេប្លេតរបស់គាត់។ គាត់ជាក្មេងឆ្លាត គាត់ចូលចិត្តការរៀនសូត្រ និងការលេង «ហ្គេម» ផងដែរ។ គាត់គឺជាសមាជិកនៃសហគមន៍ហ្គេមអនឡាញជាច្រើន។ គាត់ចាត់ទុកថាមនុស្សជាច្រើនដែលគាត់បានជួបលើប្រព័ន្ធអនឡាញជាមិត្តរបស់គាត់ ព្រោះគាត់មិនចាំបាច់ជួបមុខពួកគេទេ (ដែលវាពិបាកសម្រាប់គាត់)។ ភាគច្រើនជីវិតរបស់គាត់រស់នៅតាមរយៈទំនាក់ទំនងលើប្រព័ន្ធអនឡាញ។

ថ្មីៗនេះ ប្រធានគ្រូបានដឹងថា បុរសម្នាក់ដែលគាត់បានជួបតាមអនឡាញ (មិនស្គាល់ឈ្មោះទេ) បានផ្ញើសារបែបផ្លូវភេទ រូបថតរួមភេទ និងវីដេអូរួមភេទដល់ធៃ។ ជននោះក៏បានសុំឱ្យធៃធ្វើដូចគ្នាដែរ។ ប្រធានគ្រូបានឆ្លើយតបដោយដកយកឧបករណ៍អេឡិចត្រូនិកទាំងអស់របស់ធៃ ហើយហាមគាត់មិនឱ្យប្រើប្រព័ន្ធអនឡាញទេ។ តាំងពីពេលនោះមក ធៃបានបដិសេធមិនព្រមចេញពីបន្ទប់របស់គាត់ទេ ហើយអារដៃខ្លួនឯងដោយប្រើអំបែងកែវ។

# ឯកសារយោង

១ របាយការណ៍នៃការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់នៅកម្ពុជា អំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើប្រព័ន្ធអនឡាញ (អង្គការសកម្មភាពដើម្បីកុមារ (APLE) ខែមីនាឆ្នាំ២០២៣)

២ គោលការណ៍ប្រតិបត្តិបែបកុមារមេត្រីសម្រាប់សម្ភាសន៍ និងគាំទ្រកុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ (អង្គការសកម្មភាពដើម្បីកុមារ (APLE) ឆ្នាំ២០១៩)

៣ សៀវភៅណែនាំបង្រៀនអំពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ កម្រិតមធ្យមសិក្សាបឋមភូមិ (ក្រសួងអប់រំយុវជន និងកីឡា នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ខែមករា ឆ្នាំ ២០២៤)

៤ សៀវភៅណែនាំការបណ្តុះបណ្តាល "ការស៊ើបអង្កេតឧក្រិដ្ឋកម្មផ្លូវភេទដែលបានបើកតាមអ៊ីនធឺណិតប្រឆាំងនឹងកុមារ" / The "Investigating Cyber-Enabled Sexual Crimes Against Children" training manual (អង្គការសកម្មភាពដើម្បីកុមារ (APLE) ឆ្នាំ២០១៤)

៥ សៀវភៅណែនាំការបណ្តុះបណ្តាលអ្នកសម្របសម្រួលការផ្សព្វផ្សាយយុទ្ធនាការ «គ្រួសាររឹងមាំ» ដល់ឪពុកម្តាយនៅតាមសហគមន៍ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វកម្ពុជា ឆ្នាំ២០២២)



ព្រះគណេស

យើងរួមគ្នាកសាងវប្បធម៌គុណភាព

APLE

Australian Aid

unicef ដើម្បីកុមារគ្រប់រូប